

ឯកសារគម្ពីរព្រះត្រៃបិដកស្កេននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥០០០ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ។

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ។

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ។

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ។

ថតស្កេនដោយ
ប្អូនប្រុស ម៉ាន់ សារ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងច្រើនក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ្គិចណៃ (ភ្នំពេញ)
- ឧបាសក ជុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ួច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ានី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ ឥន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)

# ព្រះ
# ត្រៃបិដកបាឡី
# និង
# សេចក្ដីប្រែភាសាខ្មែរ
# សុត្តន្តបិដក
# ៤៤
# អង្គុត្តរនិកាយ ទសកនិបាត
# ភ្វទសមភាគ
# ទី១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស. ២៥០០

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ដង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។

ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។

ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga  The Rev. Jitsujo Arima  The Rev. Yoshimichi Ito
The Rev. Keiichi Watai  The Rev. Gijun Sugitani  The Rev. Shincho Shigeta
The Rev. Risho Maeda  The Rev. Kyoshi Nakajima  Mr. Rokusuke Ei

# សុត្តន្តបិដក

## អង្គុត្តរនិកាយ ទសកនិបាត

## ទ្វាទសមភាគ

## ៥១

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស ទសកនិបាតោ

## ទ្វាទសមោ ភាគោ

---

## តតិយបណ្ណាសកោ

### បឋមោ សមណសញ្ញាវគ្គោ

(១) តិស្សោ(១)ភិក្ខវេ សមណសញ្ញា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ ។ កតមា តិស្សោ ។ វេវណ្ណិយម្ហិ អជ្ឈុបគតោ បរប្បដិពទ្ធា មេ ជីវិកា អញ្ញោ មេ អាកប្បោ ករណីយោ(២) ។ ឥមា ខោ ភិក្ខវេ តិស្សោ សមណសញ្ញា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ ។ កតមេ សត្ត ។ និច្ចំ សន្តតការី ហោតិ សន្តតវុត្តី សីលេសុ អនភិជ្ឈាលុ ហោតិ អព្យាបជ្ជោ ហោតិ អនតិមានី ហោតិ

---

១ ម. ឯត្តកេ ឥមាតិ បាឋោ ទិស្សតិ ។ ២ ឱ. ម. ករណីយោតិ ។

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ទសកនិបាត

# ទ្វាទសមភាគ

## តតិយបណ្ណាសក

## សមណសញ្ញាវគ្គ ទី១

(១) ម្នាលភិក្ខុទាំងឡាយ សមណសញ្ញា (សេចក្តីសំគាល់របស់សមណៈ) ៣ យ៉ាង ដែលភិក្ខុបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញុំាងធម៌ ៧ ប្រការឲ្យពេញលេញបាន ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺ (បព្វជិតគប្បីពិចារណារឿយៗថា) អាត្មាអញនេះ កាន់យកនូវភេទផ្សេង (អំពីភេទរបស់គ្រហស្ថ) ១ ការប្រព្រឹត្តចិញ្ចឹមជីវិត របស់អាត្មាអញ រមែងប្រព្រឹត្តជាប់ដោយបុគ្គលដទៃ ១ អាត្មាអញ គប្បីធ្វើអាកប្បកិរិយាផ្សេង (អំពីគ្រហស្ថ) ១ ។ ម្នាលភិក្ខុទាំងឡាយ សមណសញ្ញា ៣ យ៉ាងនេះឯង ដែលភិក្ខុបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញុំាងធម៌ ៧ ប្រការឲ្យពេញលេញបាន ។ ធម៌ ៧ ប្រការ តើអ្វីខ្លះ ។ គឺភិក្ខុជាអ្នកធ្វើរឿយៗជានិច្ច ប្រព្រឹត្តមិនដាច់ក្នុងសីលទាំងឡាយ ១ ជាអ្នកមិនមានសេចក្តីលោភ ១ ជាអ្នកមិនបៀតបៀន ១ ជាអ្នកមិនមើលងាយគេ ១

សិក្ខាកាមោ ហោតិ ឥទមត្ថិតស្ស(៣) ហោតិ ជីវិតបរិក្ខារេសុ អារទ្ធវីរិយោ(៤) វិហរតិ ។ ឥមា ខោ ភិក្ខវេ តិស្សោ សមណសញ្ញា ភាវិតា ពហុលីកតា ឥមេ សត្ត ធម្មេ បរិបូរេន្តិ ។

(២) សត្តិមេ ភិក្ខវេ ពោជ្ឈង្គា ភាវិតា ពហុលីកតា តិស្សោ វិជ្ជា បរិបូរេន្តិ ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា តិស្សោ វិជ្ជា បរិបូរេន្តិ ។ កតមា តិស្សោ ។ ឥធ ភិក្ខវេ ភិក្ខុ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។បេ។

---

៣ ឱ. ម. ឥទមត្ថិស្ស ។ ៤ ឱ. ម. ឯត្ថន្តរេ សេទ្ធា អត្ថិ ។

ជាអ្នកមានសេចក្តីប្រាថ្នាក្នុងសិក្ខា ១ ភិក្ខុនោះមានសេចក្តីយល់ថា នេះជាប្រយោជន៍ ក្នុងជីវិតបរិក្ខារទាំងឡាយ ១ ជាអ្នកប្រារព្ធនូវព្យាយាម ១ ៗ ម្នាលភិក្ខុទាំងឡាយ សមណសញ្ញា ៣ យ៉ាងនេះឯង ដែលភិក្ខុបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញុំាងធម៌ ៧ ប្រការនេះឲ្យពេញលេញបាន ៗ

(២) ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ (អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង) ៧ យ៉ាងនេះ ដែលភិក្ខុបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញុំាងវិជ្ជា ៣ ប្រការឲ្យពេញលេញបាន ៗ ៧ យ៉ាង តើអ្វីខ្លះ ៗ គឺ សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិ-សម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខា-សម្ពោជ្ឈង្គ ១ ៗ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ៧ នេះឯង ដែលភិក្ខុបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញុំាងវិជ្ជា ៣ ប្រការ ឲ្យពេញលេញបាន ៗ វិជ្ជា ៣ ប្រការ តើអ្វីខ្លះ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងរលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៗ បេ ៗ

## តតិយបណ្ណាសកេ សមណសញ្ញាវគ្គោ

ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មុបគេ សត្តេ បជានាតិ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា ឥមា តិស្សោ វិជ្ជា បរិបូរេន្តិ ។

(៣) មិច្ឆត្តំ ភិក្ខវេ អាគម្ម វិរាធនា ហោតិ នោ អារាធនា ។ កថញ្ច ភិក្ខវេ មិច្ឆត្តំ អាគម្ម វិរាធនា ហោតិ នោ អារាធនា ។ មិច្ឆាទិដ្ឋិកស្ស ភិក្ខវេ មិច្ឆាសង្កប្បោ បហោតិ មិច្ឆាសង្កប្បស្ស មិច្ឆាវាចា បហោតិ មិច្ឆាវាចស្ស មិច្ឆាកម្មន្តោ បហោតិ មិច្ឆាកម្មន្តស្ស មិច្ឆាអាជីវោ បហោតិ មិច្ឆាអាជីវស្ស មិច្ឆាវាយាមោ បហោតិ មិច្ឆាវាយាមស្ស មិច្ឆាសតិ បហោតិ

រមែងរលឹកឃើញ នូវបុព្វេនិវាសច្រើនប្រការព្រមទាំងអាការ ទាំងឧទ្ទេស ដោយប្រការដូច្នេះ ១ មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធកន្លងបង់នូវចក្ខុរបស់មនុស្ស ។ បេ ។ រមែងដឹងច្បាស់ នូវពួកសត្វ ដែលអន្ទោលទៅតាមយថាកម្ម ១ ព្រោះអស់ទៅ នៃអាសវៈទាំងឡាយ ។ បេ ។ ធ្វើឲ្យជាក់ច្បាស់ហើយ សម្រេចសម្រាន្តនៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ៧ នេះឯង ដែលភិក្ខុបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងញុំាងវិជ្ជា ៣ ប្រការនេះ ឲ្យពេញលេញបាន ។

(៣) ម្នាលភិក្ខុទាំងឡាយ កិរិយាឃ្លាត (ចាកស្ថានសួគ៌និងមគ្គ) មិនបានសម្រេច ព្រោះអាស្រ័យមិច្ឆត្តៈ (សភាពដែលខុស) ។ ម្នាលភិក្ខុទាំងឡាយ កិរិយាឃ្លាត (ចាកស្ថានសួគ៌និងមគ្គ) មិនបានសម្រេច ព្រោះអាស្រ័យមិច្ឆត្តៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសេចក្តីយល់ខុស រមែងមានតម្រិះខុស បុគ្គលអ្នកមានតម្រិះខុស រមែងមានវាចាខុស បុគ្គលអ្នកមានវាចាខុស រមែងមានការងារខុស បុគ្គលអ្នកមានការងារខុស រមែងមានការចិញ្ចឹមជីវិតខុស បុគ្គលអ្នកចិញ្ចឹមជីវិតខុស រមែងមានសេចក្តីព្យាយាមខុស បុគ្គលអ្នកមានសេចក្តីព្យាយាមខុស រមែងមានការរលឹកខុស

មិច្ឆាសតិស្ស មិច្ឆាសមាធិ បហោតិ មិច្ឆាសមាធិស្ស មិច្ឆាញាណំ បហោតិ មិច្ឆាញាណិស្ស (១) មិច្ឆាវិមុត្តិ បហោតិ ។ ឯវមេវ ភិក្ខវេ មិច្ឆត្តំ អាគម្ម វិរាធនា ហោតិ នោ អារាធនា ។

(៦) សម្មត្តំ ភិក្ខវេ អាគម្ម អារាធនា ហោតិ នោ វិរាធនា ។ កថញ្ច ភិក្ខវេ សម្មត្តំ អាគម្ម អារាធនា ហោតិ នោ វិរាធនា ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ សម្មាសង្កប្បោ បហោតិ សម្មាសង្កប្បស្ស សម្មាវាចា បហោតិ សម្មាវាចស្ស សម្មាកម្មន្តោ បហោតិ សម្មាកម្មន្តស្ស សម្មាអាជីវោ បហោតិ សម្មាអាជីវស្ស សម្មាវាយាមោ បហោតិ សម្មា-វាយាមស្ស សម្មាសតិ បហោតិ សម្មាសតិស្ស សម្មា-សមាធិ បហោតិ សម្មាសមាធិស្ស សម្មាញាណំ បហោតិ សម្មាញាណិស្ស សម្មាវិមុត្តិ បហោតិ ។

---

១ ឱ. ម. មិច្ឆាញាណស្ស ។

បុគ្គលអ្នកមានការរលឹកខុស រមែងមានការដំកល់ចិត្តខុស បុគ្គលអ្នកដំកល់ចិត្តខុស រមែងមានការដឹងខុស បុគ្គលអ្នកមានការដឹងខុស រមែងមានការរួចខុស ។ ម្នាលភិក្ខុទាំងឡាយ កិរិយាឃ្លាត (ចាកស្ថានសួគ៌និងមគ្គ) មិនបានសម្រេច ព្រោះអាស្រ័យ នូវមិច្ឆត្តៈ យ៉ាងនេះឯង ។

(៤) ម្នាលភិក្ខុទាំងឡាយ ការបានសម្រេច មិនឃ្លាត (ចាកស្ថានសួគ៌និងមគ្គ) ព្រោះអាស្រ័យនូវសម្មត្តៈ (សភាពដែលត្រូវ) ។ ការបានសម្រេច មិនឃ្លាត (ចាកស្ថានសួគ៌និងមគ្គ) ព្រោះអាស្រ័យនូវសម្មត្តៈ (សភាពដែលត្រូវ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសេចក្តីយល់ត្រូវ រមែងមានតម្រិះត្រូវ បុគ្គលអ្នកមានតម្រិះត្រូវ រមែងមានវាចាត្រូវ បុគ្គលអ្នកមានវាចាត្រូវ រមែងមានការងារត្រូវ បុគ្គលអ្នកមានការងារត្រូវ រមែងមានការចិញ្ចឹមជីវិតត្រូវ បុគ្គលអ្នកមានការចិញ្ចឹមជីវិតត្រូវ រមែងមានសេចក្តីព្យាយាមត្រូវ បុគ្គលអ្នកមានសេចក្តីព្យាយាមត្រូវ រមែងមានការរលឹកត្រូវ បុគ្គលអ្នកមានការរលឹកត្រូវ រមែងមានការដំកល់ចិត្តត្រូវ បុគ្គលអ្នកមានការដំកល់ចិត្តត្រូវ រមែងមានការដឹងត្រូវ បុគ្គលអ្នកមានការដឹងត្រូវ រមែងមានការរួចត្រូវ ។

ឯវំ ខោ ភិក្ខវេ សម្មត្តំ អាគម្ម អារាធនា ហោតិ នោ វិរាធនាតិ ។ មិច្ឆាទិដ្ឋិកស្ស ភិក្ខវេ បុរិសបុគ្គលស្ស មិច្ឆាសង្កប្បស្ស មិច្ឆាវាចស្ស មិច្ឆាកម្មន្តស្ស មិច្ឆាអាជីវស្ស មិច្ឆាវាយាមស្ស មិច្ឆាសតិស្ស មិច្ឆាសមាធិស្ស មិច្ឆាញាណិស្ស មិច្ឆាវិមុត្តិស្ស យញ្ចេវ កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច វចីកម្មំ... យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា អនិដ្ឋាយ អកន្តាយ អមនាបាយ អហិតាយ ទុក្ខាយ សំវត្តន្តិ ។ តំ កិស្ស ហេតុ ។ ទិដ្ឋិ ហិ ភិក្ខវេ បាបិកា ។ សេយ្យថាបិ ភិក្ខវេ និម្ពពីជំ វា កោសាតកីពីជំ វា តិត្តកាលាពុពីជំ វា អល្លាយ បឋវិយា និក្ខិត្តំ យញ្ចេវ បឋវិរសំ ឧបាទិយតិ យញ្ច អាបោរសំ ឧបាទិយតិ សព្វន្តំ តិត្តកត្តាយ កដុកត្តាយ អសាតត្តាយ សំវត្តតិ ។

ម្នាលភិក្ខុទាំងឡាយ ការបានសម្រេច មិនឃ្លាត (ចាកស្ថានសួគ៌និងមគ្គ) ព្រោះអាស្រ័យ នូវសម្មត្តៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលប្រកប ដោយមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណៈ មិច្ឆាវិមុត្តិ បានសមាទាន នូវកាយកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ វចីកម្មណាផង... បានសមាទាន នូវមនោកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ ចេតនាណាផង សេចក្តីប្រាថ្នាណាផង ការដំកល់ចិត្តណាផង សង្ខារទាំងឡាយណាផង (របស់បុរសបុគ្គល ដែលប្រកប ដោយមិច្ឆា-ទិដ្ឋិជាដើមនោះ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិជាអំពើអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ដូចពូជស្តៅក្តី ពូជននោងព្រៃក្តី ពូជម្រះក្តី ដែលបុគ្គលដាំ ក្នុងផែនដីដែលសើមស្រូបយកនូវរសបឋវីធាតុណាផង ស្រូបយកនូវរសអាបោធាតុណាផង របស់ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីមានរសល្វីង រសហឹរ រសចត់ ។

តំ កិស្ស ហេតុ ។ ពីជម្ហិ ភិក្ខវេ បាបកំ ។ ឯវមេវ ខោ ភិក្ខវេ មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស មិច្ឆាសង្កប្បស្ស មិច្ឆាវាចស្ស មិច្ឆាកម្មន្តស្ស មិច្ឆា-អាជីវស្ស មិច្ឆាវាយាមស្ស មិច្ឆាសតិស្ស មិច្ឆាសមា-ធិស្ស មិច្ឆាញាណិស្ស មិច្ឆាវិមុត្តិស្ស យញ្ចេវ កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច វចីកម្មំ... យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា អនិដ្ឋាយ អកន្តាយ អមនាបាយ អហិតាយ ទុក្ខាយ សំវត្តន្តិ ។ តំ កិស្ស ហេតុ ។ ទិដ្ឋិ ហិ ភិក្ខវេ បាបិកា ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ បុរិសបុគ្គលស្ស សម្មាសង្កប្បស្ស សម្មាវាចស្ស សម្មាកម្មន្តស្ស សម្មាអាជីវស្ស សម្មាវាយាមស្ស សម្មាសតិស្ស សម្មាសមាធិស្ស សម្មាញាណិស្ស សម្មាវិមុត្តិស្ស

ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពូជជារបស់អាក្រក់យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលប្រកបដោយ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណៈ មិច្ឆាវិមុត្តិ បានសមាទានទូវកាយកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ វចីកម្មណាផង... បានសមាទានទូវមនោកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ ចេតនាណាផង សេចក្តីប្រាថ្នាណាផង ការដំកល់ចិត្តណាផង សង្ខារទាំងឡាយណាផង ( របស់បុរសបុគ្គលដែលប្រកប ដោយមិច្ឆាទិដ្ឋិ ជាដើមនោះ ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិជាធម្មជាតិអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គល ដែលប្រកបដោយសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សម្មាញាណៈ សម្មាវិមុត្តិ

តតិយបណ្ណាសកេ សមណសញ្ញាវគ្គោ

យស្ស កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ
យញ្ច វចីកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច
មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច
ចេតនា យា ច បត្ថនា យោ ច បណិធិ
យេ ច សង្ខារា សព្វេ តេ ធម្មា ឥដ្ឋាយ កន្តាយ
មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ តំ កិស្ស
ហេតុ ។ ទិដ្ឋិ ហិ ភិក្ខវេ ភទ្ទិកា ។ សេយ្យ-
ថាបិ ភិក្ខវេ ឧច្ឆុពីជំ វា សាលិពីជំ វា មុទ្ទិកាពីជំ
វា អល្លាយ បឋវិយា និក្ខិត្តំ យញ្ច បឋវិរសំ
ឧបាទិយតិ យញ្ច អាបោរសំ ឧបាទិយតិ សព្វន្តំ
សាតត្តាយ មធុរត្តាយ អសេចនកត្តាយ សំវត្តតិ ។
តំ កិស្ស ហេតុ ។ ពីជំហិ ភិក្ខវេ ភទ្ទកំ ។
ឯវមេវ ខោ ភិក្ខវេ សម្មាទិដ្ឋិកស្ស បុរិសបុគ្គលស្ស
សម្មាសង្កប្បស្ស សម្មាវាចស្ស សម្មាកម្មន្តស្ស
សម្មាអាជីវស្ស សម្មាវាយាមស្ស សម្មាសតិស្ស
សម្មាសមាធិស្ស សម្មាញាណិស្ស សម្មាវិមុត្តិស្ស

បានសមាទាន នូវកាយកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ បានសមាទាន នូវវចីកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ បានសមាទាន នូវមនោកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ ចេតនាណាផង សេចក្តីប្រាថ្នាណាផង ការដំកល់ចិត្តណាផង សង្ខារទាំងឡាយណាផង (របស់បុរសបុគ្គលដែលប្រកប ដោយសម្មាទិដ្ឋិជាដើមនោះ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាប្រយោជន៍ ដើម្បីសេចក្តីសុខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិ ជាធម្មជាតិល្អ ។ ម្នាលភិក្ខុទាំងឡាយ ដូចពូជអំពៅក្តី ពូជស្រូវសាលីក្តី ពូជចន្ទន៍ក្តី ដែលបុគ្គលដាំ ក្នុងផែនដីសើប ស្រូបយកនូវរស បថវីធាតុណាផង ស្រូបយកនូវរស អាបោធាតុណាផង រសទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីរសឆ្ងាញ់មានរសផ្អែម មានរសមិនបានប្រឡំ (ដោយរសដទៃ) យ៉ាងណាមិញ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពូជ ជារបស់ល្អ ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលប្រកប ដោយសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សម្មាញាណៈ សម្មាវិមុត្តិ

យញ្ចេវ កាយកម្មំ យថាទិដ្ឋិ សមត្តំ សមាទិន្នំ យញ្ច វចីកម្មំ... យញ្ច មនោកម្មំ យថាទិដ្ឋិ សមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា អនិដ្ឋាយ អកន្តាយ អមនាបាយ អហិតាយ ទុក្ខាយ សំវត្តន្តិ ។ តំ កិស្ស ហេតុ ។ ទិដ្ឋិ ហិ ភិក្ខវេ បាបិកាតិ ។

(៨) អវិជ្ជា ភិក្ខវេ បុព្វង្គមា អកុសលានំ ធម្មានំ សមាបត្តិយា អន្វទេវ អហិរិកំ អនោត្តប្បំ ។ អវិជ្ជាគតស្ស ភិក្ខវេ អវិទ្ទសុនោ មិច្ឆាទិដ្ឋិ បហោតិ មិច្ឆាទិដ្ឋិកស្ស មិច្ឆាសង្កប្បោ បហោតិ មិច្ឆាសង្កប្បស្ស មិច្ឆាវាចា បហោតិ មិច្ឆាវាចស្ស មិច្ឆាកម្មន្តោ បហោតិ មិច្ឆាកម្មន្តស្ស មិច្ឆាអាជីវោ បហោតិ មិច្ឆាអាជីវស្ស មិច្ឆាវាយាមោ បហោតិ មិច្ឆាវាយាមស្ស មិច្ឆាសតិ បហោតិ

បានសមាទាន នូវកាយកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ វចីកម្មណាផង ... បានសមាទាន នូវមនោកម្មណាផង ដ៏បរិបូណ៌តាមទិដ្ឋិ ចេតនាណាផង សេចក្ដីប្រាថ្នាណាផង ការតាំងចិត្តណាផង សង្ខារទាំងឡាយណាផង (របស់បុរសបុគ្គល ដែលប្រកប ដោយសម្មាទិដ្ឋិជាដើមនោះ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិ ជាធម្មជាតិល្អ ។

(៤) ម្នាលភិក្ខុទាំងឡាយ អវិជ្ជា ជាប្រធាន នៃការចូលប្រទះនូវពួកអកុសលធម៌ អហិរិកៈអនោត្តប្បៈ ក៏គង់ជាប់តាមដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកល្ងង់គឺអវិជ្ជា អ្នកមិនចេះដឹង រមែងមានមិច្ឆាទិដ្ឋិ បុគ្គលអ្នកប្រកប ដោយមិច្ឆាទិដ្ឋិ រមែងមានមិច្ឆាសង្កប្បៈ បុគ្គលជាមិច្ឆាសង្កប្បៈ រមែងមានមិច្ឆាវាចា បុគ្គលជាមិច្ឆាវាចា រមែងមានមិច្ឆាកម្មន្តៈ បុគ្គលជាមិច្ឆាកម្មន្តៈ រមែងមានមិច្ឆាអាជីវៈ បុគ្គលជាមិច្ឆាអាជីវៈ រមែងមានមិច្ឆាវាយាមៈ បុគ្គលជាមិច្ឆាវាយាមៈ រមែងមានមិច្ឆាសតិ

មិច្ឆាសតិស្ស មិច្ឆាសមាធិ បហោតិ មិច្ឆាសមាធិស្ស មិច្ឆាញាណំ បហោតិ មិច្ឆាញាណស្ស មិច្ឆាវិមុត្តិ បហោតិ ។ វិជ្ជា ភិក្ខវេ បុព្វង្គមា កុសលានំ ធម្មានំ សមាបត្តិយា អន្វទេវ ហិរោត្តប្បំ ។ វិជ្ជាគតស្ស ភិក្ខវេ វិទ្ទសុនោ សម្មាទិដ្ឋិ បហោតិ សម្មាទិដ្ឋិកស្ស សម្មាសង្កប្បោ បហោតិ សម្មាសង្កប្បស្ស សម្មាវាចា បហោតិ សម្មាវាចស្ស សម្មាកម្មន្តោ បហោតិ សម្មាកម្មន្តស្ស សម្មាអាជីវោ បហោតិ សម្មាអាជីវស្ស សម្មាវាយាមោ បហោតិ សម្មាវាយាមស្ស សម្មាសតិ បហោតិ សម្មាសតិស្ស សម្មាសមាធិ បហោតិ សម្មាសមាធិស្ស សម្មាញាណំ បហោតិ សម្មាញាណស្ស សម្មាវិមុត្តិ បហោតិ ។

(២) ទសយិមានិ ភិក្ខវេ និជ្ជរវត្ថូនិ ។ កតមានិ ទស ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ មិច្ឆាទិដ្ឋិ និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាទិដ្ឋិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ

បុគ្គលជាមិច្ឆាសតិ រមែងមានមិច្ឆាសមាធិ បុគ្គលជាមិច្ឆាសមាធិ រមែងមានមិច្ឆាញាណៈ បុគ្គលជាមិច្ឆាញាណៈ រមែងមានមិច្ឆាវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ វិជ្ជា ជាប្រធាន ក្នុងការចូលប្រសប់នូវពួកកុសលធម៌ ហិរិនិងឱត្តប្បៈ ក៏តែងជាប់តាមដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រកបដោយវិជ្ជាជាអ្នកចេះដឹង រមែងមានសម្មាទិដ្ឋិ បុគ្គលជាសម្មាទិដ្ឋិ រមែងមានសម្មាសង្កប្បៈ បុគ្គលជាសម្មាសង្កប្បៈ រមែងមានសម្មាវាចា បុគ្គលជាសម្មាវាចា រមែងមានសម្មាកម្មន្តៈ បុគ្គលជាសម្មាកម្មន្តៈ រមែងមានសម្មាអាជីវៈ បុគ្គលជាសម្មាអាជីវៈ រមែងមានសម្មាវាយាមៈ បុគ្គលជាសម្មាវាយាមៈ រមែងមានសម្មាសតិ បុគ្គលជាសម្មាសតិ រមែងមានសម្មាសមាធិ បុគ្គលជាសម្មាសមាធិ រមែងមានសម្មាញាណៈ បុគ្គលជាសម្មាញាណៈ រមែងមានសម្មាវិមុត្តិ ។

(៦) ម្នាលភិក្ខុទាំងឡាយ ហេតុដែលនាំឲ្យសាបរលាបទៅនេះមាន ១០ យ៉ាង ។ ១០ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយសម្មាទិដ្ឋិ រមែងមានមិច្ឆាទិដ្ឋិសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា មានមិច្ឆាទិដ្ឋិជាបច្ច័យ អកុសលធម៌ទាំងឡាយនោះ របស់បុគ្គលជាសម្មាទិដ្ឋិនោះ រមែងសាបរលាបទៅ

សម្មាទិដ្ឋិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាសង្កប្បស្ស ភិក្ខវេ មិច្ឆាសង្កប្បោ និជ្ជិណ្ណោ ហោតិ យេ ច មិច្ឆាសង្កប្បប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាសង្កប្បប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាវាចស្ស ភិក្ខវេ មិច្ឆាវាចា និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាវាចាបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាវាចាបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាកម្មន្តស្ស ភិក្ខវេ មិច្ឆាកម្មន្តោ និជ្ជិណ្ណោ ហោតិ យេ ច មិច្ឆាកម្មន្តប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាកម្មន្តប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។

កុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិជាបច្ច័យក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈ រមែងមានមិច្ឆាសង្កប្បៈសាបរលាបទៅ អកុសលធម៌ទាំងឡាយ ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាសង្កប្បៈ ជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាសង្កប្បៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាសង្កប្បៈ ជាបច្ច័យក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាចា រមែងមានមិច្ឆាវាចាសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវាចាជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះរបស់បុគ្គលជាសម្មាវាចានោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការដែលមានសម្មាវាចាជាបច្ច័យ ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាកម្មន្តៈ រមែងមានមិច្ឆាកម្មន្តៈសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាកម្មន្តៈ ជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មាកម្មន្តៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការដែលមានសម្មាកម្មន្តៈជាបច្ច័យ ក៏រមែងដល់នូវការបរិបូណ៌ដោយភាវនា ។

## តតិយបណ្ណាសកេ សមណសញ្ញាវគ្គោ

សម្មាអាជីវស្ស ភិក្ខវេ មិច្ឆាអាជីវោ និជ្ជិណ្ណោ ហោតិ យេ ច មិច្ឆាអាជីវប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាអាជីវប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាវាយាមស្ស ភិក្ខវេ មិច្ឆាវាយាមោ និជ្ជិណ្ណោ ហោតិ យេ ច មិច្ឆាវាយាមប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាវាយាមប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាសតិស្ស ភិក្ខវេ មិច្ឆាសតិ និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាសតិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាសតិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ រមែងមានមិច្ឆាអាជីវៈសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាអាជីវៈ ជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាអាជីវៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការដែលមានសម្មាអាជីវៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ រមែងមានមិច្ឆាវាយាមៈសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវាយាមៈជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាអាជីវៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការដែលមានសម្មាវាយាមៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ រមែងមានមិច្ឆាសតិសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាសតិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាសតិនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាសតិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា ។

សម្មាសមាធិស្ស ភិក្ខវេ មិច្ឆាសមាធិ និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាសមាធិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាសមាធិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាញាណិស្ស ភិក្ខវេ មិច្ឆាញាណំ និជ្ជិណ្ណំ ហោតិ យេ ច មិច្ឆាញាណប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាញាណប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាវិមុត្តិស្ស ភិក្ខវេ មិច្ឆាវិមុត្តិ និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាវិមុត្តិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាវិមុត្តិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ ឥមានិ ខោ ភិក្ខវេ ទស និជ្ជរវត្ថូនីតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ រមែងមានមិច្ឆាសមាធិ សាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាសមាធិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាសមាធិនោះ រមែងសាបរលាបទៅ ទើបកុសលធម៌ច្រើនប្រការដែលមានសម្មាសមាធិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ រមែងមានមិច្ឆាញាណៈសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាញាណៈជាបច្ច័យកើតព្រម អកុសលធម៌ទាំងអស់នោះ របស់បុគ្គលជាសម្មាញាណៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការដែលមានសម្មាញាណៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាសម្មាវិមុត្តិ រមែងមានមិច្ឆាវិមុត្តិ សាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាវិមុត្តិនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការដែលមានសម្មាវិមុត្តិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលនាំឲ្យសាបរលាបទៅ មាន ១០ យ៉ាងនេះឯង ។

(៧) អត្ថិ ភិក្ខវេ ទក្ខិណេសុ ជនបទេសុ ធោវនំ នាម តត្ថ ហោតិ អន្នម្បិ បានម្បិ ខជ្ជម្បិ ភោជ្ជម្បិ លេយ្យម្បិ បេយ្យម្បិ នច្ចម្បិ គីតម្បិ វាទិតម្បិ ។ អត្ថេតំ ភិក្ខវេ ធោវនំ នេតំ នត្ថីតិ វទាមិ ។ តញ្ច ខោ ឯតំ ភិក្ខវេ ធោវនំ ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។

(៧) ម្នាលភិក្ខុទាំងឡាយ ក្នុងទក្ខិណជនបទ តែងមានពិធីលានឆ្អឹង(១)ជាធម្មតា បាយក្តី ទឹកក្តី បង្អែមក្តី ចំអាបក្តី វត្ថុដែលគប្បីលិទ្ធក្តី ទឹកដែលគប្បីផឹកក្តី ការរាំក្តី ច្រៀងក្តី ប្រគំក្តី តែងមានក្នុងពិធីលានឆ្អឹងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពិធីលានឆ្អឹងនុ៎ះ មានមែន តថាគត មិនពោលថា ពិធីលានឆ្អឹងនោះ មិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ តែថា ពិធីលានឆ្អឹងនោះឯង ជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយៈ មិនមានប្រយោជន៍ មិនមែនប្រព្រឹត្តទៅ ដើម្បីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីរលត់ មិនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ ។

---

១ ទំនៀមថា ពួកមនុស្សក្នុងទក្ខិណាជនបទនោះ មិនដែលដុតពួកញាតិដែលស្លាប់ហើយទេ គ្រាន់តែជីករណ្តៅកប់ទុកក្នុងផែនដី លុះដល់សាកសពទាំងនោះរលួយហើយ ទើបរើសយកឆ្អឹងមកលាង ហើយដាក់ដំរៀបតាមលំដាប់ រួចនាំគ្នាបូជាដោយគ្រឿងក្រអូបនឹងផ្កាកំរងជាដើម លុះដល់ពេលនក្ខត្តឫក្ស ក៏នាំយកឆ្អឹងទាំងនោះមកហើយយំខ្សឹកខ្សួល ទើបនាំគ្នាទៅលេងនក្ខត្តឫក្ស ។ អដ្ឋកថា ។

អយញ្ច[១] ខោ ភិក្ខវេ អរិយំ ញាយំ ទេសិស្សាមិ[២] យំ ញាយំ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ យំ ញាយំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ ជរាធម្មា សត្តា ជរាយ បរិមុច្ចន្តិ មរណធម្មា សត្តា មរណេន បរិមុច្ចន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា សត្តា សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ បរិមុច្ចន្តិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

---

១ ម. អត្ថិ ។ ២ ម. ទេសិស្សាមីតិ ន ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ ពិធីលានណា រមែងប្រព្រឹត្តទៅ ដើម្បីនឿយណាយ តែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ចិត្ត ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យនូវពិធីលានណា តថាគតនឹងសំដែងនូវពិធីលានដ៏ប្រសើរនោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ នូវពិធីលាននោះចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ។

ភគវា ឯតទវោច កតមញ្ច តំ(១) ភិក្ខវេ អរិយំ ធោវនំ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ យំ ធោវនំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ ជរាធម្មា សត្តា ជរាយ បរិមុច្ចន្តិ មរណធម្មា សត្តា មរណេន បរិមុច្ចន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា សត្តា សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ បរិមុច្ចន្តិ ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ មិច្ឆាទិដ្ឋិ និទ្ធន្តា ហោតិ យេ ច មិច្ឆាទិដ្ឋិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និទ្ធន្តា ហោន្តិ សម្មាទិដ្ឋិបច្ចយា អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាសង្កប្បស្ស ភិក្ខវេ មិច្ឆាសង្កប្បោ និទ្ធន្តោ ហោតិ ...

---

១ ម. តំសទ្ទោ នត្ថិ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានជាតិជាធម្មតា រមែងប្រែចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងប្រែចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងប្រែចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងប្រែចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ ទាំងឡាយបាន ព្រោះអាស្រ័យ នូវពិធីលាងណា ពិធីលាងដ៏ប្រសើរនោះ រមែងប្រព្រឹត្តទៅ ដើម្បីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ ឈ្មោះថា បានលាងមិច្ឆាទិដ្ឋិស្អាតហើយ អកុសលធម៌ទាំងឡាយ ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិ ជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គល ដែលជាសម្មាទិដ្ឋិនោះ ឈ្មោះថា បានលាងស្អាតហើយ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈ ឈ្មោះថាបានលាងមិច្ឆាសង្កប្បៈស្អាតហើយ . . .

សម្មាវាចស្ស ភិក្ខវេ មិច្ឆាវាចា និជ្ជិណ្ណា ហោតិ... សម្មាកម្មន្តស្ស ភិក្ខវេ មិច្ឆាកម្មន្តោ និជ្ជិណ្ណោ ហោតិ... សម្មាអាជីវស្ស ភិក្ខវេ មិច្ឆាអាជីវោ និជ្ជិណ្ណោ ហោតិ... សម្មាវាយាមស្ស ភិក្ខវេ មិច្ឆាវាយាមោ និជ្ជិណ្ណោ ហោតិ... សម្មាសតិស្ស ភិក្ខវេ មិច្ឆាសតិ និជ្ជិណ្ណា ហោតិ... សម្មាសមាធិស្ស ភិក្ខវេ មិច្ឆាសមាធិ និជ្ជិណ្ណោ ហោតិ... សម្មាញាណស្ស ភិក្ខវេ មិច្ឆាញាណំ និជ្ជិណ្ណំ ហោតិ... សម្មាវិមុត្តិស្ស ភិក្ខវេ មិច្ឆាវិមុត្តិ និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាវិមុត្តិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាវិមុត្តិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាចា ឈ្មោះថា បានលាងមិច្ឆាវាចាស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាកម្មន្តៈ ឈ្មោះថា បានលាងមិច្ឆាកម្មន្តៈស្អាតហើយ.. ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ ឈ្មោះថា បានលាងមិច្ឆាអាជីវៈស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ ឈ្មោះថា បានលាងមិច្ឆាវាយាមៈស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ ឈ្មោះថា បានលាងមិច្ឆាសតិស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ ឈ្មោះថា បានលាងមិច្ឆាសមាធិស្អាតហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ ឈ្មោះថា បានលាងមិច្ឆាញាណៈស្អាតហើយ .. ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវិមុត្តិ ឈ្មោះថា បានលាងមិច្ឆាវិមុត្តិ ស្អាតហើយ អកុសលធម៌ទាំងឡាយ ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិ ជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មាវិមុត្តិនោះ ឈ្មោះថា បានលាងស្អាតហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា ។

ឥទំ ខោ តំ ភិក្ខវេ អរិយំ ញាណំ ឯកន្ត-
និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិ-
ញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ យំ
ញាណំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ
ជរាធម្មា សត្តា ជរាយ បរិមុច្ចន្តិ មរណធម្មា
សត្តា មរណេន បរិមុច្ចន្តិ សោកបរិទេវទុក្ខទោមន-
ស្សុបាយាសធម្មា សត្តា សោកបរិទេវទុក្ខទោមន-
ស្សុបាយាសេហិ បរិមុច្ចន្តីតិ ។

(៨) តិកិច្ឆកា ភិក្ខវេ វិរេចនំ ទេន្តិ បិត្តសមុ-
ដ្ឋានានម្បិ អាពាធានំ បដិឃាតាយ សេម្ហ-
សមុដ្ឋានានម្បិ អាពាធានំ បដិឃាតាយ វាត-
សមុដ្ឋានានម្បិ អាពាធានំ បដិឃាតាយ អត្ថេតំ
ភិក្ខវេ វិរេចនំ នេតំ នត្ថីតិ វទាមិ តញ្ច ខោ
ឯតំ ភិក្ខវេ វិរេចនំ សម្បជ្ជតិបិ វិបជ្ជតិបិ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានជាតិជាធម្មតា រមែងប្រែបាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងប្រែបាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងប្រែបាកមរណៈ ពួកសត្វមានសេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងប្រែបាកសេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យពិធីលាងណា ពិធីលាងដ៏ប្រសើរនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

(៨) ម្នាលភិក្ខុទាំងឡាយ ពួកពេទ្យឲ្យថ្នាំបញ្ចុះ ដើម្បីឃាត់នូវអាពាធទាំងឡាយ ដែលកើតពីប្រមាត់ខ្លះ ដើម្បីឃាត់ នូវអាពាធទាំងឡាយ ដែលកើតពីស្លេស្មខ្លះ ដើម្បីឃាត់ នូវអាពាធទាំងឡាយ ដែលកើតពីខ្យល់ខ្លះ ម្នាលភិក្ខុទាំងឡាយ ថ្នាំបញ្ចុះនោះមានមែន តថាគត មិនមែនពោលថា ថ្នាំបញ្ចុះនុ៎ះ មិនមានទេ ម្នាលភិក្ខុទាំងឡាយ តែថាថ្នាំបញ្ចុះនោះឯង សម្រេចខ្លះមិនសម្រេចខ្លះ ។

អហញ្ច ខោ តំ ភិក្ខវេ អរិយំ វិវេចនំ ទេសិ-
ស្សាមិ យំ វិវេចនំ សម្បជ្ជតិយេវ សោ វិបជ្ជតិ យំ
វិវេចនំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ
ជរាធម្មា សត្តា ជរាយ បរិមុច្ចន្តិ មរណធម្មា
សត្តា មរណេន បរិមុច្ចន្តិ សោកបរិទេវទុក្ខទោម-
នស្សុបាយាសធម្មា សត្តា សោកបរិទេវទុក្ខទោម-
នស្សុបាយាសេហិ បរិមុច្ចន្តិ តំ សុណាថ សាធុកំ
មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ
តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទ-
វោច កតមញ្ច តំ ភិក្ខវេ អរិយំ វិវេចនំ សម្បជ្ជ-
តិយេវ សោ វិបជ្ជតិ យំ វិវេចនំ អាគម្ម ជាតិធម្មា
សត្តា ជាតិយា បរិមុច្ចន្តិ ជរាធម្មា សត្តា ជរាយ
បរិមុច្ចន្តិ មរណធម្មា សត្តា មរណេន បរិមុច្ចន្តិ
សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា សត្តា
សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ បរិមុច្ចន្តិ ។

ម្នាលភិក្ខុទាំងឡាយ ថ្នាំបញ្ចុះណា សុទ្ធតែសម្រេច មិនមែនមិនសម្រេច ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំបញ្ចុះណា តថាគតនឹងសំដែងនូវថ្នាំបញ្ចុះដ៏ប្រសើរនោះឯង អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវពាក្យនោះចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំបញ្ចុះណា ថ្នាំបញ្ចុះដ៏ប្រសើរនោះ សុទ្ធតែសម្រេច មិនមែនមិនសម្រេចទេ តើដូចម្តេច ។

សម្មាទិដ្ឋិកស្ស ភិក្ខវេ មិច្ឆាទិដ្ឋិ វិហតា ហោតិ យេ ច មិច្ឆាទិដ្ឋិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស វិហតា ហោន្តិ សម្មាទិដ្ឋិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។

សម្មាសង្កប្បស្ស ភិក្ខវេ មិច្ឆាសង្កប្បោ វិហតោ ហោតិ... សម្មាវាចស្ស ភិក្ខវេ មិច្ឆាវាចា វិហតា ហោតិ... សម្មាកម្មន្តស្ស ភិក្ខវេ មិច្ឆាកម្មន្តោ វិហតោ ហោតិ... សម្មាអាជីវស្ស ភិក្ខវេ មិច្ឆាអាជីវោ វិហតោ ហោតិ... សម្មាវាយាមស្ស ភិក្ខវេ មិច្ឆាវាយាមោ វិហតោ ហោតិ... សម្មាសតិស្ស ភិក្ខវេ មិច្ឆាសតិ វិហតា ហោតិ... សម្មាសមាធិស្ស ភិក្ខវេ មិច្ឆាសមាធិ វិហតោ ហោតិ... សម្មាញាណិស្ស ភិក្ខវេ មិច្ឆាញាណំ វិហតំ ហោតិ...

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ ឈ្មោះថា បានបញ្ចុះមិច្ឆាទិដ្ឋិចេញហើយ អកុសលធម៌ទាំងឡាយ ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិ ជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាទិដ្ឋិនោះ ឈ្មោះថា បានបញ្ចុះហើយ កុសលធម៌ ច្រើនប្រការដែលមានសម្មាទិដ្ឋិ ជាបច្ច័យ រមែងដល់ នូវការបរិបូណ៌ដោយភាវនា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈ ឈ្មោះថា បានបញ្ចុះមិច្ឆា-សង្កប្បៈ ចេញហើយ... ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាសម្មាវាចា ឈ្មោះថា បានបញ្ចុះមិច្ឆាវាចា ចេញហើយ...ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាកម្មន្តៈ ឈ្មោះថា បានបញ្ចុះមិច្ឆាកម្មន្តៈ ចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ ឈ្មោះថា បានបញ្ចុះមិច្ឆា-អាជីវៈ ចេញហើយ . . .ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ ឈ្មោះថា បានបញ្ចុះមិច្ឆាវាយាមៈ ចេញហើយ . . . ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ ឈ្មោះថា បានបញ្ចុះមិច្ឆាសតិ ចេញហើយ . . . ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ ឈ្មោះថា បានបញ្ចុះមិច្ឆាសមាធិ ចេញហើយ . . . ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ ឈ្មោះថា បានបញ្ចុះមិច្ឆាញាណៈ ចេញហើយ . . .

សម្មាវិមុត្តិស្ស ភិក្ខវេ មិច្ឆាវិមុត្តិ និទ្ធន្តា ហោតិ យេ ច មិច្ឆាវិមុត្តិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និទ្ធន្តា ហោន្តិ សម្មាវិមុត្តិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ ឥទំ ខោ តំ ភិក្ខវេ អរិយំ វិរេចនំ យំ វិរេចនំ សម្បជ្ជតិយេវ នោ វិបជ្ជតិ យំ វិរេចនំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ ជរាធម្មា សត្តា ជរាយ បរិមុច្ចន្តិ មរណធម្មា សត្តា មរណេន បរិមុច្ចន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា សត្តា សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ បរិមុច្ចន្តីតិ ។

(៩) តិកិច្ឆកា ភិក្ខវេ វមនំ ទេន្តិ បិត្តសមុដ្ឋានានម្បិ អាពាធានំ បដិឃាតាយ សេម្ហសមុដ្ឋានានម្បិ អាពាធានំ បដិឃាតាយ វាតសមុដ្ឋានានម្បិ អាពាធានំ បដិឃាតាយ អត្ថេតំ ភិក្ខវេ វមនំ នេតំ នត្ថីតិ វទាមិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ ឈ្មោះថា បានបញ្ចុះមិច្ឆាទិដ្ឋិចេញហើយ អកុសលធម៌ទាំងឡាយ ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិ ជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មាទិដ្ឋិនោះ ឈ្មោះថា បានបញ្ចុះចេញហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ ថ្នាំបញ្ចុះណា សុទ្ធតែសម្រេច មិនមែនមិនសម្រេច ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំបញ្ចុះណា ថ្នាំបញ្ចុះនោះឯង ជាថ្នាំដ៏ប្រសើរ ។

(៩) ម្នាលភិក្ខុទាំងឡាយ ពួកពេទ្យឲ្យថ្នាំក្អួត ដើម្បីឃាត់នូវអាពាធទាំងឡាយ ដែលកើតពីប្រមាត់ខ្លះ ដើម្បីឃាត់ នូវអាពាធទាំងឡាយដែលកើតពីស្លេស្មខ្លះ ដើម្បីឃាត់ នូវអាពាធទាំងឡាយ ដែលកើតពីខ្យល់ខ្លះ ម្នាលភិក្ខុទាំងឡាយ ថ្នាំក្អួតនោះមានមែន តថាគត មិនពោលថា ថ្នាំក្អួតនុះមិន

តត្ថ ខោ ឯតំ ភិក្ខវេ វមនំ សម្បជ្ជតិបិ វិបជ្ជតិបិ ។ អហញ្ច ខោ តំ ភិក្ខវេ អរិយំ វមនំ ទេសិស្សាមិ យំ វមនំ សម្បជ្ជតិយេវ នោ វិបជ្ជតិ យំ វមនំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ ជរាធម្មា សត្តា ជរាយ បរិមុច្ចន្តិ មរណធម្មា សត្តា មរណេន បរិមុច្ចន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា សត្តា សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ បរិមុច្ចន្តិ តំ សុណាថ ... កតមញ្ច តំ ភិក្ខវេ អរិយំ វមនំ សម្បជ្ជតិយេវ នោ វិបជ្ជតិ យំ វមនំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ ។ បេ ។ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា សត្តា សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ បរិមុច្ចន្តិ ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ មិច្ឆាទិដ្ឋិ វន្តា ហោតិ យេ ច មិច្ឆាទិដ្ឋិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ

មានទេ ម្នាលភិក្ខុទាំងឡាយ តែថ្នាំក្អួតនោះឯង សម្រេចខ្លះមិនសម្រេចខ្លះៗ ម្នាលភិក្ខុទាំងឡាយ ថ្នាំក្អួតណាសុទ្ធតែសម្រេច មិនមែនមិនសម្រេច ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំក្អួតណា តថាគតនឹងសំដែងនូវថ្នាំក្អួត ដ៏ប្រសើរនោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ នូវពាក្យនោះចុះ ... ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ។ បេ ។ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យថ្នាំក្អួតណា ថ្នាំក្អួតដ៏ប្រសើរនោះ សុទ្ធតែសម្រេច មិនមែនមិនសម្រេច តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ ឈ្មោះថាបានក្អួតមិច្ឆាទិដ្ឋិ ចេញហើយ អកុសលធម៌ទាំងឡាយ ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិ ជាបច្ច័យ កើតព្រម

តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាទិដ្ឋិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាសង្កប្បស្ស ភិក្ខវេ មិច្ឆាសង្កប្បោ និជ្ជិណ្ណោ ហោតិ...

សម្មាវាចស្ស ភិក្ខវេ មិច្ឆាវាចា និជ្ជិណ្ណា ហោតិ...

សម្មាកម្មន្តស្ស ភិក្ខវេ មិច្ឆាកម្មន្តោ និជ្ជិណ្ណោ ហោតិ...

សម្មាអាជីវស្ស ភិក្ខវេ មិច្ឆាអាជីវោ និជ្ជិណ្ណោ ហោតិ...

សម្មាវាយាមស្ស ភិក្ខវេ មិច្ឆាវាយាមោ និជ្ជិណ្ណោ ហោតិ...

សម្មាសតិស្ស ភិក្ខវេ មិច្ឆាសតិ និជ្ជិណ្ណា ហោតិ...

សម្មាសមាធិស្ស ភិក្ខវេ មិច្ឆាសមាធិ និជ្ជិណ្ណោ ហោតិ...

សម្មាញាណស្ស ភិក្ខវេ មិច្ឆាញាណំ និជ្ជិណ្ណំ ហោតិ...

សម្មាវិមុត្តិស្ស ភិក្ខវេ មិច្ឆាវិមុត្តិ និជ្ជិណ្ណា ហោតិ...

យេ ច មិច្ឆាវិមុត្តិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ

អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាទិដ្ឋិនោះ ឈ្មោះថា បានក្អួតចេញហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិ ជាបច្ច័យ រមែងដល់ នូវការបរិបូណ៌ដោយការភាវនា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈឈ្មោះថា បានក្អួតមិច្ឆាសង្កប្បៈចេញហើយ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាចា ឈ្មោះថា បានក្អួតមិច្ឆាវាចា ចេញហើយ...បុគ្គលជាសម្មាកម្មន្តៈ ឈ្មោះថា បានក្អួតមិច្ឆាកម្មន្តៈ ចេញហើយ ...ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ ឈ្មោះថា បានក្អួតមិច្ឆាអាជីវៈចេញហើយ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ ឈ្មោះថា បានក្អួតមិច្ឆាវាយាមៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ ឈ្មោះថា បានក្អួតមិច្ឆាសតិចេញហើយ ..ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ ឈ្មោះថា បានក្អួតមិច្ឆាសមាធិចេញហើយ...ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ ឈ្មោះថា បានក្អួតមិច្ឆាញាណៈចេញហើយ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវិមុត្តិ ឈ្មោះថា បានក្អួតមិច្ឆាវិមុត្តិចេញហើយ... អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះរបស់បុគ្គលដែលជាសម្មាវិមុត្តិនោះឈ្មោះថាបានក្អួតចេញហើយ

សម្មាវិមុត្តិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនា-
បារិបូរឹ គច្ឆន្តិ ។ ឥទំ ខោ តំ ភិក្ខវេ អរិយំ
វមនំ សម្បត្តិយេវ នោ វិបត្តិ យំ វមនំ អាគម្ម
ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ ជរាធម្មា សត្តា
ជរាយ បរិមុច្ចន្តិ មរណធម្មា សត្តា មរណេន បរិ-
មុច្ចន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា សត្តា
សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ បរិមុច្ចន្តីតិ ។

(១០) ទសយិមេ ភិក្ខវេ និទ្ធមនិយា ធម្មា ។
កតមេ ទស ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ មិច្ឆា-
ទិដ្ឋិ និទ្ធន្តា ហោតិ យេ ច មិច្ឆាទិដ្ឋិបច្ចយា
អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ
តេ ចស្ស និទ្ធន្តា ហោន្តិ សម្មាទិដ្ឋិបច្ចយា ច
អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។

កុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយការនោ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានជាតិជាធម្មតា រមែងរួចចាកជាតិ ពួកសត្វមានជរាជាធម្មតា រមែងរួចចាកជរា ពួកសត្វមានមរណៈជាធម្មតា រមែងរួចចាកមរណៈ ពួកសត្វមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា រមែងរួចចាកសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ទាំងឡាយបាន ព្រោះអាស្រ័យនូវជាំក្អួតណា ជាំក្អួតដ៏ប្រសើរនោះឯង សុទ្ធតែសម្រេច មិនមែនមិនសម្រេចទេ ។

(១០) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ដែលគប្បីកំចាត់បង់នេះ មាន ១០ យ៉ាង ។ ១០ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ បានកំចាត់បង់មិច្ឆាទិដ្ឋិចេញហើយ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិ ជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គល ដែលជាសម្មាទិដ្ឋិនោះ ឈ្មោះថា បានកំចាត់បង់ហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយការនោ ។

សម្មាសង្កប្បស្ស ភិក្ខវេ មិច្ឆាសង្កប្បោ និជ្ជិណ្ណោ ហោតិ... សម្មាវាចស្ស ភិក្ខវេ មិច្ឆាវាចា និជ្ជិណ្ណា ហោតិ... សម្មាកម្មន្តស្ស ភិក្ខវេ មិច្ឆាកម្មន្តោ និជ្ជិណ្ណោ ហោតិ... សម្មាអាជីវស្ស ភិក្ខវេ មិច្ឆាអាជីវោ និជ្ជិណ្ណោ ហោតិ... សម្មាវាយាមស្ស ភិក្ខវេ មិច្ឆាវាយាមោ និជ្ជិណ្ណោ ហោតិ... សម្មាសតិស្ស ភិក្ខវេ មិច្ឆាសតិ និជ្ជិណ្ណា ហោតិ... សម្មាសមាធិស្ស ភិក្ខវេ មិច្ឆាសមាធិ និជ្ជិណ្ណោ ហោតិ... សម្មាញាណិស្ស ភិក្ខវេ មិច្ឆាញាណំ និជ្ជិណ្ណំ ហោតិ... សម្មាវិមុត្តិស្ស ភិក្ខវេ មិច្ឆាវិមុត្តិ និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាវិមុត្តិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាវិមុត្តិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្បៈ ឈ្មោះថា បានកំចាត់បង់មិច្ឆាសង្កប្បៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាចា ឈ្មោះថា បានកំចាត់បង់មិច្ឆាវាចាចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាកម្មន្តៈ ឈ្មោះថា បានកំចាត់បង់មិច្ឆាកម្មន្តៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ ឈ្មោះថា បានកំចាត់បង់មិច្ឆាអាជីវៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ ឈ្មោះថា បានកំចាត់បង់មិច្ឆាវាយាមៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ ឈ្មោះថា បានកំចាត់បង់មិច្ឆាសតិចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ ឈ្មោះថា បានកំចាត់បង់មិច្ឆាសមាធិចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណៈ ឈ្មោះថា បានកំចាត់បង់មិច្ឆាញាណៈចេញហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវិមុត្តិ ឈ្មោះថា បានកំចាត់បង់មិច្ឆាវិមុត្តិចេញហើយ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិជាបច្ច័យ កើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មាវិមុត្តិនោះ ឈ្មោះថា បានកំចាត់បង់ហើយ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។

ឥមេ ខោ ភិក្ខវេ ទស និទ្ធមនិយា ធម្មាតិ ។

(១១) អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អសេក្ខោ អសេក្ខោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ភិក្ខុ អសេក្ខោ ហោតីតិ ។ ឥធ ភិក្ខុ(១) អសេក្ខាយ សម្មាទិដ្ឋិយា សមន្នាគតោ ហោតិ អសេក្ខេន សម្មាសង្កប្បេន សមន្នាគតោ ហោតិ អសេក្ខាយ សម្មាវាចាយ សមន្នាគតោ ហោតិ អសេក្ខេន សម្មាកម្មន្តេន សមន្នាគតោ ហោតិ អសេក្ខេន សម្មាអាជីវេន សមន្នាគតោ ហោតិ អសេក្ខាយ សម្មាវាយាមេន សមន្នាគតោ ហោតិ អសេក្ខាយ សម្មាសតិយា សមន្នាគតោ ហោតិ អសេក្ខេន

---

១ ឱ. ឥធ ភិក្ខុ ភិក្ខូតិ វិស្សជ្ជតិ ។ ម. ឥធ ភិក្ខវេ ភិក្ខុស្សាតិ វិស្សជ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលគប្បីកំចាត់បង់មាន ១០ យ៉ាងនេះឯង ។

(១១) គ្រានោះ ភិក្ខុ ១ រូបបានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ត្រាស់ថា អសេក្ខៈ អសេក្ខៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាអសេក្ខៈ តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រកបដោយសម្មាទិដ្ឋិ ជាអសេក្ខៈ ប្រកបដោយសម្មាសង្កប្បៈ ជាអសេក្ខៈ ប្រកបដោយសម្មាវាចា ជាអសេក្ខៈ ប្រកបដោយសម្មាកម្មន្តៈ ជាអសេក្ខៈ ប្រកបដោយសម្មាអាជីវៈ ជាអសេក្ខៈ ប្រកបដោយសម្មាវាយាមៈ ជាអសេក្ខៈ ប្រកបដោយសម្មាសតិ ជាអសេក្ខៈ

សម្មាសមាធិនា សមន្នាគតោ ហោតិ អសេក្ខេន សម្មាញាណេន សមន្នាគតោ ហោតិ អសេក្ខាយ សម្មាវិមុត្តិយា សមន្នាគតោ ហោតិ ។ ឯវំ ខោ ភិក្ខុ(១) អសេក្ខោ ហោតីតិ ។

[១៤] ទសយិមេ ភិក្ខវេ អសេក្ខិយា ធម្មា ។ កតមេ ទស ។ អសេក្ខា សម្មាទិដ្ឋិ អសេក្ខោ សម្មាសង្កប្បោ អសេក្ខា សម្មាវាចា អសេក្ខោ សម្មាកម្មន្តោ អសេក្ខោ សម្មាអាជីវោ អសេក្ខោ សម្មាវាយាមោ អសេក្ខា សម្មាសតិ អសេក្ខោ សម្មាសមាធិ អសេក្ខំ សម្មាញាណំ អសេក្ខា សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស អសេក្ខិយា ធម្មាតិ ។

បឋមោ សមណសញ្ញាវគ្គោ ។

---

១ ឱ. ម. ភិក្ខុ ភិក្ខូតិ បាឋោ ទិស្សតិ ។

ប្រកបដោយសម្មាសមាធិ ជាអសេក្ខៈ ប្រកបដោយសម្មាញាណៈ ជាអសេក្ខៈ ប្រកបដោយសម្មាវិមុត្តិ ជាអសេក្ខៈ ។ ម្នាលភិក្ខុ (ភិក្ខុ) ជាអសេក្ខៈ យ៉ាងនេះឯង ។

(១៤) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ជាអសេក្ខៈនេះ មាន ១០ យ៉ាង ។ ១០ យ៉ាងតើអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ជាអសេក្ខៈ ១ សម្មាសង្កប្បៈ ជាអសេក្ខៈ ១ សម្មាវាចា ជាអសេក្ខៈ ១ សម្មាកម្មន្តៈ ជាអសេក្ខៈ ១ សម្មាអាជីវៈ ជាអសេក្ខៈ ១ សម្មាវាយាមៈ ជាអសេក្ខៈ ១ សម្មាសតិ ជាអសេក្ខៈ ១ សម្មាសមាធិ ជាអសេក្ខៈ ១ សម្មាញាណៈ ជាអសេក្ខៈ ១ សម្មាវិមុត្តិ ជាអសេក្ខៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយជាអសេក្ខៈ មាន ១០ យ៉ាងនេះឯង ។

ចប់ សមណសញ្ញាវគ្គ ទី ១ ។

## តស្សុទ្ទានំ

សមណសញ្ញា ពោជ្ឈង្គា មិច្ឆត្តំ ឧបវិជ្ជយ
វិជ្ជាធំ ធោវនតិកិច្ឆា និទ្ធមេន ទ្វេ ជាតិ(១) ។

---

១ ឱ. សញ្ញា ពោជ្ឈង្គា មិច្ឆត្តំ ពីជំ វិជ្ជាយ និជ្ជរា
ធោវនញ្ច តិកិច្ឆា ច និទ្ធមនំ ទ្វេ អសេខាតិ ។
ម. សញ្ញា ពោជ្ឈង្គា មិច្ឆត្តំ ពីជំ វិជ្ជាយ និជ្ជរំ
ធោវនំ តិកិច្ឆា វមនំ និទ្ធមនំ ទ្វេ អសេខាតិ ។

## ឧទ្ទាននៃសមណសញ្ញាវគ្គនោះគឺ

និយាយអំពីសេចក្តីសំគាល់របស់សមណៈ ១ អំពីការចំរើនពោជ្ឈង្គទាំង ៧ ជាបច្ច័យឲ្យបានបំពេញនូវវិជ្ជា ៣ យ៉ាង ១ អំពីការមិនបានស្ថានសួគ៌ ព្រោះអាស្រ័យ មិច្ឆត្តៈ ១ អំពីការបានស្ថានសួគ៌ព្រោះអាស្រ័យសម្មត្តៈ ១ អំពីវិជ្ជា ជាប្រធាន ក្នុងការចូលប្រសព្វនូវកុសលធម៌ ១ អំពីការលាងឆ្អឹងក្នុងទក្ខិណាជនបទ ១ អំពីពេទ្យអ្នកឲ្យថ្នាំបញ្ចុះ ១ អំពីពេទ្យអ្នកឲ្យថ្នាំក្អួត ១ អំពីធម៌ដែលគប្បីកំចាត់មាន ២ លើក ។

# ទុតិយោ បច្ចោរោហណិវគ្គោ

(១៣) អធម្មោ ច ភិក្ខវេ វេទិតព្វោ អនត្ថោ ច ធម្មោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា អនត្ថញ្ច ធម្មញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វំ ។ កតមោ ច ភិក្ខវេ អធម្មោ ច អនត្ថោ ច ។ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា មិច្ឆាកម្មន្តោ មិច្ឆាអាជីវោ មិច្ឆាវាយាមោ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណំ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អធម្មោ ច អនត្ថោ ច ។ កតមោ ច ភិក្ខវេ ធម្មោ ច អត្ថោ ច ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ សម្មាញាណំ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ធម្មោ ច អត្ថោ ច ។

# បច្ចោរោហណិវគ្គទី ២

(១៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង សភាវៈ មិនមែនប្រយោជន៍ផង គប្បីដឹងធម៌ផង ប្រយោជន៍ផង លុះដឹងច្បាស់សភាវៈ មិនមែនធម៌ផង សភាវៈ មិនមែនប្រយោជន៍ផង ដឹងនូវធម៌ផង នូវប្រយោជន៍ផង ធម៌ យ៉ាងណា ប្រយោជន៍ យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈ មិនមែនធម៌ សភាវៈ មិនមែនប្រយោជន៍ តើដូចម្តេច ។ គឺ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណៈ មិច្ឆាវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សភាវៈមិនមែនធម៌ សភាវៈមិនមែនប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម៌និងប្រយោជន៍ តើដូចម្តេច ។ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សម្មាញាណៈ សម្មាវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ ហៅថា ប្រយោជន៍ ។

អធម្មោ ច ភិក្ខវេ វេទិតព្វោ អនត្ថោ ច ធម្មោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា អនត្ថញ្ច ធម្មញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

(១៤) អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វំ ។ កតមោ ច ភិក្ខវេ អធម្មោ កតមោ ច ធម្មោ កតមោ ច អនត្ថោ កតមោ ច អត្ថោ ។ មិច្ឆាទិដ្ឋិ ភិក្ខវេ អធម្មោ សម្មាទិដ្ឋិ ធម្មោ យេ ច មិច្ឆាទិដ្ឋិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាទិដ្ឋិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យណាថា ភិក្ខុគប្បីដឹង សភាវៈមិនមែនធម៌ផង មិនមែនប្រយោជន៍ផង គប្បីដឹងធម៌ផង ប្រយោជន៍ផង លុះដឹងច្បាស់នូវសភាវៈមិនមែនធម៌ផង មិនមែនប្រយោជន៍ផង ដឹងនូវធម៌ផង ប្រយោជន៍ផង ធម៌ យ៉ាងណា ប្រយោជន៍ យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិយ៉ាងនោះដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

(១៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះៗ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ តើដូចម្តេច ធម៌ តើដូចម្តេច សភាវៈមិនមែនប្រយោជន៍ តើដូចម្តេចប្រយោជន៍ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិជាសភាវៈ មិនមែនធម៌ សម្មាទិដ្ឋិជាធម៌ ពួកអកុសលធម៌លាមកច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកអកុសលធម៌ច្រើនប្រការ មានសម្មាទិដ្ឋិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។

មិច្ឆាសង្កប្បោ ភិក្ខវេ អនត្ថោ សម្មាសង្កប្បោ អត្ថោ
យេ ច មិច្ឆាសង្កប្បប្បច្ចយា អនេកេ បាបកា អកុ-
សលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាសង្កប្ប-
ប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ
គច្ឆន្តិ អយំ អត្ថោ ។ មិច្ឆាវាចា ភិក្ខវេ អនត្ថោ
សម្មាវាចា អត្ថោ យេ ច មិច្ឆាវាចាបច្ចយា អនេកេ
បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ
សម្មាវាចាបច្ចយា ច អនេកេ កុសលា ធម្មា ភាវនា-
បារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ មិច្ឆាកម្មន្តោ ភិក្ខវេ
អនត្ថោ សម្មាកម្មន្តោ អត្ថោ យេ ច មិច្ឆាកម្មន្តប្ប-
ច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ
អយំ អនត្ថោ សម្មាកម្មន្តប្បច្ចយា ច អនេកេ
កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។

ម្នាលភិក្ខុទាំងឡាយ មិច្ឆាសង្កប្បៈ ជាសភាវៈមិនមែនធម៌ សម្មាសង្កប្បៈ ជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាសង្កប្បៈជាបច្ច័យ កើតព្រម នេះជាសភាវៈ មិនមែនប្រយោជន៍ ពួកកុសលធម៌ ច្រើនប្រការ ដែលមានសម្មាសង្កប្បៈ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាចា ជាសភាវៈមិនមែនធម៌ សម្មាវាចា ជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវាចា ជាបច្ច័យ កើតព្រម នេះជាសភាវៈ មិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាវាចា ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាកម្មន្តៈ ជាសភាវៈមិនមែនធម៌ សម្មាកម្មន្តៈ ជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាកម្មន្តៈ ជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាកម្មន្តៈ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។

### តតិយបណ្ណាសក បច្ចោរោហណីវគ្គោ

មិច្ឆាអាជីវោ ភិក្ខវេ អនត្ថោ សម្មាអាជីវោ អត្ថោ យេ ច មិច្ឆាអាជីវបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាអាជីវបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ មិច្ឆាវាយាមោ ភិក្ខវេ អនត្ថោ សម្មាវាយាមោ អត្ថោ យេ ច មិច្ឆាវាយាមបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាវាយាមបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ មិច្ឆាសតិ ភិក្ខវេ អនត្ថោ សម្មាសតិ អត្ថោ យេ ច មិច្ឆាសតិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាសតិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។

ម្នាលភិក្ខុទាំងឡាយ មិច្ឆាអាជីវៈ ជាសភាវៈមិនមែនធម៌ សម្មាអាជីវៈ ជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាអាជីវៈជាបច្ច័យ កើតព្រម នេះជាសភាវៈ មិនមែនជាប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាអាជីវៈ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាយាមៈ ជាសភាវៈមិនមែនធម៌ សម្មាវាយាមៈជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវាយាមៈជាបច្ច័យ កើតព្រម នេះជាសភាវៈ មិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាវាយាមៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាសតិ ជាសភាវៈមិនមែនធម៌ សម្មាសតិ ជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាសតិ ជាបច្ច័យ កើតព្រម នេះជាសភាវៈ មិនមែនជាប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាសតិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា នេះជាប្រយោជន៍ ។

មិច្ឆាសមាធិ ភិក្ខវេ អធម្មោ សម្មាសមាធិ ធម្មោ យេ ច មិច្ឆាសមាធិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាសមាធិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ មិច្ឆាញាណំ ភិក្ខវេ អធម្មោ សម្មាញាណំ ធម្មោ យេ ច មិច្ឆាញាណប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាញាណប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ មិច្ឆាវិមុត្តិ ភិក្ខវេ អធម្មោ សម្មាវិមុត្តិ ធម្មោ យេ ច មិច្ឆាវិមុត្តិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាវិមុត្តិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។

ម្នាលភិក្ខុទាំងឡាយ មិច្ឆាសមាធិ ជាសភាវៈ មិនមែនធម៌ សម្មាសមាធិ ជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាសមាធិ ជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ ច្រើនប្រការ ដែលមានសម្មាសមាធិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆា-ញាណៈ ជាសភាវៈមិនមែនធម៌ សម្មាញាណៈជាធម៌ ពួកអកុ-សលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាញាណៈ ជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាញាណៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាវិមុត្តិ ជាសភាវៈ មិនមែនធម៌ សម្មាវិមុត្តិ ជាធម៌ ពួកអកុសលធម៌ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិ ជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា នេះជាប្រយោជន៍ ។

## តតិយបណ្ណាសកេ បច្ចោរោហណីវគ្គោ

អធម្មោ ច ភិក្ខវេ វេទិតព្ពោ ធម្មោ ច អនត្ថោ ច វេទិតព្ពោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្ពន្តិ ឥតិ យំ តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

[ ១៨ ] អធម្មោ ច ភិក្ខវេ វេទិតព្ពោ ធម្មោ ច អនត្ថោ ច វេទិតព្ពោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្ពន្តិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ តេសំ(១) អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ

---

១ ឱ. ម. តេសំ ភិក្ខូនំ បាឋោ វិស្សុតោ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យណាថា ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

(១៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះហើយ ព្រះសុគត ពោលនូវពាក្យនេះ ហើយក្រោកចាកអាសនៈចូលទៅកាន់វិហារ ។ លុះព្រះមានព្រះភាគ ទ្រង់ចេញទៅមិនយូរប៉ុន្មាន ពួកភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា

ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អយំ ខោ អាយស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ អាយស្មា(១) អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា អានន្ទោ តេនុបសង្កមេយ្យាម

១ ឱ. ម. ចាយស្មា ។

ម្នាលអាវុសោ ព្រះមានព្រះភាគ ទ្រង់សំដែងឧទ្ទេសនេះដោយសេចក្តីបំព្រួញ ទ្រង់មិនទាន់ចែកនូវអត្ថ ដោយពិស្តារ ដល់យើងទាំងឡាយ ហើយស្តេចក្រោកចាកអាសនៈ ចូលទៅកាន់វិហារ (ឧទ្ទេសនោះថា) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង ធម៌ផង គប្បីដឹងនូវសភាវៈ មិនមែនជាប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈ មិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ នរណាហ្ន៎ គប្បីចែកនូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែង ដោយសេចក្តីបំព្រួញ មិនទាន់ចែកអត្ថដោយពិស្តារ ឲ្យពិស្តារទៅបាន ៗ លំដាប់នោះ ពួកភិក្ខុនោះ មានសេចក្តីត្រិះរិះ ដូច្នេះថា មានតែអានន្ទដ៏មានអាយុនេះទេ ដែលព្រះសាស្តា ទ្រង់សរសើរផង ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ អានន្ទដ៏មានអាយុ ទើបអាចនឹងចែកអត្ថ នៃឧទ្ទេសនេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែង ដោយសេចក្តីបំព្រួញ មិនទាន់ចែកអត្ថ ដោយពិស្តារ ឲ្យពិស្តារទៅបាន បើដូច្នោះ គួរយើងនាំគ្នា ចូលទៅរកអានន្ទ ដ៏មានអាយុ

## តតិយបណ្ណាសកេ បច្ចោរោហណិវគ្គោ

ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតមត្ថំ បុច្ឆេយ្យាម យថា នោ អាយស្មា អានន្ទោ ព្យាករិស្សតិ តថា នំ ធារេស្សាមាតិ (១) ។ អថខោ តេ ភិក្ខូ យេនាយស្មា អានន្ទោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ អានន្ទំ ឯតទវោចុំ ឥទំ ខោ នោ អាវុសោ អានន្ទ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ។

---

១ ម. ធារេយ្យាមាតិ ។

លុះចូលទៅដល់ហើយ គប្បីសួរអត្ថនេះ នឹងអានន្ទដ៏មានអាយុ អានន្ទដ៏មានអាយុ នឹងឆ្លើយដល់យើងពលគ្នា យ៉ាងណា យើងនឹងចាំទុកនូវអត្ថនោះ យ៉ាងនោះ ៗ លំដាប់នោះ ពួកភិក្ខុទាំងនោះ នាំគ្នាចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានពោលពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុ ថាម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគ ទ្រង់សំដែងឧទ្ទេសនេះ ដោយសេចក្តីបំប្រួញ មិនទាន់ចែកអត្ថដោយពិស្តារ ដល់យើងទាំងឡាយសោះហើយទ្រង់ក្រោកចាកអាសនៈចូលទៅ កាន់ព្រះវិហារ ( ឧទ្ទេសនោះថា) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុប្រតិបត្តិតាមយ៉ាងនោះ ៗ

តេសំ នោ អាវុសោ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយា-សនា វិហារំ បវិដ្ឋោ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ តេសំ នោ អាវុសោ អម្ហាកំ ឯតទហោសិ អយំ ខោ អាយ-ស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ អាយស្មា អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ

ម្នាលអាវុសោ ព្រះមានព្រះភាគរបស់យើង ទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន យើងទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងឧទ្ទេសនេះ ដោយសេចក្តីបំប្រួញ ទ្រង់មិនចាត់ចែកអត្ថ ដោយពិស្តារ ដល់យើងទាំងឡាយ ហើយក្រោកចាកអាសនៈ ចូលទៅកាន់វិហារ (ឧទ្ទេសនោះថា) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ នរណាហ្ន៎ គប្បីចែកអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសេចក្តីបំប្រួញ មិនចាត់ចែកអត្ថ ដោយពិស្តារ ឲ្យពិស្តារបាន ។ ម្នាលអាវុសោ យើងទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា មានតែអានន្ទដ៏មានអាយុនេះឯង ដែលព្រះសាស្តាសរសើរហើយផង ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ អានន្ទដ៏មានអាយុ ទើបអាចនឹងចែកអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសេចក្តីបំប្រួញ មិនចាត់ចែកអត្ថ ដោយពិស្តារ ឲ្យពិស្តារបាន

យន្នូន មយំ យេនាយស្មា អានន្ទោ តេនុបសង្ក–មិស្សាម ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតមត្ថំ បុច្ឆេយ្យាម (១) យថា នោ អាយស្មា អានន្ទោ ព្យាករិស្សតិ តថា នំ ធារេយ្យាមាតិ (២) វិភជតា-យស្មា អានន្ទោតិ ។ សេយ្យថាបិ អាវុសោ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ មូលំ អតិក្កម្ម ខន្ធំ សាខាបលាសេ សារំ បរិយេ-សិតព្វំ មញ្ញេយ្យ ឯវំ សម្បទមិទំ អាយស្មន្តានំ សត្ថរិ សម្មុខីភូតេ តំ ភគវន្តំ អតិសិត្វា (៣) អម្ហេ ឯតមត្ថំ បដិបុច្ឆិតព្វំ មញ្ញថ (៤) សោ អាវុសោ (៥) ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា

---

១ ម. បដិបុច្ឆេយ្យាម ។ ២ ឱ. ម. ធារេស្សាមាតិ ។ ៣ ម. អតិក្កមិត្វា ។
៤ ឱ. មញ្ញេថ ។ ៥ ឱ. ម. សោហាវុសោ ។

បើដូច្នោះ គួរយើងចូលទៅរកអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសួរអត្ថនេះ នឹងអានន្ទដ៏មានអាយុ អានន្ទដ៏មានអាយុនឹងឆ្លើយ ដល់យើងទាំងឡាយ យ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវអត្ថយ៉ាងនោះ សូមអានន្ទដ៏មានអាយុ ថែក (សេចក្តីនេះឲ្យទាន) ។ ព្រះអានន្ទដ៏មានអាយុ ឆ្លើយថា ម្នាលអាវុសោ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅរកខ្លឹមឈើ កាលបើឈើធំ មានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងគល់ រំលងដើម ហើយសំគាល់ថា គួរស្វែងរកខ្លឹម ត្រង់មែកនិងស្លឹកទៅវិញ មានឧបមាយ៉ាងណាមិញ សេចក្តីឧបមេយ្យក៏យ៉ាងនោះដែរ កាលបើព្រះសាស្តាគង់ ក្នុងទីចំពោះមុខ នៃលោកដ៏មានអាយុទាំងឡាយ លោកទាំងឡាយ រំលងព្រះមានព្រះភាគនោះ ហើយសំគាល់ថា គប្បីសួរសេចក្តីនេះនឹងខ្ញុំវិញ ម្នាលអាវុសោ ព្រោះថា ព្រះមានព្រះភាគនោះតែងទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ព្រះតថាគតនោះមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ ព្រះអង្គជាបុរសប្រសើរ ព្រះអង្គជាអ្នកស្តី ជាអ្នកប្រៀនប្រដៅ

អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ សោ ចេវ បនេតស្ស កាលោ អហោសិ យំ តុម្ហេ ភគវន្តំយេវ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាថ យថា នោ(១) ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាថាតិ ។ អទ្ធាវុសោ អានន្ទ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណ-ភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ សោ ចេវ បនេតស្ស កាលោ អហោសិ យំ មយំ ភគវន្តំយេវ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាម យថា នោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាម អបិចាយស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ

---

១ ឱ. ម. ភោ ។

ជាអ្នកបង្អោននូវប្រយោជន៍ អ្នកឲ្យនូវព្រះនិព្វាន ជាម្ចាស់នៃធម៌ កាលនេះ ជាកាលគួរ ដល់ព្រះតថាគតនុ៎ះហើយ លោកទាំងឡាយ គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយសាកសួរនូវសេចក្តីនៃឧទ្ទេសនេះ (បើ) ព្រះមានព្រះភាគនៃយើងសំដែងយ៉ាងណា អ្នកទាំងឡាយ គប្បីចាំទុកនូវឧទ្ទេសនោះ យ៉ាងនោះចុះ ។ ម្នាលអាវុសោ អានន្ទ ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវហេតុ ដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ដោយពិតណាស់ ព្រះតថាគតនោះមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ ព្រះអង្គជាបុរសប្រសើរ ព្រះអង្គជាអ្នកស្តីថា ជាអ្នកប្រៀនប្រដៅ ជាអ្នកបង្អោនមកនូវប្រយោជន៍ អ្នកឲ្យនូវព្រះនិព្វាន ជាម្ចាស់នៃធម៌ កាលនេះជាកាលគួរ ដល់ព្រះតថាគតនុ៎ះហើយ យើងទាំងឡាយ គប្បីចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយសាកសួរនូវសេចក្តី នៃឧទ្ទេសនុ៎ះ (បើ) ព្រះមានព្រះភាគ ទ្រង់ដោះស្រាយ ដល់យើងទាំងឡាយយ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវឧទ្ទេសនោះ យ៉ាងនោះក៏ពិតមែនហើយ ប៉ុន្តែ អានន្ទដ៏មានអាយុ (នេះ) ព្រះសាស្តាទ្រង់សរសើរផង ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញ ក៏សរសើរដែរ

អាយស្មា អានន្ទោ ឥមស្ស ភគវតោ សង្ខិត្តេន
ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន
អត្ថំ វិភជិតុំ វិភជិតាយស្មា អានន្ទោ អគរុកត្វាតិ(១) ។
តេនហាវុសោ សុណាថ សាធុកំ មនសិករោថ
ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ
អាយស្មតោ អានន្ទស្ស បច្ចស្សោសុំ ។ អាយស្មា
អានន្ទោ ឯតទវោច យំ ខោ នោ អាវុសោ ភគវា
សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា
ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច ភិក្ខវេ
វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច
អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច
យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ
កតមោ ចាវុសោ អធម្មោ កតមោ ច ធម្មោ
កតមោ ច អនត្ថោ កតមោ ច អត្ថោ ។

---

១ ឱ. អគរុករិត្វាតិ ។

អានន្ទដ៏មានអាយុនេះ អាចនឹងបែកអត្ថ នៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សំដែង ដោយសេចក្តីបំប្រួញ មិនទាន់បែកអត្ថ ដោយពិស្តារ ឲ្យពិស្តារទៅបាន សូមអានន្ទដ៏មានអាយុ កុំឲ្យបង្អែបង្អង់ មេត្តាបែកអត្ថនេះឲ្យទាន ។ ម្នាលអាវុសោ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ ខ្ញុំនឹងសំដែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ថេរវាចា របស់ព្រះអានន្ទដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះអានន្ទដ៏មានអាយុ បានពោលពាក្យនេះ ថាម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ របស់យើង ទ្រង់សំដែងនូវឧទ្ទេសណា ដោយសេចក្តីបំប្រួញ ទ្រង់មិនទាន់បែកអត្ថដោយពិស្តារ ស្រាប់តែក្រោកចាកអាសនៈចូលទៅកាន់វិហារ (ឧទ្ទេសនោះថា) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ម្នាលអាវុសោ សភាវៈមិនមែនធម៌ តើដូចម្តេច ធម៌ តើដូចម្តេច សភាវៈមិនមែនប្រយោជន៍ តើដូចម្តេច ប្រយោជន៍ តើដូចម្តេច ។

មិច្ឆាទិដ្ឋិ អាវុសោ អធម្មោ សម្មាទិដ្ឋិ ធម្មោ ។ យេ ច មិច្ឆាទិដ្ឋិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាទិដ្ឋិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ មិច្ឆាសង្កប្បោ អាវុសោ អធម្មោ សម្មាសង្កប្បោ ធម្មោ ... មិច្ឆាវាចា អាវុសោ អធម្មោ សម្មាវាចា ធម្មោ ... មិច្ឆាកម្មន្តោ អាវុសោ អធម្មោ សម្មាកម្មន្តោ ធម្មោ ... មិច្ឆាអាជីវោ អាវុសោ អធម្មោ សម្មាអាជីវោ ធម្មោ ... មិច្ឆាវាយាមោ អាវុសោ អធម្មោ សម្មាវាយាមោ ធម្មោ ... មិច្ឆាសតិ អាវុសោ អធម្មោ សម្មាសតិ ធម្មោ ... មិច្ឆាសមាធិ អាវុសោ អធម្មោ សម្មាសមាធិ ធម្មោ ... មិច្ឆាញាណំ អាវុសោ អធម្មោ សម្មាញាណំ ធម្មោ ... មិច្ឆាវិមុត្តិ អាវុសោ អធម្មោ សម្មាវិមុត្តិ ធម្មោ

ម្នាលអាវុសោ មិច្ឆាទិដ្ឋិ ជាសភាវៈមិនមែនធម៌ សម្មាទិដ្ឋិ ជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិ ជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា នេះជាប្រយោជន៍ ម្នាលអាវុសោ មិច្ឆាសង្កប្បៈ ជាសភាវៈមិនមែនធម៌ សម្មាសង្កប្បៈ ជាធម៌... ម្នាលអាវុសោ មិច្ឆាវាចា ជាសភាវៈ មិនមែនធម៌ សម្មាវាចា ជាធម៌ ... ម្នាលអាវុសោ មិច្ឆាកម្មន្តៈ ជាសភាវៈ មិនមែនធម៌ សម្មាកម្មន្តៈ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាអាជីវៈ ជាសភាវៈ មិនមែនធម៌ សម្មាអាជីវៈ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាវាយាមៈ ជាសភាវៈ មិនមែនធម៌ សម្មាវាយាមៈ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាសតិ ជាសភាវៈ មិនមែនធម៌ សម្មាសតិ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាសមាធិ ជាសភាវៈ មិនមែនធម៌ សម្មាសមាធិ ជាធម៌ .. ម្នាលអាវុសោ មិច្ឆាញាណៈ ជាសភាវៈ មិនមែនធម៌ សម្មាញាណៈ ជាធម៌ ... ម្នាលអាវុសោ មិច្ឆាវិមុត្តិ ជាសភាវៈ មិនមែនធម៌ សម្មាវិមុត្តិ ជាធម៌

## តតិយបណ្ណាសកេ បច្ចោរោហណិវគ្គោ

យេ ច មិច្ឆាវិមុត្តិបច្ចយា អនេកេ បាបកា អកុ-
សលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាវិមុត្តិបច្-
ច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរិំ
គច្ឆន្តិ អយំ អត្ថោ យំ (១) ខោ នោ អាវុសោ
ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ
អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ
ច វេទិតព្វោ ធម្មោ ច អនត្ថោ ច
វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច
វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា
បដិបជ្ជិតព្វន្តិ ឥមស្ស ខោ អហំ អាវុសោ ភគវតា
សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ
អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ អាកង្ខ-
មានា ច បន តុម្ហេ អាយស្មន្តោ ភគវន្តំយេវ ឧប-
សង្កមិត្វា ឯតមត្ថំ បដិបុច្ឆេយ្យាថ យថា នោ (២)
ភគវា ព្យាករេយ្យ (៣) តថា នំ ធារេយ្យាថាតិ ។

---

១ ម. អយំ ។ ២ ឱ. ម. តេ ។ ៣ ឱ. វ្យាករោតិ ។ ម. ព្យាករោតិ ។

ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិ ជាបច្ច័យ កើតព្រម នេះជាសភាវៈមិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា នេះជាប្រយោជន៍ ម្នាលអាវុសោ ព្រះមានព្រះភាគនៃយើង ទ្រង់សំដែងនូវឧទ្ទេសណា ដោយសេចក្តីបំប្រួញ មិនទាន់ចែកអត្ថ ដោយពិស្តារ ស្រាប់តែស្តេចក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ (ឧទ្ទេសនោះថា ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ម្នាលអាវុសោ ខ្ញុំដឹងនូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសេចក្តីបំប្រួញ ទ្រង់មិនទាន់ចែកអត្ថដោយពិស្តារ ឲ្យពិស្តារយ៉ាងនេះ ម្នាលអាវុសោ ប្រសិនបើ អ្នកទាំងឡាយប្រាថ្នា (ទឹងស្ទួរ) គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរនូវសេចក្តីនុ៎ះចុះ ព្រះមានព្រះភាគ ទ្រង់ព្យាករដល់យើងទាំងឡាយយ៉ាងណា ចូរអ្នកទាំងឡាយ ចាំទុកសេចក្តីនោះយ៉ាងនោះចុះ ។

ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យំ ខោ នោ ភន្តេ (១) ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ តេសំ នោ ភន្តេ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា

---

១ ម. អយំ បាឋោ នត្ថិ ។

ពួកភិក្ខុទាំងនោះ ទទួលតបថា ករុណាអាវុសោ ហើយត្រេកអរ រីករាយនឹងភាសិត របស់ព្រះអានន្ទដ៏មានអាយុ ហើយក្រោកចាកអាសនៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ លុះពួកភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះមានព្រះភាគដ៏ចំរើន ព្រះអង្គទ្រង់សំដែងឧទ្ទេសណា ដោយសេចក្តីបំព្រួញ ទ្រង់មិនទាន់ចែកអត្ថ ដោយពិស្តារ ដល់យើងទាំងឡាយ ស្រាប់តែក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ (ឧទ្ទេសនោះថា) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈ មិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈ មិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ បពិត្រព្រះអង្គដ៏ចំរើន កាលព្រះមានព្រះភាគ ទ្រង់បៀសចេញទៅ មិនយូរប៉ុន្មាន ពួកខ្ញុំព្រះអង្គទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះមានព្រះភាគ ទ្រង់សំដែងឧទ្ទេសនេះ ដោយសេចក្តីបំព្រួញ មិនទាន់ចែកអត្ថដោយពិស្តារ ដល់យើងទាំងឡាយ

## តតិយបណ្ណាសកេ បច្ចោរោហណិវគ្គោ

ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ អាយស្មា អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា អានន្ទោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតមត្ថំ បុច្ឆេយ្យាម

ហើយស្រាប់តែក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ (ឧទ្ទេសនោះថា) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈ មិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ នរណាហ្ន៎ គប្បីចែកអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែង ដោយសេចក្តីបំប្រួញ មិនទាន់បានចែកអត្ថដោយពិស្តារ ឲ្យពិស្តារទៅបាន បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា មានតែអានន្ទដ៏មានអាយុនេះឯង ដែលព្រះសាស្តា ទ្រង់សរសើរហើយផង ទាំងពួកសព្រហ្មចារី ជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ អានន្ទដ៏មានអាយុនេះ ទើបអាចដើម្បីចែកអត្ថនៃឧទ្ទេសនេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងដោយសេចក្តីបំប្រួញ មិនទាន់បានចែកអត្ថ ដោយពិស្តារ ឲ្យពិស្តារបាន បើដូច្នោះ គួរតែយើងទាំងឡាយ ចូលទៅរកអានន្ទ ដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសាកសួរសេចក្តីនុ៎ះនឹងអានន្ទ ដ៏មានអាយុ

យថា នោ អាយស្មា អានន្ទោ ព្យាករិស្សតិ តថា នំ ធារេយ្យាមាតិ[១] អថខោ មយំ ភន្តេ យេនាយស្មា អានន្ទោ តេនុបសង្កមិម្ហា ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតមត្ថំ អបុច្ឆិម្ហា តេសំ នោ ភន្តេ អាយស្មតា អានន្ទេន ឥមេហិ អាការេហិ ឥមេហិ បទេហិ ឥមេហិ ព្យញ្ជនេហិ អត្ថោ សុវិភត្តោតិ ។ សាធុ សាធុ ភិក្ខវេ បណ្ឌិតោ ភិក្ខវេ អានន្ទោ មហាបញ្ញោ ភិក្ខវេ អានន្ទោ មំ ចេបិ តុម្ហេ ភិក្ខវេ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាថ អហម្បិចេតំ[២] ឯវមេវ ព្យាករេយ្យំ យថា តំ អានន្ទេន ព្យាកតំ ឯសោ ចេវ តស្ស អត្ថោ ឯវញ្ច នំ ធារេយ្យាថាតិ ។

(១៦) អថខោ អាជីនោ[៣] បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ

---

១ ឱ. ម. ធារេស្សាមាតិ ។ ២ ម. អហំបិចេតំ ។ ៣ ឱ. ម. អជិតោ ។

(បើ) អានន្ទដ៏មានអាយុ ឆ្លើយចំពោះពួកយើងទាំងឡាយ យ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវអត្ថនោះយ៉ាងនោះ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ពួកខ្ញុំព្រះអង្គ ក៏ចូលទៅរកអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ទើបសាកសួរសេចក្តីនុ៎ះនឹងអានន្ទដ៏មានអាយុ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីដែលអានន្ទដ៏មានអាយុចែកហើយ ដោយអាការទាំងនេះ ដោយបទទាំងនេះ ដោយព្យញ្ជនៈទាំងនេះ ដល់ពួកខ្ញុំព្រះអង្គទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រពៃហើយ ៗ ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ អានន្ទជាអ្នកមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ អ្នកទាំងឡាយ ចូលមករកតថាគតហើយ គប្បីសាកសួរសេចក្តីនុ៎ះ តថាគតគប្បីដោះស្រាយសេចក្តីនុ៎ះយ៉ាងនោះ ដូចជាអានន្ទឆ្លើយហើយដែរ នេះជាសេចក្តីនៃឧទ្ទេសនោះ អ្នកទាំងឡាយ គប្បីចាំទុកនូវសេចក្តីនោះយ៉ាងនេះចុះ ។

(១៦) គ្រានោះ អជិតបរិព្វាជក បានចូលទៅគាល់ព្រះមានព្រះភាគ លុះបានចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីសមគួរ

ឯកមន្តំ និសិន្នោ ខោ អជិតោ បរិព្ពាជកោ ភគវន្តំ ឯតទវោច អម្ហាកំ ភោ គោតម បណ្ឌិតោ នាម សព្រហ្មចារី តេន បញ្ចមត្តានិ ចិត្តដ្ឋានសតានិ(១) យេហិ អញ្ញតិត្ថិយា ឧបារទ្ធាវ ជានន្តិ ឧបារទ្ធស្មាតិ(២) អថខោ ភគវា ភិក្ខូ អាមន្តេសិ ធារេថ នោ តុម្ហេ ភិក្ខវេ បណ្ឌិតវត្ថូនីតិ ។ ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា ភាសេយ្យ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ឥធ ភិក្ខវេ ឯកច្ចោ អធម្មិកេន វាទេន អធម្មិកំ វាទំ អភិនិគ្គណ្ហាតិ អភិនិប្បីឡេតិ

---

១ ឱ. ម. ចិត្តានិ ចិន្តិតានីតិ បាឋោ ទិស្សតិ ។ ២ ឱ. ឧបារទ្ធម្ហាតិ ។

លុះអាជិនបរិព្វាជក អង្គុយក្នុងទីសមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន សព្រហ្មចារីរបស់យើងខ្ញុំ ឈ្មោះថាជាបណ្ឌិត (ព្រោះ) ពួកអន្យតិរ្ថិយ ដែលសព្រហ្មចារីនោះ សង្កត់សង្កិនហើយ ដោយបិត្តបញ្ហាចំនួន ៥០០ រមែងដឹងខ្លួនថា ពួកយើង ត្រូវគេសង្កត់សង្កិនហើយ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចាំទុកនូវបណ្ឌិតវត្ថុដែរឬទេ ។ ព្រះមានព្រះភាគ ទ្រង់សំដែងភាសិតណា បពិត្រព្រះមានព្រះភាគ កាលនេះ ជាកាលគួរដលភាសិតនុ៎ះ បពិត្រព្រះសុគត កាលនេះ ជាកាលគួរដល់ភាសិតនុ៎ះ ពួកភិក្ខុលុះបានស្តាប់នូវភាសិត របស់ព្រះមានព្រះភាគហើយនឹងចាំទុកបាន ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ។ ទើបឯព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រមែងសង្កត់សង្កិន ញាំញីនូវវាទៈ ដែលមិនប្រកបដោយធម៌ ដោយវាទៈ ដែលមិនប្រកបដោយធម៌

តេន ច អជ្ឈត្តំ បរិសំ គច្ឆតិ តេន សា អជ្ឈត្តា បរិសា ឧច្ចាសទ្ទា មហាសទ្ទា ហោតិ បណ្ឌិតោ វត ភោ បណ្ឌិតោ វត ភោតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ អជ្ឈត្តេន ភាវេន នត្ថិកំ ភាវំ អភិនិគ្គណ្ហាតិ អភិនិប្បីឡេតិ តេន ច អជ្ឈត្តំ បរិសំ គច្ឆតិ តេន សា អជ្ឈត្តា បរិសា ឧច្ចាសទ្ទា មហាសទ្ទា ហោតិ បណ្ឌិតោ វត ភោ បណ្ឌិតោ វត ភោតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ អជ្ឈត្តេន ភាវេន នត្ថិកញ្ច ភាវំ អត្ថិកញ្ច ភាវំ អភិនិគ្គណ្ហាតិ អភិនិប្បីឡេតិ តេន ច អជ្ឈត្តំ បរិសំ គច្ឆតិ តេន សា អជ្ឈត្តា បរិសា ឧច្ចាសទ្ទា មហាសទ្ទា ហោតិ បណ្ឌិតោ វត ភោ បណ្ឌិតោ វត ភោតិ ។

រមែងដឹកនាំបរិស័ទដែលមិនប្រកបដោយធម៌ ឲ្យត្រេកអរ ដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទដែលមិនប្រកបដោយធម៌នោះ ជាអ្នកមានសំឡេងខ្ពស់សំឡេងខ្លាំងថា ឧហ្ន៎ ជននេះជាបណ្ឌិត ឧហ្ន៎ ជននេះជាបណ្ឌិត ៗ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ រមែងសង្កត់សង្កិន ញាំញីនូវវាទៈ ដែលប្រកបដោយធម៌ ដោយវាទៈ ដែលមិនប្រកបដោយធម៌ រមែងដឹកនាំបរិស័ទ ដែលមិនប្រកបដោយធម៌ ឲ្យត្រេកអរបាន ដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទដែលមិនប្រកបដោយធម៌នោះ ជាអ្នកមានសំឡេងខ្ពស់ សំឡេងខ្លាំងថា ឧហ្ន៎ ជននេះជាបណ្ឌិត ឧហ្ន៎ ជននេះជាបណ្ឌិត ៗ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ រមែងសង្កត់សង្កិន ញាំញីនូវវាទៈ ដែលប្រកបដោយធម៌ផង នូវវាទៈ ដែលមិនប្រកបដោយធម៌ផង ដោយវាទៈ ដែលមិនប្រកបដោយធម៌ រមែងដឹកនាំបរិស័ទ ដែលមិនប្រកបដោយធម៌ ឲ្យត្រេកអរ ដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទ ដែលមិនប្រកបដោយធម៌នោះ ជាអ្នកមានសំឡេងខ្ពស់ សំឡេងខ្លាំងថា ឧហ្ន៎ ជននេះជាបណ្ឌិត ឧហ្ន៎ ជននេះជាបណ្ឌិត ៗ

ឥធ បន ភិក្ខវេ ឯកច្ចោ ធម្មិកេន វាទេន អធម្មិកំ វាទំ អភិនិគ្គណ្ហាតិ អភិនិប្បីឡេតិ តេន ច អធម្មិកំ(១) បរិសំ រញ្ជេតិ តេន សា អធម្មិកា(២) បរិសា ឧច្ចាសទ្ទា មហាសទ្ទា ហោតិ បណ្ឌិតោ វត ភោ បណ្ឌិតោ វត ភោតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ ធម្មិកេន វាទេន ធម្មិកំ វាទំ អភិនិគ្គណ្ហាតិ អភិនិប្បីឡេតិ តេន ច ធម្មិកំ បរិសំ រញ្ជេតិ តេន សា ធម្មិកា បរិសា ឧច្ចាសទ្ទា មហាសទ្ទា ហោតិ បណ្ឌិតោ វត ភោ បណ្ឌិតោ វត ភោតិ ។ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ។

---

១ ឧ. ធម្មិកំ ។ ២ ឧ. ធម្មិកា ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ រមែងសង្កត់សង្កិន ញុំាញីនូវវាទៈ ដែលមិនប្រកបដោយធម៌ ដោយវាទៈ ដែលប្រកបដោយធម៌ រមែងដឹកនាំបរិស័ទ ដែលមិនប្រកបដោយធម៌ ឲ្យត្រេកអរ ដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទដែលមិនប្រកបដោយធម៌នោះ ជាអ្នកមានសំឡេងខ្ពស់ សំឡេងខ្លាំងថា ឱហ្ន៎ ជននេះជាបណ្ឌិត ឱហ្ន៎ ជននេះជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ រមែងសង្កត់សង្កិន ញុំាញីនូវវាទៈ ដែលប្រកបដោយធម៌ ដោយវាទៈ ដែលប្រកបដោយធម៌ រមែងដឹកនាំបរិស័ទ ដែលប្រកបដោយធម៌ ឲ្យត្រេកអរដោយវាទៈនោះផង ព្រោះហេតុនោះ បរិស័ទដែលប្រកបដោយធម៌នោះ ជាអ្នកមានសំឡេងខ្ពស់ សំឡេងខ្លាំងថា ឱហ្ន៎ ជននេះជាបណ្ឌិត ឱហ្ន៎ ជននេះជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះ ។

កតមោ ច ភិក្ខវេ អធម្មោ កតមោ ច ធម្មោ កតមោ ច អនត្ថោ កតមោ ច អត្ថោ ។ មិច្ឆាទិដ្ឋិ ភិក្ខវេ អធម្មោ សម្មាទិដ្ឋិ ធម្មោ យេ ច មិច្ឆាទិដ្ឋិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាទិដ្ឋិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ មិច្ឆាសង្កប្បោ ភិក្ខវេ អធម្មោ សម្មាសង្កប្បោ ធម្មោ . . .

មិច្ឆាវាចា ភិក្ខវេ អធម្មោ សម្មាវាចា ធម្មោ . . .

មិច្ឆាកម្មន្តោ ភិក្ខវេ អធម្មោ សម្មាកម្មន្តោ ធម្មោ . . .

មិច្ឆាអាជីវោ ភិក្ខវេ អធម្មោ សម្មាអាជីវោ ធម្មោ . . .

មិច្ឆាវាយាមោ ភិក្ខវេ អធម្មោ សម្មាវាយាមោ ធម្មោ . . .

មិច្ឆាសតិ ភិក្ខវេ អធម្មោ សម្មាសតិ ធម្មោ . . .

មិច្ឆាសមាធិ ភិក្ខវេ អធម្មោ សម្មាសមាធិ ធម្មោ . . .

មិច្ឆាញាណំ ភិក្ខវេ អធម្មោ សម្មាញាណំ ធម្មោ . . .

ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ តើដូចម្ដេច ធម៌ តើដូចម្ដេច សភាវៈមិនមែនប្រយោជន៍ តើដូចម្ដេច ប្រយោជន៍ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិ ជាសភាវៈមិនមែនធម៌ សម្មាទិដ្ឋិ ជាធម៌ អកុសលធម៌ដ៏លាមកទាំងឡាយ ច្រើនប្រការណា ដែលមានមិច្ឆាទិដ្ឋិ ជាបច្ច័យ កើតព្រម នេះជាសភាវៈ មិនមែនប្រយោជន៍ ពួកកុសលធម៌ច្រើនប្រការ ដែលមានសម្មាទិដ្ឋិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាសង្កប្បៈ ជាសភាវៈមិនមែនធម៌ សម្មាសង្កប្បៈ ជាធម៌... ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាចា ជាសភាវៈមិនមែនធម៌ សម្មាវាចា ជាធម៌... ម្នាលភិក្ខុទាំងឡាយ មិច្ឆាកម្មន្តៈ ជាសភាវៈមិនមែនធម៌ សម្មាកម្មន្តៈ ជាធម៌ .. ម្នាលភិក្ខុទាំងឡាយ មិច្ឆាអាជីវៈ ជាសភាវៈមិនមែនធម៌ សម្មាអាជីវៈ ជាធម៌... ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាយាមៈ ជាសភាវៈមិនមែនធម៌ សម្មាវាយាមៈជាធម៌... ម្នាលភិក្ខុទាំងឡាយ មិច្ឆាសតិ ជាសភាវៈមិនមែនធម៌ សម្មាសតិ ជាធម៌... ម្នាលភិក្ខុទាំងឡាយ មិច្ឆាសមាធិ ជាសភាវៈមិនមែនធម៌ សម្មាសមាធិ ជាធម៌... ម្នាលភិក្ខុទាំងឡាយ មិច្ឆាញាណៈ ជាសភាវៈមិនមែនធម៌ សម្មាញាណៈ ជាធម៌...

មិច្ឆាវិមុត្តិ ភិក្ខវេ អធម្មោ សម្មាវិមុត្តិ ធម្មោ យេ ច មិច្ឆាវិមុត្តិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាវិមុត្តិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ឥតិ យំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

(១៧) អថខោ សគារវោ(១) ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ឯកមន្តំ និសិន្នោ ខោ សគារវោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កឹ នុ ខោ ភោ គោតម ឱរិមំ តីរំ កឹ បារិមំ តីរន្តិ ។

១ ឱ. ម. សង្គារវោ ។

ម្នាលភិក្ខុទាំងឡាយ មិច្ឆាវិមុត្តិ ជាសភាវៈមិនមែនធម៌ សម្មាវិមុត្តិ ជាធម៌ ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការណា ដែលមានមិច្ឆាវិមុត្តិ ជាបច្ច័យ កើតព្រម នេះជាសភាវៈ មិនមែនប្រយោជន៍ ពួកកុសលធម៌ ច្រើនប្រការ ដែលមានសម្មាវិមុត្តិ ជាបច្ច័យ រមែងដល់នូវការបរិបូណ៌ ដោយភាវនា នេះជាប្រយោជន៍ ៗ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ គប្បីដឹងសភាវៈមិនមែនធម៌ផង ធម៌ផង គប្បីដឹងសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង លុះដឹងនូវសភាវៈមិនមែនធម៌ផង ធម៌ផង ដឹងនូវសភាវៈមិនមែនប្រយោជន៍ផង ប្រយោជន៍ផង ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិតាមយ៉ាងនោះដូច្នេះ ដែលតថាគត បានពោលហើយ ក៏ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ៗ

(១៧) គ្រានោះ សគារវព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយ នឹងពាក្យគួររឭក ហើយ ក៏អង្គុយក្នុងទីសមគួរ លុះសគារវព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន អ្វីជាត្រើយខាងអាយ អ្វីជាត្រើយខាងនាយ ៗ

មិច្ឆាទិដ្ឋិ ខោ ព្រាហ្មណ ឱរិមំ តីរំ សម្មាទិដ្ឋិ បារិមំ តីរំ មិច្ឆាសង្កប្បោ ឱរិមំ តីរំ សម្មាសង្កប្បោ បារិមំ តីរំ មិច្ឆាវាចា ឱរិមំ តីរំ សម្មាវាចា បារិមំ តីរំ មិច្ឆាកម្មន្តោ ឱរិមំ តីរំ សម្មាកម្មន្តោ បារិមំ តីរំ មិច្ឆាអាជីវោ ឱរិមំ តីរំ សម្មាអាជីវោ បារិមំ តីរំ មិច្ឆាវាយាមោ ឱរិមំ តីរំ សម្មាវាយាមោ បារិមំ តីរំ មិច្ឆាសតិ ឱរិមំ តីរំ សម្មាសតិ បារិមំ តីរំ មិច្ឆាសមាធិ ឱរិមំ តីរំ សម្មាសមាធិ បារិមំ តីរំ មិច្ឆាញាណំ ឱរិមំ តីរំ សម្មាញាណំ បារិមំ តីរំ មិច្ឆាវិមុត្តិ ឱរិមំ តីរំ សម្មាវិមុត្តិ បារិមំ តីរំ (១) ។ ឥទំ ខោ ព្រាហ្មណ ឱរិមំ តីរំ ឥទំ បារិមំ តីរន្តិ ។

អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា តីរមេវានុធាវតិ ។

---

១ ម. តីរន្តិ ។

ម្នាលព្រាហ្មណ៍ មិច្ឆាទិដ្ឋិ ជាត្រើយខាងអាយ សម្មាទិដ្ឋិ ជាត្រើយខាងនាយ មិច្ឆាសង្កប្បៈ ជាត្រើយខាងអាយ សម្មាសង្កប្បៈ ជាត្រើយខាងនាយ មិច្ឆាវាចា ជាត្រើយខាងអាយ សម្មាវាចា ជាត្រើយខាងនាយ មិច្ឆាកម្មន្តៈ ជាត្រើយខាងអាយ សម្មាកម្មន្តៈ ជាត្រើយខាងនាយ មិច្ឆាអាជីវៈ ជាត្រើយខាងអាយ សម្មាអាជីវៈ ជាត្រើយខាងនាយ មិច្ឆាវាយាមៈ ជាត្រើយខាងអាយ សម្មាវាយាមៈ ជាត្រើយខាងនាយ មិច្ឆាសតិ ជាត្រើយខាងអាយ សម្មាសតិ ជាត្រើយខាងនាយ មិច្ឆាសមាធិ ជាត្រើយខាងអាយ សម្មាសមាធិ ជាត្រើយខាងនាយ មិច្ឆាញាណៈ ជាត្រើយខាងអាយ សម្មាញាណៈ ជាត្រើយខាងនាយ មិច្ឆាវិមុត្តិ ជាត្រើយខាងអាយ សម្មាវិមុត្តិ ជាត្រើយខាងនាយ ។ ម្នាលព្រាហ្មណ៍ នេះជាត្រើយខាងអាយ នេះជាត្រើយខាងនាយ ។

បណ្តាមនុស្សទាំងឡាយ ពួកជនណាបានដល់នូវត្រើយខាង
នាយ (ព្រះនិព្វាន) ពួកជននោះមានប្រមាណតិច ឯសត្វក្រៅ
ពីនេះរមែងស្ទុះទៅកាន់ត្រើយគឺសក្កាយទិដ្ឋិ (នេះច្រើនជាង) ។

## តតិយបណ្ណាសកេ បច្ចោរោហណិវគ្គោ

យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។
កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ
តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។
យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ
អាទានបដិនិស្សគ្គេ អនុបាទាយ យេ រតា
ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតាតិ ។

ពួកជនណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលតថាគតសំដែង ហើយដោយប្រពៃ ពួកជននោះ ( បានឆ្លង ) នូវវដ្តៈជាទីទៅនៃមច្ចុ ដែលសត្វកម្រឆ្លងបាន ដោយក្រៃក្រពេក ហើយនឹងដល់ នូវត្រើយខាងនាយ គឺព្រះនិព្វាន ។ បណ្ឌិតត្រូវលះបង់នូវធម៌ខ្មៅ ហើយចំរើននូវធម៌ស ហើយចេញចាកអាល័យ អាស្រ័យនូវព្រះនិព្វាន ដែលមិនមានអាល័យ ការត្រេកអរបានដោយកម្រ ក្នុងវិវេកណា បណ្ឌិតអ្នកមិនមានសេចក្តីកង្វល់ គប្បីលះបង់នូវកាមទាំងឡាយ ហើយប្រាថ្នានូវសេចក្តីត្រេកអរ ក្នុងវិវេកនោះ បណ្ឌិតគប្បីធ្វើខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មងនៃចិត្តទាំងឡាយ ។ ចិត្តដែលពួកជន ចំរើនល្អប្រពៃហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ពួកជនណា ត្រេកអរក្នុងការលះបង់ នូវសេចក្តីប្រកាន់ ព្រោះមិនប្រកាន់ ពួកជនទាំងនោះ ឈ្មោះថាជាខីណាស្រព ជាអ្នកមានសេចក្តីរុងរឿង បរិនិព្វានហើយ ក្នុងលោកនេះ ។

(១៨) ឱរិមញ្ច ហិ ភិក្ខវេ តីរំ ទេសិស្សាមិ បារិមញ្ច តីរំ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមញ្ច ភិក្ខវេ ឱរិមំ តីរំ កតមញ្ច បារិមំ តីរំ ។ មិច្ឆាទិដ្ឋិ ភិក្ខវេ ឱរិមំ តីរំ សម្មាទិដ្ឋិ បារិមំ តីរំ ។ បេ ។ មិច្ឆាវិមុត្តិ ឱរិមំ តីរំ សម្មាវិមុត្តិ បារិមំ តីរំ ។ ឥទំ ខោ ភិក្ខវេ ឱរិមំ តីរំ ឥទំ បារិមំ តីរន្តិ ។

អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា តីរមេវានុធាវតិ ។

( ១៨ ) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវត្រើយខាងអាយផង នូវត្រើយខាងនាយផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្វីជាត្រើយខាងអាយ អ្វីជាត្រើយខាងនាយ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិ ជាត្រើយខាងអាយ សម្មាទិដ្ឋិ ជាត្រើយខាងនាយ ។ បេ ។ មិច្ឆាវិមុត្តិ ជាត្រើយខាងអាយ សម្មាវិមុត្តិ ជាត្រើយខាងនាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ត្រើយខាងអាយ នេះហៅថា ត្រើយខាងនាយ ។

បណ្តាមនុស្សទាំងឡាយ ពួកជនណា បានដល់នូវ
ត្រើយខាងនាយ ( ព្រះនិព្វាន ) ពួកជននោះ មាន
ប្រមាណតិច ឯពួកសត្វក្រៅពីនេះ រមែងស្ទុះ
ទៅកាន់ត្រើយគឺសក្កាយទិដ្ឋិ ( នេះប្រើនជាង ) ។

តតិយបណ្ណាសកេ បច្ចោរោហណិវគ្គោ

យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ៗ
កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ
តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ៗ
យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ
អាទានបដិនិស្សគ្គេ អនុបាទាយ យេ រតា
ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតា ៗ

ពួកជនណា ប្រព្រឹត្តតាមធម៌ ក្នុងធម៌ ដែលតថាគតសំដែង ហើយដោយប្រពៃ ពួកជននោះ បានឆ្លងនូវវដ្ដៈជាទីនៅនៃមច្ចុ ដែលសត្វឆ្លងបាន ដោយក្រៃក្រពេក ហើយនឹងបានដល់នូវត្រើយខាងនាយ គឺព្រះនិព្វាន ។ បណ្ឌិតត្រូវលះបង់នូវធម៌ខ្មៅ ហើយចំរើននូវធម៌ស ហើយចេញចាកអា-ល័យ អាស្រ័យនូវព្រះនិព្វា ដែលមិនមានអាល័យ ការត្រេកអរបានដោយកម្រ ក្នុងវិវេកណា បណ្ឌិតអ្នកមិនមានសេចក្ដីកង្វល់ គប្បីលះបង់នូវកាមទាំងឡាយ ហើយប្រាថ្នានូវសេចក្ដីត្រេកអរ ក្នុងវិវេកនោះ បណ្ឌិតគប្បីធ្វើខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មង នៃចិត្តទាំងឡាយ ។ ចិត្តដែលពួកជនណា ចំរើនល្អប្រពៃហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ពួកជនណា ត្រេកអរ ក្នុងការលះបង់នូវសេចក្ដីប្រកាន់ ព្រោះមិនប្រកាន់ ពួកជនទាំងនោះឈ្មោះថាជាខីណាស្រព ជាអ្នកមានសេចក្ដីរុងរឿង បរិនិព្វានហើយ ក្នុងលោក ។

[១៩] តេន ខោ បន សមយេន ជាណុស្សោណិ ព្រាហ្មណោ តទហុបោសថេ សីសន្ហាតោ(១) នវំ ខោមយុគំ និវត្ថោ អល្លកុសមុដ្ឋិំ(២) អាទាយ ភគវតោ អវិទូរេ ឯកមន្តំ ឋិតោ ហោតិ ។ អទ្ទសា ខោ ភគវា ជាណុស្សោណិំ ព្រាហ្មណំ តទហុបោសថេ សីសន្ហាតំ នវំ ខោមយុគំ និវត្ថំ អល្លកុសមុដ្ឋិំ អាទាយ អវិទូរេ ឯកមន្តំ ឋិតំ ទិស្វាន ជាណុស្សោណិំ ព្រាហ្មណំ ឯតទវោច កឹ នុ(៣) ត្វំ ព្រាហ្មណ តទហុបោសថេ សីសន្ហាតោ នវំ ខោមយុគំ និវត្ថោ អល្លកុសមុដ្ឋិំ អាទាយ ឯកមន្តំ ឋិតោ កឹ នុ អជ្ជ(៤) ព្រាហ្មណកុលស្សាតិ(៥) ។ បច្ចោរោហណី ភោ គោតម អជ្ជ ព្រាហ្មណកុលស្សាតិ ។ យថាកថំ បន ព្រាហ្មណ ព្រាហ្មណានំ បច្ចោរោហណី ហោតីតិ ។

---

១ ឱ ម. សីសំ ន្ហាតោ ។ ២ ឱ. អល្លំ កុសមុដ្ឋិំ ។ ៣ ឱ. កឹ នុ ខោ ។ ៤ ឱ. កឹ នុ ខោ អជ្ជ ។ ម. កឹ នុ ខ្វជ្ជ ។ ៥ ម. ព្រាហ្មណព្រហ្មកុលស្សាតិ ។

(១៩) សម័យនោះឯង ជាណុស្សោណិព្រាហ្មណ៍ កក់ដំរះក្បាល ក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់យកស្បូវស្រស់ ១ ក្ដាប់ ហើយឋិតនៅក្នុងទីសមគួរ ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ទតឃើញជាណុស្សោណិព្រាហ្មណ៍ កំពុងកក់ដំរះក្បាល ក្នុងថ្ងៃឧបោសថនោះ ស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់យកស្បូវស្រស់ ១ ក្ដាប់ ឋិតនៅក្នុងទីសមគួរ ក្នុងទីជិតនៃ (ព្រះអង្គ) លុះទ្រង់ទតឃើញហើយ ទើបទ្រង់ត្រាស់នឹងជាណុស្សោណិព្រាហ្មណ៍ដូច្នេះថា ម្នាលព្រាហ្មណ៍ ចុះហេតុដូចម្ដេច បានជាអ្នកកក់ដំរះក្បាល ក្នុងថ្ងៃឧបោសថនោះ ស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់យកនូវស្បូវស្រស់ ១ ក្ដាប់ ហើយឋិតនៅ ក្នុងទីសមគួរ ក្នុងថ្ងៃនេះ មានហេតុដូចម្ដេច ដល់ត្រកូលរបស់ព្រាហ្មណ៍ ។ បពិត្រព្រះគោតមដ៏ចំរើន ការដំរះបាប (នឹងមាន) ដល់ត្រកូលរបស់ព្រាហ្មណ៍ក្នុងថ្ងៃនេះ ។ ម្នាលព្រាហ្មណ៍ ការដំរះបាប របស់ពួកព្រាហ្មណ៍ តើដូចម្ដេច ។

ឥធ ភោ គោតម ព្រាហ្មណា តទហុបោសថេ សីសំ-ន្ហាតា នវំ ខោមយុគំ និវត្ថា អល្លេន គោមយេន បឋវឹ ឱបុញ្ជិត្វា ហរិតេហិ កុសេហិ បត្ថរិត្វា (១) អន្តរា ច វេលំ អន្តរា ច អគ្យាគារំ សេយ្យំ កប្បេន្តិ តេ តំ រត្តឹ តិក្ខត្តុំ បច្ចុដ្ឋាយ បញ្ជលិកា អគ្គឹ នមស្សន្តិ បច្ចោរោហាម ភវន្តំ បច្ចោរោហាម ភវន្តន្តិ ពហុកេន(២) ច សប្បិតេលេន នវនីតេន អគ្គឹ សន្តប្បេន្តិ តស្សា ច រត្តិយា អច្ចយេន បណីតេន ខាទនីយេន ភោជនីយេន ព្រាហ្មណេ សន្តប្បេន្តិ ឯវំ ខោ ភោ គោតម ព្រាហ្មណានំ បច្ចោរោហណី ហោតីតិ ។ អញ្ញថា ខោ ព្រាហ្មណ ព្រាហ្មណានំ បច្ចោរោហណី(៣) អញ្ញថា ច បន អរិយស្ស វិនយេ បច្ចោរោហណី ហោតីតិ ។ យថាកថំ បន ភោ គោតម អរិយស្ស វិនយេ បច្ចោរោហណី ហោតិ

---

១ ម. បរិត្ថរេត្វា ។ ២ ម. ពហុកេន ច ។ ៣ ម. ឯត្តាវតា ហោតីតិ បាឋោ ទិស្សតិ ។

បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ក្នុងលោកនេះ តែងកក់ដំរះក្បាល ក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មីនេះ លាបនូវផែនដីដោយអាចម៍គោស្រស់ ក្រាលដោយស្បូវទាំងឡាយដ៏ខៀវ ហើយសម្រេចនូវទីដេក ក្នុងចន្លោះផ្ទុកខ្ពុកប់ និងចន្លោះរោងភ្លើង ពួកព្រាហ្មណ៍ទាំងនោះ តែងក្រោកឡើងធ្វើអញ្ជលី សំពះភ្លើង ៣ ដងក្នុងរាត្រីនោះថា យើងខ្ញុំដំរះបាប នឹងលោកដ៏ចំរើន យើងខ្ញុំដំរះបាបនឹងលោកដ៏ចំរើន តែងញ៉ាំងភ្លើងឲ្យឆ្អែត ដោយទឹកដោះពរ ប្រេង ទឹកដោះខាប់ដ៏ល្មមគ្រាន់ លុះកន្លងរាត្រីនោះទៅ ក៏នាំគ្នាញ៉ាំងពួកព្រាហ្មណ៍ឲ្យឆ្អែត ដោយខាទនីយភោជនីយាហារ ដ៏ថ្លៃថ្លាទៀត បពិត្រព្រះគោតមដ៏ចំរើន ការដំរះបាប របស់ពួកព្រាហ្មណ៍ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ ការដំរះបាប របស់ពួកព្រាហ្មណ៍ ដោយឡែក ចំណែកឯការដំរះបាប ក្នុងវិន័យរបស់អរិយៈដោយឡែក ។ បពិត្រព្រះគោតមដ៏ចំរើន ការដំរះបាប ក្នុងវិន័យរបស់អរិយៈ តើដូចម្ដេច

សាធុ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុ យថា អរិយស្ស វិនយេ បច្ចោរោហណី ហោតីតិ ។ តេនហិ ព្រាហ្មណ សុណាហិ សាធុកំ មនសិ- ករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ ជាណុស្សោណិ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច ឥធ ព្រាហ្មណ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ មិច្ឆាទិដ្ឋិយា ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ មិច្ឆាទិដ្ឋិ បជហតិ មិច្ឆាទិដ្ឋិយា បច្ចោរោហតិ មិច្ឆាសង្កប្បស្ស[២] ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិ- សង្ខាយ មិច្ឆាសង្កប្បំ បជហតិ មិច្ឆាសង្កប្បា បច្ចោ- រោហតិ មិច្ឆាវាចាយ ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិ- សង្ខាយ មិច្ឆាវាចំ បជហតិ មិច្ឆាវាចាយ បច្ចោរោហតិ

២ ម. មិច្ឆាសង្កប្បោ ។

ការជំរះបាប ក្នុងវិន័យ របស់អរិយៈយ៉ាងណា សូមអារាធនាព្រះគោតមដ៏ចំរើន សំដែងធម៌យ៉ាងនោះដល់ខ្ញុំព្រះអង្គ ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ជាណុស្សោណិព្រាហ្មណ៍ ក៏ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ អរិយសាវក ក្នុងសាសនានេះ តែងពិចារណាដូច្នេះថា ផលដ៏លាមករបស់មិច្ឆាទិដ្ឋិ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាទិដ្ឋិចេញ ឈ្មោះថា ជំរះមិច្ឆាទិដ្ឋិ ផលដ៏លាមករបស់មិច្ឆាសង្កប្បៈ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាសង្កប្បៈចេញ ឈ្មោះថា ជំរះមិច្ឆាសង្កប្បៈ ផលដ៏លាមករបស់មិច្ឆាវាចា (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាវាចាចេញ

តតិយបណ្ណាសកេ បច្ចោរោហណិវគ្គោ

មិច្ឆាកម្មន្តស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ
ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ
មិច្ឆាកម្មន្តំ បជហតិ មិច្ឆាកម្មន្តា បច្ចោរោហតិ
មិច្ឆាអាជីវស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ
ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ
មិច្ឆាអាជីវំ បជហតិ មិច្ឆាអាជីវា បច្ចោរោហតិ
មិច្ឆាវាយាមស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ
ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ
មិច្ឆាវាយាមំ បជហតិ មិច្ឆាវាយាមា បច្ចោរោហតិ
មិច្ឆាសតិយា ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ
ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ
មិច្ឆាសតឹ បជហតិ មិច្ឆាសតិយា បច្ចោរោហតិ
មិច្ឆាសមាធិស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ
ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ
មិច្ឆាសមាធឹ បជហតិ មិច្ឆាសមាធិម្ហា បច្ចោរោហតិ

ផលដ៏លាមករបស់មិច្ឆាកម្មន្តៈ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាកម្មន្តៈចេញ ឈ្មោះថា ជំរះមិច្ឆាកម្មន្តៈ ផលដ៏លាមករបស់មិច្ឆាអាជីវៈ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាអាជីវៈចេញ ឈ្មោះថា ជំរះមិច្ឆាអាជីវៈ ផលដ៏លាមករបស់មិច្ឆាវាយាមៈ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាវាយាមៈចេញ ឈ្មោះថា ជំរះមិច្ឆាវាយាមៈ ផលដ៏លាមករបស់មិច្ឆាសតិ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាសតិចេញ ឈ្មោះថា ជំរះមិច្ឆាសតិ ផលដ៏លាមក របស់មិច្ឆាសមាធិ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណាដូច្នេះហើយ ក៏លះបង់មិច្ឆាសមាធិចេញ ឈ្មោះថា ជំរះមិច្ឆាសមាធិ

មិច្ឆាញាណស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ ។ សោ ឥតិ បដិសង្ខាយ មិច្ឆាញាណំ បជហតិ មិច្ឆាញាណា (១) បច្ចោ-រោហតិ មិច្ឆាវិមុត្តិយា ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ ។ សោ ឥតិ បដិសង្ខាយ មិច្ឆាវិមុត្តឹ បជហតិ មិច្ឆាវិមុត្តិយា បច្ចោ-រោហតិ ឥទំ ខោ ព្រាហ្មណ អរិយស្ស វិនយេ បច្ចោរោហណី ហោតីតិ ។ អញ្ញថា ភោ គោតម ព្រាហ្មណានំ បច្ចោរោហណី អញ្ញថា ច បន អរិយស្ស វិនយេ បច្ចោរោហណី ហោតិ ។ ឥមិស្សា ច ភោ គោតម អរិយស្ស វិនយេ បច្ចោរោហណិយា ព្រាហ្មណានំ បច្ចោរោហណី កលំ ន អគ្ឃតិ(២) សោឡសឹ ។ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណគតន្តិ ។

---

១. ម. មិច្ឆាញាណម្ហា ។ ២ ឱ. ម. នាគ្ឃតិ ។

ផលដ៏លាមករបស់មិច្ឆាញាណៈ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាញាណៈចេញ ឈ្មោះថា ដំរះមិច្ឆាញាណៈ ផលដ៏លាមករបស់មិច្ឆាវិមុត្តិ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាវិមុត្តិចេញ ឈ្មោះថា ដំរះមិច្ឆាវិមុត្តិ ម្នាលព្រាហ្មណ៍ ការដំរះបាប ក្នុងវិន័យរបស់អរិយៈយ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចំរើន ការដំរះបាប របស់ពួកព្រាហ្មណ៍ដោយឡែក ចំណែកការដំរះបាប ក្នុងវិន័យរបស់អរិយៈដោយឡែក ។ បពិត្រព្រះគោតមដ៏ចំរើន ការដំរះបាប របស់ពួកព្រាហ្មណ៍ មិនដល់នូវចំណែក ដែលចែកជា ១៦ អស់ ១៦ ដង នៃការដំរះបាប ក្នុងវិន័យរបស់អរិយៈនេះឡើយ ។ បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើន ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសកអ្នកដល់ នូវសរណគមន៍ ស្មើដោយជីវិត តាំងពីថ្ងៃនេះទៅ ។

(២០) អរិយំ វោ ភិក្ខវេ បច្ចោរោហណឹ ទេសិស្សាមិ តំ សុណាថ... កតមា ច ភិក្ខវេ អរិយា បច្ចោរោហណី ។ ឥធ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ មិច្ឆាទិដ្ឋិយា ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ មិច្ឆាទិដ្ឋឹ បជហតិ មិច្ឆាទិដ្ឋិយា បច្ចោរោហតិ មិច្ឆាសង្កប្បស្ស ខោ... មិច្ឆាវាចាយ ខោ... មិច្ឆាកម្មន្តស្ស ខោ... មិច្ឆាអាជីវស្ស ខោ... មិច្ឆាវាយាមស្ស ខោ... មិច្ឆាសតិយា ខោ... មិច្ឆាសមាធិស្ស ខោ... មិច្ឆាញាណស្ស ខោ... មិច្ឆាវិមុត្តិយា ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ មិច្ឆាវិមុត្តឹ បជហតិ មិច្ឆាវិមុត្តិយា បច្ចោរោហតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយា បច្ចោរោហណីតិ ។

(២០) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវការដំរះបាប ដ៏ប្រសើរដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរប្រុងតាំស្តាប់ ពាក្យនោះចុះ ...ម្នាលភិក្ខុទាំងឡាយ ការដំរះបាបដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ តែងពិចារណា ដូច្នេះថា ផលដ៏លាមករបស់មិច្ឆាទិដ្ឋិ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាទិដ្ឋិចេញ ឈ្មោះថា ដំរះមិច្ឆាទិដ្ឋិ ផលដ៏លាមករបស់មិច្ឆាសង្កប្បៈ ... របស់មិច្ឆាវាចា ... របស់មិច្ឆាកម្មន្តៈ ... របស់មិច្ឆាអាជីវៈ ... របស់មិច្ឆាវាយាមៈ .. របស់មិច្ឆាសតិ ... របស់មិច្ឆាសមាធិ ... របស់មិច្ឆាញាណៈ ... ផលដ៏លាមក របស់មិច្ឆាវិមុត្តិ (តែងមាន) ក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង លុះអរិយសាវកនោះ ពិចារណា ដូច្នេះហើយ ក៏លះបង់មិច្ឆាវិមុត្តិចេញ ឈ្មោះថា ដំរះមិច្ឆាវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា ការដំរះបាបដ៏ប្រសើរ ។

(៧១) សុរិយស្ស ភិក្ខវេ ឧទយតោ ឯតំ បុព្វ-ង្គមំ ឯតំ បុព្វនិមិត្តំ យទិទំ អរុណុគ្គំ(១) ឯវមេវ ខោ ភិក្ខវេ កុសលានំ ធម្មានំ ឯតំ បុព្វង្គមំ ឯតំ បុព្វនិមិត្តំ យទិទំ សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ សម្មាសង្កប្បោ បហោតិ សម្មាសង្ក-ប្បស្ស សម្មាវាចា បហោតិ សម្មាវាចស្ស សម្មា-កម្មន្តោ បហោតិ សម្មាកម្មន្តស្ស សម្មាអាជីវោ បហោតិ សម្មាអាជីវស្ស សម្មាវាយាមោ បហោតិ សម្មាវាយាមស្ស សម្មាសតិ បហោតិ សម្មាសតិស្ស សម្មាសមាធិ បហោតិ សម្មាសមាធិស្ស សម្មាញា-ណំ បហោតិ សម្មាញាណិស្ស សម្មាវិមុត្តិ បហោតិ(២) ។

---

១ ខ. អរុណគ្គំ ។ ម. អរុណុគ្គំ ។ ២ ម. ហោតីតិ ។

[២១] ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណ នេះជាប្រធាន នេះជាបុព្វនិមិត្ត នៃព្រះអាទិត្យកាលរះឡើង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិនេះជាប្រធាន នេះជាបុព្វនិមិត្ត នៃពួកកុសលធម៌ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយសម្មាទិដ្ឋិ រមែងមានសម្មាសង្កប្បៈ បុគ្គលប្រកបដោយសម្មាសង្កប្បៈ រមែងមានសម្មាវាចា បុគ្គលប្រកបដោយសម្មាវាចា រមែងមានសម្មាកម្មន្តៈ បុគ្គលប្រកបដោយសម្មាកម្មន្តៈ រមែងមានសម្មាអាជីវៈ បុគ្គលប្រកបដោយសម្មាអាជីវៈ រមែងមានសម្មាវាយាមៈ បុគ្គលប្រកបដោយសម្មាវាយាមៈ រមែងមានសម្មាសតិ បុគ្គលប្រកបដោយសម្មាសតិ រមែងមានសម្មាសមាធិ បុគ្គលប្រកបដោយសម្មាសមាធិ រមែងមានសម្មាញាណៈ បុគ្គលប្រកបដោយសម្មាញាណៈ រមែងមានសម្មាវិមុត្តិ ។

[២២] ទសយិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តន្តិ ។ កតមេ ទស ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ សម្មាញាណំ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តន្តីតិ ។

ទុតិយោ បច្ចោរោហណិវគ្គោ ។

## តស្សុទ្ទានំ

អយោ អធម្មា អជិតោ សគារវោ ច ឱរិមំ
ទ្វេ ចេវ បច្ចោរោហនិ បុព្វង្គមំ អាសវោ ទសាតិ(១) ។

---

១ ឥទំ ឧទ្ទានំ អម្ហាកំ បោត្ថកេ នត្ថិ មរម្ម-ឧរោបិយពោត្ថកេយេវ លិខិតន្តិ ។

(៦៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ ប្រការនេះ ដែលភិក្ខុចំរើនហើយ តែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។ ធម៌ ១០ ប្រការ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ សម្មាញាណៈ ១ សម្មាវិមុត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ ប្រការនេះឯង ដែលភិក្ខុចំរើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

ចប់ បច្ចោរោហណិវគ្គទី ២ ។

## ឧទ្ទាននៃបច្ចោរោហណិវគ្គនោះគឺ

និយាយ អំពីសេចក្តីចំរើន ១ សភាព
មិនមែនធម៌ ១ អជិតបរិព្វាជក ១ សគារវ
ព្រាហ្មណ៍ ១ ធម៌ជាត្រើយខាងអាយ
ពីរលើក ការជំរះបាប ១ ប្រធាន
នៃសម្មាទិដ្ឋិ ប្រៀបដោយព្រះអាទិត្យ ១
ធម៌ធ្វើឲ្យអស់ទៅនៃអាសវៈ ១ ។

# តតិយោ បារិសុទ្ធិវគ្គោ

(២៣) ទសយិមេ ភិក្ខវេ ធម្មា បរិសុទ្ធា បរិយោទាតា ន អញ្ញត្រ(១) សុគតវិនយា ។ កតមេ ទស ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ សម្មាញាណំ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា បរិសុទ្ធា បរិយោទាតា ន អញ្ញត្រ សុគតវិនយាតិ ។

(២៤) ទសយិមេ ភិក្ខវេ ធម្មា អនុប្បន្នា ឧប្បជ្ជន្តិ ន អញ្ញត្រ សុគតវិនយា ។ កតមេ ទស ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា អនុប្បន្នា ឧប្បជ្ជន្តិ ន អញ្ញត្រ សុគតវិនយាតិ ។

(២៥) ទសយិមេ ភិក្ខវេ ធម្មា មហប្ផលា មហានិសំសា ន អញ្ញត្រ សុគតវិនយា ។ កតមេ ទស ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។

---

១ ម. នាញ្ញត្រ ។

# បារិសុទ្ធិវគ្គ ទី ៣

(៦៣) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ បរិសុទ្ធផូរផង់ ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ សេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ សំដីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ការរលឹកត្រូវ ១ ការដំកល់ចិត្តមាំត្រូវ ១ ការដឹងត្រូវ ១ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង បរិសុទ្ធផូរផង់ ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

(៦៤) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ មិនទាន់កើតហើយកើតឡើង ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង មិនទាន់កើតហើយ កើតឡើង ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

(៦៥) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះមានផលច្រើន មានអានិសង្សច្រើន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។

ឥមេ ខោ ភិក្ខវេ ទស ធម្មា មហប្ផលា មហានិសំសា ន អញ្ញត្រ សុគតវិនយាតិ ។

(៦៦) ទសយិមេ ភិក្ខវេ ធម្មា រាគវិនយបរិយោសានា ហោន្តិ ទោសវិនយបរិយោសានា ហោន្តិ មោហវិនយបរិយោសានា ហោន្តិ ន អញ្ញត្រ សុគតវិនយា ។ កតមេ ទស ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា រាគវិនយបរិយោសានា ហោន្តិ ទោសវិនយបរិយោសានា ហោន្តិ មោហវិនយបរិយោសានា ហោន្តិ ន អញ្ញត្រ សុគតវិនយាតិ ។

(៦៧) ទសយិមេ ភិក្ខវេ ធម្មា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ន អញ្ញត្រ សុគតវិនយាតិ ។ កតមេ ទស ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង១០នេះឯង មានផលច្រើន មានអានិសង្ស ច្រើន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

(២៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ មានកិរិយា កំចាត់បង់នូវរាគៈជាទីបំផុត កំចាត់បង់នូវទោសៈជាទីបំផុត កំចាត់បង់នូវមោហៈ ជាទីបំផុត ក្រៅអំពីវិន័យ របស់ព្រះសុគត មិនមានឡើយ ។ ធម៌ទាំង ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង មានកិរិយា កំចាត់បង់នូវរាគៈជាទីបំផុត កំចាត់បង់នូវទោសៈជាទីបំផុត កំចាត់បង់នូវមោហៈជាទីបំផុត ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

(២៧) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីសេចក្តីស្ងប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង១០ នេះឯង ប្រព្រឹត្តទៅ ដើម្បីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីសេចក្តីស្ងប់

អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ន អញ្ញត្រ សុគតវិនយាតិ ។

(២៨) ទសយិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ ន អញ្ញត្រ សុគតវិនយា ។ កតមេ ទស ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ ន អញ្ញត្រ សុគតវិនយាតិ ។

(២៩) ទសយិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា ន អញ្ញត្រ សុគតវិនយាតិ ។ កតមេ ទស ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា ន អញ្ញត្រ សុគតវិនយាតិ ។

ដើម្បីដឹងបំពោះ ដើម្បីត្រាស់ដឹងព្រម ដើម្បីព្រះនិព្វាន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ដែលបុគ្គលបំពេនហើយ ធ្វើឲ្យរឿយ ៗ ហើយ មិនទាន់កើត ហើយកើតឡើង ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង បុគ្គលបានបំពេនហើយ ធ្វើឲ្យរឿយ ៗ ហើយ មិនទាន់កើត ហើយកើតឡើង ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ដែលបុគ្គលបានបំពេនហើយ ធ្វើឲ្យរឿយៗហើយ មានផលច្រើន មានអានិសង្សច្រើន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង ដែលបុគ្គលបានបំពេនហើយ បានធ្វើឲ្យរឿយ ៗ ហើយ មានផលច្រើន មានអានិសង្សច្រើន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

(៣០) ទសយិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា រាគវិនយបរិយោសានា ហោន្តិ ទោសវិនយបរិយោសានា ហោន្តិ មោហវិនយបរិយោសានា ហោន្តិ ន អញ្ញត្រ សុគតវិនយា ។ កតមេ ទស ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា ភាវិតា ពហុលីកតា រាគវិនយបរិយោសានា ហោន្តិ ទោសវិនយបរិយោសានា ហោន្តិ មោហវិនយបបរិយោសានា ហោន្តិ ន អញ្ញត្រ សុគតវិនយាតិ ។

(៣១) ទសយិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ន អញ្ញត្រ សុគតវិនយាតិ ។ កតមេ ទស ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា ភាវិតា ពហុលីកតា

(៣០) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើន ៗ ហើយ មានកិរិយាកំចាត់បង់នូវរាគៈជាទីបំផុត កំចាត់បង់នូវទោសៈជាទីបំផុត កំចាត់បង់នូវមោហៈជាទីបំផុត ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើន ៗ ហើយ មានកិរិយាកំចាត់បង់នូវរាគៈជាទីបំផុត កំចាត់បង់នូវទោសៈជាទីបំផុត កំចាត់បង់នូវមោហៈជាទីបំផុត ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

(៣១) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ១០ នេះ ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីសេចក្តីស្ងប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹងព្រម ដើម្បីព្រះនិព្វាន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។ ធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនៗ ហើយ

ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ន អញ្ញត្រ សុគតវិនយាតិ ។

(៣២) ទសយិមេ ភិក្ខវេ មិច្ឆត្តា ។ កតមេ ទស ។ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា មិច្ឆាកម្មន្តោ មិច្ឆាអាជីវោ មិច្ឆាវាយាមោ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណំ មិច្ឆាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស មិច្ឆត្តាតិ ។

(៣៣) ទសយិមេ ភិក្ខវេ សម្មត្តា ។ កតមេ ទស ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មា-កម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ សម្មាញាណំ សម្មាវិមុត្តិ ។ ឥមេ ខោ ភិក្ខវេ ទស សម្មត្តាតិ ។

តតិយោ បារិសុទ្ធិវគ្គោ (១) ។

---

១ ឱ.ម. បរិសុទ្ធវគ្គោ ។

តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីសេចក្តីស្ងប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹងព្រម ដើម្បីព្រះនិព្វាន ក្រៅអំពីវិន័យរបស់ព្រះសុគត មិនមានឡើយ ។

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ មិច្ឆត្តធម៌ (ធម៌ខុស) ទាំងឡាយនេះមាន ១០ ។ មិច្ឆត្តធម៌ទាំង ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ សេចក្តីត្រិះរិះខុស ១ សំដីខុស ១ ការងារខុស ១ ការចិញ្ចឹមជីវិតខុស ១ សេចក្តីព្យាយាមខុស ១ ការរលឹកខុស ១ ការដំកល់ចិត្តខុស ១ ការដឹងខុស ១ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ មិច្ឆត្តធម៌ មាន ១០ នេះឯង ។

[ ៣៧ ] ម្នាលភិក្ខុទាំងឡាយ សម្មត្តធម៌ (ធម៌ត្រូវ) ទាំងឡាយនេះមាន ១០ ។ សម្មត្តធម៌ ១០ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ សំដីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ការរលឹកត្រូវ ១ ការដំកល់ចិត្តត្រូវ ១ ការដឹងត្រូវ ១ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ សម្មត្តធម៌ មាន ១០ នេះឯង ។

ចប់ ឋាសុទ្ធិវគ្គ ទី ៣ ។

## ចតុត្ថោ សាធុវគ្គោ

(៣៤) សាធុញ្ច វោ ភិក្ខវេ ទេសិស្សាមិ អសាធុញ្ច តំ សុណាថ សាធុកំ មនសិ ករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមញ្ច ភិក្ខវេ អសាធុ(១) ។ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា មិច្ឆាកម្មន្តោ មិច្ឆាអាជីវោ មិច្ឆាវាយាមោ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណំ មិច្ឆាវិមុត្តិ ។ ឥទំ វុច្ចតិ ភិក្ខវេ អសាធុ ។ កតមញ្ច ភិក្ខវេ សាធុ(២) សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ សម្មាញាណំ សម្មាវិមុត្តិ ។ ឥទំ វុច្ចតិ ភិក្ខវេ សាធុន្តិ(៣) ។

---

១ ម. កតមោ ច ភិក្ខវេ អសាធុ ។ ២ ម. កតមោ ច ភិក្ខវេ សាធុ ។
៣ ម. សាធូតិ ។

# សាធុវគ្គទី ៤

( ៣៤ ) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវសេចក្តីចំរើនផង សេចក្តីមិនចំរើនផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនចំរើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ សេចក្តីត្រិះរិះខុស ១ សំដីខុស ១ ការងារខុស ១ ការចិញ្ចឹមជីវិតខុស ១ សេចក្តីព្យាយាមខុស ១ ការរលឹកខុស ១ ការដំកល់ចិត្តមាំខុស ១ ការដឹងខុស ១ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីមិនចំរើន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ សំដីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ការរលឹកត្រូវ ១ ការដំកល់ចិត្តមាំត្រូវ ១ ការដឹងត្រូវ ១ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីចំរើន ។

(៣៨) អរិយធម្មញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនរិយធម្មញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អនរិយោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អនរិយោ ធម្មោ ។ កតមោ ច ភិក្ខវេ អរិយោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយោ ធម្មោតិ ។

(៣៩) កុសលញ្ច វោ ភិក្ខវេ ទេសិស្សាមិ អកុសលញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមញ្ច ភិក្ខវេ អកុសលំ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។

(៣៥) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ដ៏ប្រសើរផង ធម៌មិនប្រសើរផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះធម៌មិនប្រសើរ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដ៏ប្រសើរ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដ៏ប្រសើរ ។

(៣៦) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវកុសលធម៌ផង អកុសលធម៌ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។

ឥទំ វុច្ចតិ ភិក្ខវេ អកុសលំ ។ កតមញ្ច ភិក្ខវេ កុសលំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ ឥទំ វុច្ចតិ ភិក្ខវេ កុសលំ (១)។

(៣៧) អរិយញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនរិយញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិ-ស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អនរិយោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អនរិយោ ។ កតមោ ច ភិក្ខវេ អរិយោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយោតិ ។

(៣៨) ធម្មញ្ច វោ ភិក្ខវេ ទេសិស្សាមិ អធម្មញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។

---

១ ម. កុសលន្តិ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា អកុសលធម៌ ។ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ តើដូចម្តេច ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កុសលធម៌ ។

(៣៧) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ជាប្រយោជន៍ផង ធម៌មិនជាប្រយោជន៍ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌មិនជាប្រយោជន៍ តើដូចម្តេច ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មិនជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាប្រយោជន៍ តើដូចម្តេច ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ជាប្រយោជន៍ ។

(៣៨) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ផង នូវអធម៌ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្ត ឲ្យប្រពៃចុះ តថាគតនឹងសំដែង ។

ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អធម្មោ ។ កតមោ ច ភិក្ខវេ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ធម្មោតិ ។

(៣៩) សាសវញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ អនាសវញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ សាសវោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ សាសវោ ធម្មោ ។ កតមោ ច ភិក្ខវេ អនាសវោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អនាសវោ ធម្មោតិ ។

ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អធម៌តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធម៌ ។ ម្នាលភិក្ខុទាំងឡាយ ធម៌តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ ។

(៣៩) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ដែលប្រកបដោយអាសវៈផង នូវធម៌មិនមានអាសវៈផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលប្រកបដោយអាសវៈ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ប្រកបដោយអាសវៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនមានអាសវៈ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មិនមានអាសវៈ ។

តតិយបណ្ណាសកេ សាធុវគ្គោ

[៤០] សាវជ្ជញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ អនវជ្ជញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ សាវជ្ជោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ សាវជ្ជោ ធម្មោ ។ កតមោ ច ភិក្ខវេ អនវជ្ជោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អនវជ្ជោ ធម្មោតិ ។

[៤១] តបនីយញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ អតបនីយញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ តបនីយោ ធម្មោ ។

(៤០) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ដែលប្រកបដោយទោសផង នូវធម៌មិនមានទោសផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ប្រកបដោយទោស តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស១ ។ បេ ។ ការរួចខុស១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ប្រកបដោយទោស ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនមានទោស តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មិនមានទោស ។

(៤១) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ ដែលគួរដុតកំដៅផង មិនគួរដុតកំដៅផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរដុតកំដៅ តើអ្វីខ្លះ ។

មិច្ឆាទិដ្ឋិ ។បេ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ តបនីយោ ធម្មោ ។ កតមោ ច ភិក្ខវេ អតបនីយោ ធម្មោ ។ សម្មាទិដ្ឋិ ។បេ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អតបនីយោ ធម្មោតិ ។

(៦២) អាចយគាមិញ្ច វោ ភិក្ខវេ ធម្មំ ទេសេស្សាមិ អបចយគាមិញ្ច តំ សុណាថ សាធុកំ មនសិការោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អាចយគាមី ធម្មោ ។ មិច្ឆាទិដ្ឋិ ។បេ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អាចយគាមី ធម្មោ ។ កតមោ ច ភិក្ខវេ អបចយគាមី ធម្មោ ។ សម្មាទិដ្ឋិ ។បេ។ សម្មាវិមុត្តិ ។

គឺ សេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌គួរដុតកំដៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មិនគួរដុតកំដៅ តើអ្វីខ្លះ ។ គឺ សេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មិនគួរដុតកំដៅ ។

(៤២) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលញ៉ាំងសត្វឲ្យដល់ នូវការសន្សំវដ្តៈផង នូវធម៌ដែលមិនញ៉ាំងសត្វឲ្យដល់ នូវការសន្សំវដ្តៈផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្ត ឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែល ញ៉ាំងសត្វឲ្យដល់ នូវការសន្សំវដ្តៈ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលញ៉ាំងសត្វឲ្យដល់ នូវការសន្សំវដ្តៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនញ៉ាំងសត្វឲ្យដល់ នូវការសន្សំវដ្តៈ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។

អយំ វុច្ចតិ ភិក្ខវេ អបចយគាមី ធម្មោតិ ។

(៤៣) ទុក្ខុទ្រយញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ សុខុទ្រយញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ ទុក្ខុទ្រយោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខុទ្រយោ ធម្មោ ។ កតមោ ច ភិក្ខវេ សុខុទ្រយោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ សុខុទ្រយោ ធម្មោតិ ។

(៤៤) ទុក្ខវិបាកញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ សុខវិបាកញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។

តតិយបណ្ណាសក សាធុវគ្គ

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនញុំាងសត្វឲ្យដល់នូវការសន្សំវដ្ដៈ ។

(៤៣) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលញុំាងទុក្ខឲ្យកើតឡើងផង នូវធម៌ដែលញុំាងសុខឲ្យកើតឡើងផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលញុំាងទុក្ខឲ្យកើតឡើង តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលញុំាងទុក្ខឲ្យកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលញុំាងសុខឲ្យកើតឡើង តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលញុំាងសុខឲ្យកើតឡើង ។

(៤៤) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលមានផលជាទុក្ខផង នូវធម៌ដែលមានផលជាសុខផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។

ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ ទុក្ខុ-ទ្រយោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខុទ្រយោ ធម្មោ ។ កតមោ ច ភិក្ខវេ សុខុទ្រយោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ សុខុទ្រយោ ធម្មោតិ ។

សាធុវគ្គោ ចតុត្ថោ ។

ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមានផលជាទុក្ខ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមានផលជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមានផលជាសុខ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមានផលជាសុខ ។

ចប់ សាធុវគ្គ ទី ៤ ។

# បញ្ចមោ អរិយមគ្គវគ្គោ

(៤៥) អរិយមគ្គញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនរិយមគ្គញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អនរិយោ មគ្គោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អនរិយោ មគ្គោ ។ កតមោ ច ភិក្ខវេ អរិយោ មគ្គោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយោ មគ្គោតិ ។

(៤៦) កណ្ហមគ្គញ្ច វោ ភិក្ខវេ ទេសិស្សាមិ សុក្កមគ្គញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

# អរិយមគ្គវគ្គ ទី៥

(៤៥) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ជាមគ្គដ៏ប្រសើរ ផង នូវធម៌ជាមគ្គមិនប្រសើរផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មគ្គមិនប្រសើរ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មគ្គមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ មគ្គដ៏ប្រសើរ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មគ្គដ៏ប្រសើរ ។

(៤៦) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ជាមគ្គខ្មៅផង នូវធម៌ជាមគ្គសផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ភគវា ឯតទវោច កតមោ ច ភិក្ខវេ កណ្ហមគ្គោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ កណ្ហមគ្គោ ។ កតមោ ច ភិក្ខវេ សុក្កោ មគ្គោ (១) ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ សុក្កោ មគ្គោតិ ។

(៤៧) សទ្ធម្មញ្ច វោ ភិក្ខវេ ទេសេស្សាមិ អសទ្ធម្មញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អសទ្ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អសទ្ធម្មោ ។ កតមោ ច ភិក្ខវេ សទ្ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ សទ្ធម្មោតិ ។

---

១ ឱ. ម. សុក្កមគ្គោ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មគ្គខ្មៅ តើអ្វីខ្លះ ។ គឺសេចក្ដីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មគ្គខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ មគ្គស តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មគ្គស ។

(៤៧) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវសទ្ធម្មផង នូវអសទ្ធម្មផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អសទ្ធម្ម តើអ្វីខ្លះ ។ គឺសេចក្ដីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ សទ្ធម្ម តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សទ្ធម្ម ។

(៤៨) សប្បុរិសធម្មញ្ច វោ ភិក្ខវេ ទេសិស្សាមិ អសប្បុរិសធម្មញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អសប្បុរិសធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសធម្មោ ។ កតមោ ច ភិក្ខវេ សប្បុរិសធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសធម្មោតិ ។

(៤៩) ឧប្បាទេតព្ពញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន ឧប្បាទេតព្ពញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(៤៨) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌របស់សប្បុរសផង នូវធម៌របស់អសប្បុរសផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌របស់អសប្បុរស តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌របស់អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ធម៌របស់សប្បុរស តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌របស់សប្បុរស ។

(៤៩) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលគួរឲ្យកើតឡើងផង នូវធម៌ដែលមិនគួរឲ្យកើតឡើងផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ភគវា ឯតទវោច កតមោ ច ភិក្ខវេ ន ឧប្បាទេតព្វោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ន ឧប្បាទេតព្វោ ធម្មោ ។ កតមោ ច ភិក្ខវេ ឧប្បាទេតព្វោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ឧប្បាទេតព្វោ ធម្មោតិ ។

(៥០) អាសេវិតព្វញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន អាសេវិតព្វញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ ន អាសេវិតព្វោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ន អាសេវិតព្វោ ធម្មោ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរឲ្យកើតឡើង តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរឲ្យកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរឲ្យកើតឡើង តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរឲ្យកើតឡើង ។

(៥០) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលគួរគប់រកផង នូវធម៌ដែលមិនគួរគប់រកផង ដល់អ្នកទាំងឡាយ ។ ចូរអ្នកទាំងឡាយស្តាប់ នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្ត ឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរគប់រក តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរគប់រក ។

កតមោ ច ភិក្ខវេ អាសេវិតព្វោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អាសេវិតព្វោ ធម្មោតិ ។

(៥០) ភាវេតព្វញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន ភាវេតព្វញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ ន ភាវេតព្វោ ធម្មោ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ន ភាវេតព្វោ ធម្មោ ។ កតមោ ច ភិក្ខវេ ភាវេតព្វោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ភាវេតព្វោ ធម្មោតិ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរគប់រក តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួបត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរគប់រក ។

[៥១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលគួរចំរើនផង នូវធម៌ដែលមិនគួរចំរើនផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្ត ឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែង ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរចំរើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួបខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរចំរើន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរចំរើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួបត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរចំរើន ។

(៤២) ពហុលីកាតព្ពញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ អពហុលីកាតព្ពញ្ច ។ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អពហុលីកាតព្ពោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អពហុលីកាតព្ពោ ធម្មោ ។ កតមោ ច ភិក្ខវេ ពហុលីកាតព្ពោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ពហុលីកាតព្ពោ ធម្មោតិ ។

(៩២) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលគួរធ្វើឲ្យច្រើនផង នូវធម៌ដែលមិនគួរធ្វើឲ្យច្រើនផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរធ្វើឲ្យច្រើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរធ្វើឲ្យច្រើន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរធ្វើឲ្យច្រើន តើអ្វីខ្លះ ។ គឺសេចក្តីយល់ឃើញត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរធ្វើឲ្យច្រើន ។

(៨៣) អនុស្សរិតញ្ញ វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន អនុស្សរិតញ្ញ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ ន អនុស្សរិតញ្ញោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ន អនុស្សរិតញ្ញោ ធម្មោ ។ កតមោ ច ភិក្ខវេ អនុស្សរិតញ្ញោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ អនុស្សរិតញ្ញោ ធម្មោតិ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលគួរលើកឡើង ។ ផង នូវធម៌ដែលមិនគួរលើកឡើង ។ ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរលើកឡើង ។ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរលើកឡើង ។ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរលើកឡើង តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរលើកឡើង ។ ។

(៥៤) សច្ឆិកាតព្វញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន សច្ឆិកាតព្វញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ ន សច្ឆិកាតព្វោ ធម្មោ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ ន សច្ឆិកាតព្វោ ធម្មោ ។ កតមោ ច ភិក្ខវេ សច្ឆិកាតព្វោ ធម្មោ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាវិមុត្តិ ។ អយំ វុច្ចតិ ភិក្ខវេ សច្ឆិកាតព្វោ ធម្មោតិ ៕

បញ្ចមោ អរិយមគ្គវគ្គោ ។

តតិយោ តតិយបណ្ណាសកោ ។

[៩៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ផង នូវធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ តើអ្វីខ្លះ ។ គឺសេចក្តីយល់ខុស ១ ។ បេ ។ ការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ តើអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ។

ចប់ អរិយមគ្គវគ្គ ទី ៥

ចប់ តតិយបណ្ណាសក ទី ៣ ។

## ចតុត្ថបណ្ណាសកោ

### បឋមោ បុគ្គលវគ្គោ

[៥៥] ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បុគ្គលោ ន សេវិតព្វោ ។ កតមេហិ ទសហិ ។ មិច្ឆាទិដ្ឋិកោ (១) ហោតិ មិច្ឆាសង្កប្បោ ហោតិ មិច្ឆាវាចោ (២) ហោតិ មិច្ឆាកម្មន្តោ ហោតិ មិច្ឆាអាជីវោ ហោតិ មិច្ឆាវាយាមោ ហោតិ មិច្ឆាសតិ ហោតិ មិច្ឆាសមាធិ ហោតិ មិច្ឆាញាណី (៣) ហោតិ មិច្ឆាវិមុត្តិ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ បុគ្គលោ ន សេវិតព្វោ ។ ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បុគ្គលោ សេវិតព្វោ ។ កតមេហិ ទសហិ ។ សម្មាទិដ្ឋិកោ ហោតិ សម្មាសង្កប្បោ ហោតិ សម្មាវាចោ ហោតិ សម្មាកម្មន្តោ ហោតិ សម្មាអាជីវោ ហោតិ សម្មាវាយាមោ ហោតិ

---

១ ម. មិច្ឆាទិដ្ឋិ ។ ២ ម. មិច្ឆាវាចា ។ ៣ ម. មិច្ឆាញាណំ ។ ឥមេ បាឋា យុត្តតរា ។

# បត្តបណ្ណាសក

## បុគ្គលវគ្គ ទី ១

[៥៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ពុំគួរសេពគប់ទេ ។ ប្រកបដោយធម៌ទាំង ១០ តើអ្វីខ្លះ ។ គឺជាអ្នកយល់ខុស ១ មានតម្រិះខុស ១ មានសំដីខុស ១ មានការងារខុស ១ មានការចិញ្ចឹមជីវិតខុស ១ មានព្យាយាមខុស ១ មានស្មារតីខុស ១ មានការដំកល់ចិត្តខុស ១ មានការដឹងខុស ១ មានការរួចខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ១០ នេះឯង ពុំគួរសេពគប់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ទើបគួរសេពគប់ ។ ប្រកបដោយធម៌ ១០ តើអ្វីខ្លះ ។ គឺជាអ្នកយល់ត្រូវ ១ មានតម្រិះត្រូវ ១ មានសំដីត្រូវ ១ មានការងារត្រូវ ១ មានការចិញ្ចឹមជីវិតត្រូវ ១ មានព្យាយាមត្រូវ ១

សម្មាសតិ ហោតិ សម្មាសមាធិ ហោតិ សម្មាញាណី ហោតិ សម្មាវិមុត្តិ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ បុគ្គលោ សេវិតព្វោ ។ (ឆដ្ឋវគ្គិយត្ថេរសតាទិសុត្តំ បេយ្យាលវសេន គហេតព្វំ) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បុគ្គលោ ន ភជិតព្វោ...ភជិតព្វោ...ន បយិរុបាសិតព្វោ... បយិរុបាសិតព្វោ ... ន បុជ្ជោ ហោតិ... បុជ្ជោ ហោតិ ... ន បាសំសោ ហោតិ ... បាសំសោ ហោតិ ... អគារវោ ហោតិ... សគារវោ ហោតិ... អប្បតិស្សោ (១) ហោតិ... សប្បតិស្សោ (២) ហោតិ... ន អារាធកោ ហោតិ... អារាធកោ ហោតិ... ន វិសុជ្ឈតិ... វិសុជ្ឈតិ... មានំ នាធិភោតិ..(៣) មានំ អធិភោតិ (៤)... បញ្ញាយ ន វឌ្ឍតិ... បញ្ញាយ វឌ្ឍតិ... ពហុំ អបុញ្ញំ បសវតិ ... ពហុំ បុញ្ញំ បសវតិ ។

---

១ ឱ. អប្បដិស្សោ ។ ម. អប្បដិស្សោ ។ ២ ឱ. សប្បដិស្សោ ។ ម. សប្បដិស្សោ ។ ៣ ម. នាភិភោតិ ។ ៤ ម. អភិភោតិ ។

មានស្មារតីត្រូវ ១ មានការដំកល់ចិត្តមាំត្រូវ ១ មានការដឹងត្រូវ ១ មានការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទើបគួរសេពគប់ ។ (សូត្រមានចំនួនមួយរយហាសិបប្រាំមួយជាដើម បណ្ឌិតគប្បីកប់ ដោយអំណាចនៃបេយ្យាលៈចុះ)

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ពុំគួរគប់រក ... គួរគប់រក ... ពុំគួរចូលទៅអង្គុយជិត ... គួរចូលទៅអង្គុយជិត ... ពុំគួរបូជា ... គួរបូជា ... ពុំគួរសរសើរ ... គួរសរសើរ ... ពុំគួរគោរព ... គួរគោរព ... ពុំគួរកោតក្រែង ... គួរកោតក្រែង ... ពុំគួរត្រេកអរ ... គួរត្រេកអរ ... មិនស្អាត ... ស្អាត ... មិនគ្រប់សង្កត់នូវមានះ ... គ្រប់សង្កត់នូវមានះ ... មិនចំរើន ដោយបញ្ញា ... ចំរើន ដោយបញ្ញា ... រមែងបានបាបច្រើន ... រមែងបានបុណ្យច្រើន ។

កតមេហិ ទសហិ ។ សម្មាទិដ្ឋិកោ[១] ហោតិ សម្មាសង្កប្បោ ហោតិ សម្មាវាចោ[២] ហោតិ សម្មាកម្មន្តោ ហោតិ សម្មាអាជីវោ ហោតិ សម្មាវាយាមោ ហោតិ សម្មាសតិ ហោតិ សម្មាសមាធិ ហោតិ សម្មាញាណី[៣] ហោតិ សម្មា-វិមុត្តិ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ បុគ្គលោ ពហុំ បុញ្ញំ បសវតីតិ ។

១ ម. សម្មាទិដ្ឋិ ។ ២ ម. សម្មាវាចា ។ ៣ ម. សម្មាញាណំ ។

បឋមោ បុគ្គលវគ្គោ ។

ប្រកបដោយធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺអ្នកមានប្រាជ្ញាយល់ត្រូវ ១ មានតម្រិះត្រូវ ១ មានសំដីត្រូវ ១ មានការងារត្រូវ ១ មានការចិញ្ចឹមជីវិតត្រូវ ១ មានព្យាយាមត្រូវ ១ មានស្មារតីត្រូវ ១ មានការដំកល់ចិត្តមាំត្រូវ ១ មានការដឹងត្រូវ ១ មានការរួចត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះឯង រមែងបានបុណ្យច្រើន ។

ចប់ បុគ្គលវគ្គទី ១ ។

## ទុតិយោ ជាណុស្សោណិវគ្គោ

[៥៦] តេន ខោ បន សមយេន ជាណុស្សោណិ ព្រាហ្មណោ តទហុបោសថេ សីសំន្ហាតោ នវំ ខោមយុគំ និវត្ថោ អល្លកុសមុដ្ឋឹ[១] អាទាយ ភគវតោ អវិទូរេ ឯកមន្តំ ឋិតោ ហោតិ ។ អទ្ទសា ខោ ភគវា ជាណុស្សោណឹ ព្រាហ្មណំ តទហុបោសថេ សីសំន្ហាតំ នវំ ខោមយុគំ និវត្ថំ អល្លកុសមុដ្ឋឹ អាទាយ ឯកមន្តំ ឋិតំ ទិស្វាន ជាណុស្សោណឹ ព្រាហ្មណំ ឯតទវោច កឹ នុ ត្វំ ព្រាហ្មណ តទហុ-បោសថេ សីសំន្ហាតោ នវំ ខោមយុគំ និវត្ថោ អល្ល-កុសមុដ្ឋឹ អាទាយ ឯកមន្តំ ឋិតោ កឹ នុ ខោ អជ្ជ ព្រាហ្មណកុលស្សាតិ ។ បច្ចោរោហណី ភោ គោតម អជ្ជ ព្រាហ្មណកុលស្សាតិ ។ យថាកថំ បន ព្រាហ្មណ ព្រាហ្មណានំ បច្ចោរោហណី ហោតីតិ ។

---

១ ខ. អល្លកុសមុដ្ឋិ ។

# ជាណុស្សោណិវគ្គ ទី ២

(៥៦) សម័យនោះឯង ព្រាហ្មណ៍ឈ្មោះជាណុស្សោណិ កក់ក្បាល ក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់ស្បូវស្រស់ ១ ក្តាប់ ឈរនៅក្នុងទីសមគួរ ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគបានឃើញ ជាណុស្សោណិព្រាហ្មណ៍ កក់ក្បាល ក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី កាន់ស្បូវស្រស់មួយក្តាប់ ឈរនៅក្នុងទីសមគួរ លុះឃើញហើយ ក៏ទ្រង់ត្រាស់នឹងជាណុស្សោណិព្រាហ្មណ៍ ដូច្នេះថា ម្នាលព្រាហ្មណ៍ ហេតុដូចម្តេចហ្ន៎ បានជាអ្នកកក់ក្បាល ក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់ សម្បកឈើដ៏ថ្មី កាន់យកស្បូវស្រស់មួយក្តាប់ ឈរនៅក្នុងទីសមគួរ ចុះការងារ ដូចម្តេច របស់ត្រកូលព្រាហ្មណ៍ក្នុងថ្ងៃនេះ ។ បពិត្រព្រះគោតមដ៏ចំរើន ថ្ងៃនេះ ទុកជាថ្ងៃបន្ទ្រាត់បង់នូវបាប របស់ត្រកូលព្រាហ្មណ៍ ។ ម្នាលព្រាហ្មណ៍ ការបន្ទ្រាត់បង់នូវបាប របស់ព្រាហ្មណ៍ទាំងឡាយ ដូចម្តេចទៅ ។

ឥធ ភោ គោតម ព្រាហ្មណា តទហុបោសថេ សីសន្ហាតា នវំ ខោមយុគំ និវត្ថា អល្លេន គោមយេន បឋវឹ ឱបុញ្ជិត្វា ហរិតេហិ កុសេហិ បត្ថរិត្វា (១) អន្តរា ច វេលំ អន្តរា ច អគ្យាគារំ សេយ្យំ កប្បេន្តិ ។ តេ តំ រត្តឹ តិក្ខត្តុំ បច្ចុដ្ឋាយ បញ្ជលិកា អគ្គឹ នមស្សន្តិ បច្ចោរោហាម ភវន្តំ បច្ចោរោហាម ភវន្តន្តិ ពហុកេន ច សប្បិតេលេន នវនីតេន អគ្គឹ សន្តប្បេន្តិ ។ តស្សា ច រត្តិយា អច្ចយេន បណីតេន ខាទនីយេន ភោជនីយេន ព្រាហ្មណេ សន្តប្បេន្តិ ។ ឯវំ ខោ ភោ គោតម ព្រាហ្មណានំ បច្ចោរោហណី ហោតីតិ ។ អញ្ញថា ខោ ព្រាហ្មណានំ បច្ចោរោហណី ហោតិ អញ្ញថា ច បន អរិយស្ស វិនយេ បច្ចោរោហណី ហោតីតិ ។

---

១ ម. បរិត្ថរេត្វា ។

បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ តែងកក់ក្បាល ក្នុងថ្ងៃឧបោសថនោះ ហើយស្លៀកនូវគូសំពត់សម្បកឈើដ៏ថ្មី លាបនូវផែនដី ដោយអាចម៍គោស្រស់ ក្រាលដោយស្បូវទាំងឡាយដ៏ខៀវ ហើយដេកក្នុងចន្លោះ នៃគំនរដីខ្សាច់ផង ក្នុងចន្លោះពេងភ្លើងផង ។ ព្រាហ្មណ៍ទាំងឡាយនោះ តែងក្រោកឡើង ៣ ដងក្នុងរាត្រីនោះ ហើយផ្គងអញ្ជលី នមស្ការចំពោះភ្លើងថា យើងទាំងឡាយ បន្សាត់បង់នូវបាបទឹងលោកដ៏ចំរើន យើងទាំងឡាយ បន្សាត់បង់នូវបាប ទឹងលោកដ៏ចំរើន ទើបញ៉ាំងភ្លើងឲ្យឆ្អែត ដោយទឹកដោះរាវនឹងប្រេង នឹងទឹកដោះខាប់ដ៏ច្រើន ។ លុះកន្លងរាត្រីនោះទៅហើយ ក៏ញ៉ាំងព្រាហ្មណ៍ទាំងឡាយ ឲ្យឆ្អែតដោយខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ ។ បពិត្រព្រះគោតមដ៏ចំរើន ការបន្សាត់បង់នូវបាប របស់ព្រាហ្មណ៍ទាំងឡាយ យ៉ាងនេះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការបន្សាត់បង់នូវបាប របស់ព្រាហ្មណ៍ទាំងឡាយ រមែងមាន ដោយឡែក ការបន្សាត់បង់នូវបាប ក្នុងអរិយវិន័យ រមែងមាន ដោយឡែក ។

យថាកថំ បន ភោ គោតម អរិយស្ស វិនយេ បច្ចោរោហណី ហោតិ សាធុ វត មេ ភវំ គោតមោ តថា ធម្មំ ទេសេតុ យថា អរិយស្ស វិនយេ បច្ចោរោហណី ហោតីតិ ។ តេនហិ ព្រាហ្មណ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ ជាណុស្សោណិ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច ឥធ ព្រាហ្មណ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ បាណាតិបាតស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្ប-រាយញ្ចាតិ សោ ឥតិ បដិសង្ខាយ បាណាតិបាតំ បជហតិ បាណាតិបាតា បច្ចោរោហតិ ។ អទិន្នា-ទានស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ អទិន្នា-ទានំ បជហតិ អទិន្នាទានា បច្ចោរោហតិ ។

បពិត្រព្រះគោតមដ៏ចំរើន ការបន្សាត់បង់បាប ក្នុងអរិយវិន័យ តើដូចម្តេច សូមទ្រង់ព្រះមេត្តាប្រោស ការបន្សាត់បង់បាប ក្នុងអរិយវិន័យ បែបណា សូមព្រះគោតមដ៏ចំរើន សំដែងនូវធម៌បែបនោះ ដល់ខ្ញុំព្រះអង្គ ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ជាណុស្សោណិព្រាហ្មណ៍ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ អរិយសាវកក្នុងសាសនានេះ តែងពិចារណាដូច្នេះថា ផលដ៏លាមករបស់បាណាតិបាត តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវបាណាតិបាត បន្សាត់បង់បាណាតិបាត ។ ផលដ៏លាមក របស់អទិន្នាទាន មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវអទិន្នាទាន បន្សាត់បង់អទិន្នាទាន ។

ចតុត្ថបណ្ណាសកេ ជាណុស្សោណិវគ្គោ

កាមេសុ មិច្ឆាចារស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ កាមេសុ មិច្ឆាចារំ បជហតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ ។ មុសាវាទស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ មុសាវាទំ បជហតិ មុសាវាទា បដិវិរតោ ហោតិ ។ បិសុណាយ វាចាយ ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ បិសុណាវាចំ បជហតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ។ ផរុសាយ វាចាយ ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ ផរុសវាចំ បជហតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ ។ សម្ផប្បលាបស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ សម្ផប្បលាបំ បជហតិ សម្ផប្បលាបា បដិវិរតោ ហោតិ ។

ផលដ៏លាមក របស់កាមេសុមិច្ឆាចារៈ តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវកាមេសុមិច្ឆាចារៈ បន្សាត់បង់កាមេសុមិច្ឆាចារៈ ។ ផលដ៏លាមក របស់មុសាវាទ តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវមុសាវាទ បន្សាត់បង់មុសាវាទ ។ ផលដ៏លាមក របស់បិសុណាវាចា តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវបិសុណាវាចា បន្សាត់បង់បិសុណាវាចា ។ ផលដ៏លាមក របស់ផរុសវាចា តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវផរុសវាចា បន្សាត់បង់ផរុសវាចា ។ ផលដ៏លាមក របស់សម្ផប្បលាបៈ តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវសម្ផប្បលាបៈ បន្សាត់បង់សម្ផប្បលាបៈ ។

អភិជ្ឈាយ ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ អភិជ្ឈំ បជហតិ អភិជ្ឈាយ បច្ចោរោហតិ ។ ព្យាបាទស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ ព្យាបាទំ បជហតិ ព្យាបាទា បច្ចោរោហតិ ។ មិច្ឆាទិដ្ឋិយា ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ មិច្ឆាទិដ្ឋឹ បជហតិ មិច្ឆាទិដ្ឋិយា បច្ចោរោហតិ ។ អយំ ខោ ព្រាហ្មណ អរិយស្ស វិនយេ បច្ចោរោហណី ហោតីតិ ។ អញ្ញថា ខោ ភោ គោតម ព្រាហ្មណានំ បច្ចោរោហណី ហោតិ អញ្ញថា ច បន អរិយស្ស វិនយេ បច្ចោរោហណី ហោតិ ។ ឥមិស្សា ច ភោ គោតម អរិយស្ស វិនយេ បច្ចោរោហណិយា ព្រាហ្មណានំ បច្ចោរោហណី កលំ នាគ្ឃតិ សោឡសឹ ។ អភិក្កន្តំ ភោ គោតម ។ បេ ។

ផលដ៏លាមក របស់អភិជ្ឈា តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវអភិជ្ឈា បន្ទ្រាត់បង់អភិជ្ឈា ៗ ផលដ៏លាមក របស់ព្យាបាទ តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវព្យាបាទ បន្ទ្រាត់បង់ព្យាបាទ ៗ ផលដ៏លាមក របស់មិច្ឆាទិដ្ឋិ តែងមានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវមិច្ឆាទិដ្ឋិ បន្ទ្រាត់បង់មិច្ឆាទិដ្ឋិ ៗ ម្នាលព្រាហ្មណ៍ ការបន្ទ្រាត់បង់បាប ក្នុងអរិយវិន័យ យ៉ាងនេះឯង ៗ បពិត្រព្រះអង្គដ៏ចំរើន ការបន្ទ្រាត់បង់បាប របស់ព្រាហ្មណ៍ទាំងឡាយ ដោយឡែក ការបន្ទ្រាត់បង់បាប ក្នុងអរិយវិន័យវិញ ដោយឡែក ៗ បពិត្រព្រះគោតមដ៏ចំរើន ការបន្ទ្រាត់បង់បាបរបស់ព្រាហ្មណ៍ទាំងឡាយ មិនដល់នូវចំណិតទី ១៦ ដែលចែក ១៦ ដង នៃការបន្ទ្រាត់បង់បាបក្នុងអរិយវិន័យនេះឡើយ ៗ បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ពេកណាស់ ៗ ។ បេ ៗ

ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

(៨៣) អរិយំ វោ ភិក្ខវេ បច្ចោរោហណឹ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិការោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមា ច ភិក្ខវេ អរិយា បច្ចោរោហណី ។ ឥធ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ បាណាតិបាតស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ បាណាតិបាតំ បជហតិ បាណាតិបាតា បច្ចោរោហតិ ។ អទិន្នាទានស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ អទិន្នាទានំ បជហតិ អទិន្នាទានា បច្ចោរោហតិ ។

សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

(៤៧) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវការបន្ទាក់បង់ដ៏ប្រសើរ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ការបន្ទាក់បង់ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ពិចារណាដូច្នេះថា ផលដ៏លាមក របស់បាណាតិបាត មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវបាណាតិបាត បន្ទាក់បង់បាណាតិបាត ។ ផលដ៏លាមក របស់អទិន្នាទាន មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវអទិន្នាទាន បន្ទាក់បង់អទិន្នាទាន ។

កាមេសុ មិច្ឆាចារស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ កាមេសុ មិច្ឆាចារំ បជហតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ ។ មុសាវាទស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ មុសាវាទំ បជហតិ មុសា-វាទា បដិវិរតោ ហោតិ ។ បិសុណាយ វាចាយ ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ បិសុណាវាចំ បជហតិ បិសុ-ណាយ វាចាយ បដិវិរតោ ហោតិ ។ ផរុសាយ វាចាយ ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរា-យញ្ចាតិ សោ ឥតិ បដិសង្ខាយ ផរុសាវាចំ បជហតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ ។ សម្ផប្បលាបស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិ-សម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ សម្ផប្ប-លាបំ បជហតិ សម្ផប្បលាបា បដិវិរតោ ហោតិ ។

ផលដ៏លាមក របស់កាមេសុមិច្ឆាចារៈ មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវកាមេសុមិច្ឆាចារៈ បនក្រត់បង់កាមេសុមិច្ឆាចារៈ ។ ផលដ៏លាមក របស់មុសាវាទ មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវមុសាវាទ បនក្រត់បង់មុសាវាទ ។ ផលដ៏លាមក របស់បិសុណាវាចា មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវបិសុណាវាចា បនក្រត់បង់បិសុណាវាចា ។ ផលដ៏លាមក របស់ផរុសវាចា មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវផរុសវាចា បនក្រត់បង់ផរុសវាចា ។ ផលដ៏លាមក របស់សម្ផប្បលាបៈ មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវសម្ផប្បលាបៈ បនក្រត់បង់សម្ផប្បលាបៈ ។

អភិជ្ឈាយ ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ
អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ អភិជ្ឈំ
បជហតិ អភិជ្ឈាយ បច្ចោរោហតិ ។ ព្យាបាទស្ស
ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្ប-
រាយញ្ចាតិ សោ ឥតិ បដិសង្ខាយ ព្យាបាទំ
បជហតិ ព្យាបាទា បច្ចោរោហតិ ។ មិច្ឆាទិដ្ឋិយា
ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិ-
សម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ មិច្ឆាទិដ្ឋឹ
បជហតិ មិច្ឆាទិដ្ឋិយា បច្ចោរោហតិ ។ អយំ វុច្ចតិ
ភិក្ខវេ អរិយា បច្ចោរោហណីតិ ។

(៥៨) អថខោ សង្គារវោ ព្រាហ្មណោ យេន
ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា
សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ
វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ
ខោ សង្គារវោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កឹ
នុ ខោ ភោ គោតម ឱរិមំ តីរំ កឹ បារិមំ តីរន្តិ ។

ផលដ៏លាមក របស់អភិជ្ឈា មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវអភិជ្ឈា បន្សាត់បង់អភិជ្ឈា ។ ផលដ៏លាមក របស់ព្យាបាទ មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយ-សាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវព្យាបាទ បន្សាត់បង់ព្យាបាទ ។ ផលដ៏លាមក របស់មិច្ឆាទិដ្ឋិ មានក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ដោយពិត អរិយសាវកនោះ លុះពិចារណាដូច្នេះហើយ លះបង់នូវមិច្ឆាទិដ្ឋិ បន្សាត់បង់មិច្ឆាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការបន្សាត់បង់ដ៏ប្រសើរ ។

(៥៨) គ្រានោះឯង សង្គារវព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសង្គារវព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន អ្វីហ្ន៎ជាត្រើយខាងអាយ អ្វីហ្ន៎ជាត្រើយខាងនាយ ។

បាណាតិបាតោ ខោ ព្រាហ្មណ ឱរិមំ តីរំ បាណាតិបាតា វេរមណី បារិមំ តីរំ ។ អទិន្នាទានំ ឱរិមំ តីរំ អទិន្នាទានា វេរមណី បារិមំ តីរំ ។ កាមេសុ មិច្ឆាចារោ ឱរិមំ តីរំ កាមេសុ មិច្ឆាចារា វេរមណី បារិមំ តីរំ ។ មុសាវាទោ ឱរិមំ តីរំ មុសាវាទា វេរមណី បារិមំ តីរំ ។ បិសុណាវាចា ឱរិមំ តីរំ បិសុណាយ វាចាយ វេរមណី បារិមំ តីរំ ។ ផរុសវាចា ឱរិមំ តីរំ ផរុសាយ វាចាយ វេរមណី បារិមំ តីរំ ។ សម្ផប្បលាបោ ឱរិមំ តីរំ សម្ផប្បលាបា វេរមណី បារិមំ តីរំ ។ អភិជ្ឈា ឱរិមំ តីរំ អនភិជ្ឈា បារិមំ តីរំ ។ ព្យាបាទោ ឱរិមំ តីរំ អព្យាបាទោ បារិមំ តីរំ ។ មិច្ឆាទិដ្ឋិ ឱរិមំ តីរំ សម្មាទិដ្ឋិ បារិមំ តីរំ ឥទំ ខោ ព្រាហ្មណ ឱរិមំ តីរំ ឥទំ បារិមំ តីរន្តិ ។

ម្នាលព្រាហ្មណ៍ ការសម្លាប់សត្វ ជាត្រើយខាងអាយ កិរិយាវៀរចាក ការសម្លាប់សត្វ ជាត្រើយខាងនាយ ។ កិរិយាកាន់យកទ្រព្យដែលគេមិនបានឲ្យ ជាត្រើយខាងអាយ កិរិយាវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ជាត្រើយខាងនាយ ។ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាត្រើយខាងអាយ កិរិយាវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាត្រើយខាងនាយ ។ ការពោលពាក្យកុហក ជាត្រើយខាងអាយ កិរិយាវៀរចាកការពោលពាក្យកុហក ជាត្រើយខាងនាយ ។ សំដីញុះញង់ ជាត្រើយខាងអាយ កិរិយាវៀរចាកសំដីញុះញង់ ជាត្រើយខាងនាយ ។ សំដីអាក្រក់ ជាត្រើយខាងអាយ កិរិយាវៀរចាកសំដីអាក្រក់ ជាត្រើយខាងនាយ ។ សំដីពេយពាយឥតប្រយោជន៍ ជាត្រើយខាងអាយ កិរិយាវៀរចាកសំដីពេយពាយឥតប្រយោជន៍ ជាត្រើយខាងនាយ ។ ការសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ ជាត្រើយខាងអាយ ការមិនសំឡឹងរំពៃ ចំពោះទ្រព្យអ្នកដទៃ ជាត្រើយខាងនាយ ។ ការបង់ឲ្យគេវិនាស ជាត្រើយខាងអាយ ការមិនបង់ឲ្យគេវិនាស ជាត្រើយខាងនាយ ។ ការយល់ខុស ជាត្រើយខាងអាយ ការយល់ត្រូវ ជាត្រើយខាងនាយ ។ ម្នាលព្រាហ្មណ៍ នេះឯងជាត្រើយខាងអាយ នេះជាត្រើយខាងនាយ ។

អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា តីរមេវានុធាវតិ ។
យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។
កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ
តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។
យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ
អាទានប្បដិនិស្សគ្គេ អនុបាទាយ យេ រតា
ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតាតិ ។

ចតុត្ថបណ្ណាសក ជាណុស្សោណិវគ្គ

បណ្ដាមនុស្សទាំងឡាយ ពួកជនណា បានដល់នូវត្រើយ
ខាងនាយ ( ព្រះនិព្វាន ) ពួកជននោះ មានប្រមាណតិច
ឯសត្វក្រៅពីនេះ រមែងស្ទុះទៅកាន់ត្រើយគឺសក្កាយទិដ្ឋិ
(សត្វនេះច្រើនជាង) ។ ពួកជនណាប្រព្រឹត្តតាមនូវធម៌ ក្នុង
ធម៌ដែលតថាគតសំដែងហើយដោយប្រពៃ ពួកជននោះបាន
ឆ្លងនូវវដ្ដៈជាទីនៅនៃមច្ចុ ដែលសត្វឆ្លងបានដោយក្រៃក្រ
ពេក ទើបដល់នូវត្រើយខាងនាយគឺព្រះនិព្វាន ។ បណ្ឌិត
គប្បីលះបង់នូវធម៌ខ្មៅ ចំរើននូវធម៌ស ចេញចាកអាល័យ
អាស្រ័យនូវព្រះនិព្វានដែលមិនមានអាល័យ សេចក្ដីត្រេក-
អរបានដោយកម្រ ក្នុងវិវេកណា បណ្ឌិតអ្នកមិនមានសេចក្ដី
កង្វល់ លះបង់នូវកាមទាំងឡាយ ហើយប្រាថ្នានូវសេចក្ដី
ត្រេកអរក្នុងវិវេកនោះ បណ្ឌិតគប្បីធ្វើខ្លួនឲ្យផូរផង់ ចាកគ្រឿង
សៅហ្មងនៃចិត្តទាំងឡាយ ។ ចិត្តដែលពួកជនណាចំរើន
ល្អប្រពៃហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ
ពួកជនណា ត្រេកអរក្នុងការលះបង់សេចក្ដីប្រកាន់ ព្រោះ
មិនប្រកាន់ ពួកជនទាំងនោះ ឈ្មោះថា ជាខីណាស្រព
មានសេចក្ដី ( រុងរឿង ) បរិនិព្វានហើយ ក្នុងលោក ។

(៥៩) ឱរិមញ្ច ភិក្ខវេ តីរំ ទេសេស្សាមិ
បារិមញ្ច តីរំ តំ សុណាថ ។បេ។ កតមញ្ច ភិក្ខវេ
ឱរិមំ តីរំ កតមញ្ច បារិមំ តីរំ ។ បាណាតិបាតោ
ខោ ភិក្ខវេ ឱរិមំ តីរំ បាណាតិបាតា វេរមណី
បារិមំ តីរំ ។ អទិន្នាទានំ ឱរិមំ តីរំ អទិន្នាទានា
វេរមណី បារិមំ តីរំ ។ កាមេសុ មិច្ឆាចារោ ឱរិមំ តីរំ
កាមេសុ មិច្ឆាចារា វេរមណី បារិមំ តីរំ ។ មុសាវាទោ
រិមំ តីរំ មុសាវាទា វេរមណី បារិមំ តីរំ ។
បិសុណា វាចា ឱរិមំ តីរំ បិសុណាយ វាចាយ
វេរមណី បារិមំ តីរំ ។ ផរុសា វាចា ឱរិមំ តីរំ
ផរុសាយ វាចាយ វេរមណី បារិមំ តីរំ ។

(៥៩) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវត្រើយខាងអាយផង នូវត្រើយខាងនាយផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ត្រើយខាងអាយ តើដូចម្តេច ត្រើយខាងនាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការសម្លាប់សត្វ ជាត្រើយខាងអាយ កិរិយាវៀរចាកការសម្លាប់សត្វ ជាត្រើយខាងនាយ ។ ការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ជាត្រើយខាងអាយ កិរិយាវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ជាត្រើយខាងនាយ ។ ការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាត្រើយខាងអាយ កិរិយាវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាត្រើយខាងនាយ ។ ការពោលនូវពាក្យកុហក ជាត្រើយខាងអាយ កិរិយាវៀរចាកការពោលពាក្យកុហក ជាត្រើយខាងនាយ ។ សំដីញុះញង់ ជាត្រើយខាងអាយ កិរិយាវៀរចាកសំដីញុះញង់ ជាត្រើយខាងនាយ ។ សំដីអាក្រក់ ជាត្រើយខាងអាយ កិរិយាវៀរ ចាកសំដីអាក្រក់ ជាត្រើយខាងនាយ ។

ចតុត្ថបណ្ណាសកេ ជាណុស្សោណិវគ្គោ

សម្ផប្បលាបោ ឱរិមំ តីរំ សម្ផប្បលាបា វេរមណី
បារិមំ តីរំ ។ អភិជ្ឈា ឱរិមំ តីរំ អនភិជ្ឈា
បារិមំ តីរំ ។ ព្យាបាទោ ឱរិមំ តីរំ អព្យាបាទោ
បារិមំ តីរំ ។ មិច្ឆាទិដ្ឋិ ឱរិមំ តីរំ សម្មាទិដ្ឋិ
បារិមំ តីរំ ។ ឥទំ ខោ ភិក្ខវេ ឱរិមំ តីរំ ឥទំ
បារិមំ តីរន្តិ ។

អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា តីរមេវានុធាវតិ ។
យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។

ការពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ជាត្រើយខាងអាយ កិរិយាវៀរចាកការពោល នូវពាក្យឥតប្រយោជន៍ ជាត្រើយខាងនាយ ។ ការសំឡឹងរំពៃ ចំពោះទ្រព្យអ្នកដទៃ ជាត្រើយខាងអាយ ការមិនសំឡឹងរំពៃ ចំពោះទ្រព្យអ្នកដទៃ ជាត្រើយខាងនាយ ។ ការចង់ឲ្យគេវិនាស ជាត្រើយខាងអាយ ការមិនចង់ឲ្យគេវិនាស ជាត្រើយខាងនាយ ។ ការយល់ខុស ជាត្រើយខាងអាយ ការយល់ត្រូវ ជាត្រើយខាងនាយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងត្រើយខាងអាយ នេះត្រើយខាងនាយ ។

បណ្ដាមនុស្សទាំងឡាយ ពួកជនណា បានដល់នូវត្រើយ
ខាងនាយ (ព្រះនិព្វាន) ពួកជននោះ មានប្រមាណតិច
ឯសត្វក្រៅពីនេះ រមែងស្ទុះទៅកាន់ត្រើយ គឺសក្កាយទិដ្ឋិ
(សត្វនេះច្រើនជាង) ។ ពួកជនណា ប្រព្រឹត្តតាមធម៌ ក្នុងធម៌
ដែលតថាគត សំដែងហើយដោយប្រពៃ ពួកជននោះ
បានឆ្លងនូវវដ្ដៈជាទីនៅនៃមច្ចុ ដែលសត្វឆ្លងបាន ដោយក្រ
ក្រៃពេក ហើយដល់នូវត្រើយខាងនាយ គឺព្រះនិព្វាន ។

កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ
តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។
យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ
អាទានប្បដិនិស្សគ្គេ អនុបាទាយ យេ រតា
ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតាតិ ។

(៦០) អធម្មោ ច ភិក្ខវេ វេទិតព្វោ អនត្ថោ ច ធម្មោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា អនត្ថញ្ច ធម្មញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វំ ។

បណ្ឌិតគប្បីលះបង់នូវធម៌ខ្មៅ ចំរើននូវធម៌ស ហើយចេញចាកអាល័យ អាស្រ័យនូវព្រះនិព្វាន ដែលមិនមានអាល័យ សេចក្តីត្រេកអរ បានដោយកម្រ ក្នុងវិវេកណា បណ្ឌិតអ្នកមិនមានសេចក្តីកង្វល់ គប្បីលះបង់ នូវកាមទាំងឡាយ ប្រាថ្នានូវសេចក្តីត្រេកអរ ក្នុងវិវេកនោះ បណ្ឌិតគប្បីធ្វើខ្លួនឲ្យផូរផង់ ចាកគ្រឿងសៅហ្មងនៃចិត្តទាំងឡាយ ។ ចិត្តដែលពួកជនណា ចំរើនល្អប្រពៃហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ពួកជនណា ត្រេកអរ ក្នុងការលះបង់នូវសេចក្តីប្រកាន់ ព្រោះមិនប្រកាន់ ពួកជនទាំងនោះជាខីណាស្រព ឈ្មោះថា មានសេចក្តីរុងរឿង បរិនិព្វានហើយក្នុងលោក ។

(៦០) ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែន ជាធម៌ផង សភាវៈមិនមែន ជាប្រយោជន៍ផង ភិក្ខុគប្បីដឹង ធម៌ផង ប្រយោជន៍ផង ភិក្ខុគប្បីដឹង (ទាំងអស់) លុះបានដឹងនូវសភាវៈមិនមែនធម៌ និងសភាវៈមិនមែនប្រយោជន៍ បានដឹងនូវធម៌ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍ យ៉ាងណា ភិក្ខុគប្បីប្រតិបត្តិ យ៉ាងនោះចុះ ។

កតមោ ច ភិក្ខវេ អធម្មោ ច អនត្ថោ ច ។ បាណាតិបាតោ អទិន្នាទានំ កាមេសុមិច្ឆាចារោ មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ អភិជ្ឈា ព្យាបាទោ មិច្ឆាទិដ្ឋិ ។ អយំ វុច្ចតិ ភិក្ខវេ អធម្មោ ច អនត្ថោ ច ។ កតមោ ច ភិក្ខវេ ធម្មោ ច អត្ថោ ច ។ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុមិច្ឆាចារា វេរមណី មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អនភិជ្ឈា អព្យាបាទោ សម្មាទិដ្ឋិ ។ អយំ វុច្ចតិ ភិក្ខវេ ធម្មោ ច អត្ថោ ច ។ អធម្មោ ច ភិក្ខវេ វេទិតព្វោ អនត្ថោ ច

ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងសភាវៈមិនមែនប្រយោជន៍ តើដូចម្តេច ។ គឺការសម្លាប់សត្វ ការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ ការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ការពោលនូវពាក្យកុហក សំដីញុះញង់ សំដីអាក្រក់ ការពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ការសំឡឹងរំពៃ ចំពោះទ្រព្យអ្នកដទៃ ការចង់ឲ្យគេវិនាស ការយល់ខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សភាវៈមិនមែនធម៌ និងសភាវៈមិនមែនប្រយោជន៍ទេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌និងប្រយោជន៍ តើដូចម្តេច ។ កិរិយាវៀរចាកការសម្លាប់សត្វ កិរិយាវៀរចាកការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ កិរិយាវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ កិរិយាវៀរចាកការពោលនូវពាក្យកុហក កិរិយាវៀរចាកសំដីញុះញង់ កិរិយាវៀរចាកសំដីអាក្រក់ កិរិយាវៀរចាកការពោលពាក្យរោយរាយ ឥតប្រយោជន៍ មិនសំឡឹងរំពៃ ចំពោះទ្រព្យអ្នកដទៃ ការមិនចង់ឲ្យគេវិនាស ការយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះទើបហៅថា ធម៌និងប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ក្តី សភាវៈមិនមែនប្រយោជន៍ក្តី ភិក្ខុគប្បីដឹង ធម៌ក្តី ប្រយោជន៍ក្តី ភិក្ខុគប្បីដឹង ( ទាំងអស់ )

ធម្មោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា អនត្ថញ្ច ធម្មញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

(៦១) អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ តេសំ ភិក្ខូនំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ

លុះបានដឹង នូវសភាវៈមិនមែនជាធម៌ និងសភាវៈមិនមែនជាប្រយោជន៍ បានដឹង នូវធម៌និងប្រយោជន៍ហើយ ធម៌ យ៉ាងណា ប្រយោជន៍ យ៉ាងណា គប្បីប្រតិបត្តិ យ៉ាងនោះចុះ ពាក្យណា ដែលតថាគតពោលហើយដូច្នេះ ពាក្យនេះ តថាគតពោលហើយ ព្រោះអាស្រ័យនូវសេចក្តីនុ៎ះ ។

(៦១) ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ភិក្ខុគប្បីដឹង(ទាំងអស់) លុះបានដឹងនូវសភាវៈមិនមែនធម៌ និងធម៌ បានដឹងនូវសភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិតាម យ៉ាងនោះចុះ ។ ព្រះមានព្រះភាគទ្រង់បានត្រាស់ពាក្យនេះ លុះព្រះសុគតត្រាស់ពាក្យនេះរួចហើយ ក្រោកចាកអាសនៈចូលទៅកាន់វិហារ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន ភិក្ខុទាំងនោះមានសេចក្តីត្រិះរិះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សំដែងនូវឧទ្ទេសនេះឯង ដោយសង្ខេបពេក មិនទ្រង់ចែករំលែកនូវអត្ថ ដោយសេចក្តីពិស្តារ ដល់យើងទាំងឡាយសោះ ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា

អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ
ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច
អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ
តថា បដិបជ្ជិតព្វន្តិ ។ កោ នុ ខោ ឥមស្ស ភគវតា
សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្ត-
ស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ អថខោ តេសំ
ភិក្ខូនំ ឯតទហោសិ អយំ ខោ អាយស្មា មហា-
កច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ
សព្រហ្មចារីនំ បហោតិ អាយស្មា មហាកច្ចានោ
ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស
វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន
មយំ យេនាយស្មា មហាកច្ចានោ តេនុបសង្កមេ-
យ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯត-
មត្ថំ បុច្ឆេយ្យាម យថា នោ អាយស្មា មហា-
កច្ចានោ ព្យាករិស្សតិ តថា នំ ធារេស្សាមាតិ ។

ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងនូវសភាវៈមិនមែនធម៌ និងធម៌ បានដឹងនូវសភាវៈមិនមែនប្រយោជន៍ និងប្រយោជន៍ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិតាម យ៉ាងនោះចុះ ។ ភិក្ខុអង្គណាហ្ន៎ គប្បីចែករំលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយសង្ខេប មិនចែករំលែកនូវអត្ថដោយពិស្តារ ឲ្យពិស្តារបាន ។ គ្រានោះឯង ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈដ៏មានអាយុអង្គនេះ ព្រះសាស្តាទ្រង់សរសើរហើយ ទាំងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ មានតែព្រះមហាកច្ចានៈដ៏មានអាយុ ទើបអាចចែករំលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយសង្ខេប មិនបានចែករំលែកនូវអត្ថ ដោយពិស្តារ ឲ្យពិស្តារបាន បើដូច្នេះ គួរតែយើងទាំងអស់គ្នា ចូរទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសាកសួរនូវសេចក្តីនុ៎ះ នឹងព្រះមហាកច្ចានៈដ៏មានអាយុ ព្រះមហាកច្ចានៈដ៏មានអាយុ នឹងព្យាករ ដល់យើងទាំងឡាយ យ៉ាងណា យើងទាំងអស់គ្នា នឹងចាំទុកនូវរឿងនុ៎ះ យ៉ាងនោះ ។

អថខោ តេ ភិក្ខូ យេនាយស្មា មហាកច្ចានោ តេនុ-
បសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា មហាកច្ចានេន
សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារណីយំ
វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា
ខោ តេ ភិក្ខូ អាយស្មន្តំ មហាកច្ចានំ ឯតទវោចុំ ឥទំ
ខោ នោ អាវុសោ កច្ចាន ភគវា សង្ខិត្តេន ឧទ្ទេសំ
ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា
វិហារំ បវិដ្ឋោ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ
ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា
ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា
អត្ថោ តថា បដិបជ្ជិតព្វន្តិ ។ តេសំ នោ អាវុសោ
អម្ហាកំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ

លំដាប់នោះឯង ពួកភិក្ខុទាំងនោះចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរាក់ទាក់ ជាមួយនឹងព្រះមហាកច្ចានៈដ៏មានអាយុ លុះបញ្ចប់ពាក្យ ដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយ ក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយ ក្នុងទីសមគួរហើយ ក៏បានពោលទៅនឹងព្រះមហាកច្ចានៈដ៏មានអាយុដូច្នេះថា ម្នាលអាវុសោកច្ចានៈ ព្រះមានព្រះភាគទ្រង់សំដែងឡើងនូវឧទ្ទេសនេះឯង ដោយសង្ខេប មិនបានចែករំលែក នូវអត្ថដោយពិស្តារ ដល់យើងទាំងឡាយ ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ក្តី ធម៌ក្តី ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ក្តី ប្រយោជន៍ក្តី ភិក្ខុគប្បីដឹង (ទាំងអស់) លុះបានដឹង នូវសភាវៈមិនមែនធម៌ នឹងធម៌ បានដឹង នូវសភាវៈ មិនមែនប្រយោជន៍ នឹងប្រយោជន៍ហើយ ធម៌ យ៉ាងណា ប្រយោជន៍ យ៉ាងណា គប្បីប្រតិបត្តិតាម យ៉ាងនោះចុះ ។ ម្នាលអាវុសោ កាលព្រះមានព្រះភាគ ចៀសចេញទៅមិនយូរប៉ុន្មាន យើងទាំងអស់គ្នានោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា

ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ។ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ តេសំ នោ អាវុសោ អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ

ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សំដែងឡើងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប មិនចែករំលែកនូវអត្ថ ដោយសេចក្តីពិស្តារ ដល់យើងទាំងឡាយនោះ ក៏ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ ទាំងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ ទាំងប្រយោជន៍ ភិក្ខុគប្បីដឹង (ទាំងអស់) លុះបានដឹងនូវសភាវៈមិនមែនជាធម៌ទាំងធម៌ផង បានដឹងនូវសភាវៈមិនមែនជាប្រយោជន៍ ទាំងប្រយោជន៍ផងហើយ ធម៌ យ៉ាងណា ប្រយោជន៍ យ៉ាងណា គប្បីប្រតិបត្តិតាមយ៉ាងនោះចុះ ។ ភិក្ខុអង្គណាហ្ន៎ គប្បីចែករំលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងឡើងហើយ ដោយសង្ខេប មិនបានចែករំលែកនូវអត្ថ ដោយពិស្តារ ឲ្យពិស្តារបាន ។ ម្នាលអាវុសោ កាលពួកយើងទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈ ដ៏មានអាយុ អង្គនេះឯង ព្រះសាស្តាទ្រង់សរសើរហើយ ទាំងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ

អាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន
ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស
វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា
មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា
អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បុច្ឆេយ្យាម យថា
នោ អាយស្មា មហាកច្ចានោ ព្យាករិស្សតិ តថា នំ
ធារេស្សាមាតិ វិភជតាយស្មា មហាកច្ចានោតិ ។
សេយ្យថាបិ អាវុសោ បុរិសោ សារត្ថិកោ សារគវេសី
សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ
សារវតោ អតិក្កម្មេវ មូលំ អតិក្កម្ម ខន្ធំ
សាខាបលាសេ សារំ បរិយេសិតព្វំ មញ្ញេយ្យ
ឯវំ សម្បទមិទំ អាយស្មន្តានំ សត្ថរិ សម្មុខីភូតេ

មានតែព្រះមហាកច្ចានៈដ៏មានអាយុ ទើបអាចចែករលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងឡើងហើយ ដោយសង្ខេប មិនចែករលែក នូវអត្ថដោយពិស្តារ ឲ្យពិស្តារបាន បើដូច្នោះ គួរតែយើងទាំងអស់គ្នា ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ គប្បីសួរនូវសេចក្តីនុ៎ះ នឹងព្រះមហា-កច្ចានៈដ៏មានអាយុ ព្រះមហាកច្ចានៈដ៏មានអាយុ នឹងព្យាករ ដល់យើងទាំងឡាយ យ៉ាងណា យើងទាំងអស់គ្នា នឹងចាំនូវសេចក្តីនុ៎ះ យ៉ាងនោះ សូមព្រះមហាកច្ចានៈ ដ៏មានអាយុ ចែករលែក (នូវសេចក្តីនុ៎ះ) ។ ព្រះមហាកច្ចានៈតបថា ម្នាលអាវុសោទាំងឡាយ ដូចបុរសអ្នកត្រូវការ ដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមឋិតនៅ (ចំពោះមុខ) ក៏រំលងគល់ រំលងដើម ហើយសំគាល់ថា គួរស្វែងរកខ្លឹមត្រង់មែកនឹងស្នឹកទៅវិញ យ៉ាងណាមិញ សេចក្តីប្រៀបធៀប ក៏យ៉ាងនោះ កាលព្រះសាស្តា គង់នៅចំពោះមុខ នៃលោកដ៏មានអាយុទាំងឡាយ

តំ ភគវន្តំ អតិសិត្វា អម្ហេ ឯតមត្ថំ បដិបុច្ឆិតព្ពំ មញ្ញថ(១) ។ សោ ហិ អាវុសោ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ ។ សោ ចេវ បនេតស្ស កាលោ អហោសិ យំ តុម្ហេ ភគវន្តំយេវ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាថ យថា នោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាថាតិ ។ អទ្ធាវុសោ កច្ចាន ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ ។

---

១ ឱ. មញ្ញេថ ។ ម. មញ្ញេយ្យាថ ។

លោកទាំងឡាយ ក៏រំលងព្រះមានព្រះភាគអង្គនោះ ហើយមកសំគាល់នូវសេចក្តីដែលត្រូវសួរនុ៎ះនឹងយើងវិញ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីពិតថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ព្រះតថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ មានសភាពជាបុគ្គលប្រសើរ ជាអ្នកស្តីថា អ្នកប្រៀនប្រដៅ អ្នកចង្អុលបង្ហាញនូវប្រយោជន៍ អ្នកឲ្យនូវព្រះនិព្វាន ម្ចាស់ព្រោះធម៌ ។ អើ កាលនោះជាកាលសមគួរ ដល់ព្រះតថាគតអង្គនុ៎ះហើយ អ្នកទាំងឡាយ គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរនូវសេចក្តីនុ៎ះចុះ ព្រះមានព្រះភាគទ្រង់ព្យាករ ដល់យើងរាល់គ្នា យ៉ាងណា អ្នកទាំងឡាយ គប្បីចាំនូវសេចក្តីនុ៎ះ យ៉ាងនោះចុះ ។ ម្នាលកច្ចានៈដ៏មានអាយុ ព្រះមានព្រះភាគទ្រង់ជ្រាបនូវហេតុ ដែលគួរជ្រាប ទ្រង់ឃើញនូវហេតុ ដែលគួរឃើញតាមពិត ព្រះតថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ ជាបុគ្គលប្រសើរ ជាអ្នកស្តីថា អ្នកប្រៀនប្រដៅ អ្នកចង្អុលបង្ហាញនូវប្រយោជន៍ អ្នកឲ្យនូវព្រះនិព្វាន ម្ចាស់ព្រោះធម៌ ។ អើ

សោ ចេវ បនេតស្ស កាលោ អហោសិ យំ មយំ ភគវន្តំយេវ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាម យថា នោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាម ។ អបិចាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ អាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ វិភជតាយស្មា មហាកច្ចានោ អគរុកត្វាតិ(១) ។ តេនហាវុសោ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាកច្ចានស្ស បច្ចស្សោសុំ ។ អាយស្មា មហាកច្ចានោ ឯតទវោច យំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា

---

១ ឱ. អគរុករិត្វាតិ ។ ម. អគរុំករិត្វាតិ ។

កាលនោះ ជាកាលសមគួរ ដល់ព្រះតថាគតអត្ថនុ៎ះហើយ យើងទាំងឡាយ គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរនូវសេចក្តីនុ៎ះ ចុះ ព្រះមានព្រះភាគ ទ្រង់ព្យាករ ដល់យើងទាំងឡាយ យ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវសេចក្តីនុ៎ះ យ៉ាងនោះចុះ ៗ ចំណែកខាងព្រះមហាកច្ចានៈដ៏មានអាយុ ព្រះសាស្តា ទ្រង់សរសើរហើយទាំងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ មានតែព្រះមហាកច្ចានៈដ៏មានអាយុ ទើបអាចចែករលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រភាគ ទ្រង់សំដែងឡើងហើយដោយសង្ខេប មិនចែករលែក នូវអត្ថដោយពិស្តារ ឲ្យពិស្តារបាន សូមព្រះមហាកច្ចានៈដ៏មានអាយុ កុំបង្អែបង្អង់ឡើយ ចែករលែក (សេចក្តី) ទៅចុះ ៗ បើដូច្នោះ អ្នកទាំងឡាយ ចូរស្តាប់ ចូរធ្វើទុកក្នុងចិត្ត ឲ្យប្រពៃចុះ ខ្ញុំនឹងសំដែង ៗ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ នូវថេរវាចា របស់ព្រះមហាកច្ចានៈ ដ៏មានអាយុថា ករុណាអាវុសោ ៗ ព្រះមហាកច្ចានៈ ដ៏មានអាយុ ពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សំដែងឡើង នូវឧទ្ទេស ដោយសង្ខេប មិនបានចែករលែក នូវអត្ថ ដោយពិស្តារ ដល់យើងទាំងឡាយ

ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច ភិក្ខវេ
វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ
ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា
អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិ-
តព្វន្តិ ។ កតមោ ចាវុសោ អធម្មោ កតមោ ច
ធម្មោ កតមោ ច អនត្ថោ កតមោ ច អត្ថោ ។
បាណាតិបាតោ អាវុសោ អធម្មោ បាណាតិបាតា
វេរមណី ធម្មោ យេ ច បាណាតិបាតប្បច្ចយា អនេកេ
បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ
បាណាតិបាតា វេរមណីបច្ចយា ច អនេកេ កុសលា
ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ អទិន្នាទានំ
អាវុសោ អធម្មោ អទិន្នាទានា វេរមណី ធម្មោ

ក៏ស្រាប់តែ ក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌នឹងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ នឹងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងនូវសភាវៈមិនមែនធម៌ នឹងធម៌ បានដឹងនូវសភាវៈ មិនមែនប្រយោជន៍នឹងប្រយោជន៍ហើយ ធម៌ យ៉ាងណា ប្រយោជន៍ យ៉ាងណា គប្បីប្រតិបត្តិ យ៉ាងនោះចុះ ។ ម្នាលអាវុសោទាំងឡាយ ចុះសភាវៈ មិនមែនធម៌ តើដូចម្តេច ធម៌ តើដូចម្តេច សភាវៈមិនមែនប្រយោជន៍ តើដូចម្តេច ប្រយោជន៍ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ការសម្លាប់សត្វ មិនមែនធម៌ទេ កិរិយាវៀរចាកការសម្លាប់សត្វ ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន កើតឡើង ព្រោះបច្ច័យគឺការសម្លាប់សត្វនេះ ជាសភាវៈមិនមែនប្រយោជន៍ទេ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយភាវនា ព្រោះបច្ច័យគឺកិរិយាវៀរចាកការសម្លាប់សត្វ នេះទើបជាប្រយោជន៍ ។ ការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ មិនមែនជាធម៌ កិរិយាវៀរចាកការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ

យេ ច អទិន្នាទានប្បច្ចយា អនេកេ បាបកា
អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ អទិន្នាទានា
វេរមណីបច្ចយា ច អនេកេ កុសលា ធម្មា ភាវនា-
បារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ កាមេសុ មិច្ឆាចារោ
ភិក្ខវេ អធម្មោ កាមេសុ មិច្ឆាចារា វេរមណី
ធម្មោ យេ ច កាមេសុ មិច្ឆាចារប្បច្ចយា អនេកេ
បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ ។
កាមេសុ មិច្ឆាចារា វេរមណីបច្ចយា ច អនេកេ
កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ
អត្ថោ ។ មុសាវាទោ ភិក្ខវេ អធម្មោ មុសាវាទា
វេរមណី ធម្មោ យេ ច មុសាវាទប្បច្ចយា អនេកេ
បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ

ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសល ដ៏លាមកច្រើន រមែងកើតឡើងព្រម ព្រោះបច្ច័យគឺការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ នេះមិនមែនប្រយោជន៍ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ ដោយភាវនា ព្រោះបច្ច័យគឺកិរិយាវៀរចាកការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ មិនមែនជាធម៌ទេ កិរិយាវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាធម៌ ធម៌ទាំងឡាយណា ជាអកុសល ដ៏លាមកច្រើន រមែងកើតឡើងព្រម ព្រោះបច្ច័យគឺការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ នេះមិនមែនជាប្រយោជន៍ ។ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ ដោយភាវនា ព្រោះបច្ច័យគឺកិរិយាវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ នេះទើបជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ការពោលនូវពាក្យកុហក មិនមែនជាធម៌ កិរិយាវៀរចាកការពោលនូវពាក្យកុហក ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសល ដ៏លាមកច្រើន រមែងកើតឡើងព្រម ព្រោះបច្ច័យ គឺការពោលនូវពាក្យកុហក នេះមិនមែនជាប្រយោជន៍ទេ

មុសាវាទា វេរមណីបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ បិសុណាវាចា អធម្មោ បិសុណាយ វាចាយ វេរមណី ធម្មោ យេ ច បិសុណាវាចាបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ បិសុណាយ វាចាយ វេរមណីបច្ចយា អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ ផរុសា វាចា អធម្មោ ផរុសាយ វាចាយ វេរមណី ធម្មោ យេ ច ផរុសវាចាបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ ផរុសាយ វាចាយ វេរមណីបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ សម្ផប្បលាបោ អធម្មោ សម្ផប្បលាបា វេរមណី ធម្មោ យេ ច សម្ផប្បលាបបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ

ធម៌ទាំងឡាយជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ដោយការនាព្រោះ បច្ច័យគឺកិរិយាវៀរចាកការពោល នូវពាក្យកុហក នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ សំដីញុះញង់ មិនមែនជាធម៌ កិរិយា វៀរចាកសំដីញុះញង់ ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសល ដ៏លាមកច្រើន រមែងកើតឡើងព្រម ព្រោះបច្ច័យ គឺ សំដីញុះញង់ នេះមិនមែនជាប្រយោជន៍ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវ ការបរិបូណ៌ ដោយការនា ព្រោះបច្ច័យគឺកិរិយាវៀរចាកសំដីញុះញង់ នេះទើបជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ សំដីអាក្រក់ មិនមែនជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសល ដ៏លាមកច្រើន កើតឡើងព្រម ព្រោះបច្ច័យគឺសំដីអាក្រក់ នេះមិនមែនជាប្រយោជន៍ទេ ធម៌ទាំងឡាយ ជាកុសលច្រើន តែងដល់នូវការបរិបូណ៌ ដោយការនា ព្រោះបច្ច័យគឺកិរិយាវៀរចាកសំដីអាក្រក់ នេះជាប្រយោជន៍ ។ ម្នាល អាវុសោទាំងឡាយ ការពោលពាក្យរោយរាយ ឥតប្រយោជន៍ មិន មែនជាធម៌ កិរិយាវៀរចាកការពោលពាក្យរោយរាយ ឥតប្រយោជន៍ ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសល ដ៏លាមកច្រើន តែងកើត ឡើងព្រម ព្រោះបច្ច័យគឺការពោលពាក្យរោយរាយ ឥតប្រយោជន៍

អយំ អនត្ថោ សម្ផប្បលាបា វេរមណីបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ អភិជ្ឈា អាវុសោ អធម្មោ អនភិជ្ឈា ធម្មោ យេ ច អភិជ្ឈាបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ អនភិជ្ឈាបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ ព្យាបាទោ អាវុសោ អធម្មោ អព្យាបាទោ ធម្មោ យេ ច ព្យាបាទបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ អព្យាបាទបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។

នេះមិនមែនជាប្រយោជន៍ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ ដោយការនោ ព្រោះបច្ច័យគឺកិរិយាវៀរចាកការពោលពាក្យរោយរាយ ឥតប្រយោជន៍ នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ការសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ មិនមែនជាធម៌ ការមិនសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន តែងកើតឡើងព្រម ព្រោះបច្ច័យគឺការសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ នេះមិនមែនជាប្រយោជន៍ ធម៌ទាំងឡាយជាកុសលច្រើន តែងដល់នូវការបរិបូណ៌ ដោយការនោ ព្រោះបច្ច័យគឺការមិនសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ការចង់ឲ្យគេវិនាស មិនមែន ជាធម៌ ការមិនចង់ឲ្យគេវិនាស ជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសល ដ៏លាមកច្រើន រមែងកើតឡើងព្រម ព្រោះបច្ច័យគឺការចង់ឲ្យគេវិនាស នេះមិនមែនជាប្រយោជន៍ទេ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ ដោយការនោ ព្រោះបច្ច័យគឺការមិនចង់ឲ្យគេវិនាស នេះទើបជាប្រយោជន៍ ។

មិច្ឆាទិដ្ឋិ អាវុសោ អធម្មោ សម្មាទិដ្ឋិ ធម្មោ យេ ច មិច្ឆាទិដ្ឋិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាទិដ្ឋិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរិំ គច្ឆន្តិ អយំ អត្ថោ ។ យំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ឥមស្ស ខោ អហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភជិត្វា ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។

ម្នាលអាវុសោទាំងឡាយ ការយល់ខុស មិនមែនជាធម៌ ការយល់ត្រូវជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសល ដ៏លាមកច្រើន កើតឡើងព្រម ព្រោះបច្ច័យគឺការយល់ខុស នេះមិនមែនជាប្រយោជន៍ ធម៌ទាំងឡាយជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ ដោយភាវនា ព្រោះបច្ច័យ គឺ ការយល់ត្រូវ នេះជាប្រយោជន៍ ។ ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សំដែងនូវឧទ្ទេសណា ដោយសង្ខេប មិនចែកវែកនូវអត្ថ (នៃឧទ្ទេសនុ៎ះ) ដោយពិស្តារ ដល់យើងទាំងឡាយ ក៏ស្រាប់តែ ក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ ទឹងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ ទឹងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងសភាវៈមិនមែនជាធម៌ ទឹងធម៌ បានដឹងនូវសភាវៈ មិនមែនជាប្រយោជន៍ ទឹងប្រយោជន៍ហើយ ធម៌ យ៉ាងណា ប្រយោជន៍ យ៉ាងណា គប្បីប្រតិបត្តិយ៉ាងនោះចុះ ម្នាលអាវុសោទាំងឡាយ ចំណែកខាងខ្ញុំ តែងដឹងនូវអត្ថនៃឧទ្ទេសនេះឯង ដែលព្រះមានព្រះភាគទ្រង់សំដែងឡើង ដោយសង្ខេប មិនចែកវែកនូវអត្ថ ដោយពិស្តារ ឲ្យពិស្តារបានយ៉ាងនេះ ។

អាកង្ខមានា ច បន តុម្ហេ អាវុសោ ភគវន្តំយេវ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាថ យថា នោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាថាតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាកច្ចានស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យំ ខោ នោ ភន្តេ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ។

ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ កាលបើប្រាថ្នា ត្រូវតែចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរសេចក្តីនុ៎ះ ព្រះមានព្រះភាគព្យាករ ដល់យើងទាំងឡាយ យ៉ាងណា អ្នកទាំងឡាយ ត្រូវចាំទុកនូវសេចក្តីនុ៎ះ យ៉ាងនោះចុះ ។ ពួកភិក្ខុទាំងនោះ ត្រេកអរអនុមោទនា ចំពោះភាសិតរបស់ព្រះមហាកច្ចានៈ ដ៏មានអាយុថា ករុណាអាវុសោ ហើយក៏ក្រោកចាកអាសនៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ ។ ភិក្ខុទាំងនោះ លុះអង្គុយ ក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់សំដែងនូវឧទ្ទេសណា ដោយសង្ខេប មិនបែកវែកនូវអត្ថ (នៃឧទ្ទេសនុ៎ះ) ដោយពិស្តារ ក៏ស្រាប់តែក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ ទឹងធម៌ ភិក្ខុគប្បីដឹង សភាវៈ មិនមែនប្រយោជន៍ ទឹងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងសភាវៈមិនមែនធម៌ ទឹងធម៌ បានដឹងសភាវៈ មិនមែនប្រយោជន៍ ទឹងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍ យ៉ាងណា គប្បីប្រតិបត្តិ យ៉ាងនោះចុះ ។

## ចតុត្ថបណ្ណាសកេ ជាណុស្សោណិវគ្គោ

តេសំ នោ ភន្តេ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ
ឯតទហោសិ ឥមំ ខោ នោ អាវុសោ ភគវា
សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ
អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ អធម្មោ ច
ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ
អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច
វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា
បដិបជ្ជិតព្វន្តិ ។ កោ នុ ខោ ឥមស្ស ភគវតា
សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ វិភជេ-
យ្យាតិ ។ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ
អយំ ខោ អាយស្មា មហាកច្ចានោ សត្ថុ ចេវ
សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ

ចតុត្ថបណ្ណាសក ជាណុស្សោណិវគ្គ

បពិត្រព្រះអង្គដ៏ចំរើន កាលព្រះមានព្រះភាគ ទ្រង់ចេញទៅ មិនយូរប៉ុន្មាន យើងខ្ញុំទាំងឡាយនោះ មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សំដែងនូវឧទ្ទេសនេះឯងដោយសង្ខេប មិនបានចែកវែក នូវអត្ថដោយពិស្តារ ដល់យើងទាំងឡាយ ក៏ស្រាប់តែ ក្រោកចាកអាសនៈ ហើយយាងចូលទៅកាន់វិហារថា ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍និងប្រយោជន៍ ភិក្ខុគប្បីដឹង លុះបានដឹងសភាវៈមិនមែនធម៌ និងធម៌ បានដឹងសភាវៈមិនមែនប្រយោជន៍និងប្រយោជន៍ហើយ ធម៌ យ៉ាងណា ប្រយោជន៍ យ៉ាងណា គប្បីប្រតិបត្តិយ៉ាងនោះចុះ ៗ ភិក្ខុអង្គណា ហ្ន៎ គប្បីចែកវែក នូវអត្ថនៃឧទ្ទេសនេះដែលព្រះមានព្រះភាគ ទ្រង់សំដែងឡើងដោយសង្ខេប ឲ្យពិស្តារបាន ៗ បពិត្រព្រះអង្គដ៏ចំរើន យើងទាំងនោះ មានសេចក្តីត្រិះរិះ ដូច្នេះថា ព្រះមហាកច្ចានៈ ដ៏មានអាយុនេះឯង ព្រះសាស្តា ទ្រង់សរសើរហើយ ទាំងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញ ក៏សរសើរហើយដែរ

សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស ទសកនិបាតោ

អាយស្មា មហាកច្ចានោ ឥមស្ស ភគវតា
សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ
អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ
យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧប-
សង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បុច្ឆេ-
យ្យាម យថា នោ អាយស្មា មហាកច្ចានោ ព្យាក-
រិស្សតិ តថា នំ ធារេស្សាមាតិ ។ អថខោ មយំ
ភន្តេ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិម្ហា
ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ
បុច្ឆិម្ហា ។ តេសំ នោ ភន្តេ អាយស្មតា មហា-
កច្ចានេន ឥមេហិ អាការេហិ ឥមេហិ បទេហិ ឥមេហិ
ព្យញ្ជនេហិ អត្ថោ សុវិភត្តោតិ ។ សាធុ សាធុ
ភិក្ខវេ បណ្ឌិតោ ភិក្ខវេ មហាកច្ចានោ មហាបញ្ញោ

មានតែព្រះមហាកច្ចានៈដ៏មានអាយុ ទើបអាចចែកលែក នូវអត្ថនៃឧទ្ទេសនេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងឡើង ដោយសង្ខេប មិនបានចែកលែកនូវអត្ថ ដោយពិស្តារឲ្យពិស្តារបាន បើដូច្នោះ គួរតែយើងទាំងឡាយ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយគប្បីសួរនូវសេចក្ដីនុ៎ះ នឹងព្រះមហាកច្ចានៈដ៏មានអាយុ ព្រះមហា-កច្ចានៈដ៏មានអាយុ នឹងព្យាករ ដល់យើងទាំងឡាយ យ៉ាងណា យើងទាំងឡាយ នឹងចាំទុក នូវសេចក្ដីនោះ យ៉ាងនោះ ។ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ យើងទាំងឡាយ ក៏ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានសួរនូវសេចក្ដីនុ៎ះ នឹងព្រះមហាកច្ចានៈ ដ៏មានអាយុ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមហា-កច្ចានៈដ៏មានអាយុ បានចែកលែក សេចក្ដីស្រួលបួល ដោយអាការទាំងឡាយនេះ ដោយបទទាំងឡាយនេះ ដោយព្យញ្ជនៈទាំងឡាយនេះ ដល់យើងទាំងឡាយនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រពៃហើយ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ ជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ ជាអ្នកមានប្រាជ្ញាច្រើន

ភិក្ខវេ មហាកច្ចានោ មំ ចេបិ តុម្ហេ ភិក្ខវេ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាថ អហម្បិ ចេតំ ឯវមេវ ព្យាករេយ្យំ យថា តំ មហាកច្ចានេន ព្យាកតំ ឯសោ ចេវ តស្ស អត្ថោ ឯវញ្ច នំ ធារេយ្យាថាតិ ។

(៦២) អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ។ កតមោ ច ភិក្ខវេ អធម្មោ កតមោ ច ធម្មោ កតមោ ច អនត្ថោ កតមោ ច អត្ថោ ។ បាណាតិបាតោ ភិក្ខវេ អធម្មោ បាណាតិ-បាតា វេរមណី ធម្មោ យេ ច បាណាតិបាតប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ អ្នកទាំងឡាយ ចូលមករកតថាគត ហើយសួរនូវសេចក្តីនុ៎ះ តថាគត ក៏ព្យាករនូវសេចក្តីនុ៎ះដូចសេចក្តី ដែលមហា-កច្ចានៈ បានព្យាករហើយ យ៉ាងនោះដែរ សេចក្តីនោះឯងនៃឧទ្ទេសនោះ អ្នកទាំងឡាយ គប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនេះចុះ ។

[៦២] ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ ទាំងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនប្រយោជន៍ ទាំងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹង នូវសភាវៈមិនមែនធម៌ ទាំងធម៌ បានដឹងសភាវៈមិនមែនប្រយោជន៍ ទាំងប្រយោជន៍ហើយ ធម៌ យ៉ាងណា ប្រយោជន៍ យ៉ាងណា គប្បីប្រតិបត្តិ យ៉ាងនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនធម៌ តើដូចម្តេច ធម៌ តើដូចម្តេច សភាវៈមិនមែនប្រយោជន៍ តើដូចម្តេច ប្រយោជន៍ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការសម្លាប់សត្វមិនមែនធម៌ទេ កិរិយាវៀរចាកការសម្លាប់សត្វជាធម៌ ឯធម៌ទាំងឡាយណា ជាអកុសល ដ៏លាមកច្រើន កើតឡើងព្រម ព្រោះបច្ច័យគឺការសម្លាប់សត្វ នេះមិនមែនប្រយោជន៍ទេ

បាណាតិបាតា វេរមណីបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ អទិន្នាទានំ ភិក្ខវេ អធម្មោ អទិន្នាទានា វេរមណី ធម្មោ... កាមេសុ មិច្ឆាចារោ ភិក្ខវេ អធម្មោ កាមេសុ មិច្ឆាចារា វេរមណី ធម្មោ... មុសាវាទោ ភិក្ខវេ អធម្មោ មុសាវាទា វេរមណី ធម្មោ... បិសុណា វាចា ភិក្ខវេ អធម្មោ បិសុណាយ វាចាយ វេរមណី ធម្មោ... ផរុសាវាចា ភិក្ខវេ អធម្មោ ផរុសាយ វាចាយ វេរមណី ធម្មោ... សម្ផប្បលាបោ ភិក្ខវេ អធម្មោ សម្ផប្បលាបា វេរមណី ធម្មោ...

ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ ដោយការនា ព្រោះបច្ច័យគឺកិរិយាវៀរចាកការសម្លាប់សត្វ នេះទើបជាប្រយោជន៍ ។

ម្នាលភិក្ខុទាំងឡាយ ការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ មិនមែនជាធម៌ទេ កិរិយាវៀរចាកការកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ ជាធម៌... ម្នាលភិក្ខុទាំងឡាយ ការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ មិនមែនជាធម៌ទេ កិរិយាវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ ការពោលនូវពាក្យកុហក មិនមែនជាធម៌ទេ កិរិយាវៀរចាកការពោលនូវពាក្យកុហក ជាធម៌... ម្នាលភិក្ខុទាំងឡាយ សំដីញុះញង់គេ មិនមែនជាធម៌ទេ កិរិយាវៀរចាក សំដីញុះញង់គេ ជាធម៌ ... ម្នាលភិក្ខុទាំងឡាយ សំដីអាក្រក់ មិនមែនជាធម៌ទេ ការវៀរចាកសំដីអាក្រក់ ជាធម៌... ម្នាលភិក្ខុទាំងឡាយ សំដីរោយរាយ ឥតប្រយោជន៍ មិនមែនជាធម៌ទេ កិរិយាវៀរចាកសំដីរោយរាយ ឥតប្រយោជន៍ ជាធម៌...

អភិជ្ឈា ភិក្ខវេ អធម្មោ អនភិជ្ឈា ធម្មោ ... ព្យាបាទោ ភិក្ខវេ អធម្មោ អព្យាបាទោ ធម្មោ ... មិច្ឆាទិដ្ឋិ ភិក្ខវេ អធម្មោ សម្មាទិដ្ឋិ ធម្មោ យេ ច មិច្ឆា-ទិដ្ឋិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ អយំ អនត្ថោ សម្មាទិដ្ឋិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ អយំ អត្ថោ ។ អធម្មោ ច ភិក្ខវេ វេទិតព្វោ ធម្មោ ច អនត្ថោ ច វេទិតព្វោ អត្ថោ ច អធម្មញ្ច វិទិត្វា ធម្មញ្ច អនត្ថញ្ច វិទិត្វា អត្ថញ្ច យថា ធម្មោ យថា អត្ថោ តថា បដិបជ្ជិតព្វន្តិ ឥតិ យំ តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

ម្នាលភិក្ខុទាំងឡាយ ការសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ មិនមែនជាធម៌ទេ ការមិនសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ ជាធម៌... ម្នាលភិក្ខុទាំងឡាយ ការចង់ឲ្យគេវិនាស មិនមែនជាធម៌ទេ ការមិនចង់ឲ្យគេវិនាស ជាធម៌... ម្នាលភិក្ខុទាំងឡាយ ការយល់ខុស មិនមែនជាធម៌ទេ ការយល់ត្រូវ ជាធម៌ ធម៌ទាំងឡាយណា ជាអកុសលដ៏លាមកច្រើន តែងកើតឡើងព្រម ព្រោះបច្ច័យគឺការយល់ខុស នេះមិនមែនជាប្រយោជន៍ទេ ធម៌ទាំងឡាយ ជាកុសលច្រើន រមែងដល់នូវការបរិបូណ៌ ដោយការនាំព្រោះបច្ច័យគឺការយល់ត្រូវ នេះជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈមិនមែនជាធម៌ និងធម៌ ភិក្ខុគប្បីដឹង សភាវៈមិនមែនជាប្រយោជន៍ និងប្រយោជន៍ ក៏ភិក្ខុគប្បីដឹង លុះបានដឹងសភាវៈមិនមែនជាធម៌ និងធម៌ ដឹងនូវសភាវៈមិនមែនជាប្រយោជន៍ និងប្រយោជន៍ហើយ ធម៌យ៉ាងណា ប្រយោជន៍យ៉ាងណា គប្បីប្រតិបត្តិ យ៉ាងនោះចុះ ពាក្យណា ដែលតថាគត ពោលហើយដូច្នេះ ពាក្យនុ៎ះ តថាគត បានពោលហើយ ព្រោះអាស្រ័យ នូវសេចក្តីនេះ ។

(៦៣) បាណាតិបាតម្បាហំ(១) ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។ អទិន្នាទានម្បាហំ ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។ កាមេសុ មិច្ឆាចារម្បាហំ ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។ មុសាវាទម្បាហំ ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។ បិសុណវាចម្បាហំ ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។ ផរុសវាចម្បាហំ ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។ សម្ផប្បលាបម្បាហំ ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។

---

១ ឱ. បាណាតបាតម្បហំ ។ ម. បាណាតិបាតំបាហំ ។

[៦៣] ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បាណាតិបាត មាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អទិន្នាទាន មាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា កាមេសុមិច្ឆាចារមាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈ ជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា មុសាវាទមាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បិសុណាវាចា មាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ផរុសវាចា មាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សម្ផប្បលាបមាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។

អភិជ្ឈំបហំ ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។ ព្យាបាទំបហំ ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។ មិច្ឆាទិដ្ឋឹបហំ ភិក្ខវេ តិវិធំ វទាមិ លោភហេតុកម្បិ ទោសហេតុកម្បិ មោហហេតុកម្បិ ។ ឥតិ ខោ ភិក្ខវេ លោភោ កម្មនិទានសម្ភវោ ទោសោ កម្មនិទានសម្ភវោ មោហោ កម្មនិទានសម្ភវោ លោភក្ខយា កម្មនិទានសង្ខយោ ទោសក្ខយា កម្មនិទានសង្ខយោ មោហក្ខយា កម្មនិទានសង្ខយោតិ ។

(៦៤) សបរិក្កមនោ អយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ អបរិក្កមនោ ។ កថញ្ច ភិក្ខវេ សបរិក្កមនោ អយំ ធម្មោ នាយំ ធម្មោ អបរិក្កមនោ ។

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អភិជ្ឈាមាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ព្យាបាទមាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា មិច្ឆាទិដ្ឋិមាន ៣ ប្រការ គឺ មានលោភៈជាហេតុ ១ មានទោសៈជាហេតុ ១ មានមោហៈជាហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរដូច្នេះឯង លោភៈឈ្មោះថាជាហេតុ ជាដែនកើតនៃកម្ម ទោសៈឈ្មោះថាជាហេតុ ជាដែនកើតនៃកម្ម មោហៈឈ្មោះថាជាហេតុ ជាដែនកើតនៃកម្ម ព្រោះអស់លោភៈ ទើបអស់ហេតុនៃកម្ម ព្រោះអស់ទោសៈ ទើបអស់ហេតុនៃកម្ម ព្រោះអស់មោហៈ ទើបអស់ហេតុនៃកម្ម ។

(៦៤) ម្នាលភិក្ខុទាំងឡាយ ធម៌នេះ ប្រកបដោយការប្រែត្រឡប់ ធម៌នេះ មិនមែនជាមិនមានការប្រែត្រឡប់ទេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌នេះ ប្រកបដោយការប្រែត្រឡប់ ធម៌នេះមិនមែនជាមិនមានការប្រែត្រឡប់ តើដោយអធិប្បាយដូចម្តេច ។

បាណាតិបាតស្ស ភិក្ខវេ បាណាតិបាតា វេរមណី បរិក្កមនំ ហោតិ អទិន្នាទានស្ស ភិក្ខវេ អទិន្នាទានា វេរមណី បរិក្កមនំ ហោតិ កាមេសុមិច្ឆាចារស្ស ភិក្ខវេ កាមេសុមិច្ឆាចារា វេរមណី បរិក្កមនំ ហោតិ មុសាវាទស្ស ភិក្ខវេ មុសាវាទា វេរមណី បរិក្កមនំ ហោតិ បិសុណាវាចស្ស ភិក្ខវេ បិសុណាយ វាចាយ វេរមណី បរិក្កមនំ ហោតិ ផរុសវាចស្ស ភិក្ខវេ ផរុសាយ វាចាយ វេរមណី បរិក្កមនំ ហោតិ សម្ផប្បលាបស្ស ភិក្ខវេ សម្ផប្បលាបា វេរមណី បរិក្កមនំ ហោតិ អភិជ្ឈាលុស្ស ភិក្ខវេ អនភិជ្ឈា បរិក្កមនំ ហោតិ ព្យាបន្នស្ស ភិក្ខវេ អព្យាបាទោ បរិក្កមនំ ហោតិ មិច្ឆាទិដ្ឋិកស្ស ភិក្ខវេ សម្មាទិដ្ឋិ បរិក្កមនំ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកសម្លាប់សត្វ វៀរចាកការសម្លាប់សត្វវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកលួចទ្រព្យគេ វៀរចាកការលួចទ្រព្យគេវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តខុស ក្នុងកាម វៀរចាកការប្រព្រឹត្តខុស ក្នុងកាមវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលពាក្យកុហក វៀរចាកការពោលពាក្យកុហកវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលពាក្យញុះញង់ វៀរចាកការពោលពាក្យញុះញង់វិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យអាក្រក់វិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកពោលពាក្យឥតប្រយោជន៍ វៀរចាកការពោលពាក្យឥតប្រយោជន៍វិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានអភិជ្ឈា មិនមានអភិជ្ឈាវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានព្យាបាទ មិនមានព្យាបាទវិញ ឈ្មោះថា ការប្រែត្រឡប់ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកយល់ខុស មានការយល់ត្រូវវិញ ឈ្មោះថា ការប្រែត្រឡប់ ។

ឯវំ ខោ ភិក្ខវេ បរក្កមំ ហោតិ ។ ឯវំ ខោ ភិក្ខវេ សបរក្កមោ នាយំ ធម្មោ អបរក្កមោតិ ។

(៦៨) ឯកំ សមយំ ភគវា បាវាយំ វិហរតិ ចុន្ទស្ស កម្មារបុត្តស្ស អម្ពវនេ ។ អថខោ ចុន្ទោ កម្មារបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចុន្ទំ កម្មារបុត្តំ ភគវា ឯតទវោច កស្ស នោ ត្វំ ចុន្ទ សោចេយ្យានិ រោចេសីតិ ។ ព្រាហ្មណា ភន្តេ បច្ឆាភូមកា កមណ្ឌលុកា សេវាលមាលកា អគ្គិបរិចារិកា ឧទកោរោហកា សោចេយ្យានិ បញ្ញាបេន្តិ តេសាហំ សោចេយ្យានិ រោចេមីតិ ។

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា ការប្រែត្រឡប់ ។ ម្នាលភិក្ខុទាំងឡាយ ធម៌នេះ ដែលប្រកបដោយការប្រែត្រឡប់ មិនមែនជាមិនមានការប្រែត្រឡប់ យ៉ាងនេះឯង ។

[ ៦៩ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងអម្ពវន (ព្រៃស្វាយ) របស់កម្មារបុត្រឈ្មោះចុន្ទ ជិតក្រុងបាវា ។ គ្រានោះ ចុន្ទកម្មារបុត្រ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះចុន្ទកម្មារបុត្រ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលចុន្ទ អ្នកពេញចិត្តនឹងការស្អាត របស់អ្នកណា ។ ចុន្ទកម្មារបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រាហ្មណ៍ទាំងឡាយដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់ល័ក្កចាន់(១) ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច តែងបញ្ញត្តនូវការស្អាត ខ្ញុំព្រះអង្គពេញចិត្តចំពោះការស្អាត របស់ព្រាហ្មណ៍ទាំងនោះ ។

---

១ ប្រដាប់សម្រាប់ដាក់ទឹកក្នុងវេលាដើរផ្លូវ គឺក្អម, កំសៀវ, បំពង់, កុណ្ឌី, ទីកោ ។

យថាកថំ បន ចុន្ទ ព្រាហ្មណា បច្ឆាភូមកា កមណ្ឌលុកា សេវាលមាលកា អគ្គិបរិចារិកា ឧទកោរោហកា សោចេយ្យានិ បញ្ញាបេន្តីតិ ។ ឥធ ភន្តេ ព្រាហ្មណា បច្ឆាភូមកា កមណ្ឌលុកា សេវាលមាលកា អគ្គិបរិចារិកា ឧទកោរោហកា តេ សាវកេ(១) ឯវំ សមាទបេន្តិ ឯហិ ត្វំ អម្ភោ បុរិស កាលស្សេវ(២) ឧដ្ឋហន្តោ សយនម្ហា បថវឹ អាមសេយ្យាសិ នោ ចេ បថវឹ អាមសេយ្យាសិ អល្លគោមយានិ(៣) អាមសេយ្យាសិ នោ ចេ អល្លគោមយានិ អាមសេយ្យាសិ ហរិតានិ តិណានិ អាមសេយ្យាសិ នោ ចេ ហរិតានិ អាមសេយ្យាសិ អគ្គឹ បរិចរេយ្យាសិ នោ ចេ អគ្គឹ បរិចរេយ្យាសិ បញ្ជលិកោ អាទិច្ចំ នមស្សេយ្យាសិ នោ ចេ បញ្ជលិកោ អាទិច្ចំ នមស្សេយ្យាសិ សាយតតិយកំ ឧទកំ ឱរោហេយ្យាសីតិ(៤) ។

---

១ ឱ. សាវកម្ហេ ។ ២ ឱ.ម. កាលស្សេវ វុដ្ឋហន្តោ វ ។ ៣ ឱ. អល្លានិ គោមយានិ ។
៤ ម. ឱរោហេយ្យាសីតិ ។

ម្នាលចុន្ទ ចុះពួកព្រាហ្មណ៍ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់ល័ក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច តែងបញ្ញត្តនូវការស្អាត យ៉ាងណាខ្លះ ៗ បពិត្រព្រះអង្គដ៏ចំរើន ក្នុងលោកនេះ ពួកព្រាហ្មណ៍ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់ល័ក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច ព្រាហ្មណ៍ទាំងនោះ តែងបបួលពួកសាវ័កថា នែបុរសអើយ អ្នកចូរមកអាយ កាលបើអ្នកក្រោកអំពីដំណេក ក្នុងវេលាព្រឹកព្រហាមហើយ គប្បីស្ទាបផែនដី បើអ្នកមិនស្ទាបផែនដីទេ គប្បីស្ទាបអាចម៍គោស្រស់ បើអ្នកមិនស្ទាបអាចម៍គោស្រស់ទេ គប្បីស្ទាបស្មៅស្រស់ បើអ្នកមិនស្ទាបស្មៅស្រស់ទេ គប្បីបម្រើភ្លើង បើអ្នកមិនបម្រើភ្លើងទេ គប្បីប្រណម្យអញ្ជលី នមស្ការព្រះអាទិត្យ បើអ្នកមិនប្រណម្យអញ្ជលី នមស្ការព្រះអាទិត្យទេ គប្បីចុះត្រាំទឹកជាគំរប់ ៣ ដង ទាំងពេលល្ងាច ។

ឯវំ ខោ ភន្តេ ព្រាហ្មណា បច្ឆាភូមកា កាមណ្ឌលុកា
សេវាលមាលិកា អគ្គិបរិចារិកា ឧទកោរោហកា
សោចេយ្យានិ បញ្ញាបេន្តិ តេសាហំ សោចេយ្យានិ
រោចេមីតិ ។ អញ្ញថា ខោ ចុន្ទ ព្រាហ្មណា បច្ឆាភូ-
មកា កាមណ្ឌលុកា សេវាលមាលិកា អគ្គិបរិចា-
រិកា ឧទកោរោហកា សោចេយ្យានិ បញ្ញាបេន្តិ អញ្ញ-
ថា ច បន អរិយស្ស វិនយេ សោចេយ្យំ ហោតីតិ ។
យថាកថំ បន ភន្តេ អរិយស្ស វិនយេ សោចេយ្យំ
ហោតិ សាធុ មេ ភន្តេ ភគវា តថា ធម្មំ ទេសេតុ
យថា អរិយស្ស វិនយេ សោចេយ្យំ ហោតីតិ ។
តេនហិ ចុន្ទ សុណាហិ សាធុកំ មនសិករោហិ
ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ ចុន្ទោ កម្មារបុត្តោ
ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច តិវិធំ ខោ
ចុន្ទ កាយេន អសោចេយ្យំ ហោតិ ចតុព្វិធំ វាចាយ
អសោចេយ្យំ ហោតិ តិវិធំ មនសា អសោចេយ្យំ ហោតិ ។

បពិត្រព្រះអង្គដ៏ចំរើន ពួកព្រាហ្មណ៍ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់ល័ក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច តែងបញ្ញត្តនូវការស្អាត យ៉ាងនេះឯង ខ្ញុំព្រះអង្គ តែងពេញចិត្តនឹងការស្អាត របស់ព្រាហ្មណ៍ទាំងនោះ ។ នៃចុន្ទ ពួកព្រាហ្មណ៍ ដែលនៅខាងក្រោយភូមិ ជាអ្នកប្រើប្រាស់ល័ក្កចាន់ ប្រើប្រាស់សំពត់ដូចផ្កាសារាយ ជាអ្នកបម្រើភ្លើង ជាអ្នកចុះត្រាំទឹកព្រឹកល្ងាច បញ្ញត្តនូវការស្អាត ដោយឡែក ចំណែកការស្អាតក្នុងអរិយវិន័យ ដោយឡែក ។ បពិត្រព្រះអង្គដ៏ចំរើន ចុះការស្អាតក្នុងអរិយវិន័យ តើដូចម្តេច បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គសំដែងធម៌ តាមដំណើរការស្អាត ក្នុងអរិយវិន័យ ឲ្យបានដល់ខ្ញុំព្រះអង្គ ។ ម្នាលចុន្ទ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្ត ដោយប្រពៃចុះ តថាគតនឹងសំដែង ។ ចុន្ទកម្មារបុត្រ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលចុន្ទ ការមិនស្អាតដោយកាយ មាន ៣ ប្រការ ការមិនស្អាតដោយវាចា មាន ៤ ប្រការ ការមិនស្អាតដោយចិត្ត មាន ៣ ប្រការ ។

កថញ្ច ចុន្ទ តិវិធំ កាយេន អសោចេយ្យំ ហោតិ ។ ឥធ ចុន្ទ ឯកច្ចោ បាណាតិបាតី ហោតិ លុទ្ទោ លោហិតបាណី ហតបហតេ(១) និវិដ្ឋោ អទយាបន្នោ បាណភូតេសុ អទិន្នាទាយី ហោតិ យន្តំ បរស្ស បរវិត្តូបករណំ(២) គាមគតំ វា អរញ្ញគតំ(៣) វា អទិន្នំ ថេយ្យសង្ខាតំ អាទាតា ហោតិ កាមេសុ មិច្ឆាចារី ហោតិ យា តា មាតុរក្ខិតា បិតុរក្ខិតា ភាតុរក្ខិតា ភគិនិរក្ខិតា ញាតិរក្ខិតា ធម្មរក្ខិតា សស្សាមិកា សបរិទណ្ឌា អន្តមសោ មាលាគុណបរិក្ខិត្តាបិ(៤) តថារូបាសុ ចារិត្តំ អាបជ្ជិតា ហោតិ ។ ឯវំ ខោ ចុន្ទ តិវិធំ កាយេន អសោចេយ្យំ ហោតិ ។ កថញ្ច ចុន្ទ ចតុព្វិធំ វាចាយ អសោចេយ្យំ ហោតិ ។

---

១ ម. បហតបហតេ ។ ២ ឱ. ម. បរវិត្តូបករណំ ៣ ឱ.ម. ឯត្ថន្តរេ គត្ថិ បាឋោ ទិស្សតិ ។
៤ ម. មាលាគុឡបរិក្ខិតាបិ ។

ម្នាលចុន្ទ ចុះការមិនស្អាតដោយកាយ មាន ៣ ប្រការ តើដូចម្តេច ។ ម្នាលចុន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាមនុស្សមានចិត្តអាក្រក់ មានដៃប្រឡាក់ឈាម មានចិត្តបោះជាប់ ក្នុងការសម្លាប់សត្វ មានចិត្តមិនអាសូរចំពោះពួកសត្វ ១ ជាអ្នកលួចទ្រព្យគេ គឺជាអ្នកកាន់យកនូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ គេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ដែលគេមិនបានឲ្យ ដែលហៅថា លួច ១ ជាអ្នកប្រព្រឹត្តខុសក្នុងកាម គឺជាអ្នកដល់នូវការប្រព្រឹត្តកន្លង ក្នុងស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា (កំណត់ទុក) ដោយហោចទៅ សូម្បីតែស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ ១ ។ ម្នាលចុន្ទ ការមិនស្អាតដោយកាយ មាន ៣ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ការមិនស្អាត ដោយវាចា មាន ៤ ប្រការ តើដូចម្តេច ។

ឥធ ចុន្ទ ឯកច្ចោ មុសាវាទី ហោតិ សភគ្គតោ(១) វា បរិសគ្គតោ វា ញាតិមជ្ឈគ្គតោ វា បូគមជ្ឈគ្គតោ វា រាជកុលមជ្ឈគ្គតោ វា អភិនីតោ សក្ខី បុដ្ឋោ ឯហិ ភោ(២) បុរិស យំ ជានាសិ តំ វទេហីតិ សោ អជានំ វា អាហ(៣) ជានាមីតិ ជានំ វា អាហ ន ជានាមីតិ អបស្សំ វា អាហ បស្សាមីតិ បស្សំ វា អាហ ន បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិស-កិញ្ចិក្ខហេតុ វា សម្បជានមុសា ភាសិតា ហោតិ បិសុណវាចោ ហោតិ ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ឥមេសំ អក្ខាតា អមុសំ ភេទាយ ឥតិ សមគ្គានំ វា ភេត្តា ភិន្នានំ វា អនុប្បទាតា វគ្គារាមោ វគ្គរតោ វគ្គនន្ទី វគ្គករណឹ

---

១ ឱ. សភគតោ ។ ២ ឱ. ម. សក្ខិបុដ្ឋោ ឯហម្ភោ ។ ៣ ឱ. ម. គហំ ។

ម្នាលបុន្ន បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកពោលពាក្យកុហក ទោះបី ឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិសទ្យក្តី ឋិតនៅក្នុងកណ្តាលញាតិក្តី ឋិតនៅក្នុងកណ្តាលសេនីក្តី ឋិតនៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅធ្វើជាសាក្សី ហើយសួរថា នែបុរសអើយ ចូរអ្នកមកអាយ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុគ្គលនោះ កាលមិនដឹងក៏និយាយថា ខ្ញុំដឹងក៏មាន កាលដឹងនិយាយថា ខ្ញុំមិនដឹងក៏មាន កាលមិនឃើញនិយាយថា ខ្ញុំឃើញក៏មាន កាលឃើញនិយាយថា ខ្ញុំមិនឃើញក៏មាន ជាអ្នកពោលពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុតែខ្លួនក្តី ហេតុអ្នកដទៃក្តី ព្រោះហេតុសំណូក គឺអាមិសៈបន្តិចបន្តួចក្តី ១ ជាអ្នកពោលពាក្យញុះញង់ គឺឮពាក្យអំពីសំណាក់ជននេះហើយនាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនពួកនេះ ឬឮពាក្យអំពីសំណាក់ជនឯណោះនាំមកប្រាប់ជននេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកបំបែកពួកជនដែលព្រមព្រៀងគ្នាផង ជាអ្នកដំរុលពួកជន ដែលបែកគ្នាហើយផង ជាអ្នកត្រេកអរតែក្នុងពួក មានតម្រេកក្នុងពួក ជាអ្នករីករាយតែក្នុងពួក

វាចំ ភាសិតា ហោតិ ផរុសវាចោ ហោតិ
យា សា វាចា អណ្ឌកា កក្កសា បរកដុកា
បរាភិសជ្ជនី កោធសាមន្តា អសមាធិសំវត្តនិកា
តថារូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបី ហោតិ
អកាលវាទី អភូតវាទី អនត្ថវាទី អធម្មវាទី អវិន-
យវាទី អនិធានវតឹ វាចំ ភាសិតា ហោតិ អកាលេន
អនបទេសំ អបរិយន្តវតឹ អនត្ថសញ្ហិតំ ។ ឯវំ ខោ
ចុន្ទ ចតុព្វិធំ វាចាយ អសោចេយ្យំ ហោតិ ។
កថញ្ច ចុន្ទ តិវិធំ មនសា អសោចេយ្យំ ហោតិ ។ ឥធ
ចុន្ទ ឯកច្ចោ អភិជ្ឈាលុ ហោតិ យន្តំ បរស្ស បរវិត្តូប-
ករណំ តំ អភិជ្ឈិតា ហោតិ អហោ វត យំ បរស្ស
តំ មម អស្សាតិ ព្យាបន្នចិត្តោ ហោតិ បទុដ្ឋមន-
សង្កប្បោ ឥមេ សត្តា ហញ្ញន្តុ វា វជ្ឈន្តុ វា ឧច្ឆិជ្ជន្តុ វា

ជាអ្នកពោលពាក្យធ្វើឲ្យប្រកាន់ពួក ដោយប្រការដូច្នេះ ១ ជាអ្នកពោលពាក្យអាក្រក់ គឺជាអ្នកពោលពាក្យទ្រគោះ បោះបោក ខ្ទោះខ្ទួរ ពេលពល ស្ទាក់ដំណើរដទៃ ជាពាក្យជិតនឹងសេចក្ដីក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិ ១ ជាអ្នកពោលពាក្យឥតប្រយោជន៍ គឺពោលពាក្យខុសកាល ពោលពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពោលពាក្យដែលមិនគួរឲ្យតាំងទុកក្នុងហឫទ័យបាន ជាពាក្យពោលខុសកាល ប្រាសចាកគ្រឿងអាង ជាពាក្យមិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ១ ។ ម្នាលចុន្ទ ការមិនស្អាតដោយវាចា មាន ៤ ប្រការ យ៉ាងនេះឯង ។ ម្នាលចុន្ទ ចុះការមិនស្អាតដោយចិត្ត មាន ៣ ប្រការ តើដូចម្ដេច ។ ម្នាលចុន្ទ បុគ្គលខ្លះក្នុងលោកនេះ ច្រើនដោយអភិជ្ឈា គឺជាអ្នកគយ-គន់នូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ ដោយគិតថា ឱហ្ន៎ គ្រឿងឧបករណ៍ ដែលជាទ្រព្យសម្បត្តិ នៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអញ ១ ជាអ្នកមានចិត្តព្យាបាទ គឺជាមនុស្សមានតម្រិះក្នុងចិត្ត ដែលទោសប្រទុស្តហើយថា សត្វទាំងឡាយនេះ ចូរលំបាកខ្លះ ចូរបែកគ្នាខ្លះ ចូរសាបសូន្យទៅខ្លះ

វិនស្សន្តុ វា មា វា អហេសុន្តិ(១) មិច្ឆាទិដ្ឋិកោ ហោតិ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មា-បដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ ឯវំ ខោ ចុន្ទ តិវិធំ មនសា អសោចេយ្យំ ហោតិ ។ ឥមេ ខោ ចុន្ទ ទស អកុសលកម្មបថា ។ ឥមេហិ ខោ ចុន្ទ ទសហិ អកុសលេហិ កម្មបថេហិ សមន្នាគតោ សកាលស្សេវ ឧដ្ឋហន្តោ សយនម្ហា បឋវី ចេបិ អាមសតិ អសុចិយេវ ហោតិ នោ ចេបិ បឋវី អាមសតិ អសុចិយេវ ហោតិ អល្លានិ ចេបិ គោមយានិ អាមសតិ អសុចិយេវ ហោតិ

១ ឱ. ម. អហេសុំ ឥតិ វា ។

បូវិនាសទៅខ្លះ កុំបីមានបាន (អ្វីបន្តិចបន្តួច) ឡើយ ១ ជាអ្នកមាន គំនិតយល់ខុស គឺជាមនុស្សយល់ឃើញនូវសេចក្តីវិបរីតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ផលវិបាករបស់កុសលាកុសលកម្ម ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន លោកនេះ មិនមាន លោកខាងមុខ មិនមាន មាតា មិនមាន បិតា មិនមាន សត្វទាំងឡាយជាឧបបាតិកកំណើត មិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯងហើយសំដែងប្រាប់មិនមាន ១ ។ ម្នាលចុន្ទ ការមិនស្អាតដោយចិត្ត មាន ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលចុន្ទ ការមិនស្អាតទាំង ១០ នេះឯង ហៅថា អកុសលកម្មបថ ។ ម្នាលចុន្ទ បុគ្គលដែលប្រកបដោយអកុសលកម្មបថទាំង ១០ នេះហើយ បើទុកជាក្រោកឡើងអំពីដំណេក ក្នុងវេលាព្រឹកព្រហាម ហើយស្ទាបផែនដីក្តី ក៏នៅតែជាមនុស្សមិនស្អាតដដែល បើទុកជាមិនស្ទាបផែនដីក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាស្ទាបអាចម៍គោស្រស់ក្តី ក៏នៅតែមិនស្អាតដដែល

នោ ចេបិ អល្លានិ គោមយានិ អាមសតិ អសុចិយេវ ហោតិ ហរិតានិ ចេបិ តិណានិ អាមសតិ អសុចិយេវ ហោតិ នោ ចេបិ ហរិតានិ តិណានិ អាមសតិ អសុចិយេវ ហោតិ អគ្គឹ ចេបិ បរិចរតិ អសុចិយេវ ហោតិ នោ ចេបិ អគ្គឹ បរិចរតិ អសុចិយេវ ហោតិ បញ្ជលិកោ ចេបិ អាទិច្ចំ នមស្សតិ អសុចិយេវ ហោតិ នោ ចេបិ បញ្ជលិកោ អាទិច្ចំ នមស្សតិ អសុចិយេវ ហោតិ សាយតតិយកំ ចេបិ ឧទកំ ឱរោហតិ អសុចិយេវ ហោតិ នោ ចេបិ សាយតតិយកំ ឧទកំ ឱរោហតិ អសុចិយេវ ហោតិ ។ តំ កិស្ស ហេតុ ។ ឥមេ ចុន្ទ ទស អកុសលកម្មបថា អសុចី ចេវ(១) ហោន្តិ អសុចិករណា ច ។ ឥមេសំ បន ចុន្ទ ទសន្នំ អកុសលានំ កម្មបថានំ សមន្នាគមនហេតុ និរយោ បញ្ញាយតិ តិរច្ឆានយោនិ បញ្ញាយតិ បិត្តិវិសយោ បញ្ញាយតិ យា វា(២) បនញ្ញាបិ កាចិ ទុគ្គតិ ហោតិ(៣) ។

---

១ ឱ. ម. អសុចិយេវ ។ ២ ម. ច ។ ៣ ឱ. ទុគ្គតិហោតិ ទិស្សតិ ។

បើទុកជាមិនស្ទាបអាចម៍គោស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាស្ទាបស្មៅស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិនស្ទាបស្មៅស្រស់ក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាបម្រើភ្លើងក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិនបម្រើភ្លើងក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាប្រណម្យអញ្ជលី នមស្ការព្រះអាទិត្យក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិនប្រណម្យអញ្ជលី នមស្ការព្រះអាទិត្យក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាចុះត្រាំទឹកជាគំរប់ ៣ ដងនឹងពេលល្ងាចក្តី ក៏នៅតែមិនស្អាតដដែល បើទុកជាមិនចុះត្រាំទឹក ជាគំរប់ ៣ ដងនឹងពេលល្ងាចក្តី ក៏នៅតែមិនស្អាតដដែល ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះអកុសលកម្មបថទាំង ១០ នេះឯង ជាគន្លងមិនស្អាតផង ជាផ្លូវកន្សោកើតរបស់មិនស្អាតផង ។ ម្នាលចុន្ទ មួយទៀត ព្រោះហេតុនៃការប្រកបព្រមដោយអកុសលកម្មបថទាំង ១០ ប្រការនេះ នរកក៏ប្រាកដ តិរច្ឆាន ក៏ប្រាកដ បិត្តិវិស័យ ក៏ប្រាកដឡើង ឬក៏មានទុគ្គតិ (ដំណើរអាក្រក់) ក្រៅពីនេះណាមួយ (មានទៀតមិនខាន) ។

តិវិធំ ខោ ចុន្ទ កាយេន សោចេយ្យំ ហោតិ ចតុព្វិធំ វាចាយ សោចេយ្យំ ហោតិ តិវិធំ មនសា សោចេយ្យំ ហោតិ ។ កថញ្ច ចុន្ទ តិវិធំ កាយេន សោចេយ្យំ ហោតិ ។ ឥធ ចុន្ទ ឯកច្ចោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ គាមគតំ វា អរញ្ញគតំ វា តំ អទិន្នំ ថេយ្យសង្ខាតំ អនាទាតា ហោតិ កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ យា តា មាតុរក្ខិតា បិតុរក្ខិតា ភាតុរក្ខិតា ភគិនិរក្ខិតា ញាតិរក្ខិតា ធម្មរក្ខិតា សស្សាមិកា សបរិទណ្ឌា អន្តមសោ មាលាគុណបរិក្ខិត្តាបិ តថារូបាសុ ន ចារិត្តំ អាបជ្ជិតា ហោតិ ។

ម្នាលចុន្ទ ការស្អាតដោយកាយមាន ៣ ប្រការ ការស្អាតដោយវាចាមាន ៤ ប្រការ ការស្អាតដោយចិត្តមាន ៣ ប្រការ ។ ម្នាលចុន្ទ ចុះការស្អាតដោយកាយមាន ៣ ប្រការ តើដូចម្តេច ។ ម្នាលចុន្ទ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់នូវបាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា ដាក់ចុះនូវគ្រឿងសស្ត្រាវុធ ប្រកបដោយសេចក្តីខ្មាស ដល់នូវមេត្តាចិត្ត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះពួកសត្វទាំងអស់ ១ ជាអ្នកលះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ជាអ្នកមិនកាន់យកនូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ គេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ដែលគេមិនបានឲ្យ ដោយចិត្តលួចឡើយ ១ ជាអ្នកលះបង់ កាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆាចារ ជាអ្នកមិនដល់នូវការប្រព្រឹត្តកន្លង ក្នុងស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ត្រកូលប្រកបដោយធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា (កំណត់ទុក) ដោយហោចទៅ សូម្បីតែស្ត្រី ដែលបុរសបំពាក់កម្រងផ្កាទុក ១ ។

ឯវំ ខោ ចុន្ទ តិវិធំ កាយេន សោចេយ្យំ ហោតិ ។ កថញ្ច ចុន្ទ ចតុព្វិធំ វាចាយ សោចេយ្យំ ហោតិ ។ ឥធ ចុន្ទ ឯកច្ចោ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សភគ្គតោ(១) វា បរិសគ្គតោ វា ញាតិមជ្ឈគ្គតោ វា បូគមជ្ឈគ្គតោ វា រាជកុលមជ្ឈគ្គតោ វា អភិនីតោ សក្ខីបុដ្ឋោ ឯហិ ភោ បុរិស យំ ជានាសិ តំ វទេហីតិ សោ អជានំ វា អាហ ន ជានាមីតិ ជានំ វា អាហ ជានាមីតិ អបស្សំ វា អាហ ន បស្សាមីតិ បស្សំ វា អាហ បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា ន សម្បជានមុសា ភាសិតា ហោតិ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ន ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា

---

១ ឱ. សភាគតោ ។

ម្នាលចុន្ទ ការស្អាត ដោយកាយមាន ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលចុន្ទ ចុះការស្អាត ដោយវាចាមាន ៤ ប្រការ តើដូចម្តេច ។ ម្នាលចុន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកលះបង់មុសាវាទ វៀរស្រឡះ ចាកមុសាវាទ ទោះបីឋិតនៅ ក្នុងរោងក្តី ឋិតនៅ ក្នុងបរិសទ្យក្តី ឋិតនៅ ក្នុងកណ្តាលញាតិក្តី ឋិតនៅ ក្នុងកណ្តាលសេនីក្តី ឋិតនៅ ក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅធ្វើជាសាក្សីហើយសួរថា នែបុរសអើយ ចូរអ្នកមកអាយ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុគ្គលនោះ កាលមិនដឹងក៏និយាយថា ខ្ញុំមិនដឹង កាលដឹងនិយាយថា ខ្ញុំដឹង កាលមិនឃើញនិយាយថា ខ្ញុំមិនឃើញ ឬកាលឃើញ និយាយថា ខ្ញុំឃើញ ជាអ្នកមិនពោលពាក្យកុហកទាំងដឹង ដូច្នេះ ព្រោះហេតុតែខ្លួនក្តី ហេតុអ្នកដទៃក្តី ព្រោះហេតុសំណូកគឺអាមិសៈបន្តិចបន្តួចក្តី ១ ជាអ្នកលះបង់បិសុណាវាចា វៀរស្រឡះចាកបិសុណាវាចា ឮពាក្យអំពីសំណាក់ជននេះហើយ មិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឬ. ឮពាក្យ អំពីសំណាក់ជនឯណោះ ហើយមិននាំមកប្រាប់ជនទាំងនេះ

អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនិយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា ហោតិ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។ ឯវំ ខោ ចុន្ទ ចតុព្វិធំ វាចាយ សោចេយ្យំ ហោតិ ។ កថញ្ច ចុន្ទ តិវិធំ មនសា សោចេយ្យំ ហោតិ ។

ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកផ្សះផ្សានូវពួកជន ដែលបែកគ្នាផង ជាអ្នកទំនុកបម្រុងនូវពួកជនដែលរួបរួមគ្នាផង ជាអ្នកត្រេកអរក្នុងសេចក្តីព្រមព្រៀងគ្នាផង ជាអ្នកមានតម្រេកតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នករីករាយ ក្នុងសេចក្តីព្រមព្រៀងគ្នា ពោលនូវវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀងគ្នា ដោយប្រការដូច្នេះ ១ ជាអ្នកលះបង់ផរុសវាចា វៀរស្រឡះចាកផរុសវាចា ជាអ្នកពោលតែវាចាមិនមានទោស ជាសុខដល់ត្រចៀក គួរឲ្យកើតសេចក្តីស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជាវាចាអ្នកបុរី ជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន ១ ជាអ្នកលះបង់សម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ ពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យដែលជាវិន័យ ពោលពាក្យដែលគួរតាំងទុកក្នុងហឫទ័យ ជាពាក្យត្រូវតាមកាលវេលា ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបដោយប្រយោជន៍ ១ ។ ម្នាលចុន្ទ ការស្អាត ដោយវាចា មាន ៤ ប្រការយ៉ាងនេះឯង ។ ម្នាលចុន្ទ ចុះការស្អាត ដោយចិត្ត មាន ៣ ប្រការ តើដូចម្តេច ។

ឥធ ភន្តេ ឯកច្ចោ អនភិជ្ឈាលុ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ តំ អនភិជ្ឈាតា ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ អព្យាបន្នចិត្តោ ហោតិ អប្បទុដ្ឋមនសង្កប្បោ ឥមេ សត្តា អវេរា[១] អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តូតិ សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ ឯវំ ខោ ភន្តេ តិវិធំ មនសា សោចេយ្យំ ហោតិ ។

---

១ ម. ឯត្ថន្តរេ ហោន្តូតិ បាឋោ ទិស្សតិ ។

ម្នាលចុន្ទ បុគ្គលខ្លះ ក្នុងលោកនេះ មិនមានអភិជ្ឈា ជាអ្នកមិនគយគន់នូវគ្រឿងឧបករណ៍ ដែលជាទ្រព្យសម្បត្តិ នៃបុគ្គលដទៃដោយគិតថា ឱហ្ន៎ គ្រឿងឧបករណ៍ ដែលជាទ្រព្យសម្បត្តិនៃបុគ្គលណា គ្រឿងឧបករណ៍នោះ គប្បីបានមកអញ ដូច្នេះឡើយ ១ ជាអ្នកមានចិត្តមិនព្យាបាទ គឺជាមនុស្ស មានតម្រិះក្នុងចិត្ត ដែលពោលមិនប្រទូស្តហើយថា សត្វទាំងឡាយ នេះកុំមានពៀរនឹងគ្នា កុំព្យាបាទគ្នា កុំមានទុក្ខ ចូររក្សាខ្លួន ឲ្យបានសេចក្តីសុខចុះ ១ ជាអ្នកមានសេចក្តីយល់ត្រូវ គឺជាមនុស្ស យល់ឃើញនូវសេចក្តីមិនវិបរីតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ការបូជាតូច មានផល ផលវិបាកនៃកុសលាកុសលកម្ម ដែលសត្វធ្វើល្អធ្វើអាក្រក់ មាន លោកនេះមាន លោកខាងមុខមាន មាតាមាន បិតាមាន ពួកសត្វទាំងឡាយជាឧបបាតិកកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ នឹងលោកខាងមុខដោយប្រាជ្ញា ដ៏ឧត្តមរបស់ខ្លួនឯង ហើយសំដែងប្រាប់មាន ១ ។ ម្នាលចុន្ទ ការស្អាត ដោយចិត្ត មាន ៣ ប្រការ យ៉ាងនេះឯង ។

ឥមេ ខោ ចុន្ទ ទស កុសលកម្មបថា ។ ឥមេហិ ខោ ចុន្ទ ទសហិ កុសលេហិ កម្មបថេហិ សមន្នាគតោ កាលស្សេវ ឧដ្ឋហន្តោ សយនម្ហា បឋវឹ ចេបិ អាមសតិ សុចិយេវ ហោតិ នោ ចេបិ បឋវឹ អាមសតិ សុចិយេវ ហោតិ អល្លានិ ចេបិ គោមយានិ អាមសតិ សុចិយេវ ហោតិ នោ ចេបិ អល្លានិ គោមយានិ អាមសតិ សុចិយេវ ហោតិ ហរិតានិ ចេបិ តិណានិ អាមសតិ សុចិយេវ ហោតិ នោ ចេបិ ហរិតានិ តិណានិ អាមសតិ សុចិយេវ ហោតិ អគ្គឹ ចេបិ បរិចរតិ សុចិយេវ ហោតិ នោ ចេបិ អគ្គឹ បរិចរតិ សុចិយេវ ហោតិ បញ្ជលិកោ ចេបិ អាទិច្ចំ នមស្សតិ សុចិយេវ ហោតិ នោ ចេបិ បញ្ជលិកោ អាទិច្ចំ នមស្សតិ សុចិយេវ ហោតិ សាយតតិយកំ ចេបិ ឧទកំ ឱរោហតិ សុចិយេវ ហោតិ នោ ចេបិ សាយតតិយកំ ឧទកំ ឱរោហតិ សុចិយេវ ហោតិ ។

ម្នាលចុន្ទ ការស្អាតទាំង ១០ ប្រការនេះ ហៅថា កុសលកម្មបថ ១០ ។ ម្នាលចុន្ទ បុគ្គលដែលប្រកប ដោយកុសលកម្មបថទាំង ១០ នេះហើយ បើទុកជាក្រោកឡើងអំពីដំណេកក្នុងវេលាព្រឹកព្រហាម ហើយ ស្ទាបផែនដីក្តី ក៏នៅជាមនុស្សស្អាតដដែល បើទុកជាមិនស្ទាបផែនដីក្តី ក៏នៅស្អាតដដែល បើទុកជាស្ទាបអាចម៍គោស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាមិនស្ទាបអាចម៍គោស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាស្ទាបស្មៅស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាមិនស្ទាបស្មៅស្រស់ក្តី ក៏នៅស្អាតដដែល បើទុកជាបម្រើភ្លើងក្តី ក៏នៅស្អាតដដែល បើទុកជាមិនបម្រើភ្លើងក្តី ក៏នៅស្អាតដដែល បើទុកជាប្រណម្យអញ្ជលី នមស្ការព្រះអាទិត្យក្តី ក៏នៅស្អាតដដែល បើទុកជាមិនប្រណម្យអញ្ជលី នមស្ការព្រះអាទិត្យក្តី ក៏នៅតែស្អាតដដែល បើទុកជាចុះត្រាំទឹកជាគំរប់ ៣ ដងទឹងពេលល្ងាចក្តី ក៏នៅតែស្អាតដដែល បើទុកជាមិនចុះត្រាំទឹកជាគំរប់ ៣ ដងទឹងពេលល្ងាចក្តី ក៏នៅតែស្អាតដដែល ។

តំ កិស្ស ហេតុ ។ ឥមេ ចុន្ទ ទស កុសល-
កម្មបថា សុចិ ចេវ ហោន្តិ សុចិករណា ច ។ ឥមេ-
សញ្ច បន ចុន្ទ ទសន្នំ កុសលានំ កម្មបថានំ
សមន្នាគមនហេតុ ទេវា បញ្ញាយន្តិ មនុស្សា
បញ្ញាយន្តិ យា វា បនញ្ញាបិ កាចិ សុគតិយោ ហោន្តិ ។
ឯវំ វុត្តេ ចុន្ទោ កម្មារបុត្តោ ភគវន្តំ ឯតទវោច
អភិក្កន្តំ ភន្តេ ។បេ។ ឧបាសកំ មំ ភន្តេ
ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

(៦៦) អថខោ ជាណុស្សោណិ ព្រាហ្មណោ
យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា
ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ
សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះកុសលកម្មបថទាំង ១០ ប្រការនេះឯង ជាគន្លងស្ពានផង ជាផ្លូវកឲ្យកើតរបស់ស្ពានផង ។ ម្នាលចុន្ទ មួយទៀត ព្រោះហេតុនៃការប្រកបព្រមដោយកុសលកម្មបថទាំង ១០ ប្រការនេះ ទេវតា ក៏ប្រាកដ មនុស្ស ក៏ប្រាកដ ឬក៏មានសុគតិ (ដំណើរល្អ) ក្រៅពីនេះណាមួយ (មានទៀតមិនខាន) ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ចុន្ទកម្មារបុត្រ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពីរោះណាស់ ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

(៦៦) លំដាប់នោះ ជាណុស្សោណិព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹក នាំឲ្យកើតសេចក្តីសន្ទស្សាលហើយ អង្គុយក្នុងទីសមគួរ ។

ឯកមន្តំ និសិន្នោ ខោ ជាណុស្សោណិ ព្រាហ្មណោ ភគវន្តំ ឯតទវោច មយមស្សុ ភោ គោតម ព្រាហ្មណា នាម ទានានិ ទេម សទ្ធានិ ករោម ឥទំ ទានំ បេតានំ ញាតិសាលោហិតានំ ឧបកប្បតុ ឥទំ ទានំ បេតា ញាតិសាលោហិតា បរិភុញ្ជន្តុ កច្ចិ តំ ភោ គោតម ទានំ បេតានំ ញាតិសាលោហិតានំ ឧបកប្បតិ កច្ចិ តេ បេតា ញាតិសាលោហិតា តំ ទានំ បរិភុញ្ជន្តីតិ ។ ឋានេ ខោ ព្រាហ្មណ ឧបកប្បតិ នោ អដ្ឋានេតិ ។ កតមំ(១) ភោ គោតម ឋានំ កតមំ អដ្ឋានន្តិ ។ ឥធ ព្រាហ្មណ ឯកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណវាចោ(២) ហោតិ ផរុសវាចោ(៣) ហោតិ សម្ផប្បលាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ

១ ឱ. កតមញ្ច បន ។ ២ ឱ. ម. បិសុណាវាចោ ។ ៣ ឱ.ម. ផរុសាវាចោ ។

លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន យើងជាព្រាហ្មណ៍តែងឲ្យទាន តែងធ្វើអំពើដែលគេគប្បីធ្វើ ដោយសទ្ធាហើយឧទ្ទិសថា ទាននេះ សូមឲ្យសម្រេចផល ដល់ប្រេតទាំងឡាយ ជាញាតិសាលោហិត ពួកប្រេតទាំងឡាយ ជាញាតិសាលោហិត សូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏ចំរើន ចុះទាននោះនឹងសម្រេចផលដល់ប្រេតទាំងឡាយ ជាញាតិសាលោហិតដែរឬទេ ប្រេតទាំងឡាយជាញាតិសាលោហិតនោះ នឹងបរិភោគនូវទាននោះ បានដែរឬទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ទាននោះសម្រេចផលក្នុងទីគួរ មិនសម្រេចផល ក្នុងទីមិនគួរ ។ បពិត្រព្រះគោតមដ៏ចំរើន ទីដែលគួរ តើដូចម្តេច ទីដែលមិនគួរ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសំឡាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ

មិច្ឆាទិដ្ឋិកោ សោ កាយស្ស ភេទា បរម្មរណា និរយំ ឧបបជ្ជតិ យោ នេរយិកានំ សត្តានំ អាហារោ តេន សោ តត្ថ យាបេតិ តេន សោ តត្ថ តិដ្ឋតិ ឥទំ(១) ខោ ព្រាហ្មណ អដ្ឋានំ យត្ថ ឋិតស្ស តំ ទានំ ន ឧបកប្បតិ ។ ឥធ បន ព្រាហ្មណ ឯកច្ចោ បាណាតិបាតី ហោតិ ។បេ។ មិច្ឆាទិដ្ឋិកោ ហោតិ សោ កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបជ្ជតិ យោ តិរច្ឆានយោនិកានំ សត្តានំ អាហារោ តេន សោ តត្ថ យាបេតិ តេន សោ តត្ថ តិដ្ឋតិ ឥទម្បិ ខោ ព្រាហ្មណ អដ្ឋានំ យត្ថ ឋិតស្ស តំ ទានំ ន ឧបកប្បតិ ។ ឥធ បន ព្រាហ្មណ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ

---

១ ឱ. ម. ឥទម្បិ ។

មានសេចក្ដីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើត ក្នុងនរក អាហារណា ជាអាហារ សម្រាប់សត្វទាំងឡាយ កើតក្នុងនរក សត្វនរកនោះ តែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងនរកនោះ ដោយសារអាហារនោះ សត្វនរកនោះ ឋិតនៅក្នុងនរកនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅ ក្នុងទីណា ទីនេះឯងហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ បេ ។ មានសេចក្ដីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើត ក្នុងកំណើតនៃតិរច្ឆាន អាហារណា ជាអាហារ សម្រាប់សត្វទាំងឡាយ ដែលកើត ក្នុងកំណើតតិរច្ឆាន សត្វតិរច្ឆាននោះ ក៏ញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងទីនោះ ដោយអាហារនោះ សត្វតិរច្ឆាននោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅ ក្នុងទីណា ទីនេះឯងហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ ចំណែកឯបុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះ ចាកបាណាតិបាត វៀរស្រឡះ ចាកអទិន្នាទាន

កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា
បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ
ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា
បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ
ហោតិ សម្មាទិដ្ឋិកោ ហោតិ សោ កាយស្ស ភេទា
បរម្មរណា មនុស្សានំ សហព្យតំ ឧបបជ្ជតិ យោ
មនុស្សានំ អាហារោ តេន សោ តត្ថ យាបេតិ
តេន សោ តត្ថ តិដ្ឋតិ ឥទម្បិ ខោ ព្រាហ្មណ
អដ្ឋានំ យត្ថ ឋិតស្ស តំ ទានំ ន ឧបកប្បតិ ។
ឥធ បន ព្រាហ្មណ ឯកច្ចោ បាណាតិបាតា
បដិវិរតោ ហោតិ ។ បេ ។ សម្មាទិដ្ឋិកោ ហោតិ សោ
កាយស្ស ភេទា បរម្មរណា ទេវានំ សហព្យតំ ឧប-
បជ្ជតិ យោ ទេវានំ អាហារោ តេន សោ តត្ថ យាបេតិ
តេន សោ តត្ថ តិដ្ឋតិ ឥទម្បិ ខោ ព្រាហ្មណ
អដ្ឋានំ យត្ថ ឋិតស្ស តំ ទានំ ន ឧបកប្បតិ ។

វៀរស្រឡះ ចាកមុសាវាទ វៀរស្រឡះ ចាកបិសុណាវាចា វៀរស្រឡះ ចាកផរុសវាចា វៀរស្រឡះ ចាកសម្ផប្បលាបៈ ជាអ្នកមិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ មានសេចក្ដីយល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើត ក្នុងពួកមនុស្ស អាហារណា ជាអាហារសម្រាប់ពួកមនុស្ស បុគ្គលនោះ ក៏ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ បុគ្គលនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផល ដល់សត្វដែលឋិតនៅ ក្នុងទីណា ទីនេះឯងហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះ ចាកបាណាតិបាត ។ បេ ។ មានសេចក្ដីយល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើត ក្នុងពួកទេវតា អាហារណា ជាអាហារសម្រាប់ពួកទេវតា ទេវតានោះ ក៏ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងទីនោះ ដោយអាហារនោះ ទេវតានោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅ ក្នុងទីណា ទីនេះឯងហៅថា ទីមិនគួរ ។

៩៨ ព្រាហ្មណា ឯកច្ចោ បាណាតិបាតី ហោតិ ។ បេ ។ មិច្ឆាទិដ្ឋិកោ ហោតិ សោ កាយស្ស ភេទា បរម្មរណា បិត្តិវិសយំ ឧបបជ្ជតិ យោ បិត្តិវិសយិកានំ សត្តានំ អាហារោ តេន សោ តត្ថ យាបេតិ តេន សោ តត្ថ តិដ្ឋតិ យំ វា បនស្ស ឥតោ អនុប្បវេច្ឆន្តិ មិត្តាមច្ចា វា ញាតិសាលោហិតា វា តេន សោ តត្ថ យាបេតិ តេន សោ តត្ថ តិដ្ឋតិ ឥទម្បិ ខោ ព្រាហ្មណ ឋានំ យត្ថ ឋិតស្ស តំ ទានំ ឧបកប្បតីតិ ។ សចេ បន ភោ គោតម សោ បេតោ ញាតិសាលោហិតោ តំ ឋានំ អនុបបន្នោ ហោតិ កោ តំ ទានំ បរិភុញ្ជតីតិ ។ អញ្ញេបិស្ស ព្រាហ្មណ បេតា ញាតិសាលោហិតា តំ ឋានំ ឧបបន្នា ហោន្តិ តេ តំ ទានំ បរិភុញ្ជន្តីតិ ។

ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ បេ ។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើត ក្នុងបិត្តិវិស័យ អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយដែលកើត ក្នុងបិត្តិវិស័យ ប្រេតនោះ ក៏ញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះ ឋិតនៅ ក្នុងទីនោះ ដោយសារអាហារនោះ ឬក៏ពួកមិត្រអាមាត្យក្តី ជនជាញាតិសាលោហិតក្តី ឧទ្ទិសឲ្យនូវទានណា ដល់ប្រេតនោះ អំពីលោកនេះ ប្រេតនោះក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះឋិតនៅ ក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះសម្រេចផល ដល់សត្វដែលឋិតនៅ ក្នុងទីណា ទីនេះឯងហៅថាទីគួរ ។ ជាណុស្សោណិព្រាហ្មណ៍ ក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចំរើន ចុះប្រសិនបើ ប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើត ក្នុងទីនោះទេ តើអ្នកណា បរិភោគទាននោះ ។ អើព្រាហ្មណ៍ពួកប្រេត ដែលជាញាតិសាលោហិត ដទៃទៀត របស់គេ គង់ទៅកើតក្នុងទីនោះមិនខាន ប្រេតទាំងនោះឯង បរិភោគទាននោះ ។

សចេ បន ភោ គោតម សោ ចេវ បេតោ ញាតិសាលោហិតោ តំ ឋានំ អនុបបន្នោ ហោតិ អញ្ញេបិស្ស បេតា ញាតិសាលោហិតា តំ ឋានំ អនុបបន្នា ហោន្តិ កោ តំ ទានំ បរិភុញ្ជតីតិ ។ អដ្ឋានំ ខោ ឯតំ ព្រាហ្មណ អនវកាសោ យន្តំ ឋានំ វិវិត្តំ អស្ស ឥមិនា ទីឃេន អទ្ធុនា យទិទំ បេតេហិ ញាតិសាលោហិតេហិ អបិច ព្រាហ្មណ ទាយកោបិ អនិប្ផលោតិ(១) ។ អដ្ឋានេបិ ភវំ គោតមោ បរិកប្បំ វទតីតិ ។ អដ្ឋានេបិ ខោ អហំ ព្រាហ្មណ បរិកប្បំ វទាមិ ឥធ ព្រាហ្មណ ឯកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណវាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋិកោ ហោតិ សោ ទានំ ទេតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ

១ ម. អនិប្ផលោ ហោតីតិ ។

បពិត្រព្រះគោតមដ៏ចំរើន ចុះប្រសិនបើ ប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើត ក្នុងទីនោះទេ ចាំងពួកប្រេតជាញាតិសាលោហិត ដទៃទៀតរបស់គេ ក៏មិនបានទៅកើត ក្នុងទីនោះដែរ តើអ្នកណា បរិភោគទាននោះ ។ នែព្រាហ្មណ៍ ទីណាដែលស្ងាត់ ចាកប្រេតចាំងឡាយជាញាតិសាលោហិត ដោយកាល ជាយូរអង្វែងនេះ ទីនោះមិនមែនជាហេតុ មិនមែនជាឱកាស គឺជាមិនធ្លាប់មានឡើយ ម្នាលព្រាហ្មណ៍ មួយទៀត ធម្មតាអ្នកឲ្យទាន មិនមែនជាគ្មានផលទេ ។ ឱព្រះគោតមដ៏ចំរើន ពោលកំណត់ ក្នុងទីមិនគួរបានដែរតើ ។ អើព្រាហ្មណ៍ តថាគតពោលកំណត់ ក្នុងទីមិនគួរបានដែរ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យ ឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយល់ខុស ប៉ុន្តែបុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប

សេយ្យាវសថំ បទីបេយ្យំ សោ កាយស្ស ភេទា បរម្មរណា ហត្ថីនំ សហព្យតំ ឧបបជ្ជតិ សោ តត្ថ លាភី ហោតិ អន្នស្ស បានស្ស មាលាគន្ធវិលេបនស្ស យំ ខោ ព្រាហ្មណ ឥធ បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណវាចោ ផរុសវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋិកោ តេន សោ កាយស្ស ភេទា បរម្មរណា ហត្ថីនំ សហព្យតំ ឧបបជ្ជតិ យញ្ច ខោ សោ ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេន សោ តត្ថ លាភី ហោតិ អន្នស្ស បានស្ស មាលាគន្ធវិលេបនស្ស ។ ឥធ បន ព្រាហ្មណ ឯកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណវាចោ ហោតិ ផរុសវាចោ ហោតិ

ទីដេក ទីនៅ គ្រឿងឧបករណ៍របស់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតជាមួយពួកដំរី ឯដំរីនោះ ជាសត្វតែងស្គាល់ បាយ ទឹក កម្រងផ្កា និងគ្រឿងឧបករណ៍ផ្សេង ៗ ក្នុងកំណើត នៃដំរីនោះ ម្នាលព្រាហ្មណ៍ ត្រង់ដែលបុគ្គល ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុស ក្នុងកាម ពោលពាក្យកុហក ពោលពាក្យញុះ-ញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្ដីយល់ខុស ជាទោសនាំឲ្យបុគ្គលនោះ បែកធ្លាយរាងកាយ ស្លាប់ទៅ ទៅកើតជាមួយនឹងពួកដំរី ត្រង់ដែលបុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍របស់ប្រទីប ដល់សមណៈឬព្រាហ្មណ៍ ជាគុណបណ្ដាល ឲ្យបុគ្គលនោះជាសត្វតែងស្គាល់ បាយ ទឹក កម្រងផ្កា គ្រឿងប្រដាប់ផ្សេង ៗ ក្នុងកំណើតនៃដំរីនោះ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុស ក្នុងកាម ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់

សម្ផប្បលាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋិកោ ហោតិ សោ ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ សោ កាយស្ស ភេទា បរម្មរណា អស្សានំ សហព្យតំ ឧបបជ្ជតិ ... គុន្នំ សហព្យតំ ឧបបជ្ជតិ ... កុក្កុរានំ សហព្យតំ ឧបប-ជ្ជតិ សោ តត្ថ លាភី ហោតិ អន្នស្ស បានស្ស មាលាគន្ធវិលេបនស្ស យំ ខោ ព្រាហ្មណ ឥធ បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចោ ផរុសវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋិកោ តេន សោ កាយស្ស ភេទា បរម្មរណា កុក្កុរានំ សហព្យតំ ឧបបជ្ជតិ យញ្ច ខោ សោ ទាតា ហោតិ ស-មណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ

ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយល់ខុស ប៉ុន្តែបុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍ របស់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយពួកសេះ... កើតជាមួយពួកគោ... កើតជាមួយពួកឆ្កែ ឯសត្វនោះ តែងស្វាក់បាយ ទឹក កម្រងផ្កា និងគ្រឿងប្រដាប់ផ្សេងៗ ម្នាលព្រាហ្មណ៍ ត្រង់ដែលបុគ្គលក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយល់ខុស ជាទោសនាំឲ្យបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយនឹងពួកឆ្កែ ត្រង់ដែលបុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍ របស់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍

តេន សោ តត្ថ លាភី ហោតិ អន្នស្ស បានស្ស មាលាគន្ធាលង្ការស្ស ។ ឥធ ព្រាហ្មណ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋិកោ ហោតិ សោ ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ សោ កាយស្ស ភេទា បរម្មរណា មនុស្សានំ សហព្យតំ ឧបបជ្ជតិ សោ តត្ថ លាភី ហោតិ មានុសកានំ បញ្ចន្នំ កាមគុណានំ យំ ខោ ព្រាហ្មណ ឥធ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ

ជាគុណ នាំឲ្យបុគ្គលនោះ ជាសត្វតែងស្ទាក់បាយ ទឹក កម្រងផ្កា គ្រឿងប្រដាប់ផ្សេង ៗ ក្នុងកំណើតនាគនោះ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះ ចាកបាណាតិបាត វៀរស្រឡះ ចាកអទិន្នាទាន វៀរស្រឡះ ចាកកាមេសុមិច្ឆាចារ វៀរស្រឡះ ចាកមុសាវាទ វៀរស្រឡះ ចាកបិសុណាវាចា វៀរស្រឡះ ចាកផរុសវាចា វៀរស្រឡះ ចាកសម្ផប្បលាបៈ ជាអ្នកមិនមានអភិជ្ឈា មានចិត្តមិនព្យាបាទ មានសេចក្តីយល់ត្រូវ បុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍ របស់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ លុះបុគ្គលនោះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកមនុស្ស បុគ្គលនោះ តែងស្ទាក់នូវកាមគុណ ៥ ជារបស់មនុស្ស ក្នុងកំណើតនៃមនុស្សនោះ ម្នាលព្រាហ្មណ៍ ត្រង់ដែលបុគ្គល ក្នុងលោកនេះ ជាអ្នកវៀរស្រឡះ ចាកបាណាតិបាត វៀរស្រឡះ ចាកអទិន្នាទាន

កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋិកោ ហោតិ តេន សោ កាយស្ស ភេទា បរម្មរណា មនុស្សានំ សហព្យតំ ឧបបជ្ជតិ យញ្ច ខោ សោ ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេន សោ តត្ថ លាភី ហោតិ មានុសកានំ បញ្ចន្នំ កាមគុណានំ ។ ឥធ បន ព្រាហ្មណ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សម្មាទិដ្ឋិកោ ហោតិ សោ ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ

វៀរស្រឡះ ចាកកាមេសុ មិច្ឆាចារ វៀរស្រឡះ ចាកមុសាវាទ វៀរស្រឡះ ចាកបិសុណាវាចា វៀរស្រឡះ ចាកផរុសវាចា វៀរស្រឡះ ចាកសម្ផប្បលាបៈ ជាអ្នកមិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវ ជាគុណនាំឲ្យបុគ្គលនោះ បែកធ្លាយរាង៍កាយ ស្លាប់ទៅ ទៅកើតជាមួយនឹងពួកមនុស្ស គ្រន់ដែលបុគ្គលជា អ្នកឲ្យបាយទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍ របស់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ ជាគុណ បណ្តាលឲ្យបុគ្គលនោះ ទៅជាអ្នកស្កាក់ នូវកាមគុណ ៥ ជារបស់មនុស្ស ក្នុងកំណើតនៃមនុស្សនោះ ៗ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ វៀរស្រឡះ ចាកបាណាតិបាត ៗ បេ ៗ មានសេចក្តីយល់ត្រូវ ប៉ុន្តែបុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍ របស់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍

សោ កាយស្ស ភេទា បរម្មរណា ទេវានំ សហព្យតំ ឧបបជ្ជតិ សោ តត្ថ លាភី ហោតិ ទិព្វានំ បញ្ចន្នំ កាមគុណានំ យំ ខោ ព្រាហ្មណ ឥធ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សម្មាទិដ្ឋិកោ ហោតិ តេន សោ កាយស្ស ភេទា បរម្មរណា ទេវានំ សហព្យតំ ឧបបជ្ជតិ យញ្ច ខោ សោ ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេន សោ តត្ថ លាភី ហោតិ ទិព្វានំ បញ្ចន្នំ កាមគុណានំ អបិច ព្រាហ្មណ ទាយកោបិ អនិប្ផលោតិ ។ អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម យាវញ្ចិទំ ភោ គោតម អលមេវ ទាតុំ អលំ សទ្ធានិ កាតុំ យត្រ ហិ នាម ទាយកោបិ អនិប្ផលោតិ ។

បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយពួកទេវតា ទេវតានោះ ជាអ្នកស្កាក់ទ្បវកាមគុណ ៥ ជាទិព្វ ក្នុងទេវលោកនោះ ម្នាលព្រាហ្មណ៍ ត្រង់ដែលបុគ្គល ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត ។ បេ ។ មានសេចក្តីយល់ត្រូវ ជាគុណនាំឲ្យបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាមួយពួកទេវតា ត្រង់ដែលបុគ្គលនោះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ គ្រឿងឧបករណ៍ របស់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ ជាគុណនាំឲ្យបុគ្គលនោះ ជាអ្នកស្កាក់ទ្បវកាមគុណ ៥ ជាទិព្វ ក្នុងទេវលោកនោះ ម្នាលព្រាហ្មណ៍ ក៏ធម្មតាអ្នកឲ្យទាន មិនមែនជាគ្មានផល ឡើយ ។ ជាណុស្សោណិព្រាហ្មណ៍ ទូលថា បពិត្រព្រះគោតម ដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះគោតម ដ៏ចំរើន ចម្លែកណាស់ បពិត្រព្រះគោតម ដ៏ចំរើន ដំណើរនេះ គួរណាស់តែឲ្យទាន គួរណាស់តែធ្វើ ដែលគេគប្បីធ្វើដោយសទ្ធា ព្រោះថា អ្នកឲ្យទាន មិនមែនជាគ្មានផលឡើយ ។

ឯវមេតំ ព្រាហ្មណ ឯវមេតំ ព្រាហ្មណ ទាយកោបិ[១] ព្រាហ្មណ អនិប្ផលោតិ ។ អភិក្កន្តំ ភោ គោតម ។បេ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

ទុតិយោ ជាណុស្សោណិវគ្គោ ។

---

១ ឱ. ម. ទាយកោបិ ហិ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អើព្រាហ្មណ៍ ដំណើរនុ៎ះ យ៉ាងហ្នឹងឯង អើព្រាហ្មណ៍ ដំណើរនុ៎ះ យ៉ាងហ្នឹងឯង អើព្រាហ្មណ៍ អ្នកឲ្យទាន មិនមែនជាគ្មានផលទេ ។ ជាណុស្សោណិព្រាហ្មណ៍ ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះតទៅ ។

ចប់ ជាណុស្សោណិវគ្គ ទី ២ ។

# តតិយោ សុទ្ធវគ្គោ

(៦៧) សាធុញ្ច វោ ភិក្ខវេ ទេសិស្សាមិ អសាធុញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមញ្ច ភិក្ខវេ អសាធុំ(១) ។ បាណាតិបាតោ អទិន្នាទានំ កាមេសុ មិច្ឆាចារោ មុសាវាទោ បិសុណាវាចា ផរុសាវាចា សម្ផប្បលាបោ អភិជ្ឈា ព្យាបាទោ មិច្ឆាទិដ្ឋិ ឥទំ វុច្ចតិ ភិក្ខវេ អសាធុំ ។ កតមញ្ច ភិក្ខវេ សាធុំ(២) ។ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អនភិជ្ឈា អព្យាបាទោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ ភិក្ខវេ សាធុន្តិ(៣) ។

---

១ ម. អសាធុ ។ ២ ម. សាធុ ។ ៣ ម. សាធូតិ ។

# សុទ្ធវគ្គ ទី ៣

(៦៧) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង កម្មល្អផង កម្មមិនល្អផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគ ដូច្នេះថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កម្មមិនល្អ តើដូចម្តេច ។ គឺ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនល្អ ។ ម្នាលភិក្ខុទាំងឡាយ កម្មល្អ តើដូចម្តេច ។ គឺ ចេតនាជាហេតុវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ ការមិនមានអភិជ្ឈា មិនមានព្យាបាទ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មល្អ ។

(៦៨) អរិយធម្មញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនរិយធម្មញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អនរិយោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អនរិយោ ធម្មោ ។ កតមោ ច ភិក្ខវេ អរិយោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អរិយោ ធម្មោតិ ។

(៦៩) កុសលញ្ច វោ ភិក្ខវេ ទេសិស្សាមិ អកុសលញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមញ្ច ភិក្ខវេ អកុសលំ ។

(៦៨) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែង អរិយធម៌ (ធម៌ដ៏ប្រសើរ) ផង អនរិយធម៌ (ធម៌មិនប្រសើរ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អនរិយធម៌ តើដូចម្តេច ។ គឺ បាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនរិយធម៌ ។ ម្នាលភិក្ខុទាំងឡាយ អរិយធម៌ តើដូចម្តេច ។ គឺ ចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អរិយធម៌ ។

(៦៩) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែង កុសលកម្មផង អកុសលកម្មផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អកុសលកម្ម តើដូចម្តេច ។

បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ ឥទំ វុច្ចតិ ភិក្ខវេ អកុសលំ ។ កតមញ្ច ភិក្ខវេ កុសលំ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ ឥទំ វុច្ចតិ ភិក្ខវេ កុសលន្តិ ។

(៧០) អត្ថញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនត្ថញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អនត្ថោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អនត្ថោ ។ កតមោ ច ភិក្ខវេ អត្ថោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អត្ថោតិ ។

គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អកុសលកម្ម ។ ម្នាលភិក្ខុទាំងឡាយ កុសលកម្ម តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កុសលកម្ម ។

(៧០) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងធម៌ ដែលមានប្រយោជន៍ផង ឥតប្រយោជន៍ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ឥតប្រយោជន៍ តើដូចម្តេច ។ គឺ បាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មានប្រយោជន៍ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌មានប្រយោជន៍ ។

(៧១) ធម្មញ្ច វោ ភិក្ខវេ ទេសេស្សាមិ អធម្មញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អធម្មោ ។ កតមោ ច ភិក្ខវេ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ធម្មោតិ ។

(៧២) សាសវញ្ច វោ ភិក្ខវេ ទេសេស្សាមិ អនាសវញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ សាសវោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ សាសវោ ធម្មោ ។

(៧១) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវធម៌ផង នូវអធម៌ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធម៌ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ ។

(៧២) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែង នូវសាសវធម៌ (ធម៌ប្រកបដោយអាសវៈ) ផង អនាសវធម៌ (ធម៌មិនមានអាសវៈ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សាសវធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សាសវធម៌ ។

កតមោ ច ភិក្ខវេ អនាសវោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អនាសវោ ធម្មោតិ ។

(៧៣) សាវជ្ជញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ អនវជ្ជញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ សាវជ្ជោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ សាវជ្ជោ ធម្មោ ។ កតមោ ច ភិក្ខវេ អនវជ្ជោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អនវជ្ជោ ធម្មោតិ ។

ម្នាលភិក្ខុទាំងឡាយ អនាសវធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនាសវធម៌ ។

(៧៣) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវសាវជ្ជធម៌ (ធម៌ប្រកបដោយទោស) ផង អនវជ្ជធម៌ (ធម៌មិនមានទោស) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សាវជ្ជធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សាវជ្ជធម៌ ។ ម្នាលភិក្ខុទាំងឡាយ អនវជ្ជធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនវជ្ជធម៌ ។

(៧៤) តបនិយញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ អតបនិយញ្ច តំ សុណាថ ។បេ។ កតមោ ច ភិក្ខវេ តបនិយោ ធម្មោ ។ បាណាតិបាតោ ។បេ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ តបនិយោ ធម្មោ ។ កតមោ ច ភិក្ខវេ អតបនិយោ ធម្មោ ។ បាណាតិបាតា វេរមណី ។បេ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អតបនិយោ ធម្មោតិ ។

(៧៥) អាចយគាមិញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ អបចយគាមិញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អាចយគាមី ធម្មោ ។ បាណាតិបាតោ ។បេ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អាចយគាមី ធម្មោ ។

(៧៨) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវតបនិយធម៌ (ធម៌ដែលធ្វើសត្វឲ្យក្តៅ) ផង អតបនិយធម៌ (ធម៌ដែលមិនធ្វើសត្វឲ្យក្តៅ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តបនិយធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា តបនិយធម៌ ។ ម្នាលភិក្ខុទាំងឡាយ អតបនិយធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អតបនិយធម៌ ។

(៧៩) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង អាចយគាមិធម៌ (ធម៌ដល់នូវការសន្សំបាប) ផង អបចយគាមិធម៌ (ធម៌មិនដល់នូវការសន្សំបាប) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អាចយគាមិធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាចយគាមិធម៌ ។

កតមោ ច ភិក្ខវេ អបចយគាមី ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អបចយគាមី ធម្មោតិ ។

[៧៦] ទុក្ខុទ្រយញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ សុខុទ្រយញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ ទុក្ខុទ្រយោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ទុក្ខុទ្រយោ ធម្មោ ។ កតមោ ច ភិក្ខវេ សុខុទ្រយោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ សុខុទ្រយោ ធម្មោតិ ។

ម្នាលភិក្ខុទាំងឡាយ អបចយគាមិធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អបចយគាមិធម៌ ។

(៧៦) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវទុក្ខុទ្រយធម៌ (ធម៌ចំរើនសេចក្តីទុក្ខ) ផង សុខុទ្រយធម៌ (ធម៌ចំរើនសេចក្តីសុខ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ទុក្ខុទ្រយធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខុទ្រយធម៌ ។ ម្នាលភិក្ខុទាំងឡាយ សុខុទ្រយធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុខុទ្រយធម៌ ។

(៧៧) ទុក្ខវិបាកញ្ច វោ ភិក្ខវេ ធម្មំ ទេសិ-ស្សាមិ សុខវិបាកញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទ-វោច កតមោ ច ភិក្ខវេ ទុក្ខវិបាកោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ទុក្ខវិបាកោ ធម្មោ ។ កតមោ ច ភិក្ខវេ សុខវិបាកោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ សុខវិបាកោ ធម្មោតិ ។

តតិយោ សុត្តវគ្គោ ។

(៧៧) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវទុក្ខវិបាកធម៌ (ធម៌ឲ្យផលជាទុក្ខ) ផង សុខវិបាកធម៌ (ធម៌ឲ្យផលជាសុខ) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងឡាយនោះ ទទួលតបព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទុក្ខវិបាកធម៌ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខវិបាកធម៌ ។ ម្នាលភិក្ខុទាំងឡាយ សុខវិបាកធម៌ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុខវិបាកធម៌ ។

ចប់ សុត្តវគ្គ ទី ៣ ។

# ចតុត្ថោ សេដ្ឋវគ្គោ

(៧៨) អរិយមគ្គញ្ច វោ ភិក្ខវេ ទេសិស្សាមិ អនរិយមគ្គញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ អនរិយោ មគ្គោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អនរិយោ មគ្គោ ។ កតមោ ច ភិក្ខវេ អរិយោ មគ្គោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អរិយោ មគ្គោតិ ។

(៧៩) កណ្ហមគ្គញ្ច វោ ភិក្ខវេ ទេសិស្សាមិ សុក្កមគ្គញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ កណ្ហោ មគ្គោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ កណ្ហោ មគ្គោ ។ កតមោ ច ភិក្ខវេ សុក្កោ មគ្គោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ សុក្កោ មគ្គោតិ ។

# សេដ្ឋវគ្គ ទី ៤

(៧៨) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង ផ្លូវដ៏ប្រសើរផង ផ្លូវមិនប្រសើរផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ផ្លូវមិនប្រសើរ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផ្លូវមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ផ្លូវប្រសើរ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផ្លូវប្រសើរ ។

(៧៩) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង ផ្លូវខ្មៅផង ផ្លូវសផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ផ្លូវខ្មៅ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផ្លូវខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ផ្លូវស តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផ្លូវស ។

(៨០) សទ្ធម្មញ្ច វោ ភិក្ខវេ[១] ទេសិស្សាមិ អសទ្ធម្មញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ អសទ្ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អសទ្ធម្មោ ។ កតមោ ច ភិក្ខវេ សទ្ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ សទ្ធម្មោតិ ។

(៨១) សប្បុរិសធម្មញ្ច វោ ភិក្ខវេ ទេសិស្សាមិ អសប្បុរិសធម្មញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ អសប្បុរិសធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសធម្មោ ។ កតមោ ច ភិក្ខវេ សប្បុរិសធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសធម្មោតិ ។

---

១ ម. ឯត្ថន្តរេ ធម្មន្តិ បាឋោ ទិស្សតិ ។

(៨០) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវសទ្ធម្ម (ធម៌ស្ងប់រម្ងាប់) ផង អសទ្ធម្ម (ធម៌មិនស្ងប់រម្ងាប់) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្ដាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អសទ្ធម្ម តើដូចម្ដេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ សទ្ធម្ម តើដូចម្ដេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ នេះហៅថា សទ្ធម្ម ។

(៨១) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នូវសប្បុរិសធម៌ (ធម៌របស់សប្បុរស) ផង អសប្បុរិសធម៌ (ធម៌របស់អសប្បុរស) ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្ដាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរិសធម៌ តើដូចម្ដេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសធម៌ តើដូចម្ដេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរិសធម៌ ។

(៨២) ឧប្បាទេតព្ពញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន ឧប្បាទេតព្ពញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ ន ឧប្បាទេតព្ពោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ន ឧប្បាទេតព្ពោ ធម្មោ ។ កតមោ ច ភិក្ខវេ ឧប្បាទេតព្ពោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ឧប្បាទេតព្ពោ ធម្មោតិ(១) ។

(៨៣) អាសេវិតព្ពញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន អាសេវិតព្ពញ្ច(២) តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ ន អាសេវិតព្ពោ ធម្មោ ។

---

១ ម. ឥតោ បរំ ឧប្បាទេតព្ពញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ អនុប្បាទេតព្ពញ្ច តំ សុណាថ ។ កតមោ ច ភិក្ខវេ ឧប្បាទេតព្ពោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ឧប្បាទេតព្ពោ ធម្មោ ។ កតមោ ច ភិក្ខវេ អនុប្បាទេតព្ពោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អនុប្បាទេតព្ពោ ធម្មោតិ ឥមេ បាឋា ហោន្តិ ។ ២ ម. នាសេវិតព្ពញ្ច ។

(៨២) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដែលគួរ ឲ្យកើតឡើងផង ធម៌ដែលមិនគួរ ឲ្យកើតឡើងផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរ ឲ្យកើតឡើង តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរឲ្យកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរឲ្យកើតឡើង តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរឲ្យកើតឡើង ។

(៨៣) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងធម៌ដែលគេ គួរសេពផង ធម៌ដែលគេមិនគួរសេពផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគេ មិនគួរសេព តើដូចម្តេច ។

បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ន អាសេវិតព្វោ ធម្មោ ។ កតមោ ច ភិក្ខវេ អាសេវិតព្វោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អាសេវិតព្វោ ធម្មោតិ ។

(៨៦) ភាវេតព្វញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន ភាវេតព្វញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ ន ភាវេតព្វោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ន ភាវេតព្វោ ធម្មោ ។ កតមោ ច ភិក្ខវេ ភាវេតព្វោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ភាវេតព្វោ ធម្មោតិ ។

(៨៩) ពហុលីកាតព្វញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន ពហុលីកាតព្វញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ ន ពហុលីកាតព្វោ ធម្មោ ។

គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគេមិនគួរសេព ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគេគួរសេព តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគេគួរសេព ។

(៨៤) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ ដែលគួរបំរើនផង ធម៌ដែលមិនគួរបំរើនផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលមិនគួរបំរើន តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរបំរើន ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលគួរបំរើន តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរបំរើន ។

(៨៥) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងធម៌ដែលគេគួរធ្វើឲ្យច្រើនផង ធម៌ដែលគេ មិនគួរធ្វើឲ្យច្រើនផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគេ មិនគួរធ្វើឲ្យច្រើន តើដូចម្តេច ។

បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ន ពហុលីកាតព្វោ ធម្មោ ។ កតមោ ច ភិក្ខវេ ពហុលីកាតព្វោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ពហុលីកាតព្វោ ធម្មោតិ ។

(៨៦) អនុស្សរិតព្វញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន អនុស្សរិតព្វញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ ន អនុស្សរិតព្វោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ន អនុស្សរិតព្វោ ធម្មោ ។ កតមោ ច ភិក្ខវេ អនុស្សរិតព្វោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ អនុស្សរិតព្វោ ធម្មោតិ ។

គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគេ មិនគួរធ្វើឲ្យច្រើន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគេ គួរធ្វើឲ្យច្រើន តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគេ គួរធ្វើឲ្យច្រើន ។

(៨៦) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ដែលគួរនឹករកផង ធម៌ដែលមិនគួរនឹករកផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរនឹករក តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរនឹករក ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរនឹករក តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិ-បាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរនឹករក ។

[៨៧] សច្ឆិកាតព្វញ្ច វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ ន សច្ឆិកាតព្វញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ ន សច្ឆិកាតព្វោ ធម្មោ ។ បាណាតិបាតោ ។ បេ ។ មិច្ឆាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ ន សច្ឆិកាតព្វោ ធម្មោ ។ កតមោ ច ភិក្ខវេ សច្ឆិកាតព្វោ ធម្មោ ។ បាណាតិបាតា វេរមណី ។ បេ ។ សម្មាទិដ្ឋិ អយំ វុច្ចតិ ភិក្ខវេ សច្ឆិកាតព្វោ ធម្មោតិ ។

ចតុត្ថោ សេដ្ឋវគ្គោ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ផង ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេច ។ គឺបាណាតិបាត ។ បេ ។ មិច្ឆាទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលមិនគួរធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេច ។ គឺចេតនាជាហេតុវៀរចាកបាណាតិបាត ។ បេ ។ ការយល់ឃើញត្រូវ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ។

ចប់ សេដ្ឋវគ្គ ទី៤ ។

# បញ្ចមោ សេវិតព្វាសេវិតព្វវគ្គោ

(៨៨) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បុគ្គលោ ន សេវិតព្វោ ។ កតមេហិ ទសហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុមិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋិកោ ហោតិ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ បុគ្គលោ ន សេវិតព្វោ ។ ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បុគ្គលោ សេវិតព្វោ ។ កតមេហិ ទសហិ ។ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុមិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ

## សេវិតព្វាសេវិតព្វវគ្គ ទី ៥

(៨៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ មិនគួរសេពគប់ឡើយ ។ ធម៌ ១០ ប្រការ តើដូចម្ដេច ។ គឺបុគ្គលជាអ្នកសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាម ១ ពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ១ ពោលពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ ១ ជាអ្នកច្រើនដោយអភិជ្ឈា ១ មានចិត្តព្យាបាទ ១ មានសេចក្ដីយល់ខុស ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការនេះឯង មិនគួរសេពគប់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ ទើបគួរសេពគប់ ។ ធម៌ ១០ ប្រការ តើដូចម្ដេច ។ គឺបុគ្គលជាអ្នកវៀរស្រឡះចាកបាណាតិបាត ១ វៀរស្រឡះចាកអទិន្នាទាន ១ វៀរស្រឡះចាកកាមេសុមិច្ឆាចារ ១ វៀរស្រឡះចាកមុសាវាទ ១ វៀរស្រឡះចាកបិសុណាវាចា ១ វៀរស្រឡះចាកផរុសវាចា ១

សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋិកោ ហោតិ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ សេវិតព្វោតិ ។ (ឥធ ទ្វិសតានិ សុត្តានិ បេយ្យាលវសេន គណិតព្វំ) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បុគ្គលោ ន ភជិតព្វោ ... ភជិតព្វោ ... ន បយិរុបាសិតព្វោ ... បយិរុបាសិតព្វោ ... ន បុជ្ជោ(១) ហោតិ ... បុជ្ជោ(២) ហោតិ ... ន បាសំសោ ហោតិ ... បាសំសោ ហោតិ ... អគារវោ ហោតិ ... សគារវោ ហោតិ ... អប្បតិស្សោ ហោតិ ... សប្បតិស្សោ ហោតិ ... ន អារាធកោ ហោតិ, ... អារាធកោ ហោតិ ... ន វិសុជ្ឈតិ ... វិសុជ្ឈតិ ... ឋានំ នាធិគោតិ ... ឋានំ អធិគោតិ ... បញ្ញាយ ន វឌ្ឍតិ ... បញ្ញាយ វឌ្ឍតិ ... ពហុំ អបុញ្ញំ បសវតិ ... ពហុំ បុញ្ញំ បសវតិ ។

---

១ ២ ម. បូជា ។

វៀរស្រឡះ ចាកសម្ផប្បលាបៈ១ ជាអ្នកមិនមានអភិជ្ឈា១ មិនមានចិត្តព្យាបាទ១ មានសេចក្តីយល់ត្រូវ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការនេះឯង ទើបគួរសេពគប់ ។ (ក្នុងទីនេះបណ្ឌិតត្រូវរកប់សូត្រមាន ២០០ សូត្រជាដើម ដោយអំណាចបេយ្យាលៈ)

ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ មិនគួរគប់រកឡើយ . . . គួរគប់រក . . មិនគួរចូលទៅអង្គុយជិត . . . គួរចូលទៅអង្គុយជិត . . . ជាបុគ្គលមិនគួរបូជា . . . គួរបូជា . . . មិនគួរសរសើរ . . . គួរសរសើរ . . . មិនគួរគោរព . . . គួរគោរព . . . មិនគួរកោតក្រែង . . . គួរកោតក្រែង . . . មិនគួរប្រាសប្រាណ . . . គួរប្រាសប្រាណ . . . មិនបរិសុទ្ធ . . . បរិសុទ្ធ . . . មិនគ្រប់សង្កត់នូវមានះ . . . គ្រប់សង្កត់នូវមានះ . . . មិនចំរើនដោយប្រាជ្ញា . . . ចំរើនដោយប្រាជ្ញា . . . រមែងបានបាបច្រើន . . . រមែងបានបុណ្យច្រើន ។

កតមេហិ ទសហិ ។ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុ-សាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋិកោ ហោតិ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ បុគ្គលោ ពហុំ បុញ្ញំ បសវតិ ។

បញ្ចមោ សេវិតព្វាសេវិតព្វវគ្គោ ។

## ចតុត្ថោ ចតុត្ថបណ្ណាសកោ ។

ចុះបុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ តើដូចម្តេច ។ បុគ្គលជាអ្នកវៀរស្រឡះចាកបាណាតិបាត ១ វៀរស្រឡះចាកអទិន្នាទាន ១ វៀរស្រឡះចាកកាមេសុមិច្ឆាចារ ១ វៀរស្រឡះចាកមុសាវាទ ១ វៀរស្រឡះចាកបិសុណាវាចា ១ វៀរស្រឡះចាកផរុសវាចា ១ វៀរស្រឡះចាកសម្ផប្បលាបៈ ១ មិនមានអភិជ្ឈា ១ មិនមានចិត្តព្យាបាទ ១ មានសេចក្តីយល់ត្រូវ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយធម៌ ១០ ប្រការនេះឯង រមែងបានទទួលបុណ្យច្រើន ។

ចប់ សេវិតព្វាសេវិតព្វវគ្គ ទី ៥ ។

## ចប់ ចតុត្ថបណ្ណាសក ទី ៤ ។

# បញ្ចមបណ្ណាសកេ

## បឋមោ បឋមវគ្គោ

(៨៩) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ទសហិ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ លុទ្ទោ(១) លោហិតបាណី ហតប្បហតេ(២) និវិដ្ឋោ អទយាបន្នោ សព្វបាណភូតេសុ អទិន្នាទាយី ហោតិ យំ តំ បរស្ស បរវិត្តូបករណំ គាមគតំ វា អរញ្ញគតំ វា (៣) អទិន្នំ ថេយ្យសង្ខាតំ អាទាតា ហោតិ កាមេសុ មិច្ឆាចារី ហោតិ យា តា មា-តុរក្ខិតា បិតុរក្ខិតា ភាតុរក្ខិតា ភគិនិរក្ខិតា ញាតិរក្ខិតា ធម្មរក្ខិតា សស្សាមិកា សបរិទណ្ឌា អន្តមសោ មាលាគុណបរិក្ខិត្តាបិ តថារូបាសុ ចារិត្តំ អាបជ្ជិតា ហោតិ មុសាវាទី ហោតិ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគតោ វា បូគមជ្ឈគតោ វា

---

១ ឱ. ម. រុទ្ទោ ។ ២ ម. បហតបហតេ ។ ៣ ឱ. ម. ឯត្ថន្តរេ នត្ថិ បាឋោ ទិស្សតិ ។

# បញ្ចមបណ្ណាសក

## បឋមវគ្គទី ១

[៨៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ទំនងជាធ្លាក់ទៅក្នុងនរក ដូចជាគេនាំទៅទំលាក់ ។ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ អ្នកមានចិត្តអាក្រក់ អ្នកមានបាតដៃប្រឡាក់ដោយឈាម តាំងនៅខ្ជាប់ក្នុងការសម្លាប់រឿយ ៗ មិនដល់នូវសេចក្ដីអាណិតអាសូរ ចំពោះសព្វសត្វទាំងឡាយ ១ ជាអ្នកលួចទ្រព្យគេ គឺថាជាអ្នកកាន់យកនូវគ្រឿងឧបករណ៍ ជាសម្បត្តិនៃបុគ្គលដទៃ ដែលគេមិនបានឲ្យ ពោលគឺការលួច ដែលជាទ្រព្យ ឋិតនៅ ក្នុងស្រុកក្ដី ឋិតនៅ ក្នុងព្រៃក្ដី ១ ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ អ្នកដល់នូវការប្រព្រឹត្តកន្លង ចំពោះស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្ដី មានអាជ្ញា (កំណត់ទុក) ដោយហោចទៅ សូម្បីតែស្ត្រីដែលមានគេបំពាក់កម្រងផ្កា ១ ជាអ្នកនិយាយកុហក គឺទោះបីឋិតនៅក្នុងពេនក្ដី ឋិតនៅក្នុងបរិសទ្យក្ដី ឋិតនៅក្នុងកណ្ដាលនៃញាតិក្ដី ឋិតនៅក្នុងកណ្ដាលសេនីក្ដី

រាជកុលមជ្ឈគតោ វា អភិនីតោ សក្ខី បុដ្ឋោ ឯហិ ភោ(១) បុរិស យំ ជានាសិ តំ វទេហីតិ សោ អជានំ វា អាហ(២) ជានាមីតិ ជានំ វា អាហ ន ជានាមីតិ អបស្សំ វា អាហ បស្សាមីតិ បស្សំ វា អាហ ន បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសា ភាសិតា ហោតិ បិសុណវាចោ ហោតិ ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ សមគ្គានំ ភេត្តា ភិន្នានំ(៣) អនុប្បទាតា វគ្គារាមោ វគ្គរតោ វគ្គនន្ទី វគ្គករណឹ វាចំ ភាសិតា ហោតិ ផរុសវាចោ ហោតិ យា សា វាចា អណ្ឌកា កក្កសា បរកដុកា បរាភិសជ្ជនី កោធសាមន្តា អសមាធិសំវត្តនិកា

---

១ ឱ ម. ឯហម្ភោ ។ ២ ឱ. ម. អហំ ។ ៣ ឱ. សមគ្គានំ វា ភេត្តា ភិន្នានំ វាតិ ទិស្សតិ ។ ប. សមគ្គានំ វា ភេទកា ភិន្នានំ វាតិ ទិស្សតិ ។

បិតនៅ ក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំមក សួរជាសាក្សីថា នែបុរសអើយ ចូរអ្នកចូលមកអាយ បើអ្នកដឹងនូវហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុរសនោះ កាលបើមិនដឹង ក៏និយាយថា ខ្ញុំដឹង ក៏មាន កាលបើដឹង និយាយថា ខ្ញុំមិនដឹង ក៏មាន កាលបើមិនឃើញនិយាយថា ខ្ញុំឃើញក៏មាន កាលបើឃើញនិយាយថា ខ្ញុំមិនឃើញក៏មាន ជាអ្នកពោលនូវពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុសំណូក គឺ អាមិសៈបន្តិចបន្តួចក្តី ១ ជាអ្នកពោលពាក្យញុះញង់ គឺឮពាក្យអំពីសំណាក់ជននេះ ហើយនាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឬ ឮពាក្យអំពីសំណាក់ជនឯណោះ មកប្រាប់ជនឯណេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកបំបែកនូវពួកជនដែលព្រមព្រៀងគ្នា អ្នកជំរុលពួកជនដែលបែកគ្នាហើយ អ្នកត្រេកអរក្នុងពួក មានតម្រេកក្នុងពួក អ្នករីករាយក្នុងពួក អ្នកពោលវាចាធ្វើឲ្យប្រកាន់ពួកដូច្នេះ អ្នកពោលពាក្យអាក្រក់ អ្នកពោលពាក្យទ្រគោះ ខ្ទោះខ្ទរ ពេលពាល ដល់អ្នកដទៃ ដៀមដាម ដល់អ្នកដទៃ ជាពាក្យជិតសេចក្តីក្រោធ មិនប្រព្រឹត្តទៅ ដើម្បីសមាធិ ១

តំ ឯវរូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបី ហោតិ អកាលវាទី អភូតវាទី អនត្ថវាទី អធម្មវាទី អវិនយវាទី អនិធានវតឹ វាចំ ភាសិតា ហោតិ អកាលេន(១) អនបទេសំ អបរិយន្តវតឹ អនត្ថសញ្ហិតំ អភិជ្ឈាលុ ហោតិ យំ តំ បរស្ស បរវិត្តុបករណំ តំ អភិជ្ឈិតា ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ ព្យាបន្នចិត្តោ ហោតិ បទុដ្ឋមនសង្កប្បោ ឥមេ សត្តា ហញ្ញន្តុ វា វជ្ឈន្តុ វា ឧច្ឆិជ្ជន្តុ វា វិនស្សន្តុ វា មា វា អហេសុន្តិ(២) មិច្ឆាទិដ្ឋិកោ ហោតិ វិបរីត-ទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា

---

១ ឱ. ម. អកាលេន ។ ២ ឱ. ម. អហេសុំ ឥតិ វាតិ ។

ជាអ្នកពោលពាក្យ ឥតប្រយោជន៍ គឺពោលពាក្យខុសកាល ពោលពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពាក្យដែលមិនគួរ ឲ្យអ្នកផងគាំទ្រទុកក្នុងហឫទ័យ ជាពាក្យខុសកាល មិនមានគ្រឿងអាង មិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ១ ជាអ្នកច្រើនដោយអភិជ្ឈា សំឡឹងគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃណាថា ឱហ្ន៎ គ្រឿងឧបករណ៍នោះ គប្បីបានមកអញ ១ ជាអ្នកមានចិត្តព្យាបាទ ជាអ្នកមានតម្រិះក្នុងចិត្តដែលប្រទុស្តហើយថា សត្វទាំងឡាយនេះ ចូរលំបាកខ្លះ ចូរបែកគ្នាខ្លះ ចូរសាបសូន្យទៅខ្លះ កុំកើតមានឡើយខ្លះ ១ ជាអ្នកមានគំនិតយល់ខុស ជាអ្នកយល់ឃើញសេចក្តីវិបរីតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ផលវិបាករបស់កុសលាកុសលកម្ម ដែលសត្វធ្វើល្អនិងធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាក៏មិនមាន បិតាមិនមាន សត្វទាំងឡាយជាឧបបាតិកៈកំណើត មិនមាន សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោកជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ

យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ទសហិ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ គាមគតំ វា អរញ្ញគតំ វា អទិន្នំ ថេយ្យសង្ខាតំ ន(១) អាទាតា ហោតិ កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ យា តា មាតុរក្ខិតា បិតុរក្ខិតា ភាតុរក្ខិតា

---

១ ឱ. ម. ន តំ អទិន្នំ ថេយ្យសង្ខាតំ ទិស្សតិ ។

ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម របស់ខ្លួន ហើយសំដែងប្រាប់ មិនមាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបព្រមដោយធម៌ ១០ នេះឯង នឹងធ្លាក់ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះ នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅដម្កល់ទុក ។ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ ជាអ្នកអៀនខ្មាស ដល់នូវសេចក្តីអាណិតអាសូរ អ្នកមានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ ដល់សព្វសត្វ ១ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ជាអ្នកមិនលួចទ្រព្យគេដែលជាគ្រឿងឧបករណ៍ គឺ សម្បត្តិនៃបុគ្គលដទៃ ដែលជាទ្រព្យឋិតនៅក្នុងស្រុកក្តី ឋិតនៅក្នុងព្រៃក្តី ដែលគេមិនឲ្យ ពោលគឺការលួច ១ លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ អ្នកមិនដល់នូវការប្រព្រឹត្តកន្លងបំពានស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា

ភគិនិរក្ខិតា ញាតិរក្ខិតា ធម្មរក្ខិតា សស្សាមិកា សបរិទណ្ឌា អន្តមសោ មាលាគុណបរិក្ខិត្តាបិ ឯតា-រូបាសុ ច ចារិត្តំ អាបជ្ជិតា ហោតិ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគ្គតោ វា បូគមជ្ឈគ្គតោ វា រាជកុលមជ្ឈគ្គតោ វា អភិនីតោ សក្ខី បុដ្ឋោ ឯហិ ភោ បុរិស យំ ជានាសិ តំ វទេហីតិ សោ អជានំ វា អាហ ន ជានាមីតិ ជានំ វា អាហ ជានាមីតិ អបស្សំ វា អាហ ន បស្សាមីតិ បស្សំ វា អាហ បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា ន សម្បជានមុសា ភា-សិតា ហោតិ បិសុណវាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ន ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ

បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្ដី មានអាជ្ញា (កំណត់ទុក) ដោយហោចទៅ សូម្បីតែស្ត្រីដែលគេបំពាក់កម្រងផ្កា ១ លះបង់នូវមុសាវាទ វៀរចាកមុសាវាទ ទោះបើឋិតនៅ ក្នុងរោងក្ដី ឋិតនៅក្នុងបរិសទ្យក្ដី ឋិតនៅ ក្នុងកណ្ដាលនៃញាតិក្ដី ឋិតនៅ ក្នុងកណ្ដាលសេនីក្ដី ឋិតនៅ ក្នុងកណ្ដាលនៃរាជត្រកូលក្ដី ដែលគេនាំមកសួរជាសាក្សីថា នែបុរសអើយ ចូរអ្នកចូលមកអាយ អ្នកដឹងនូវហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុរសនោះ កាលមិនដឹងនិយាយថា ខ្ញុំមិនដឹងក៏មាន កាលដឹងនិយាយថា ខ្ញុំដឹងក៏មាន កាលមិនឃើញនិយាយថា ខ្ញុំមិនឃើញក៏មាន កាលឃើញនិយាយថា ខ្ញុំឃើញក៏មាន ជាអ្នកមិនពោលនូវពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុនៃខ្លួនក្ដី ព្រោះហេតុនៃបុគ្គលដទៃក្ដី ព្រោះហេតុសំណូកគឺអាមិសៈបន្តិចបន្តួចក្ដី ១ លះបង់នូវបិសុណាវាចា វៀរចាកបិសុណាវាចា ឮពាក្យអំពីសំណាក់ជននេះ ហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឬ ឮពាក្យអំពីសំណាក់ជនឯណោះ មិននាំមកប្រាប់ដល់ជននេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកផ្សះផ្សាពួកជនដែលបែកគ្នា ឬជាអ្នកទំនុកបំរុងនូវពួកជនដែលព្រមព្រៀង ជាអ្នកត្រេកអរ ក្នុងការព្រមព្រៀង

សមគ្គារតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ផរុសវាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនិយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា ហោតិ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ អនភិជ្ឈាលុ ហោតិ យន្តំ បរស្ស បរវិត្តុបករណំ តំ អនភិជ្ឈិតា ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ អព្យាបន្នចិត្តោ ហោតិ អប្បទុដ្ឋមនសង្កប្បោ ឥមេ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តូតិ

ជាអ្នកមានតម្រេក ក្នុងសេចក្តីព្រមព្រៀង ជាអ្នករីករាយ ក្នុងការព្រមព្រៀង ពោលវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀងគ្នា ១ លះបង់ផរុស-វាចា វៀរចាកផរុសវាចា ជាអ្នកពោលតែវាចាដែលមិនមានទោស ជាវាចាស្រួលដល់ត្រចៀក គួរឲ្យគេស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជាវាចាអ្នកបុរី ជាទីស្រឡាញ់នៃជនច្រើន ជាសំដីពេញចិត្តនៃជនច្រើន ១ លះបង់នូវសម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ជាអ្នកពោលត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យដែលជាវិន័យ ពោលពាក្យដែលគួរឲ្យគេតាំងទុក ជាពាក្យត្រូវតាមកាល ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបព្រមដោយប្រយោជន៍ ១ ជាអ្នកមិនមានអភិជ្ឈា ជាអ្នកមិនគយគន់នូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃថា ឱហ្ន៎ គ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះគប្បីបានមកអញ ដូច្នេះឡើយ ១ ជាអ្នកមានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្តដែលទោស មិនប្រទូស្តថា សត្វទាំងឡាយនេះ កុំបង់ពៀរគ្នា កុំព្យាបាទគ្នា កុំមានទុក្ខ ចូររក្សាខ្លួន ឲ្យបានសេចក្តីសុខចុះ ១

សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(៩០) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ទសហិ ។ បាណាតិបាតី ហោតិ ។ បេ ។ មិច្ឆាទិដ្ឋិកោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។

ជាអ្នកយល់ត្រូវ ឃើញសេចក្តីមិនវិបរីតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ការបូជាតូច មានផល ផលវិបាក នៃកុសលាកុសលកម្ម ដែលបុគ្គលធ្វើល្អនិងអាក្រក់ មាន លោកនេះ មាន លោកខាងមុខ មាន មាតា មាន បិតា មាន សត្វទាំងឡាយ ជាឧបបាតិកៈកំណើត មាន សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និង លោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយសំដែងប្រាប់ មាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង នេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅដម្កល់ទុក ។

(៩០) ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ប្រកបដោយធម៌១០ យ៉ាង នឹងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ។ បេ ។ ជាអ្នកយល់ខុស ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ១០ យ៉ាង នេះឯង នឹងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។

ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ទសហិ ។ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សម្មាទិដ្ឋិកោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(៩១) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ឧបាសិកា យថាភតំ និក្ខិត្តា ឯវំ និរយេ ។ កតមេហិ ទសហិ ។ បាណាតិបាតិនី ហោតិ ។ បេ ។ មិច្ឆាទិដ្ឋិកា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតា ឧបាសិកា យថាភតំ និក្ខិត្តា ឯវំ និរយេ ។ ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ឧបាសិកា យថាភតំ និក្ខិត្តា ឯវំ សគ្គេ ។ កតមេហិ ទសហិ ។ បាណាតិបាតា បដិវិរតា ហោតិ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ប្រកបដោយធម៌ ១០ យ៉ាង នឹងទៅកើតឯឋានសួគ៌ ដូចជាគេនាំយកទៅដម្កល់ទុក ។ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ ជាអ្នកយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ប្រកបដោយធម៌ ១០ យ៉ាង នេះឯង នឹងទៅកើតឯឋានសួគ៌ ដូចជាគេនាំយកទៅដម្កល់ទុក ។

(៩១) ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ប្រកបដោយធម៌ ១០ យ៉ាង នឹងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ។ បេ ។ ជាអ្នកយល់ខុស ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាងនេះឯង នឹងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ១០ យ៉ាង នឹងទៅកើតឯឋានសួគ៌ ដូចជាគេនាំយកទៅដម្កល់ទុក ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ។ បេ ។

សម្មាទិដ្ឋិកា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតា ឧបាសិកា យថាភតំ និក្ខិត្តា ឯវំ សគ្គេតិ ។

(៩២) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ឧបាសិកា អវិសារទា អគារំ អជ្ឈាវសតិ ។ កតមេហិ ទសហិ ។ បាណាតិបាតិនី ហោតិ ។ បេ ។ មិច្ឆាទិដ្ឋិកា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតា ឧបាសិកា អវិសារទា អគារំ អជ្ឈាវសតិ ។ ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតា ឧបាសិកា វិសារទា អគារំ អជ្ឈាវសតិ ។ កតមេហិ ទសហិ ។ បាណាតិបាតា បដិវិរតា ហោតិ ។ បេ ។ សម្មាទិដ្ឋិកា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតា ឧបាសិកា វិសារទា អគារំ អជ្ឈាវសតីតិ ។

ជាអ្នកយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ប្រកបដោយធម៌ ១០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅដម្កល់ទុក ។

[៩២] ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ប្រកបដោយធម៌ ១០ យ៉ាង ជាអ្នកមិនក្លៀវក្លាគ្រប់គ្រងផ្ទះ ។ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ។ បេ ។ ជាអ្នកយល់ខុស ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ប្រកបដោយធម៌ ១០ យ៉ាងនេះឯង ជាអ្នកមិនក្លៀវក្លា គ្រប់គ្រងផ្ទះ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ប្រកបដោយធម៌ ១០ យ៉ាងជាអ្នកក្លៀវក្លា គ្រប់គ្រងផ្ទះ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ ជាអ្នកយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ប្រកបដោយធម៌ ១០ យ៉ាង នេះឯង ជាអ្នកក្លៀវក្លា គ្រប់គ្រងផ្ទះ ។

(៩៣) សំសប្បតិបរិយាយំ(១) វោ ភិក្ខវេ ធម្មបរិយាយំ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច(២) ភិក្ខវេ សំសប្បតិបរិយាយោ ធម្មបរិយាយោ ។ កម្មស្សកា ភិក្ខវេ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករោន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ លុទ្ទោ លោហិតបាណី ហតប្បហតេ និវិដ្ឋោ អទយាបន្នោ សព្វបាណភូតេសុ ។ សោ សំសប្បតិ កាយេន សំសប្បតិ វាចាយ សំសប្បតិ មនសា ។ តស្ស ជិម្ហំ កាយកម្មំ ហោតិ ជិម្ហំ វចីកម្មំ ជិម្ហំ

១ ឱ. សំសប្បនិយបរិយាយំ ។ ម. សំសប្បនីយំ ។ ២ ឱ. ឯត្ថន្តរេ សោតិ បាឋោ ទិស្សតិ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម្មបរិយាយ ជាហេតុនៃសេចក្តីរន្ធត់ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ធ្វើទុកក្នុងចិត្តឲ្យប្រពៃ តថាគតនឹងសំដែង ។ ពួកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម្មបរិយាយជាហេតុនៃសេចក្តីរន្ធត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក ទោះធ្វើនូវកម្មណា ជាបុណ្យក្តី ជាបាបក្តី រមែងជាទាយាទនៃកម្មនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ មានចិត្តអាក្រក់ មានបាតដៃប្រឡាក់ដោយឈាម តាំងនៅខ្ជាប់ក្នុងការសម្លាប់រឿយ ៗ មិនមានសេចក្តីរន្ធត់អាណិតអាសូរ ចំពោះពួកសត្វទាំងពួង ។ បុគ្គលនោះរមែងរន្ធត់ដោយកាយ រន្ធត់ដោយវាចា រន្ធត់ដោយចិត្ត ។ បុគ្គលនោះឈ្មោះថា មានកាយកម្ម វៀច (វេញវេញ) វចីកម្ម វៀច

មនោកម្មំ ជិម្ហំ គតិ ជិម្ហា ឧបបត្តិ(១) ។ ជិម្ហគតិ-កស្ស ខោ បនាហំ ភិក្ខវេ ជិម្ហូបបត្តិកស្ស ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ យេ វា ឯកន្តទុក្ខា និរយា យា វា សំសប្បជាតិកា តិរច្ឆានយោនិ ។ កតមា ច សា ភិក្ខវេ សំសប្បជាតិកា តិរច្ឆាន-យោនិ អហិ វិច្ឆិកា សតបទី នកុលា ពិឡារា(២) មូសិកា ឧលូកា យេ វា បនញ្ញេបិ កេចិ តិរ-ច្ឆានយោនិកា សត្តា មនុស្សេ ទិស្វា សំសប្បន្តិ ។ ឥតិ ខោ ភិក្ខវេ ភូតា ភូតស្ស ឧបបត្តិ ហោតិ ។ យំ ករោតិ តេន ឧបបជ្ជតិ ឧបបន្នមេនំ ផស្សា ផុសន្តិ ឯវមហំ ភិក្ខវេ កម្មទាយាទា សត្តាតិ វទាមិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ អទិន្នាទាយី ហោតិ ... កាមេសុ មិច្ឆាចារី ហោតិ ... មុសា-វាទី ហោតិ ... បិសុណាវាចោ ហោតិ ... ផរុសវាចោ ហោតិ ... សម្ផប្បលាបី ហោតិ ...

---

១ ឱ. ម. ជិម្ហុបបត្តិ ។ ២ ម. នង្គុលពិឡារា ។

មនោកម្ម វៀច គតិ វៀច ឧបបត្តិ (ការកើតឡើង) ក៏វៀច ៗ ម្នាលភិក្ខុទាំងឡាយ បណ្ដាគតិទាំងពីររបស់សត្វ មានគតិ វៀច មានឧបបត្តិ វៀច តថាគតពោលនូវគតិណាមួយគឺនិរយគតិ មានទុក្ខតែម្យ៉ាង ឬតិរច្ឆានយោនិគតិ មានជាតិដ៏វង្វត់ ៗ ម្នាលភិក្ខុទាំងឡាយ តិរច្ឆាន-យោនិគតិ ប្រកបដោយវង្វត់នោះ តើដូចម្ដេច គឺពស់ ខ្យួយ ក្អែប ស្កា សំពោច កណ្ដុរ មៀម ឬក៏ពួកសត្វ កើតក្នុងកំណើតតិរច្ឆានណាមួយ ក្រៅពីនេះ ឃើញមនុស្សទាំងឡាយហើយ ក៏រមែងវង្វត់ ៗ ម្នាលភិក្ខុទាំងឡាយ ឧបបត្តិរបស់សត្វ តាមសភាវៈ រមែងមានដោយប្រការដូច្នេះឯង ៗ បុគ្គលធ្វើនូវកម្មណា រមែងកើតឡើងដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ (របស់វិបាក) ក៏រមែងពាល់ត្រូវនូវបុគ្គលដែលកើតមកនោះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សត្វទាំងឡាយ មានកម្មជាទាយាទ យ៉ាងនេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លួចយកទ្រព្យដែលគេមិនបានឲ្យ... ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ... ពោលពាក្យកុហក ... មានសំដីញុះញង់ ... មានសំដីអាក្រក់ ... ពោលពាក្យឥតប្រយោជន៍ ...

អភិជ្ឈាលុ ហោតិ... ព្យាបន្នចិត្តោ ហោតិ...
មិច្ឆាទិដ្ឋិកោ ហោតិ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ
យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ
វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ
នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ
លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិ-
បន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ
អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ សោ សំសប្បតិ
កាយេន សំសប្បតិ វាចាយ សំសប្បតិ មនសា ។
តស្ស ជិម្ហំ កាយកម្មំ ហោតិ ជិម្ហំ វចីកម្មំ ជិម្ហំ
មនោកម្មំ ជិម្ហា គតិ ជិម្ហុបបត្តិ ។ ជិម្ហគតិកស្ស
ខោ បនាហំ ភិក្ខវេ ជិម្ហុបបត្តិកស្ស ទ្វិន្នំ គតីនំ
អញ្ញតរំ គតឹ វទាមិ យេ វា ឯកន្តទុក្ខា
និរយា យា វា សំសប្បជាតិកា តិរច្ឆានយោនិ ។

មានចិត្តប្រើនដោយអភិជ្ឈា . . .  មានចិត្តព្យាបាទ · · ·  ជាមិច្ឆាទិដ្ឋិ យល់ឃើញសេចក្តីវិបរីតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ផលវិបាករបស់កុសលាកុសលកម្ម ដែលសត្វធ្វើល្អនិងអាក្រក់ មិនមាន លោកនេះ មិនមាន លោកខាងមុខ មិនមាន មាតា មិនមាន បិតា មិនមាន សត្វទាំងឡាយជាឧបបាតិកៈកំណើត មិនមាន សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោក អ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួន ហើយសំដែងប្រាប់ មិនមាន ។ បុគ្គលនោះ រមែងវេ្ងតដោយកាយ វេ្ងតដោយវាចា វេ្ងតដោយចិត្ត ។ បុគ្គលនោះឈ្មោះថា មានកាយកម្មវៀច វចីកម្មវៀច មនោកម្មវៀច គតិវៀច ឧបបត្តិវៀច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាគតិពីរយ៉ាងរបស់សត្វ មានគតិវៀច មានឧបបត្តិវៀច តថាគតពោលគតិណាមួយ គឺនិរយគតិ មានទុក្ខតែម្យ៉ាង ឬតិរច្ឆានយោនិគតិ មានជាតិវេ្ងត ។

កតមា ច សា ភិក្ខវេ សំសប្បជាតិកា តិរច្ឆានយោនិ អហិ វិច្ឆិកា សតបទី នកុលា ពិឡារា មូសិកា ឧលូកា យេ វា បនញ្ញេបិ កេចិ តិរច្ឆានយោនិកា សត្តា មនុស្សេ ទិស្វា សំសប្បន្តិ ។ ឥតិ ខោ ភិក្ខវេ ភូតា ភូតស្ស ឧបបត្តិ ហោតិ ។ យំ ករោតិ តេន ឧបបជ្ជតិ ឧបបន្នមេនំ ផស្សា ផុសន្តិ ឯវមហំ ភិក្ខវេ កម្មទាយាទា សត្តាតិ វទាមិ ។ កម្មស្សកា ភិក្ខវេ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករោន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ តិរច្ឆានយោនិគតិ ប្រកបដោយជាតិវេទ្ធត់នោះ តើអ្វីខ្លះ គឺពស់ ខ្ទួយ ក្អែប ស្កា សំពោច កណ្ដុរ មៀម ឬក៏ពួកសត្វកើតក្នុងកំណើតតិរច្ឆានណាមួយ ក្រៅពីនេះ ឃើញមនុស្សហើយរមែងវេទ្ធត់ ៗ ម្នាលភិក្ខុទាំងឡាយ ឧបបត្តិនៃសត្វ តាមសភាវៈរមែងមានដោយប្រការដូច្នេះឯង ៗ បុគ្គលធ្វើនូវកម្មណា រមែងកើតដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ (របស់វិបាក) រមែងពាល់ត្រូវនូវបុគ្គលដែលកើតមកនោះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថាសត្វទាំងឡាយ មានកម្មជាទាយាទយ៉ាងនេះឯង ៗ ម្នាលភិក្ខុទាំងឡាយសត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក ទោះធ្វើនូវកម្មណាជាបុណ្យក្ដី ជាបាបក្ដី រមែងជាទាយាទនៃកម្មនោះ ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់នូវបាណាតិបាតវៀរចាក បាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាវុធដាក់ចុះហើយ ជាអ្នកអៀនខ្មាស មានសេចក្ដីអាណិតអាសូរ មានសេចក្ដីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ · ៗ

សោ ន សំសប្បតិ កាយេន ន សំសប្បតិ វាចាយ ន សំសប្បតិ មនសា ។ តស្ស ឧជុ(១) កាយកម្មំ ហោតិ ឧជុ វចីកម្មំ ឧជុ មនោកម្មំ ឧជុ គតិ ឧជុបបត្តិ ។ ឧជុគតិកស្ស ខោ បនាហំ ភិក្ខវេ ឧជុបបត្តិកស្ស ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ យេ វា ឯកន្តសុខា សគ្គា យានិ វា បន តានិ ឧច្ចាកុលានិ ខត្តិយមហាសាលកុលានិ វា ព្រាហ្ម-ណមហាសាលកុលានិ វា គហបតិមហាសាលកុលានិ វា អឌ្ឍានិ មហទ្ធនានិ មហាភោគានិ ពហុតជាតរូប-រជតានិ ពហុតវិត្តូបករណានិ ពហុតធនធញ្ញានិ ។ ឥតិ ខោ ភិក្ខវេ ភូតា ភូតស្ស ឧបបត្តិ ហោតិ ។ យំ ករោតិ តេន ឧបបជ្ជតិ ឧបបន្នមេនំ ផស្សា ផុសន្តិ ឯវមហំ ភិក្ខវេ កម្មទាយាទា សត្តាតិ វទាមិ ។

---

១ ឱ. ឧជុំ ។

បុគ្គលនោះ រមែងមិនវេទ្ធត់ដោយកាយ មិនវេទ្ធត់ដោយវាចា មិនវេទ្ធត់ដោយចិត្ត ។ បុគ្គលនោះឈ្មោះថា មានកាយកម្មត្រង់ វចីកម្មត្រង់ មនោកម្មត្រង់ គតិត្រង់ ឧបបត្តិត្រង់ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាគតិទាំងពីរ របស់សត្វមានគតិត្រង់ មានឧបបត្តិត្រង់ តថាគតពោលនូវគតិណាមួយ គឺសត្វទាំងឡាយដែលមានសុខតែម្យ៉ាង ឬពួកត្រកូលខ្ពស់ ដែលជាត្រកូលខត្តិយមហាសាល ឬព្រាហ្មណមហាសាល ឬក៏គហបតិមហាសាល ដែលជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាស និងប្រាក់ច្រើន មានសម្បត្តិ និងគ្រឿងឧបករណ៍ច្រើន មានទ្រព្យ និងស្រូវច្រើន ។ ម្នាលភិក្ខុទាំងឡាយ ឧបបត្តិនៃសត្វតាមសភាវៈ រមែងមានដោយប្រការដូច្នេះឯង ។ បុគ្គលធ្វើនូវកម្មណា រមែងកើតដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ (របស់វិបាក) រមែងពាល់ត្រូវ នូវបុគ្គល ដែលកើតមកនោះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សត្វទាំងឡាយ មានកម្មជាទាយាទ យ៉ាងនេះឯង ។

ឥធ បន ភិក្ខវេ ឯកច្ចោ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ... កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ... មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ... បិសុណាវាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ... ផរុសវាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ... សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ... អនភិជ្ឈាលុ ហោតិ... អព្យាបន្នចិត្តោ ហោតិ... សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។

បញ្ចមបណ្ណាសក បឋមវគ្គ

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ... លះបង់ការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ... លះបង់មុសាវាទ វៀរចាក មុសាវាទ ... លះបង់ បិសុណាវាចា វៀរចាក បិសុណាវាចា ... លះបង់ផរុសវាចា វៀរចាកផរុសវាចា ... លះបង់សម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ... មិនច្រើនដោយអភិជ្ឈា... មានចិត្តមិនព្យាបាទ ... ជាសម្មាទិដ្ឋិ មានសេចក្តីយល់ឃើញមិនវិបរីតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ការបូជាតូច មានផល ផលវិបាករបស់កុសលាកុសលកម្ម ដែលសត្វធ្វើល្អនិងអាក្រក់ មាន លោកនេះមាន លោកខាងមុខ មាន មាតា មាន បិតា មាន សត្វទាំងឡាយ ជាឧបបាតិកៈកំណើត មាន ពួកសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវលោកនេះ និងលោកខាងមុខ ដោយបញ្ញាដ៏ឧត្តម របស់ខ្លួនហើយសំដែងប្រាប់ មាន ។

សោ ន សំសប្បតិ កាយេន ន សំសប្បតិ
វាចាយ ន សំសប្បតិ មនសា ។ តស្ស ឧជុ
កាយកម្មំ ហោតិ ឧជុ វចីកម្មំ ឧជុ មនោកម្មំ
ឧជុ គតិ ឧជុបបត្តិ ។ ឧជុគតិកស្ស ខោ
បនាហំ ភិក្ខវេ ឧជុបបត្តិកស្ស ទ្វិន្នំ គតីនំ អញ្ញ-
តរំ គតឹ វទាមិ យេ វា ឯកន្តសុខា សគ្គា
យានិ វា បន តានិ ឧច្ចាកុលានិ ខត្តិយមហាសាល-
កុលានិ វា ព្រាហ្មណមហាសាលកុលានិ វា គហ-
បតិមហាសាលកុលានិ វា អឌ្ឍានិ មហទ្ធនានិ
មហាភោគានិ ពហុតជាតរូបរជតានិ ពហុតវិត្តូបករ-
ណានិ ពហុតធនធញ្ញានិ ។ ឥតិ ខោ ភិក្ខវេ
ភូតា ភូតស្ស ឧបបត្តិ ហោតិ ។ យំ ករោតិ
តេន ឧបបជ្ជតិ ឧបបន្នមេនំ ផស្សា ផុសន្តិ
ឯវមហំ ភិក្ខវេ កម្មទាយាទា សត្តាតិ វទាមិ ។

បុគ្គលនោះ រមែងមិនរន្ធត់ដោយកាយ មិនរន្ធត់ដោយវាចា មិនរន្ធត់ដោយចិត្ត ។ បុគ្គលនោះ លោកហៅថា មានកាយកម្មត្រង់ វចីកម្មត្រង់ មនោកម្មត្រង់ មានគតិត្រង់ មានឧបបត្តិត្រង់ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាគតិទាំងពីរ របស់សត្វមានគតិត្រង់ មានឧបបត្តិត្រង់ តថាគតពោលនូវគតិណាមួយ គឺ សត្វទាំងឡាយដែលមានសុខតែម្យ៉ាង ឬពួកត្រកូលខ្ពស់ ៗ ដែលជាត្រកូលខត្តិយមហាសាល ឬព្រាហ្មណមហាសាល ឬគហបតីមហាសាល ដែលជាត្រកូល ស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាស នឹងប្រាក់ច្រើន មានសម្បត្តិ នឹងគ្រឿងឧបករណ៍ច្រើន មានទ្រព្យ នឹងស្រូវច្រើន ។ ម្នាលភិក្ខុទាំងឡាយ ឧបបត្តិនៃសត្វតាមសភាវៈ រមែងមានដោយប្រការដូច្នេះឯង ។ បុគ្គលធ្វើនូវកម្មណា រមែងកើតឡើងដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ (របស់វិបាក)រមែងពាល់ត្រូវនូវបុគ្គលដែលកើតមកនោះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សត្វទាំងឡាយ មានកម្មជាទាយាទ យ៉ាងនេះឯង ។

កម្មស្សកា ភិក្ខវេ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករោន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវន្តិ ។ អយំ ខោ ភិក្ខវេ សំសប្បតិបរិយាយោ ធម្មបរិយាយោតិ(១) ។

(៩៤) នាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវិទិត្វា(២) ព្យន្តិភាវំ វទាមិ តញ្ច ខោ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ(៣) វា អបរេ វា បរិយាយេ ។ ន ត្វេវាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវិទិត្វា ទុក្ខស្សន្តកិរិយំ វទាមិ ។ តត្រ ភិក្ខវេ តិវិធ(៤) កាយកម្មន្តសន្ទោសព្យាបត្តិ(៥) អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា(៦) ហោតិ

១. ហោតិ ធម្មបរិយាយោ ។ ២ ម. អប្បដិសំវេទិត្វា ។ ៣ ខ. ម. ឧបបជ្ជំ ។ ៤ ខ. ម. តិវិធា ។ ៥ ម. កាយកម្មន្តសន្ទោសព្យាបត្តិ ។ ៦ ម. អកុសលំ សញ្ចេតនិកំ ទុក្ខុទ្រយំ ទុក្ខវិបាកំ ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពន្ធ មានកម្មជាទីរលឹក តែងធ្វើនូវកម្មណា ជាបុណ្យក្តី ជាបាបក្តី រមែងជាទាយាទនៃកម្មនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា ធម្មបរិយាយជាហេតុនៃសេចក្តីរន្ធត់ ។

(៩៦) ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលពោលនូវការអស់ទៅ នៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯង រមែងកើតក្នុងបច្ចុប្បន្នក៏មាន ក្នុងអត្តភាពជាលំដាប់ក៏មាន ក្នុងអត្តភាពដទៃតទៅក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនបានទទួលនូវផលនៃកម្ម ប្រកបដោយចេតនា ដែលសត្វបានធ្វើហើយ សន្សំហើយទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាអកុសលកម្មទាំងនោះ វិបត្តិគឺទោស នៃកាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល

ចតុព្វិធំ(១) វចីកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ តិវិធំ(២) មនោកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។ កថញ្ច ភិក្ខវេ តិវិធំ កាយកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ លុទ្ទោ(៣) លោហិតបាណី ហតប្បហតេ និវិដ្ឋោ អទយាបន្នោ សព្វបាណភូតេសុ អទិន្នាទាយី ហោតិ យំ តំ បរស្ស បរវិត្តូបករណំ គាមគតំ វា អរញ្ញគតំ វា អទិន្នំ ថេយ្យសង្ខាតំ អាទាតា ហោតិ កាមេសុ មិច្ឆាចារី ហោតិ យា តា មាតុរក្ខិតា បិតុរក្ខិតា ភាតុរក្ខិតា ភគិនិរក្ខិតា ញាតិរក្ខិតា ធម្មរក្ខិតា សស្សាមិកា សបរិទណ្ឌា អន្តមសោ មាលាគុណបរិក្ខិត្តាបិ តថារូបាសុ ចារិត្តំ អាបជ្ជិតា ហោតិ ។

១ ឱ. ម. ចតុព្វិធា ។ ២ តិវិធា ។ ៣ ឱ. ម. លុទ្ធោ ។

វិបត្តិគឺទោស នៃវចីកម្ម ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា មានទុក្ខជាកម្រៃ មានទុក្ខជាផល វិបត្តិគឺទោស នៃមនោកម្ម ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា មានទុក្ខជាកម្រៃ មានទុក្ខជាផល ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោសនៃកាយកម្ម ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា មានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ មានចិត្តអាក្រក់ មានបាតដៃប្រឡាក់ដោយឈាម តាំងនៅខ្ជាប់ក្នុងការសម្លាប់រឿយៗ មិនមានសេចក្តីអាណិតអាសូរ ចំពោះសព្វសត្វទាំងឡាយ ជាអ្នកលួចយកទ្រព្យដែលគេមិនបានឲ្យ ជាអ្នកកាន់យកនូវសម្បត្តិនិងគ្រឿងឧបករណ៍ នៃបុគ្គលដទៃ ជាទ្រព្យឋិតនៅក្នុងស្រុកក្តី ឋិតនៅក្នុងព្រៃក្តី ដែលគេមិនបានឲ្យ ពោលគឺការលួច ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាអ្នកដល់នូវការប្រព្រឹត្តកន្លង ក្នុងស្ត្រីទាំងឡាយ ដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា (កំណត់ទុក) ដោយហោចទៅ សូម្បីតែស្ត្រីដែលគេបំពាក់កម្រងផ្កា ។

ឥតិ ខោ ភិក្ខវេ តិវិធា កាយកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។ កថញ្ច ភិក្ខវេ ចតុព្វិធា វចីកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ មុសាវាទី ហោតិ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគ្គតោ វា បូគមជ្ឈគ្គតោ វា រាជកុលមជ្ឈគ្គតោ វា អភិនីតោ សក្ខិបុដ្ឋោ ឯហំ ភោ បុរិស យំ ជានាសិ តំ វទេហីតិ សោ អជានំ វា អាហ ជានាមីតិ ជានំ វា អាហ ន ជានាមីតិ អបស្សំ វា អាហ បស្សាមីតិ បស្សំ វា អាហ ន បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសា ភាសិតា ហោតិ បិសុណាវាចោ ហោតិ

ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោស នៃកាយកម្ម ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោស នៃវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា មានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកនិយាយពាក្យកុហក ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិសទ្យក្តី ឋិតនៅក្នុងកណ្តាលនៃញាតិក្តី ឋិតនៅក្នុងកណ្តាលនៃសេនីក្តី ឋិតនៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅសួរជាសាក្សីថា នែបុរសអើយ អ្នកចូរមកអាយ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះ បុរសនោះ កាលបើមិនដឹង និយាយថា ខ្ញុំដឹងក៏មាន កាលបើដឹង និយាយថា ខ្ញុំមិនដឹងក៏មាន កាលបើមិនឃើញ និយាយថា ខ្ញុំឃើញក៏មាន កាលបើឃើញ និយាយថា ខ្ញុំមិនឃើញក៏មាន ជាអ្នកពោលពាក្យកុហក ទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុនៃខ្លួនក្តី ហេតុនៃបុគ្គលដទៃក្តី ព្រោះសំណូកគឺអាមិសៈបន្តិចបន្តួចក្តី ជាអ្នកពោលពាក្យញុះញង់

ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ សមគ្គានំ វា ភេត្តា ភិន្នានំ វា អនុប្បទាតា វគ្គារាមោ វគ្គរតោ វគ្គនន្ទី វគ្គករណឹ វាចំ ភាសិតា ហោតិ ផរុសវាចោ ហោតិ យា សា វាចា អណ្ឌកា កក្កសា បរកដុកា បរាភិសជ្ជនី កោធសាមន្តា អសមាធិសំវត្តនិកា តថារូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបី ហោតិ អកាលវាទី អភូតវាទី អនត្ថវាទី អធម្មវាទី អវិនយវាទី អនិធានវតឹ វាចំ ភាសិតា ហោតិ អកាលេន អនបទេសំ អបរិយន្តវតឹ អនត្ថសញ្ហិតំ ។ ឯវំ ខោ ភិក្ខវេ ចតុព្វិធំ វចីកម្មន្តសន្ទោសព្យាបត្តិ អកុសល-សញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។

ឮពាក្យអំពីសំណាក់ជននេះហើយនាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឬឮពាក្យអំពីសំណាក់ជនឯណោះ មកប្រាប់ពួកជននេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកបំបែកពួកជនដែលព្រមព្រៀងគ្នាផង ជាអ្នកដំរុលពួកជនដែលបែកគ្នាស្រាប់ហើយផង មានសេចក្តីត្រេកអរក្នុងពួក រីករាយក្នុងពួក មានតម្រេកក្នុងពួក ជាអ្នកពោលវាចាធ្វើឲ្យប្រកាន់ពួក ជាអ្នកពោលពាក្យអាក្រក់ ជាអ្នកពោលពាក្យទ្រគោះខ្លោះខ្លួរ ពេលពលដល់អ្នកដទៃ ជៀមជាមដល់អ្នកដទៃ ជាវាចាជិតសេចក្តីក្រោធ មិនប្រព្រឹត្តទៅ ដើម្បីសមាធិ ជាអ្នកពោលពាក្យឥតប្រយោជន៍ ពោលពាក្យខុសកាល ពោលពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពោលពាក្យដែលមិនគួរឲ្យគេតាំងទុកក្នុងហឫទ័យ ជាពាក្យខុសកាល មិនមានគ្រឿងអាង មិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោស នៃវចីកម្ម ៤ យ៉ាង ដែលប្រកប ដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។

កថញ្ច ភិក្ខវេ តិវិធំ មនោកម្មសន្ទោសព្យាបត្តិ
អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា
ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ អភិជ្ឈាលុ
ហោតិ យំ តំ បរស្ស បរវិត្តូបករណំ តំ អភិជ្ឈិតា
ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ
ព្យាបន្នចិត្តោ ហោតិ បទុដ្ឋមនសង្កប្បោ ឥមេ សត្តា
ហញ្ញន្តុ វា វជ្ឈន្តុ វា ឧច្ឆិជ្ជន្តុ វា វិនស្សន្តុ វា
មា វា អហេសុន្តិ មិច្ឆាទិដ្ឋិកោ ហោតិ វិបរីតទស្ស-
នោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ
សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ
អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា
នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ
លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មា-
បដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ
សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ។

ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោស នៃមនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកច្រើនដោយអភិជ្ឈា សំឡឹងសម្បត្តិនិងគ្រឿងឧបករណ៍ នៃបុគ្គលដទៃថា ធ្វើដូចម្តេចហ្ន៎ សម្បត្តិនិងគ្រឿងឧបករណ៍នោះគប្បីបានមកអញ ជាអ្នកមានចិត្តព្យាបាទ គឺមានតម្រិះក្នុងចិត្ត ដែលទោសប្រទុស្តហើយថា សត្វទាំងឡាយនេះ ចូរលំបាកខ្លះ ចូរដាច់បែបទៅខ្លះ ចូរសាបសូន្យទៅខ្លះ ចូរហិនហោចទៅខ្លះ កុំកើតមានទៀតខ្លះ ជាអ្នកយល់ខុស សេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ផលវិបាកនៃកុស-លាកុសលកម្ម ដែលសត្វធ្វើល្អនិងអាក្រក់ មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមាន បិតាមិនមាន សត្វជាឧបបាតិកៈកំណើតមិនមាន សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោក ជាអ្នកប្រព្រឹត្តល្អប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយបញ្ញាដ៏ឧត្តមរបស់ខ្លួន ហើយសំដែងប្រាប់ មិនមាន ។

ឯវំ ខោ ភិក្ខវេ តិវិធំ មនោកម្មសន្ទោ-
សព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា
ទុក្ខវិបាកា ហោតិ ។ តិវិធកាយកម្មស-
ន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកាហេតុ វា
ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ
ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ចតុព្វិធវចីកម្មស-
ន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកាហេតុ វា
ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ
ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ តិវិធមនោកម្មស-
ន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកាហេតុ វា
ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ
ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ សេយ្យថាបិ
ភិក្ខវេ អបណ្ណកោ មណិ ឧទ្ធំ ខិត្តោ យេន
យេនេវ បតិដ្ឋាតិ សុប្បតិដ្ឋិតំយេវ បតិដ្ឋាតិ

ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោសនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វលុះបែកធ្លាយពន្ធកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិគឺទោសនៃកាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុ-សលចេតនាក៏មាន ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយពន្ធកាយស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិគឺទោសនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយពន្ធកាយ ស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិគឺទោសនៃមនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាគូប្បាសកា (មានជ្រុង ៤) ដែលបុគ្គលបោះទៅខាងលើហើយធ្លាក់ចុះមកត្រង់ទីណា រមែងតាំងនៅស៊ប់ ក្នុងទីនោះ ឧបមាយ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ តិវិធកាយកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកាហេតុ ភ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ចតុព្វិធវចីកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតន-និកាហេតុ ភ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ តិវិធមនោ-កម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកាហេតុ ភ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ នាហំ ភិក្ខវេ សញ្ចេតន-និកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវេទិត្វា ព្យន្តិភាវំ វទាមិ តញ្ច ខោ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។ ន ត្វេវាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវេទិត្វា ទុក្ខស្សន្តកិរិយំ វទាមិ ។

ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិគឺទោសនៃកាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន សត្វទាំងឡាយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិគឺទោសនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិគឺទោសនៃមនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលពោលនូវសេចក្តីអស់ទៅ នៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯង រមែងកើតក្នុងបច្ចុប្បន្នេះក៏មាន ក្នុងអត្តភាព ជាលំដាប់ក៏មាន ក្នុងអត្តភាព ដទៃក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលពោល នូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនទាន់បានទទួល នូវផលនៃកម្មដែលប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយទេ ។

តត្រ ភិក្ខវេ តិវិធំ កាយកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ចតុព្វិធំ វចីកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ តិវិធំ មនោកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។

កតមញ្ច ភិក្ខវេ តិវិធំ កាយកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ គាមគតំ វា អរញ្ញគតំ វា

ម្នាលភិក្ខុទាំងឡាយ បណ្ដាកុសលកម្មទាំងនោះ សម្បត្តិគឺសេចក្ដីចំរើន នៃកាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល សម្បត្តិនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល សម្បត្តិនៃមនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃកាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ ជាអ្នកអៀនខ្មាស ប្រកបដោយសេចក្ដីអាណិតអាសូរ មានសេចក្ដីអនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងឡាយ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ជាអ្នកមិនកាន់យកសម្បត្តិនិងគ្រឿងឧបករណ៍នៃបុគ្គលដទៃ ដែលជាសម្បត្តិ ឋិតនៅក្នុងស្រុកក្ដី ឋិតនៅក្នុងព្រៃក្ដី

អទិន្នំ ថេយ្យសង្ខាតំ ន អាទាតា ហោតិ កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ យា តា មាតុរក្ខិតា បិតុរក្ខិតា ភាតុរក្ខិតា ភគិនិរក្ខិតា ញាតិរក្ខិតា ធម្មរក្ខិតា សស្សាមិកា សបរិទណ្ឌា អន្តមសោ មាលាគុឡបរិក្ខិត្តាបិ តថារូបាសុ ន ចារិត្តំ អាបជ្ជិតា ហោតិ ឯវំ ខោ ភិក្ខវេ តិវិធំ កាយកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។

កថញ្ច ភិក្ខវេ ចតុព្វិធំ វចីកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគតោ វា បូគមជ្ឈគតោ វា រាជកុលមជ្ឈគតោ វា អភិនីតោ សក្ខី បុដ្ឋោ ឯហិ ភោ បុរិស យំ ជានាសិ តំ វទេហីតិ សោ អជានំ វា អាហ ន ជានាមីតិ ជានំ វា អាហ ជានាមីតិ

ដែលគេមិនបានឲ្យ ពោលគឺការលួច លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ មិនដល់នូវការប្រព្រឹត្តខុស ក្នុងស្ត្រីទាំងឡាយ ដែលមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្តី មានអាជ្ញា (កំណត់ទុក) ដោយហោចទៅសូម្បីតែស្ត្រីដែលគេបំពាក់កម្រងផ្កា ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃវចីកម្មមាន៤យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ លះបង់មុសាវាទ វៀរចាកមុសាវាទ ទោះបី ឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិសទ្យក្តី ឋិតនៅក្នុងកណ្តាល នៃញាតិក្តី ឋិតនៅក្នុងកណ្តាលនៃសេនីក្តី ឋិតនៅក្នុងកណ្តាល នៃរាជត្រកូលក្តី ដែលគេនាំទៅសួរជាសាក្សីថា នែបុរសអើយ អ្នកចូរមកអាយ បើអ្នកដឹងនូវហេតុណា ចូរនិយាយហេតុនោះ បុរសនោះ កាលមិនដឹង និយាយថា ខ្ញុំមិនដឹងក៏មាន កាលដឹង និយាយថា ខ្ញុំដឹងក៏មាន

អបស្សំ វា អាហ ន បស្សាមីតិ បស្សំ វា អាហ បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា ន សម្បជានមុសា ភាសិតា ហោតិ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ន ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ផរុសវាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនិយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី

កាលមិនឃើញ និយាយថា ខ្ញុំមិនឃើញក៏មាន កាលឃើញ និយាយថា ខ្ញុំឃើញក៏មាន ជាអ្នកមិនពោលពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុសំណូក គឺអាមិសៈបន្តិចបន្តួចក្តី លះបង់បិសុណាវាចា វៀរចាកបិសុណាវាចា ឮពាក្យពីជននេះ ហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីទឹងបំបែកពួកជននេះ ឬឮពាក្យអំពីសំណាក់ជនឯណោះ មិននាំទៅប្រាប់ជននេះ ដើម្បីទឹងបំបែកពួកជនឯណោះ ជាអ្នកពោលពាក្យផ្សះផ្សាពួកជនដែលបែកគ្នា ឬជាអ្នកទំនុកបម្រុងពួកជនដែលព្រមព្រៀងគ្នាស្រាប់ ជាអ្នកត្រេកអរ ក្នុងការព្រមព្រៀង មានតម្រេក ក្នុងសេចក្តីព្រមព្រៀង រីករាយក្នុងសេចក្តីព្រមព្រៀង ពោលវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀង លះបង់ផរុសវាចា វៀរចាកផរុសវាចា ជាអ្នកពោលតែវាចា ដែលមិនមានទោស ជាវាចាស្រួលដល់ត្រចៀក គួរឲ្យគេស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជាវាចាអ្នកក្រុង ជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន លះបង់សម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ជាអ្នកពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យជាអត្ថ ពោលពាក្យជាធម៌

វិនយវាទី និធានវតឹ វាចំ ភាសិតា ហោតិ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ឥមំ ខោ ភិក្ខវេ ចតុត្ថំ វចីកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។

កតមញ្ច ភិក្ខវេ តិវិធំ មនោកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ អនភិជ្ឈាលុ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ តំ អនភិជ្ឈិតា ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ អព្យាបន្នចិត្តោ ហោតិ អប្បទុដ្ឋមនសង្កប្បោ ឥមេ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តូតិ សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ ។ បេ ។

ពោលពាក្យជាវិន័យ ពោលពាក្យដែលគួរឲ្យគេតាំងទុក ជាពាក្យត្រូវតាមកាល ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបដោយប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផលដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ មិនច្រើនដោយអភិជ្ឈា ជាអ្នកមិនគយគន់សម្បត្តិទឹងគ្រឿងឧបករណ៍នៃបុគ្គលដទៃថា ធ្វើដូចម្តេចហ្ន៎ សម្បត្តិទឹងគ្រឿងឧបករណ៍នៃបុគ្គលដទៃ គប្បីបានមកអញ ដូច្នេះឡើយ មានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្ត ដែលពោស មិនប្រទុស្តថា សត្វទាំងឡាយនេះ កុំចងពៀរនឹងគ្នា កុំព្យាបាទនឹងគ្នា កុំមានទុក្ខចូររក្សាខ្លួន ឲ្យបានសេចក្តីសុខចុះ ជាសម្មាទិដ្ឋិ ជាអ្នកយល់ឃើញ នូវសេចក្តីមិនវិបរិតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ការបូជាតូច មានផល ។ បេ ។

យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ឯវំ ខោ ភិក្ខវេ តិវិធំ មនោកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។ តិវិធកាយកម្មន្តសម្បត្តិ កុសលសញ្ចេតនិកាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ចតុព្វិធវចីកម្មន្តសម្បត្តិ កុសលសញ្ចេតនិ-កាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តិវិធ-មនោកម្មន្តសម្បត្តិ កុសលសញ្ចេតនិកាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សេយ្យថាបិ ភិក្ខវេ អបណ្ណកោ មណិ ឧទ្ធំ ខិត្តោ

សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនឹងលោកខាងមុខ ដោយបញ្ញាដ៏ឧត្តមខ្លួនឯង ហើយសំដែងប្រាប់ ក៏មាន ម្នាលភិក្ខុទាំងឡាយ សម្បត្តិនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដោយប្រការដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិនៃកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិនៃវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោកព្រោះហេតុតែសម្បត្តិនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន ៗ ម្នាលភិក្ខុទាំងឡាយ ដូចជាគ្រាប់បាសកា(មានជ្រុង៦)ដែលបុគ្គលបោះទៅខាងលើ

យេន យេនេវ បតិដ្ឋាតិ សុប្បតិដ្ឋិតំយេវ បតិដ្ឋាតិ ឯវមេវ ខោ ភិក្ខវេ តិវិធកាយកម្មន្តសម្បត្តិ កុសលសញ្ចេតនិកាហេតុ វា សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ចតុព្វិធវចីកម្មន្តសម្បត្តិ កុសលសញ្ចេតនិកាហេតុ វា សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ តិវិធមនោកម្មន្តសម្បត្តិ កុសលសញ្ចេតនិកាហេតុ វា សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។

(៩៨) នាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវិទិត្វា ព្យន្តីភាវំ វទាមិ តញ្ច ខោ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។

ហើយធ្លាក់ចុះមក តាំងនៅត្រង់ជ្រុងណា រមែងតាំងនៅស៊ប់ ត្រង់ជ្រុងនោះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិនៃកាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន សត្វទាំងឡាយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុតែសម្បត្តិនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនាក៏មាន ។

[៩៩] ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលពោលនូវការអស់ទៅនៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯង រមែងកើតមានក្នុងបច្ចុប្បន្ននេះក៏មាន ក្នុងអត្តភាពជាលំដាប់ក៏មាន ក្នុងអត្តភាពដទៃក៏មាន ។

៨ នាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវិទិត្វា ទុក្ខស្សន្តកិរិយំ វទាមិ ។ តត្រ ភិក្ខវេ តិវិធំ កាយកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ចតុព្វិធំ វចីកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ តិវិធំ មនោកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។

កថញ្ច ភិក្ខវេ តិវិធំ កាយកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។ បេ ។ ឯវំ ខោ ភិក្ខវេ តិវិធំ កាយកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។

ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលពោល នូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនទាន់ទទួលផល នៃកម្មប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាអកុសលកម្មទាំងនោះ វិបត្តិគឺទោសនៃកាយកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល វិបត្តិគឺទោសនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល វិបត្តិគឺទោសរបស់មនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ។

ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោស របស់កាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្តេច ។បេ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោសនៃកាយកម្ម ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។

កតមញ្ច ភិក្ខវេ ចតុព្វិធំ វចីកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។ បេ ។ ឯវំ ខោ ភិក្ខវេ ចតុព្វិធំ វចីកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។

កតមញ្ច ភិក្ខវេ តិវិធំ មនោកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។ បេ ។ ឯវំ ខោ ភិក្ខវេ តិវិធំ មនោកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកា ទុក្ខុទ្រយា ទុក្ខវិបាកា ហោតិ ។ តិវិធកាយកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ចតុព្វិធវចីកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកាហេតុ វា ។ បេ ។

ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោសនៃវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្ដេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោសនៃវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោសរបស់មនោកម្មមាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល តើដូចម្ដេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិគឺទោសនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា រមែងមានទុក្ខជាកម្រៃ មានទុក្ខជាផល ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយ រាងកាយ ស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែវិបត្តិគឺទោសរបស់កាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនា ក៏មាន ព្រោះហេតុតែវិបត្តិគឺទោសរបស់វចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយអកុសលចេតនា ក៏មាន ។ បេ ។

តិវិធមនោកម្មន្តសន្ទោសព្យាបត្តិ អកុសលសញ្ចេតនិកាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ នាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវិទិត្វា ព្យន្តិការំ វទាមិ តញ្ច ខោ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។ ន ត្វេវាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវិទិត្វា ទុក្ខស្សន្តកិរិយំ វទាមិ ។ តត្រ ភិក្ខវេ តិវិធំ កាយកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ចតុព្វិធំ វចីកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ តិវិធំ មនោកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនៃវិបត្តិគឺទោសនៃមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយអកុសលចេតនាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលពោលនូវសេចក្តីអស់ទៅ នៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯង រមែងកើត ក្នុងបច្ចុប្បន្នក៏មាន ក្នុងអត្តភាព ជាលំដាប់ក៏មាន ក្នុងអត្តភាព ដទៃទៅក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនដែលពោល នូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនទទួលនូវផល នៃកម្មទាំងឡាយ ប្រកបដោយចេតនាដែលសត្វធ្វើហើយ សន្សំហើយទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកុសលកម្មទាំងនោះ សម្បត្តិគឺកាយកម្ម មាន៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល សម្បត្តិគឺវចីកម្មមាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃមានសុខជាផល សម្បត្តិគឺមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ។

កតមញ្ច ភិក្ខវេ តិវិធំ កាយកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។ បេ ។ ឯវំ ខោ ភិក្ខវេ តិវិធំ កាយកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។

កតមញ្ច ភិក្ខវេ ចតុព្វិធំ វចីកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។ បេ ។ ឯវំ ខោ ភិក្ខវេ ចតុព្វិធំ វចីកម្មន្តសម្បត្តិ ហោតិ(១) ។

កតមញ្ច ភិក្ខវេ តិវិធំ មនោកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។ បេ ។ ឯវំ ខោ ភិក្ខវេ តិវិធំ មនោកម្មន្តសម្បត្តិ កុសលសញ្ចេតនិកា សុខុទ្រយា សុខវិបាកា ហោតិ ។

---

១ ម. ចតុព្វិធា វចីកម្មន្តសម្បត្តិ កុសលំ សញ្ចេតនិកំ សុខុទ្រយំ សុខវិបាកំ ហោតីតិ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិគឺកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា មានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សម្បត្តិគឺកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិគឺវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា មានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សម្បត្តិគឺវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ សម្បត្តិគឺមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា មានសុខជាកម្រៃ មានសុខជាផល តើដូចម្តេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សម្បត្តិគឺមនោកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា រមែងមានសុខជាកម្រៃ មានសុខជាផល ដូច្នេះឯង ។

តិវិធកាយកម្មន្តសម្បត្តិ កុសលសញ្ចេតនិកាហេតុ ច ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ចតុព្វិធវចីកម្មន្តសម្បត្តិ កុសលសញ្ចេតនិកាហេតុ ច ។ បេ ។ តិវិធមនោ-កម្មន្តសម្បត្តិ កុសលសញ្ចេតនិកាហេតុ ច ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។

(៩៦) នាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវិទិត្វា ព្យន្តិភាវំ វទាមិ តញ្ច ខោ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។ ន ត្វេវាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវិទិត្វា ទុក្ខស្សន្តកិរិយំ វទាមិ ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើត ឯសុគតិសួគ៌ ទេវលោក ព្រោះហេតុតែសម្បត្តិគឺកាយកម្ម មាន ៣ យ៉ាង ដែលប្រកបដោយកុសលចេតនា ក៏មាន ព្រោះហេតុតែសម្បត្តិគឺវចីកម្ម មាន ៤ យ៉ាង ដែលប្រកបដោយកុសលចេតនា ក៏មាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើត ឯសុគតិសួគ៌ ទេវលោក ព្រោះហេតុតែសម្បត្តិគឺមនោកម្ម ដែលប្រកបដោយកុសលចេតនា ក៏មាន ។

(៩៦) ម្នាលភិក្ខុទាំងឡាយ. តថាគត មិនដែលពោលនូវសេចក្តីអស់ទៅនៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ ព្រោះមិនបានទទួលនូវផលទេ ឯផលនោះឯង រមែងកើតក្នុងបច្ចុប្បន្ន ក៏មាន ក្នុងអត្តភាពជាលំដាប់ ក៏មាន ក្នុងអត្តភាពដទៃ ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខ ព្រោះមិនបានទទួលនូវផល នៃកម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយទេ ។

ស ខោ សោ ភិក្ខវេ អរិយសាវកោ ឯវំ វិគតាភិជ្ឈោ
វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ
មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ
តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ
តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ
មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន
អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ
សោ ឯវំ បជានាតិ បុព្វេ ខោ មេ ឥទំ ចិត្តំ
បរិត្តំ អហោសិ(១) អភាវិតំ ឯតរហិ បន មេ ឥទំ ចិត្តំ
អប្បមាណំ សុភាវិតំ យំ ខោ បន កិញ្ចិ
បមាណកតំ កម្មំ ន តំ តត្រាវសិស្សតិ ន តំ
តត្រាវតិដ្ឋតិ(២) ។ តំ កឹ មញ្ញថ ភិក្ខវេ ទហ-
រគ្គេ(៣) ចេ(៤) អយំ កុមារោ មេត្តាចេតោវិមុត្តឹ
ភាវេយ្យ អបិ នុ ខោ បាបកម្មំ ករេយ្យាតិ ។

---

១ ឱ. ម. អហោសិ ។ ២ ឱ. ម. តត្រាវតិដ្ឋតីតិ ។ ៣ ម. ទហរទគ្គេ ។ ៤ ឱ. ម. ឯត្តកោ សោតិ បាឋោ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវកនោះឯង ប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ជាអ្នកមិនវង្វេង មានប្រាជ្ញាស្មារតីខ្ជាប់ខ្ជួន មានចិត្តប្រកបដោយមេត្តា ផ្សាយទៅ កាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ មានប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម ទទឹង ទិសទទឹង គឺ ទិសតូច ៗ ផ្សាយទៅ កាន់លោកទាំងមូល ដោយយកខ្លួន ទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួង ដោយប្រការដូច្នេះ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា ចិត្តអាត្មាអញនេះ ជាកាមាវចរៈ ដែលមិនបានចំរើនហើយ ក្នុងកាលមុន លុះដល់ក្នុងកាលឥឡូវនេះ ចិត្តអាត្មាអញនេះ ជាអរូបាវចរៈ ដែលបានចំរើនល្អហើយ ម្យ៉ាងទៀត កម្មណាមួយ ដែលជាកាមាវចរៈ កម្មនោះ រមែងមិនសល់នៅក្នុងចិត្តនោះ កម្មនោះមិនឋិតនៅក្នុងចិត្តនោះទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវកម្មនោះដូចម្ដេច បើកុមារនេះ ចំរើនមេត្តាចេតោវិមុត្តិ ចាប់ដើមតាំងអំពីខ្លួននៅក្មេង តើកុមារនោះ គប្បីធ្វើនូវបាបកម្ម បានដែរឬទេ ។

នោ ហេតំ ភន្តេ ។ អករោន្តំ ខោ បន បាបកម្មំ អបិនុ ខោ ទុក្ខំ ផុសេយ្យាតិ ។ នោ ហេតំ ភន្តេ អករោន្តញ្ហិ ភន្តេ បាបកម្មំ កុតោ ទុក្ខំ ផុសិស្សតីតិ (១) ។ ភាវេតព្វា ខោ បនាយំ ភិក្ខវេ មេត្តាចេតោវិមុត្តិ ឥត្ថិយា វា បុរិសេន វា ឥត្ថិយា វា ភិក្ខវេ បុរិសស្ស វា នាយំ កាយោ អាទាយ គមនីយោ ចិត្តន្តរោ អយំ ភិក្ខវេ មច្ចោ ។ សោ ឯវំ បជានាតិ យំ ខោ មេ ឥទំ(២) កិញ្ចិ បុព្វេ ឥមិនា ករជកាយេន បាបកម្មំ កតំ សព្វន្តំ ឥធ វេទនិយំ តំ អនុគភវិស្សតីតិ (៣) ។ ឯវំ ភាវិតា ខោ ភិក្ខវេ មេត្តាចេតោវិមុត្តិ អនាគាមិតាយ សំវត្តតិ ឥធ បញ្ញស្ស ភិក្ខុនោ ឧត្តរឹ វិមុត្តឹ អប្បដិវិជ្ឈតោតិ ។

---

១ ម. ផុសិស្សតិ ។ ២ ឱ. ឥធ ។ ៣ ឱ. ម. ន តំ អនុគំ ភវិស្សតីតិ ។

បពិត្រព្រះអង្គដ៏ចំរើន មិនបានទេ ។ សេចក្តីទុក្ខគប្បីពាល់ត្រូវនូវកុមារនេះ កាលដែលមិនធ្វើនូវបាបកម្ម បានដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន មិនបានទេ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា សេចក្តីទុក្ខនឹងពាល់ត្រូវអ្នកដែលមិនធ្វើ នូវបាបកម្មអំពីណាបាន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាង មេត្តាចេតោវិមុត្តិនេះ ស្ត្រីក្តី បុរសក្តី គួរចំរើនដោយពិត ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី មិនអាចកាន់យកនូវកាយនេះហើយ ទៅកាន់បរលោកទេ ម្នាលភិក្ខុទាំងឡាយ សត្វនេះ មានចិត្តជាមូលហេតុ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា បាបកម្មណាមួយ ដែលអាត្មាអញធ្វើហើយ ដោយករជកាយនេះ ក្នុងកាលមុន បាបកម្មទាំងអស់នោះ អាត្មាអញត្រូវទទួលផលក្នុងលោកនេះ បាបកម្មនោះនឹងលែងមានតទៅ ។ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលភិក្ខុអ្នកមានប្រាជ្ញា ក្នុងសាសនានេះ កាលមិនបានពិចារណា ឃើញច្បាស់នូវវិមុត្តិ គឺ អរហត្តផលតទៅ ចំរើនហើយយ៉ាងនេះ ក៏រមែងប្រព្រឹត្តទៅ ដើម្បីអនាគាមិធម៌ ។

ករុណាសហគតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ សោ ឯវំ បជានាតិ បុព្វេ ខោ មេ ឥទំ ចិត្តំ បរិត្តំ អហោសិ អភាវិតំ ឯតរហិ បន មេ ឥទំ ចិត្តំ អប្បមាណំ សុភាវិតំ យំ ខោ បន កិញ្ចិ បមាណកតំ កម្មំ ន តំ តត្រាវសិស្សតិ ន តំ តត្រាវតិដ្ឋតិ ។ តំ កឹ មញ្ញថ ភិក្ខវេ ទហរតគ្គេ ចេ អយំ កុមារោ ឧបេក្ខាចេតោវិមុត្តឹ ភាវេយ្យ អបិ នុ ខោ បាបកម្មំ ករេយ្យាតិ ។ នោ ហេតំ ភន្តេ ។ អករោន្តំ ខោ បន បាបកម្មំ អបិ នុ ខោ ទុក្ខំ ផុសេយ្យាតិ ។

ភិក្ខុមានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខា ដ៏ធំទូលាយ មានប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទឹងទិសទទឹងគឺទិសតូចៗ ផ្សាយទៅកាន់លោកទាំងមូល ដោយយកខ្លួន ទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ដោយប្រការដូច្នេះ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា ចិត្តអាត្មាអញ នេះជាកាមាវចរចិត្ត មិនទាន់បានចំរើន ក្នុងកាលមុនទេ លុះដល់ក្នុងកាលឥឡូវនេះ ចិត្តអាត្មាអញនេះ ជារូបាវចរៈដែលបានចំរើនល្អហើយ ចំណែកខាងកម្មណាមួយ ជាកាមាវចរៈ កម្មនោះនឹងមិនសល់នៅក្នុងចិត្តនោះទេ កម្មនោះមិនឋិតនៅក្នុងចិត្តនោះទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះដូចម្តេច បើកុមារនេះ ចំរើនឧបេក្ខាចេតោវិមុត្តិ ចាប់ដើមតាំងអំពីខ្លួននៅក្មេង តើគប្បីធ្វើបាបកម្មបានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន មិនបានទេ ។ សេចក្តីទុក្ខគប្បីពាល់ត្រូវនូវកុមារនោះ កាលដែលមិនធ្វើនូវបាបកម្ម ដែរឬទេ ។

នោ ហេតំ ភន្តេ អករោន្តញ្ហិ ភន្តេ បាបកម្មំ កុតោ ទុក្ខំ ផុសិស្សតីតិ ។ ភាវេតព្វា ខោ បនាយំ ភិក្ខវេ ឧបេក្ខាចេតោវិមុត្តិ ឥត្ថិយា វា បុរិសេន វា ឥត្ថិយា វា ភិក្ខវេ បុរិសស្ស វា នាយំ កាយោ អាទាយ គមនីយោ ចិត្តន្តរោ អយំ ភិក្ខវេ មច្ចោ ។ សោ ឯវំ បជានាតិ យំ ខោ មេ ឥទំ កិញ្ចិ បុព្វេ ឥមិនា ករជកាយេន បាបកម្មំ កតំ សព្វំ តំ ឥធ វេទនិយំ ន តំ អនុភវិស្សតីតិ ។ ឯវំ ភាវិតា ខោ ភិក្ខវេ ឧបេក្ខាចេតោវិមុត្តិ អនាគាមិតាយ សំវត្តតិ ឥធ បញ្ញស្ស ភិក្ខុនោ ឧត្តរឹ វិមុត្តឹ អប្បដិវិជ្ឈតោតិ ។

(៩៧) អថខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

បពិត្រព្រះអង្គដ៏ចំរើន មិនបានទេ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថាសេចក្តីទុក្ខ នឹងពាល់ត្រូវនូវអ្នកដែលមិនធ្វើបាបកម្មអំពីណាបាន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងឧបេក្ខាចេតោវិមុត្តិនេះ ស្ត្រីក្តី បុរសក្តី គួរចំរើនដោយពិត ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី មិនអាចកាន់យកនូវកាយនេះ ទៅកាន់បរលោកទេ ម្នាលភិក្ខុទាំងឡាយ សត្វនេះមានចិត្តជាមូលហេតុ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា បាបកម្មឯណាមួយ ដែលអាត្មាអញ បានធ្វើហើយ ដោយករជកាយនេះក្នុងកាលមុន បាបកម្មទាំងអស់នោះ អាត្មាអញត្រូវទទួលផល ក្នុងលោកនេះ បាបកម្មនោះនឹងលែងមានតទៅ ។ ម្នាលភិក្ខុទាំងឡាយឧបេក្ខាចេតោវិមុត្តិ ដែលភិក្ខុអ្នកមានប្រាជ្ញា ក្នុងសាសនានេះ កាលមិនបានពិចារណា ឃើញច្បាស់នូវវិមុត្តិគឺអរហត្តផលតទៅ ចំរើនហើយយ៉ាងនេះ ក៏រមែងប្រព្រឹត្តទៅ ដើម្បីជាអនាគាមិធម៌ ។

(៩៧) គ្រានោះឯងព្រាហ្មណ៍ម្នាក់ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។

ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណោ ភគវន្តំ
ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ
កោ បច្ចយោ យេនមិធេកច្ចេ សត្តា កាយស្ស
ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ
ឧបបជ្ជន្តីតិ ។ អធម្មចរិយាវិសមចរិយាហេតុ ខោ
ព្រាហ្មណ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្ម-
រណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តីតិ ។
កោ បន ភោ គោតម ហេតុ កោ បច្ចយោ
យេនមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា
សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ ធម្មចរិយ-
សមចរិយាហេតុ ខោ ព្រាហ្មណ ឯវមិធេកច្ចេ សត្តា
កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបជ្ជន្តិ(១) ។ ន ខោ អហំ ឥមស្ស ភោតោ គោត-
មស្ស សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាមិ

១ ឱ. ម. ឧបបជ្ជន្តីតិ ។

លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីសមគួរហើយ ក៏ទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកសត្វខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ សត្វពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនៃការមិនប្រព្រឹត្តធម៌ និងការប្រព្រឹត្តមិនស្មើយ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចំរើន ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតឯសុគតិសួគ៌ ទេវលោក ។ ម្នាលព្រាហ្មណ៍ សត្វទាំងឡាយ ពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ ទេវលោក ព្រោះហេតុនៃការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើយ៉ាងនេះឯង ។ ភាសិតសង្ខេបរបស់ព្រះ-គោតមដ៏ចំរើននេះខ្ញុំព្រះអង្គ មិនដឹងច្បាស់នូវសេចក្តីដោយពិស្តារបានទេ

សាធុ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុ យថាហំ ឥមស្ស ភោតោ គោតមស្ស សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានេយ្យន្តិ ។ តេនហិ ព្រាហ្មណ សុណាហិ សាធុកំ មនសិក-រោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ សោ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទ-វោច តិវិធំ ខោ ព្រាហ្មណ កាយេន អធម្មចរិយ-វិសមចរិយា ហោតិ ចតុព្វិធំ វាចាយ អធម្មចរិយ-វិសមចរិយា ហោតិ តិវិធំ មនសា អធម្មចរិយ-វិសមចរិយា ហោតិ ។

កថញ្ច ព្រាហ្មណ តិវិធំ កាយេន អធម្មចរិយ-វិសមចរិយា ហោតិ ។ បេ ។ ឯវំ ខោ ព្រាហ្មណ តិវិធំ កាយេន អធម្មចរិយវិសមចរិយា ហោតិ ។

កថញ្ច ព្រាហ្មណ ចតុព្វិធំ វាចាយ អធម្មចរិយ-វិសមចរិយា ហោតិ ។ បេ ។ ឯវំ ខោ ព្រាហ្មណ ចតុព្វិធំ វាចាយ អធម្មចរិយវិសមចរិយា ហោតិ ។

ភាសិតសង្ខេបរបស់ព្រះគោតមដ៏ចំរើននេះ ខ្ញុំព្រះអង្គ គប្បីដឹងនូវសេចក្តីដោយពិស្តារបានយ៉ាងណា សូមព្រះគោតមដ៏ចំរើន សំដែងធម៌យ៉ាងនោះដល់ខ្ញុំព្រះអង្គឲ្យបាន ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ព្រាហ្មណ៍នោះទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់សំដែងដូច្នេះថា ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ នឹងការប្រព្រឹត្តមិនស្មើ ដោយកាយមាន ៣ យ៉ាង ការមិនប្រព្រឹត្តធម៌ នឹងការប្រព្រឹត្តមិនស្មើដោយវាចា ៤ យ៉ាង ការមិនប្រព្រឹត្តធម៌ នឹងការប្រព្រឹត្តមិនស្មើដោយចិត្ត ៣ យ៉ាង ។

ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ នឹងការប្រព្រឹត្តមិនស្មើ ដោយកាយ មាន ៣ យ៉ាង តើដូចម្តេច ។ បេ ។ ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ នឹងការប្រព្រឹត្តមិនស្មើ ដោយកាយ ៣ យ៉ាងនេះឯង ។

ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ នឹងការប្រព្រឹត្តមិនស្មើ ដោយវាចា ៤ យ៉ាង តើដូចម្តេច ។ បេ ។ ម្នាលព្រាហ្មណ៍ ការមិនប្រព្រឹត្តធម៌ នឹងការប្រព្រឹត្តមិនស្មើ ដោយវាចា ៤ យ៉ាងនេះឯង ។

កតមញ្ច ព្រាហ្មណ តិវិធំ មនសា អធម្មចរិយាវិសមចរិយា ហោតិ ។ បេ ។ ឯវំ ខោ ព្រាហ្មណ តិវិធំ មនសា អធម្មចរិយាវិសមចរិយា ហោតិ ។ ឯវំ អធម្មចរិយាវិសមចរិយាហេតុ ខោ ព្រាហ្មណ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ តិវិធំ ខោ ព្រាហ្មណ កាយេន ធម្មចរិយាសមចរិយា ហោតិ ចតុព្វិធំ វាចាយ ធម្មចរិយាសមចរិយា ហោតិ តិវិធំ មនសា ធម្មចរិយាសមចរិយា ហោតិ ។

កតមញ្ច ព្រាហ្មណ តិវិធំ កាយេន ធម្មចរិយាសមចរិយា ហោតិ ។ បេ ។ ឯវំ ខោ ព្រាហ្មណ តិវិធំ កាយេន ធម្មចរិយាសមចរិយា ហោតិ ។

កតមញ្ច ព្រាហ្មណ ចតុព្វិធំ វាចាយ ធម្មចរិយាសមចរិយា ហោតិ ។ បេ ។ ឯវំ ខោ ព្រាហ្មណ ចតុព្វិធំ វាចាយ ធម្មចរិយាសមចរិយា ហោតិ ។

ម្នាលព្រាហ្មណ៍ ចុះការប្រព្រឹត្តិធម៌ នឹងការប្រព្រឹត្តិមិនស្មើ ដោយចិត្តមាន ៣ យ៉ាង តើដូចម្តេច ។ បេ ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តិធម៌នឹងការប្រព្រឹត្តិមិនស្មើ ដោយចិត្ត មាន ៣ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ សត្វពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនៃការមិនប្រព្រឹត្តិធម៌ នឹងការប្រព្រឹត្តិមិនស្មើ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តិធម៌ នឹងការប្រព្រឹត្តិស្មើ ដោយកាយ ៣ យ៉ាង ការប្រព្រឹត្តិធម៌ នឹងការប្រព្រឹត្តិស្មើ ដោយវាចា ៤ យ៉ាង ការប្រព្រឹត្តិធម៌ នឹងការប្រព្រឹត្តិស្មើ ដោយចិត្ត ៣ យ៉ាង ។

ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តិធម៌ នឹងការប្រព្រឹត្តិស្មើ ដោយកាយ មាន ៣ យ៉ាងតើដូចម្តេច ។ បេ ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តិធម៌នឹងការប្រព្រឹត្តិស្មើ ដោយកាយ ៣ យ៉ាងនេះឯង ។

ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តិធម៌ នឹងការប្រព្រឹត្តិស្មើ ដោយវាចា មាន ៤ យ៉ាង តើដូចម្តេច ។ បេ ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តិធម៌ នឹងការប្រព្រឹត្តិស្មើ ដោយវាចា ៤ យ៉ាងនេះឯង ។

កថញ្ច ព្រាហ្មណ តិវិធំ មនសា ធម្មចរិយសមចរិយា ហោតិ ។ បេ ។ ឯវំ ខោ ព្រាហ្មណ តិវិធំ មនសា ធម្មចរិយសមចរិយា ហោតិ ។ ឯវំ ធម្មចរិយសមចរិយាហេតុ ខោ ព្រាហ្មណ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ៨

បឋមោ បឋមវគ្គោ ។

ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌ នឹងការប្រព្រឹត្តស្មើ ដោយចិត្ត មាន ៣ យ៉ាង តើដូចម្តេច ។ បេ ។ ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តធម៌នឹងការប្រព្រឹត្តស្មើ ដោយចិត្ត ៣ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ សត្វពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯសុគតិសួគ៌ ទេវលោក ព្រោះហេតុនៃការប្រព្រឹត្តធម៌នឹងការប្រព្រឹត្តស្មើ យ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

ចប់ បឋមវគ្គទី ១ ។

## ទុតិយោ ទុតិយវគ្គោ

[៩៨] ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ទសហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសាវាចោ ហោតិ សម្ផប្ប-លាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋិកោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ទសហិ ។ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ

## ទុតិយវគ្គ ទី២

(៩៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ១០ យ៉ាង ទំនងធ្លាក់ទៅកាន់នរកដូចជាគេនាំយកទៅទំលាក់ ។ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ១ ជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ ជាអ្នកពោលនូវពាក្យកុហក ១ ជាអ្នកពោលនូវពាក្យញុះញង់ ១ ជាអ្នកពោលនូវពាក្យអាក្រក់ ១ ជាអ្នកពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ១ ជាអ្នកច្រើនដោយការសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ ១ ជាអ្នកមានចិត្តព្យាបាទ ១ ជាអ្នកយល់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទំនងធ្លាក់ទៅកាន់នរក ដូចជាគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ទំនងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅដំកល់ទុក ។ ធម៌ទាំង ១០ យ៉ាងតើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ វៀរចាកបិសុណាវាចា ១ វៀរចាកផរុសវាចា ១

សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋិកោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។

(៩៩) វីសតិយា ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ វីសតិយា ។ អត្តនា ច បាណាតិបាតី ហោតិ បរញ្ច បាណាតិបាតេ សមាទបេតិ អត្តនា ច អទិន្នាទាយី ហោតិ បរញ្ច អទិន្នាទានេ សមាទបេតិ អត្តនា ច កាមេសុ មិច្ឆាចារី ហោតិ បរញ្ច កាមេសុ មិច្ឆាចារេ សមាទបេតិ អត្តនា ច មុសាវាទី ហោតិ បរញ្ច មុសាវាទេ សមាទបេតិ អត្តនា ច បិសុណាវាចោ ហោតិ បរញ្ច បិសុណាយ វាចាយ សមាទបេតិ អត្តនា ច ផរុសាវាចោ ហោតិ បរញ្ច ផរុសាយ វាចាយ សមាទបេតិ

វៀរចាកសម្ផប្បលាបៈ ១ ជាអ្នកមិនប្រ័នដោយអភិជ្ឈា ១ មានចិត្តមិនព្យាបាទ ១ ជាសម្មាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅដំកល់ទុក ។

(៩៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាង ទឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ធម៌ ២០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនឲ្យ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការកាន់យកទ្រព្យដែលគេមិនឲ្យ ១ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យញុះញង់ ១ ពោលពាក្យអាក្រក់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យអាក្រក់ ១

អត្តនា ច សម្ផប្បលាបី ហោតិ បរញ្ច សម្ផប្បលាបេ សមាទបេតិ អត្តនា ច អភិជ្ឈាលុ ហោតិ បរញ្ច អភិជ្ឈាយ សមាទបេតិ អត្តនា ច ព្យាបន្នចិត្តោ ហោតិ បរញ្ច ព្យាបាទេ សមាទបេតិ អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ ។ ឥមេហិ ខោ ភិក្ខវេ វីសតិយា ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ វីសតិយា ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ វីសតិយា ។ អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ អត្តនា ច អទិន្នាទានា បដិវិរតោ ហោតិ បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ អត្តនា ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ បរញ្ច កាមេសុ មិច្ឆាចារា វេរមណិយា សមាទបេតិ

ពោលពាក្យឥតប្រយោជន៍ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យឥតប្រយោជន៍ ១ ច្រើនដោយអភិជ្ឈា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងអភិជ្ឈា ១ មានចិត្តព្យាបាទដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការព្យាបាទ ១ ជាអ្នកយល់ខុស ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការយល់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ទុក ។ ធម៌ ២០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទានដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១

អត្តនា ច មុសាវាទា បដិវិរតោ ហោតិ បរញ្ច មុសា-
វាទា វេរមណិយា សមាទបេតិ អត្តនា ច បិសុណាយ
វាចាយ បដិវិរតោ ហោតិ បរញ្ច បិសុណាយ វាចាយ
វេរមណិយា សមាទបេតិ អត្តនា ច ផរុសាយ
វាចាយ បដិវិរតោ ហោតិ បរញ្ច ផរុសាយ វាចាយ
វេរមណិយា សមាទបេតិ អត្តនា ច សម្ផប្បលាបា
បដិវិរតោ ហោតិ បរញ្ច សម្ផប្បលាបា វេរមណិយា
សមាទបេតិ អត្តនា ច អនភិជ្ឈាលុ ហោតិ បរញ្ច
អនភិជ្ឈាយ សមាទបេតិ អត្តនា ច អព្យាបន្នចិត្តោ
ហោតិ បរញ្ច អព្យាបាទេ សមាទបេតិ អត្តនា ច
សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទ-
បេតិ ។ ឥមេហិ ខោ ភិក្ខវេ វីសតិយា ធម្មេហិ
សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។

(១០០) តឹសាយ ភិក្ខវេ ធម្មេហិ សមន្នាគតោ
យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ តឹសាយ ។

វៀរចាកមុសាវាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកមុសាវាទ ១ វៀរចាកបិសុណាវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបិសុណាវាចា ១ វៀរចាកផរុសវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាបៈ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកសម្ផប្បលាបៈ ១ ជាអ្នកមិនច្រើនដោយអភិជ្ឈា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងអនភិជ្ឈា ១ មិនមានចិត្តព្យាបាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការមិនព្យាបាទ ១ ជាសម្មាទិដ្ឋិ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងសម្មាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ២០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ទុក ។

(១០០) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាងនឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ធម៌ ៣០ យ៉ាងតើអ្វីខ្លះ ។

អត្តនា ច បាណាតិបាតី ហោតិ បរញ្ច បាណាតិបាតេ សមាទបេតិ បាណាតិបាតេ ច សមនុញ្ញោ ហោតិ អត្តនា ច អទិន្នាទាយី ហោតិ បរញ្ច អទិន្នាទានេ សមាទបេតិ អទិន្នាទានេ ច សមនុញ្ញោ ហោតិ អត្តនា ច កាមេសុ មិច្ឆាចារី ហោតិ បរញ្ច កាមេសុ មិច្ឆាចារេ សមាទបេតិ កាមេសុ មិច្ឆាចារេ ច សមនុញ្ញោ ហោតិ អត្តនា ច មុសាវាទី ហោតិ បរញ្ច មុសាវាទេ សមាទបេតិ មុសាវាទេ ច សមនុញ្ញោ ហោតិ អត្តនា ច បិសុណាវាចោ ហោតិ បរញ្ច បិសុណាយ វាចាយ សមាទបេតិ បិសុណាយ ច វាចាយ សមនុញ្ញោ ហោតិ អត្តនា ច ផរុសវាចោ ហោតិ បរញ្ច ផរុសាយ វាចាយ សមាទបេតិ ផរុសាយ ច វាចាយ សមនុញ្ញោ ហោតិ អត្តនា ច សម្ផប្បលាបី ហោតិ បរញ្ច សម្ផប្បលាបេ សមាទបេតិ សម្ផប្បលាបេ ច សមនុញ្ញោ ហោតិ

គឺជាអ្នកសម្លាប់សត្វ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការសម្លាប់សត្វ ១ ពេញចិត្ត ក្នុងការសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ពេញចិត្ត ក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ ពេញចិត្ត ក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យកុហក ១ ពេញចិត្ត ក្នុងការពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការពោលពាក្យញុះញង់ ១ ពេញចិត្ត ក្នុងការពោលពាក្យញុះញង់ ១ ពោលពាក្យអាក្រក់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យអាក្រក់ ១ ពេញចិត្ត ក្នុងការពោលពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យឥតប្រយោជន៍ ១ ពេញចិត្ត ក្នុងការពោលពាក្យឥតប្រយោជន៍ ១

អត្តនា ច អភិជ្ឈាលុ ហោតិ បរញ្ច អភិជ្ឈាយ
សមាទបេតិ អភិជ្ឈាយ ច សមនុញ្ញោ ហោតិ
អត្តនា ច ព្យាបន្នចិត្តោ ហោតិ បរញ្ច ព្យាបាទេ
សមាទបេតិ ព្យាបាទេ ច សមនុញ្ញោ ហោតិ
អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆា-
ទិដ្ឋិយា ច សមាទបេតិ មិច្ឆាទិដ្ឋិយា ច សម-
នុញ្ញោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ
ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ
និរយេ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ
យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ
តីហិ ។ អត្តនា ច បាណាតិបាតា បដិវិរតោ
ហោតិ បរញ្ច បាណាតិបាតា វេរមណិយា សមាទ-
បេតិ បាណាតិបាតា វេរមណិយា ច សមនុញ្ញោ
ហោតិ អត្តនា ច អទិន្នាទានា បដិវិរតោ
ហោតិ បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ
អទិន្នាទានា វេរមណិយា ច សមនុញ្ញោ ហោតិ

ច្រើនសំឡឹងរំពៃ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការសំឡឹងរំពៃ ១ ពេញចិត្ត ក្នុងការសំឡឹងរំពៃ ១ មានចិត្តគុំគួន ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការគុំគួន ១ ពេញចិត្ត ក្នុងការគុំគួន ១ យល់ខុស ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការយល់ខុស ១ ពេញចិត្ត ក្នុងការយល់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៣០ យ៉ាងនេះឯង នឹងធ្លាក់ទៅ ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៣០ យ៉ាង នឹងទៅកើតឯឋានសួគ៌ ដូចជាគេនាំយកទៅដំកល់ទុក ។ ធម៌ ៣០ យ៉ាងតើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកបាណាតិបាត ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបាណាតិបាត ១ ពេញចិត្ត ក្នុងការវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកអទិន្នាទាន ១ ពេញចិត្ត ក្នុងការវៀរចាកអទិន្នាទាន ១

អត្តនា ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ បរញ្ច កាមេសុ មិច្ឆាចារា វេរមណិយា សមាទបេតិ កាមេសុ មិច្ឆាចារា វេរមណិយា ច សមនុញ្ញោ ហោតិ អត្តនា ច មុសាវាទា បដិវិរតោ ហោតិ បរញ្ច មុសាវាទា វេរមណិយា ច សមាទបេតិ មុសាវាទា វេរមណិយា ច សមនុញ្ញោ ហោតិ អត្តនា ច បិសុណាយ វាចាយ បដិវិរតោ ហោតិ បរញ្ច បិសុណាយ វាចាយ វេរមណិយា សមាទបេតិ បិសុណាយ វាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ អត្តនា ច ផរុសាយ វាចាយ បដិវិរតោ ហោតិ បរញ្ច ផរុសាយ វាចាយ វេរមណិយា សមាទបេតិ ផរុសាយ ច វាចាយ វេរមណិយា សមនុញ្ញោ ហោតិ អត្តនា ច សម្ផប្បលាបា បដិវិរតោ ហោតិ បរញ្ច សម្ផប្បលាបា វេរមណិយា សមនុញ្ញោ ហោតិ អត្តនា ច អភិជ្ឈាលុ ហោតិ

វៀរចាកកាមេសុមិច្ឆាចារ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១ ពេញចិត្ត ក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកមុសាវាទ ១ ពេញចិត្ត ក្នុងការវៀរចាកមុសាវាទ ១ វៀរចាកបិសុណាវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបិសុណាវាចា ១ ពេញចិត្ត ក្នុងការវៀរចាកបិសុណាវាចា ១ វៀរចាកផរុសវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកផរុសវាចា ១ ពេញចិត្ត ក្នុងការវៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាបៈ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកសម្ផប្បលាបៈ ១ ពេញចិត្ត ក្នុងការវៀរចាកសម្ផប្បលាបៈ ១ ជាអ្នកមិនមានអភិជ្ឈា ដោយខ្លួនឯង ១

បរញ្ច អនភិជ្ឈាយ សមាទបេតិ អនភិជ្ឈាយ ច សមនុញ្ញោ ហោតិ អត្តនា ច អព្យាបន្នចិត្តោ ហោតិ បរញ្ច អព្យាបាទេ សមាទបេតិ អព្យាបាទេ ច សមនុញ្ញោ ហោតិ អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ សម្មាទិដ្ឋិយា ច សមនុញ្ញោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ វីសតិយា ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(១០១) ចត្តារីសាយ(១) ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចត្តារីសាយ ។ អត្តនា ច បាណាតិបាតី ហោតិ បរញ្ច បាណាតិបាតេ សមាទបេតិ បាណាតិបាតេ ច សមនុញ្ញោ ហោតិ បាណាតិបាតស្ស ច វណ្ណំ ភាសតិ អត្តនា ច អទិន្នាទាយី ហោតិ បរញ្ច អទិន្នាទានេ សមាទបេតិ

១ ឱ.ម. ចត្តារីសាយ ។

បបួលអ្នកដទៃ ក្នុងការមិនមានអភិជ្ឈា ១ ពេញចិត្ត ក្នុងការមិនមានអភិជ្ឈា ១ មានចិត្តមិនព្យាបាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការមិនព្យាបាទ ១ ពេញចិត្ត ក្នុងការមិនព្យាបាទ ១ យល់ត្រូវ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការយល់ត្រូវ ១ ពេញចិត្ត ក្នុងការយល់ត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៣០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ទុក ។

(១០១) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៤០ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ធម៌ ៤០ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការសម្លាប់សត្វ ១ ពេញចិត្ត ក្នុងការសម្លាប់សត្វ ១ ពោលសរសើរគុណ នៃការសម្លាប់សត ១ កាន់យកទ្រព្យដែលគេមិនឲ្យ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការកាន់យកទ្រព្យ ដែលគេមិនឲ្យ ១

អទិន្នាទានេ ច សមន្នាគតោ ហោតិ អទិន្នាទានស្ស
ច វណ្ណំ ភាសតិ អត្តនា ច កាមេសុ មិច្ឆាចារី
ហោតិ បរញ្ច កាមេសុ មិច្ឆាចារេ សមាទបេតិ
កាមេសុ មិច្ឆាចារេ ច សមន្នាគតោ ហោតិ កាមេសុ
មិច្ឆាចារស្ស ច វណ្ណំ ភាសតិ អត្តនា ច មុសាវាទី
ហោតិ បរញ្ច មុសាវាទេ សមាទបេតិ មុសាវាទេ ច សម-
ន្នាគតោ ហោតិ មុសាវាទស្ស ច វណ្ណំ ភាសតិ អត្តនា
ច បិសុណាវាចោ ហោតិ បរញ្ច បិសុណាយ វាចាយ
សមាទបេតិ បិសុណាយ ច វាចាយ សមន្នាគតោ
ហោតិ បិសុណាយ ច វាចាយ វណ្ណំ ភាសតិ អត្តនា
ច ផរុសាវាចោ ហោតិ បរញ្ច ផរុសាយ វាចាយ សមា-
ទបេតិ ផរុសាយ ច វាចាយ សមន្នាគតោ ហោតិ
ផរុសាយ ច វាចាយ វណ្ណំ ភាសតិ អត្តនា ច
សម្ផប្បលាបី ហោតិ បរញ្ច សម្ផប្បលាបេ សមាទបេតិ

ពេញចិត្ត ក្នុងការកាន់យកទ្រព្យ ដែលគេមិនឲ្យ ១ ពោលសរសើរគុណ នៃការកាន់យកទ្រព្យ ដែលគេមិនឲ្យ ១ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ ពេញចិត្ត ក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ ពោលសរសើរគុណ នៃការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យកុហក ១ ពេញចិត្ត ក្នុងការពោលពាក្យកុហក ១ ពោលសរសើរគុណ នៃការពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យញុះញង់ ១ ពេញចិត្ត ក្នុងការពោលពាក្យញុះញង់ ១ ពោលសរសើរគុណ នៃការពោលពាក្យញុះញង់ ១ ពោលពាក្យអាក្រក់ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យអាក្រក់ ១ ពេញចិត្ត ក្នុងការពោលពាក្យអាក្រក់ ១ ពោលសរសើរគុណ នៃការពោលពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យ ឥតប្រយោជន៍ ១

សម្ផប្បលាបេ ច សមនុញ្ញោ ហោតិ សម្ផប្ប-លាបស្ស(១) ច វណ្ណំ ភាសតិ អត្តនា ច អភិជ្ឈាលុ ហោតិ បរញ្ច អភិជ្ឈាយ សមាទបេតិ អភិជ្ឈាយ ច សមនុញ្ញោ ហោតិ អភិជ្ឈាយ ច វណ្ណំ ភាសតិ អត្តនា ច ព្យាបន្នចិត្តោ ហោតិ បរញ្ច ព្យាបាទេ សមាទបេតិ ព្យាបាទេ ច សម-នុញ្ញោ ហោតិ ព្យាបាទស្ស ច វណ្ណំ ភាសតិ អត្ត-នា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ មិច្ឆាទិដ្ឋិយា ច សមនុញ្ញោ ហោតិ មិច្ឆាទិដ្ឋិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ភិក្ខវេ ចត្តាឡីសាយ ធម្មេហិ សមន្នាគតោ យថា-ភតំ និក្ខិត្តោ ឯវំ និរយេ ។ ចត្តាឡីសាយ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចត្តាឡីសាយ ។

១ ម. សម្ផប្បលាបេ ។

ពេញចិត្ត ក្នុងការពោលពាក្យឥតប្រយោជន៍ ១ ពោលសរសើរគុណនៃការពោលពាក្យឥតប្រយោជន៍ ១ ជាអ្នកមានអភិជ្ឈា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងអភិជ្ឈា ១ ពេញចិត្ត ក្នុងអភិជ្ឈា ១ ពោលសរសើរគុណ នៃអភិជ្ឈា ១ មានចិត្តព្យាបាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការព្យាបាទ ១ ពេញចិត្ត ក្នុងការព្យាបាទ ១ ពោលសរសើរគុណ នៃការព្យាបាទ ១ យល់ខុស ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការយល់ខុស ១ ពេញចិត្ត ក្នុងការយល់ខុស ១ ពោលសរសើរគុណ នៃការយល់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៤០ យ៉ាងនេះឯង នឹងធ្លាក់ទៅ ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៤០ យ៉ាង នឹងទៅកើត ឯស្ថានសួគ៌ ដូចជាគេនាំយកទៅ ដាក់ទុក ។ ធម៌ ៤០ យ៉ាង តើអ្វីខ្លះ ។

អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ
បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ
បាណាតិបាតា វេរមណិយា ច សមនុញ្ញោ ហោតិ
បាណាតិបាតា វេរមណិយា ច វណ្ណំ ភាសតិ អត្តនា
ច អទិន្នាទានា បដិវិរតោ ហោតិ បរញ្ច អទិន្នាទានា
វេរមណិយា សមាទបេតិ អទិន្នាទានា វេរមណិយា
ច សមនុញ្ញោ ហោតិ អទិន្នាទានា វេរមណិយា
ច វណ្ណំ ភាសតិ អត្តនា ច កាមេសុ មិច្ឆាចារា
បដិវិរតោ ហោតិ បរញ្ច កាមេសុ មិច្ឆាចារា វេរ-
មណិយា សមាទបេតិ កាមេសុ មិច្ឆាចារា វេរមណិយា
ច សមនុញ្ញោ ហោតិ កាមេសុ មិច្ឆាចារា វេរ-
មណិយា ច វណ្ណំ ភាសតិ អត្តនា ច មុសាវាទា
បដិវិរតោ ហោតិ បរញ្ច មុសាវាទា វេរមណិយា
សមាទបេតិ មុសាវាទា វេរមណិយា ច សមនុញ្ញោ
ហោតិ មុសាវាទា វេរមណិយា ច វណ្ណំ ភាសតិ

គឺជាអ្នកវៀរចាកបាណាតិបាត ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបាណាតិបាត ១ ពេញចិត្ត ក្នុងការវៀរចាកបាណាតិបាត ១ ពោលសរសើរគុណ នៃការវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរ ចាកអទិន្នាទាន ១ ពេញចិត្ត ក្នុងការវៀរចាកអទិន្នាទាន ១ ពោលសរសើរគុណ នៃការវៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរ ចាកកាមេសុមិច្ឆាចារ ១ ពេញចិត្ត ក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១ ពោលសរសើរគុណ នៃការវៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរ ចាកមុសាវាទ ១ ពេញចិត្ត ក្នុងការវៀរ ចាកមុសាវាទ ១ ពោលសរសើរគុណ នៃការវៀរចាកមុសាវាទ ១

អត្តនា ច បិសុណាយ វាចាយ បដិវិរតោ ហោតិ បរញ្ច បិសុណាយ វាចាយ វេរមណិយា សមាទបេតិ បិសុណាយ វាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ បិសុណាយ វាចាយ វេរមណិយា ច វណ្ណំ ភាសតិ អត្តនា ច ផរុសាយ វាចាយ បដិវិរតោ ហោតិ បរញ្ច ផរុសាយ វាចាយ វេរមណិយា សមាទបេតិ ផរុសាយ វាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ ផរុសាយ វាចាយ វេរមណិយា ច វណ្ណំ ភាសតិ អត្តនា ច សម្ផប្បលាបា បដិវិរតោ ហោតិ បរញ្ច សម្ផប្បលាបា វេរមណិយា សមាទបេតិ សម្ផប្បលាបា វេរមណិយា ច សមនុញ្ញោ ហោតិ សម្ផប្បលាបា វេរមណិយា ច វណ្ណំ ភាសតិ អត្តនា ច អនភិជ្ឈាលុ ហោតិ បរញ្ច អនភិជ្ឈាយ សមាទបេតិ អនភិជ្ឈាយ ច សមនុញ្ញោ ហោតិ អនភិជ្ឈាយ ច វណ្ណំ ភាសតិ អត្តនា ច អព្យាបន្នចិត្តោ ហោតិ

វៀរចាកបិសុណាវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបិសុណាវាចា ១ ពេញចិត្ត ក្នុងការវៀរ ចាកបិសុណាវាចា ១ ពោលសរសើរគុណ នៃការវៀរចាកបិសុណាវាចា ១ វៀរចាកផរុសវាចា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកផរុសវាចា ១ ពេញចិត្ត ក្នុងការវៀរចាក ផរុសវាចា ១ ពោលសរសើរគុណ នៃការវៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាបៈ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកសម្ផប្បលាបៈ ១ ពេញចិត្ត ក្នុងការវៀរចាកសម្ផប្បលាបៈ ១ ពោលសរសើរគុណ នៃការវៀរចាកសម្ផប្បលាបៈ ១ ជាអ្នកមិនមានអភិជ្ឈា ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការមិនមានអភិជ្ឈា ១ ពេញចិត្ត ក្នុងការមិនមានអភិជ្ឈា ១ ពោលសរសើរគុណ នៃការមិនមានអភិជ្ឈា ១ មិនមានចិត្តព្យាបាទ ដោយខ្លួនឯង ១

បរញ្ច អព្យាបាទេ សមាទបេតិ អព្យាបាទេ ច សមនុញ្ញោ ហោតិ អព្យាបាទស្ស ច វណ្ណំ ភាសតិ អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ សម្មាទិដ្ឋិយា ច សមនុញ្ញោ ហោតិ សម្មាទិដ្ឋិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ភិក្ខវេ ចត្តាឡីសាយ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។

(៣០២) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ខតំ ឧបហតំ អត្តានំ បរិហរតិ... អក្ខតំ អនុបហតំ អត្តានំ បរិហរតិ... វីសតិយា ភិក្ខវេ... តឹសាយ ភិក្ខវេ... ចត្តាឡីសាយ ភិក្ខវេ ធម្មេហិ សមន្នាគតោ ខតំ ឧបហតំ អត្តានំ បរិហរតិ... អក្ខតំ អនុបហតំ អត្តានំ បរិហរតិ ។ បេ ។ ឥមេហិ ខោ ភិក្ខវេ ចត្តាឡីសាយ ធម្មេហិ សមន្នាគតោ អក្ខតំ អនុបហតំ អត្តានំ បរិហរតីតិ ។

ទុតិយោ ទុតិយវគ្គោ ។

បបួលអ្នកដទៃ ក្នុងការមិនព្យាបាទ ១ ពេញចិត្ត ក្នុងការមិនព្យាបាទ ១ ពោលសរសើរគុណ នៃការមិនព្យាបាទ ១ ជាអ្នកយល់ត្រូវ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការយល់ត្រូវ ១ ពេញចិត្ត ក្នុងការយល់ត្រូវ ១ ពោលសរសើរគុណ នៃការយល់ត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាងនេះឯង ទឹងទៅកើត ឯស្ថានសួគ៌ ដូចគេនាំយកទៅដំកល់ទុក ។

(១០២) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌គាស់រំលើង ផ្តាច់ផ្តិលចោលហើយ ... ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌មិនបានគាស់រំលើង ផ្តាច់ផ្តិលចោលហើយ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២០ យ៉ាង... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាង... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាង ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌គាស់រំលើង ផ្តាច់ផ្តិលចោលហើយ ... ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌មិនបានគាស់រំលើង ផ្តាច់ផ្តិល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាងនេះឯង ឈ្មោះថា រក្សាទុកនូវខ្លួន ដែលមានកុសលធម៌ មិនបានគាស់រំលើង ផ្តាច់ផ្តិលចោលឡើយ ។

ចប់ ទុតិយវគ្គ ទី ២ ។

# តតិយោ តតិយវគ្គោ

[១០៣] ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឯកច្ចោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ... ឯកច្ចោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ... វីសតិយា ភិក្ខវេ... តឹសាយ ភិក្ខវេ... ចត្តាឡីសាយ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឯក-ច្ចោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ... ឯកច្ចោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ បេ ។

# តតិយវគ្គ ទី៣

(១០៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយធម៌ទាំង ១០ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ... បុគ្គលខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ឯសុគតិសួគ៌ ទេវលោក ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ២០ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៣០ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយធម៌ ៤០ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ... បុគ្គលខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ឯសុគតិសួគ៌ ទេវលោក ។ បេ ។

ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ... បណ្ឌិតោ វេទិតព្វោ ... វីសតិយា ភិក្ខវេ ... តឹសាយ ភិក្ខវេ ... ចត្តាឡីសាយ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ... បណ្ឌិតោ វេទិតព្វោ ឥមេហិ ខោ ភិក្ខវេ ចត្តាឡីសាយ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ ។

តតិយោ តតិយវគ្គោ ។

(ឥមេសុ ចតុត្ថបញ្ចមេសុ វគ្គេសុ សុត្តគណនា បេយ្យាលវសេន វេទិតព្វា) ។

បញ្ចមបណ្ណាសក តតិយវគ្គ

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ១០ យ៉ាង គេគប្បីដឹងថាជាបុគ្គលពាល ... គប្បីដឹងថាជាបណ្ឌិត... ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ប្រកបដោយធម៌ ២០ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣០ យ៉ាង... ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាង គេគប្បីដឹងថាជាបុគ្គលពាល... គប្បីដឹងថាជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាង នេះឯង គេគប្បីដឹងថាជាបណ្ឌិត ។

ចប់ តតិយវគ្គ ទី៣ ។

( ការពេប់ទូវសូត្រ ក្នុងវគ្គ ទី ៤ នឹងវគ្គទី ៥ នេះ បណ្ឌិតគប្បីដឹង ដោយអំណាចបេយ្យាល: ) ។

(១០៦) រាគស្ស ភិក្ខវេ អភិញ្ញាយ ទស ធម្មា ភាវេតព្វា ។ កតមេ ទស ។ អសុភសញ្ញា មរណសញ្ញា អាហារេ បដិក្កូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ទស ធម្មា ភាវេតព្វាតិ ។

(១០៨) រាគស្ស ភិក្ខវេ អភិញ្ញាយ ទស ធម្មា ភាវេតព្វា ។ កតមេ ទស ។ អនិច្ចសញ្ញា អនត្តសញ្ញា អាហារេ បដិក្កូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អដ្ឋិកសញ្ញា បុឡវកសញ្ញា វិនីលកសញ្ញា វិបុព្វកសញ្ញា វិច្ឆិទ្ទកសញ្ញា ឧទ្ធុមាតកសញ្ញា ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ទស ធម្មា ភាវេតព្វាតិ ។

(១០៨) ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ នូវរាគៈ ។ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ គឺអសុភសញ្ញា ១ មរណសញ្ញា ១ អាហារេ បដិកូលសញ្ញា ១ សព្វលោកេ អនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេ ទុក្ខសញ្ញា ១ ទុក្ខេ អនត្តសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ នូវរាគៈ ។

(១០៩) ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ នូវរាគៈ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺ អនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អាហារេ បដិកូលសញ្ញា ១ សព្វលោកេ អនភិរតសញ្ញា ១ អដ្ឋិកសញ្ញា ១ បុឡុវកសញ្ញា ១ វិនីលកសញ្ញា ១ វិបុព្វកសញ្ញា ១ វិច្ឆិទ្ទកសញ្ញា ១ ឧទ្ធុមាតកសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ នូវរាគៈ ។

(១០៦) រាគស្ស ភិក្ខវេ អភិញ្ញាយ ទស ធម្មា ភាវេតព្វា ។ កតមេ ទស ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ សម្មាញាណំ សម្មាវិមុត្តិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ទស ធម្មា ភាវេតព្វាតិ ។

(១០៧) រាគស្ស ភិក្ខវេ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ឧបសមាយ ចាគាយ បដិនិស្សគ្គាយ(១) ទស ធម្មា ភាវេតព្វា ។បេ។

១ ឱ.ម. ឯត្ថន្តរេ ឥមេតិ បាឋោ ទិស្សតិ ។

(១០៦) ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ នូវរាគៈ ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ សម្មាញាណៈ ១ សម្មាវិមុត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ នូវរាគៈ ។

(១០៧) ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង បុគ្គលគប្បីចំរើន ដើម្បីកំណត់ដឹង អស់រលីង លះបង់ អស់ទៅ សូន្យទៅ នឿយណាយ រលត់ ស្ងប់រម្ងាប់ លះបោល រលោស់បោល នូវរាគៈ ។ បេ ។

ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ឧបសមាយ ចាគាយ បដិនិស្សគ្គាយ ឥមេ ទស ធម្មា ភាវេតព្វាតិ ។

បណ្ណាសកោ បញ្ចមោ ។

ទសកនិបាតោ និដ្ឋិតោ ។

ធម៌ ១០ យ៉ាងនេះ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ កំណត់ដឹង អស់រលីង លះបង់ អស់ទៅ សូន្យទៅ នឿយណាយ រំលត់ ស្ងប់រម្ងាប់ លះចោល រលាស់ចោល នូវទោសៈ មោហៈ ក្រោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។

ចប់ បណ្ណាសក ទី ៥ ។

ចប់ ទសកនិបាត ។

# សុត្តន្តបិដកេ

## អង្គុត្តរនិកាយស្ស ឯកាទសកនិបាតោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### បឋមោ និស្សយវគ្គោ

(១០៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កិមត្ថិយានិ ភន្តេ កុសលានិ សីលានិ កិមានិសំសានីតិ ។ អវិប្បដិសារត្ថានិ ខោ អានន្ទ កុសលានិ សីលានិ អវិប្បដិសារានិសំសានិ ។ អវិប្បដិសារោ បន ភន្តេ កិមត្ថិយោ កិមានិសំសោតិ ។

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ឯកាទសកនិបាត

សូមក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

## និស្សយវគ្គ ទី ១

(១០៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សីលទាំងឡាយ ជាកុសលមានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ សីលទាំងឡាយជាកុសល មានអវិប្បដិសារៈ(សេចក្តីមិនក្តៅក្រហាយ) ជាប្រយោជន៍ មានអវិប្បដិសារៈជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចំរើន អវិប្បដិសារៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។

អវិប្បដិសារោ ខោ អានន្ទ បាមុជ្ជត្ថោ បាមុជ្ជា-
និសំសោ ។ បាមុជ្ជំ បន ភន្តេ កិមត្ថិយំ
កិមានិសំសន្តិ ។ បាមុជ្ជំ ខោ អានន្ទ បីតត្ថំ
បីតានិសំសំ ។ បីតិ បន ភន្តេ កិមត្ថិយា
កិមានិសំសាតិ ។ បីតិ ខោ អានន្ទ បស្សទ្ធត្ថា
បស្សទ្ធានិសំសា ។ បស្សទ្ធិ បន ភន្តេ កិមត្ថិយា
កិមានិសំសាតិ ។ បស្សទ្ធិ ខោ អានន្ទ សុខត្ថា
សុខានិសំសា ។ សុខំ បន ភន្តេ កិមត្ថិយំ
កិមានិសំសន្តិ ។ សុខំ ខោ អានន្ទ សមាធត្ថំ
សមាធានិសំសំ ។ សមាធិ បន ភន្តេ កិមត្ថិយោ
កិមានិសំសោតិ ។ សមាធិ ខោ អានន្ទ យថាភូតញាណ-
ទស្សនត្ថោ យថាភូតញាណទស្សនានិសំសោ ។

ម្នាលអានន្ទ អវិប្បដិសារៈ មានបាមុជ្ជៈ ( សេចក្តីរីករាយទន់ ) ជាប្រយោជន៍ មានបាមុជ្ជៈជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចំរើន បាមុជ្ជៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បាមុជ្ជៈ មានបីតិ ( សេចក្តីរីករាយខ្លាំង ) ជាប្រយោជន៍ មានបីតិជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចំរើន បីតិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បីតិ មានបស្សទ្ធិ ( សេចក្តីស្ងប់រម្ងាប់ ) ជាប្រយោជន៍ មានបស្សទ្ធិជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចំរើន បស្សទ្ធិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បស្សទ្ធិ មានសុខៈជាប្រយោជន៍ មានសុខៈជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចំរើន សុខៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ សុខៈ មានសមាធិ ( ការតាំងចិត្តមាំ ) ជាប្រយោជន៍ មានសមាធិ ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចំរើន សមាធិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ សមាធិ មានយថាភូតញាណទស្សនៈ (ការឃើញនូវសច្ចៈ ៤ ដោយញាណតាមពិត) ជាប្រយោជន៍ មានយថាភូតញាណទស្សនៈ ជាអានិសង្ស ។

បឋមោ និស្សយវគ្គោ

យថាភូតញាណទស្សនំ បន ភន្តេ កិមត្ថិយំ កិមានិសំសន្តិ ។ យថាភូតញាណទស្សនំ ខោ អានន្ទ និព្ពិទត្ថំ និព្ពិទានិសំសំ ។ និព្ពិទា បន ភន្តេ កិមត្ថិយា កិមានិសំសាតិ ។ និព្ពិទា ខោ អានន្ទ វិរាគត្ថា វិរាគានិសំសា ។ វិរាគោ បន ភន្តេ កិមត្ថិយោ កិមានិសំសោតិ ។ វិរាគោ ខោ អានន្ទ វិមុត្តិញាណទស្សនត្ថោ វិមុត្តិញាណទស្សនា-និសំសោតិ ។ ឥតិ ខោ អានន្ទ កុសលានិ សីលានិ អវិប្បដិសារត្ថានិ អវិប្បដិសារានិសំសានិ អវិប្បដិសា-រោ បាមុជ្ជត្ថោ បាមុជ្ជានិសំសោ បាមុជ្ជំ បីតត្ថំ បីតានិសំសំ បីតិ បស្សទ្ធត្ថា បស្សទ្ធានិសំសា បស្សទ្ធិ សុខត្ថា សុខានិសំសា សុខំ សមា-ធត្ថំ សមាធានិសំសំ សមាធិ យថាភូតញា-ណទស្សនត្ថោ យថាភូតញាណទស្សនានិសំសោ

បពិត្រព្រះអង្គដ៏ចំរើន យថាភូតញ្ញាណទស្សនៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ យថាភូតញ្ញាណទស្សនៈ មាននិព្វិទា (សេចក្តីនឿយណាយ) ជាប្រយោជន៍ មាននិព្វិទា ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចំរើន និព្វិទា មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ និព្វិទា មានវិរាគៈ (ការប្រាសចាកតម្រេក) ជាប្រយោជន៍ មានវិរាគៈ ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចំរើន វិរាគៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ វិរាគៈ មានវិមុត្តិញ្ញាណទស្សនៈ (បច្ចវេក្ខណញ្ញាណ) ជាប្រយោជន៍ មានវិមុត្តិញ្ញាណទស្សនៈ ជាអានិសង្ស ។ ម្នាលអានន្ទ សីលទាំងឡាយជាកុសល មានអវិប្បដិសារៈជាប្រយោជន៍ មានអវិប្បដិ-សារៈជាអានិសង្ស អវិប្បសារៈ មានបាមុជ្ជៈជាប្រយោជន៍ មានបាមុជ្ជៈ ជាអានិសង្ស បាមុជ្ជៈ មានបីតិជាប្រយោជន៍ មានបីតិជាអានិសង្ស បីតិ មានបស្សទ្ធិជាប្រយោជន៍ មានបស្សទ្ធិជាអានិសង្ស បស្សទ្ធិ មានសុខៈ ជាប្រយោជន៍ មានសុខៈ ជាអានិសង្ស សុខៈ មានសមាធិ ជាប្រយោជន៍ មានសមាធិជាអានិសង្ស សមាធិ មានយថាភូតញ្ញាណ-ទស្សនៈ ជាប្រយោជន៍ មានយថាភូតញ្ញាណទស្សនៈ ជាអានិសង្ស

យថាភូតញាណទស្សនំ និព្វិទត្ថំ និព្វិទានិសំសំ និព្វិទា វិរាគត្ថា វិរាគានិសំសា វិរាគោ វិមុត្តិញាណទស្សនត្ថោ វិមុត្តិញាណទស្សនានិសំសោ ។ ឥតិ ខោ អានន្ទ កុសលានិ សីលានិ អនុបុព្វេន អរហត្តាយ បរិបូរេន្តីតិ(១) ។

(១០៩) សីលវតោ ភិក្ខវេ សីលសម្បន្នស្ស ន ចេតនាយ ករណីយំ អវិប្បដិសារោ មេ ឧប្បជ្ជតូតិ ។ ធម្មតា ឯសា ភិក្ខវេ យំ សីលវតោ សីលសម្បន្នស្ស អវិប្បដិសារោ ឧប្បជ្ជតិ ។ អវិប្បដិសារិស្ស ភិក្ខវេ ន ចេតនាយ ករណីយំ បាមុជ្ជំ មេ ឧប្បជ្ជតូតិ ។ ធម្មតា ឯសា ភិក្ខវេ យំ អវិប្បដិសារិស្ស បាមុជ្ជំ ឧប្បជ្ជតិ ។ បមុទិតស្ស ភិក្ខវេ ន ចេតនាយ ករណីយំ បីតិ មេ ឧប្បជ្ជតូតិ ។ ធម្មតា ឯសា ភិក្ខវេ យំ បមុទិតស្ស បីតិ ឧប្បជ្ជតិ ។

---

១ ឱ. ម. អគ្គាយ បូរេន្តីតិ ។

យថាភូតញាណទស្សនៈ មាននិព្វិទាជាប្រយោជន៍ មាននិព្វិទាជាអានិសង្ស និព្វិទា មានវិរាគៈជាប្រយោជន៍ មានវិរាគៈជាអានិសង្ស វិរាគៈ មានវិមុត្តិញាណទស្សនៈជាប្រយោជន៍ មានវិមុត្តិញាណទស្សនៈជាអានិសង្ស ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ សីលទាំងឡាយជាកុសល តែងបរិបូណ៌ ដើម្បីព្រះអរហត្ត តាមលំដាប់ដោយប្រការ ដូច្នេះឯង ។

(១០៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល មិនគប្បីធ្វើដោយចេតនាថា អវិប្បដិសារៈ ចូរកើតដល់អាត្មាអញដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ តែងកើតឡើង ដល់បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមិនមានវិប្បដិសារៈ មិនគប្បីធ្វើដោយចេតនាថា បាមុជ្ជៈ ចូរកើតឡើងដល់អាត្មាអញដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បាមុជ្ជៈ តែងកើតឡើងដល់បុគ្គលអ្នកមិនមានវិប្បដិសារៈ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានបាមុជ្ជៈ មិនគប្បីធ្វើដោយចេតនាថា បីតិ ចូរកើតឡើងដល់អាត្មាអញដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បីតិ តែងកើតឡើងដល់បុគ្គលមានបាមុជ្ជៈ នេះជាធម្មតា ។

## បឋមោ និស្សយវគ្គោ

បីតិមនស្ស ភិក្ខវេ ន ចេតនាយ ករណីយំ កាយោ មេ បស្សម្ភតូតិ ។ ធម្មតា ឯសា ភិក្ខវេ យំ បីតិមនស្ស កាយោ បស្សម្ភតិ ។ បស្សទ្ធកាយស្ស ភិក្ខវេ ន ចេតនាយ ករណីយំ សុខំ វេទិយាមីតិ[១] ។ ធម្មតា ឯសា ភិក្ខវេ យំ បស្សទ្ធកាយោ សុខំ វេទិយតិ ។ សុខិនោ ភិក្ខវេ ន ចេតនាយ ករណីយំ ចិត្តំ មេ សមាធិយតូតិ ។ ធម្មតា ឯសា ភិក្ខវេ យំ សុខិនោ ចិត្តំ សមាធិយ-តិ ។ សមាហិតស្ស ភិក្ខវេ ន ចេតនាយ ករណីយំ យថាភូតំ បជានាមិ បស្សាមីតិ ។ ធម្មតា ឯសា ភិក្ខវេ យំ សមាហិតោ យថាភូតំ បជានាតិ បស្សតិ ។ យថាភូតំ ភិក្ខវេ ជានតោ បស្សតោ ន ចេតនាយ ករណីយំ និព្វិន្ទាមីតិ ។ ធម្មតា ឯសា ភិក្ខវេ យំ យថាភូតំ ជានំ បស្សំ និព្វិន្ទតិ ។

១ ម. វេទយិស្សាមីតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានបីតិចិត្ត មិនគប្បីធ្វើដោយចេតនាថា កាយរបស់អាត្មាអញ ចូរស្ងប់រម្ងាប់ ដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ កាយរបស់បុគ្គលមានបីតិចិត្ត តែងស្ងប់រម្ងាប់ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានកាយប្បស្សទ្ធិ មិនគប្បីធ្វើដោយចេតនាថា អាត្មាអញទទួលសេចក្តីសុខដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយប្បស្សទ្ធិ តែងទទួលសេចក្តីសុខ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសេចក្តីសុខ មិនគប្បីធ្វើដោយចេតនាថា ចិត្តរបស់អាត្មាអញ ចូរតាំងមាំដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់បុគ្គលអ្នកមានសេចក្តីសុខតែងតាំងមាំ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសមាធិចិត្ត មិនគប្បីធ្វើដោយចេតនាថា អាត្មាអញដឹង អាត្មាអញឃើញ តាមពិតដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសមាធិចិត្ត តែងដឹង តែងឃើញតាមពិត នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង កាលឃើញតាមពិត មិនគប្បីធ្វើដោយចេតនាថា អាត្មាអញនឿយណាយដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង កាលឃើញតាមពិត តែងនឿយណាយ នេះជាធម្មតា ។

និព្វិន្នស្ស[១] ភិក្ខវេ ន ចេតនាយ ករណីយំ វិរជ្ជាមីតិ ។ ធម្មតា ឯសា ភិក្ខវេ យំ និព្វិន្នោ វិរជ្ជតិ ។ វិរតចិត្តស្ស ភិក្ខវេ ន ចេតនាយ ករណីយំ វិមុត្តិញាណទស្សនំ សច្ឆិករោមីតិ ។ ធម្មតា ឯសា ភិក្ខវេ យំ វិរតោ វិមុត្តិញាណទស្សនំ សច្ឆិករោតិ ។ ឥតិ ខោ ភិក្ខវេ វិរាគោ វិមុត្តិញាណទស្សនត្ថោ វិមុត្តិញាណទស្សនានិសំសោ និព្វិទា វិរាគត្ថា វិរាគានិសំសា យថាភូតញាណទស្សនំ និព្វិទត្ថំ និព្វិទានិសំសំ សមាធិ យថាភូតញាណទស្សនត្ថោ យថាភូតញាណទស្សនានិសំសោ សុខំ សមាធត្ថំ សមាធានិសំសំ បស្សទ្ធិ សុខត្ថា សុខានិសំសា បីតិ បស្សទ្ធត្ថា បស្សទ្ធានិសំសា បាមុជ្ជំ បីតត្ថំ បីតានិសំសំ អវិប្បដិសារោ បាមុជ្ជត្ថោ បាមុជ្ជានិសំសោ

---

១ ឱ. និព្វិន្ទស្ស ។ ម. និព្វិទស្ស ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលនឿយណាយ មិនគប្បីធ្វើ ដោយចេតនាថា អាត្មាអញ ប្រាសចាកតម្រេកដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនឿយណាយប្រាសចាកតម្រេក នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានចិត្តប្រាសចាកតម្រេក មិនគប្បីធ្វើ ដោយចេតនាថា អាត្មាអញ ធ្វើឲ្យជាក់ច្បាស់ នូវវិមុត្តិញាណទស្សនៈ ដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល អ្នកប្រាសចាកតម្រេក តែងធ្វើឲ្យជាក់ច្បាស់ នូវវិមុត្តិញាណទស្សនៈ នេះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ វិរាគៈ មានវិមុត្តិញាណទស្សនៈ ជាប្រយោជន៍ មានវិមុត្តិញាណទស្សនៈ ជាអានិសង្ស និព្វិទា មានវិរាគៈជាប្រយោជន៍ មានវិរាគៈជាអានិសង្ស យថាភូតញាណទស្សនៈ មាននិព្វិទា ជាប្រយោជន៍ មាននិព្វិទា ជាអានិសង្ស សមាធិ មានយថាភូតញាណទស្សនៈ ជាប្រយោជន៍ មានយថាភូតញាណទស្សនៈ ជាអានិសង្ស សុខៈ មានសមាធិ ជាប្រយោជន៍ មានសមាធិ ជាអានិសង្ស បស្សទ្ធិ មានសុខៈ ជាប្រយោជន៍ មានសុខៈជាអានិសង្ស បីតិ មានបស្សទ្ធិ ជាប្រយោជន៍ មានបស្សទ្ធិជាអានិសង្ស បាមុជ្ជៈ មានបីតិជាប្រយោជន៍ មានបីតិ ជាអានិសង្ស អវិប្បដិសារៈ មានបាមុជ្ជៈ ជាប្រយោជន៍ មានបាមុជ្ជៈ ជាអានិសង្ស

កុសលានិ សីលានិ អវិប្បដិសារត្ថានិ អវិប្បដិសារានិសំសានិ ។ ឥតិ ខោ ភិក្ខវេ ធម្មា(១) ធម្មេ អភិសន្ទេន្តិ ធម្មា(២) ធម្មេ បរិបូរេន្តិ អបារា បារំគមនាយាតិ ។

(១១០) ទុស្សីលស្ស ភិក្ខវេ សីលវិបន្នស្ស ហតូបនិសោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូបនិសំ ហោតិ បាមុជ្ជំ បាមុជ្ជេ អសតិ បាមុជ្ជវិបន្នស្ស ហតូបនិសា ហោតិ បីតិ បីតិយា អសតិ បីតិវិបន្នស្ស ហតូបនិសា ហោតិ បស្សទ្ធិ បស្សទ្ធិយា អសតិ បស្សទ្ធិវិបន្នស្ស ហតូបនិសំ ហោតិ សុខំ សុខេ អសតិ សុខវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតូបនិសំ ហោតិ យថាភូតញាណទស្សនំ

---

១ – ២ ឱ. ឯត្ថន្តរេ បសទ្ទោ អត្ថិ ។

សីលទាំងឡាយ ជាកុសល មានអវិប្បដិសារៈ ជាប្រយោជន៍ មានអវិប្បដិសារៈ ជាអានិសង្ស ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ តែងញ៉ាំងធម៌ទាំងឡាយ ឲ្យប្រព្រឹត្តទៅ ធម៌ទាំងឡាយ តែងញ៉ាំងធម៌ទាំងឡាយ ឲ្យបរិបូណ៌ ដើម្បីចេញ អំពីទីមិនមែនជាត្រើយ ទៅកាន់ត្រើយគឺព្រះនិព្វាន ដោយប្រការដូច្នេះ ។

(១១០) ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកទ្រុស្តសីល វិបត្តិចាកសីល តែងសាបសូន្យចាកឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈ មិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈតែងសាបសូន្យ ចាកឧបនិស្ស័យ នៃបាមុជ្ជៈ កាលបើបាមុជ្ជៈមិនមាន បុគ្គលអ្នកវិបត្តិចាកបាមុជ្ជៈតែងសាបសូន្យចាកឧបនិស្ស័យ នៃបីតិ កាលបើបីតិ មិនមាន បុគ្គលអ្នកវិបត្តិចាកបីតិ តែងសាបសូន្យចាកឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិមិនមាន បុគ្គលអ្នកវិបត្តិចាកបស្សទ្ធិ តែងសាបសូន្យចាកឧបនិស្ស័យ នៃសុខៈ កាលបើសុខៈមិនមាន បុគ្គលអ្នកវិបត្តិចាកសុខៈ តែងសាបសូន្យចាកឧបនិស្ស័យ នៃសម្មាសមាធិ កាលបើសម្មាសមាធិមិនមាន បុគ្គលអ្នកវិបត្តិចាកសម្មាសមាធិ តែងសាបសូន្យចាកឧបនិស្ស័យ នៃយថាភូតញ្ញាណទស្សនៈ

យថាភូតញ្ញាណទស្សនេ អសតិ យថាភូតញ្ញាណទស្សនវិបន្នស្ស ហតូបនិសា ហោតិ និព្ពិទា និព្ពិទាយ អសតិ និព្ពិទាវិបន្នស្ស ហតូបនិសោ ហោតិ វិរាគោ វិរាគេ អសតិ វិរាគវិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញ្ញាណទស្សនំ ។ សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសវិបន្នោ តស្ស បបដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ន បារិបូរឹ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ ទុស្សីលស្ស សីលវិបន្នស្ស ហតូបនិសោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូបនិសំ ហោតិ ។បេ។ វិមុត្តិញ្ញាណទស្សនំ ។ សីលវតោ ភិក្ខវេ សីលសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ សតិ អវិប្បដិសារសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ បាមុជ្ជំ

កាលបើ យថាភូតញាណទស្សនៈ មិនមាន បុគ្គល អ្នកវិបត្តិចាក យថាភូតញាណទស្សនៈ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃនិព្វិទា កាលបើនិព្វិទាមិនមាន បុគ្គលអ្នកវិបត្តិចាកនិព្វិទា តែងសាបសូន្យចាក ឧបនិស្ស័យ នៃវិរាគៈ កាលបើវិរាគៈមិនមាន បុគ្គលអ្នកវិបត្តិចាកវិរាគៈ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃវិមុត្តិញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើ ដែលប្រាសចាកមែកនិងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏មិនដល់ នូវការពេញលេញ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនដល់ នូវការពេញលេញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងសាបសូន្យ ចាកឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើ អវិប្បដិសារៈ មិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យ ចាកឧបនិស្ស័យ ។ បេ ។ នៃវិមុត្តិញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ ដោយសីល តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមាន បុគ្គលអ្នកបរិបូណ៌ដោយអវិប្បដិសារៈ តែងបរិបូណ៌ដោយឧបនិស្ស័យ នៃបាមុជ្ជៈ

បាមុជ្ជេ សតិ បាមុជ្ជសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ បីតិ បីតិយា សតិ បីតិសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ បស្សទ្ធិ បស្សទ្ធិយា សតិ បស្សទ្ធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ សុខំ សុខេ សតិ សុខសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ សតិ យថាភូតញាណទស្សនសម្បន្នស្ស ឧបនិស-សម្បន្នា ហោតិ និព្វិទា និព្វិទាយ សតិ និព្វិ-ទាសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ វិរាគោ វិរាគេ សតិ វិរាគសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ វិមុត្តិញាណទស្សនំ ។ សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសសម្បន្នោ តស្ស បបដិកាបិ បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ បារិបូរឹ គច្ឆតិ

កាលបើបាមុជ្ជៈមាន បុគ្គល អ្នកបរិបូណ៌ ដោយបាមុជ្ជៈ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃបីតិ កាលបើបីតិមាន បុគ្គលអ្នកបរិបូណ៌ ដោយ បីតិ តែងបរិបូណ៌ ដោយឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិ មាន បុគ្គលអ្នកបរិបូណ៌ ដោយបស្សទ្ធិ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃសុខៈ កាលបើ សុខៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយសុខៈ តែង បរិបូណ៌ ដោយឧបនិស្ស័យ នៃសម្មាសមាធិ កាលបើសម្មាសមាធិ មាន បុគ្គលអ្នកបរិបូណ៌ ដោយសម្មាសមាធិ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃយថាភូតញ្ញាណទស្សនៈ កាលបើ យថាភូតញ្ញាណទស្សនៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយយថាភូតញ្ញាណទស្សនៈ តែងបរិបូណ៌ ដោយ ឧបនិស្ស័យនៃនិព្វិទា កាលបើនិព្វិទា មាន បុគ្គលអ្នកបរិបូណ៌ ដោយ និព្វិទា តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃវិរាគៈ កាលបើ វិរាគៈមាន បុគ្គលអ្នកបរិបូណ៌ ដោយវិរាគៈ តែងបរិបូណ៌ ដោយ ឧបនិស្ស័យ នៃវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចដើមឈើ ដែលបរិបូណ៌ ដោយមែកនិងស្លឹកហើយ ក្រមរបស់ឈើនោះក្តី ដល់នូវការពេញលេញ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏ដល់នូវការពេញលេញ យ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ សីលវតោ សីលសម្បន្នស្ស
ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ
សតិ អវិប្បដិសារសម្បន្នស្ស ឧបនិសសម្បន្នំ
ហោតិ ។បេ។ វិមុត្តិញាណទស្សនំ ។

[១១១] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ
អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ
តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោ-
សុំ ។ អាយស្មា សារីបុត្តោ ឯតទវោច ទុស្សីលស្ស
អាវុសោ សីលវិបន្នស្ស ហតូបនិសោ ហោតិ
អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិសារ-
វិបន្នស្ស ហតូបនិសំ ហោតិ បាមុជ្ជំ បាមុជ្ជេ
អសតិ បាមុជ្ជវិបន្នស្ស ហតូបនិសា ហោតិ
បីតិ បីតិយា អសតិ បីតិវិបន្នស្ស ហតូបនិ-
សា ហោតិ បស្សទ្ធិ បស្សទ្ធិយា អសតិ
បស្សទ្ធិវិបន្នស្ស ហតូបនិសំ ហោតិ សុខំ

ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ ដោយសីល តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើ អវិប្បដិសារៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយអវិប្បដិសារៈ តែងបរិបូណ៌ ដោយឧបនិស្ស័យ ។ បេ ។ នៃវិមុត្តិញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

[១១១] ក្នុងទីនោះឯង ព្រះសារីបុត្រដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោ ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ថេរវាចា នៃព្រះសារីបុត្រដ៏មានអាយុថា ករុណា អាវុសោ ។ ព្រះសារីបុត្រដ៏មានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកទ្រុស្តសីល វិបត្តិចាកសីលហើយ តែងសាបសូន្យចាកឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈ មិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យ ចាកឧបនិស្ស័យនៃបាមុជ្ជៈ កាលបើបាមុជ្ជៈ មិនមាន បុគ្គលអ្នកវិបត្តិ ចាកបាមុជ្ជៈ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃបីតិ កាលបើបីតិ មិនមាន បុគ្គលអ្នកវិបត្តិចាក បីតិ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃបស្សទ្ធិ កាលបើបស្សទ្ធិ មិនមាន បុគ្គលអ្នកវិបត្តិចាកបស្សទ្ធិ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃសុខៈ

សុខេ អសតិ សុខវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតូបនិសំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ យថាភូតញាណទស្សនវិបន្នស្ស ហតូបនិសា ហោតិ និព្វិទា និព្វិទាយ អសតិ និព្វិទាវិបន្នស្ស ហតូបនិសោ ហោតិ វិរាគោ វិរាគេ អសតិ វិរាគវិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញាណទស្សនំ ។ សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលាសវិបន្នោ តស្ស បបដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ន បារិបូរឹ គច្ឆតិ ឯវមេវ ខោ អាវុសោ ទុស្សីលស្ស សីលវិបន្នស្ស ហតូបនិសោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូបនិសំ ហោតិ ។ បេ ។

បឋម និស្សយវគ្គ

កាលបើសុខៈ មិនមាន បុគ្គលអ្នកវិបត្តិ ចាកសុខៈ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃសម្មាសមាធិ កាលបើសម្មាសមាធិ មិនមាន បុគ្គលអ្នកវិបត្តិ ចាកសម្មាសមាធិ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃយថាភូតញាណទស្សនៈ កាលបើយថាភូតញាណទស្សនៈ មិនមាន បុគ្គលអ្នកវិបត្តិ ចាកយថាភូតញាណទស្សនៈ តែងសាបសូន្យចាកឧបនិស្ស័យ នៃនិព្វិទា កាលបើនិព្វិទា មិនមាន បុគ្គលអ្នកវិបត្តិចាកនិព្វិទា តែងសាបសូន្យ ចាកឧបនិស្ស័យនៃវិរាគៈ កាលបើវិរាគៈ មិនមាន បុគ្គលអ្នកវិបត្តិចាកវិរាគៈ តែងសាបសូន្យចាកឧបនិស្ស័យ នៃវិមុត្តិញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលប្រាសចាកមែកនិងស្លឹកហើយ ក្រមរ របស់ឈើនោះក្តី ក៏មិនដល់នូវការពេញលេញ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកទ្រុស្តសីល វិបត្តិចាកសីល តែងសាបសូន្យ ចាកឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈ មិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យ ចាកឧបនិស្ស័យ ។ បេ ។

វិមុត្តិញាណទស្សនំ ។ សីលវតោ អាវុសោ សីលសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ សតិ អវិប្បដិសារសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ បាមុជ្ជំ បាមុជ្ជេ សតិ បាមុជ្ជសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ បីតិ បីតិយា សតិ បីតិសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ បស្សទ្ធិ បស្សទ្ធិយា សតិ បស្សទ្ធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ សុខំ សុខេ សតិ សុខសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ សតិ យថាភូតញាណទស្សនសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ និព្វិទា និព្វិទាយ សតិ និព្វិទាសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ វិរាគោ វិរាគេ សតិ វិរាគសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ វិមុត្តិញាណទស្សនំ ។

នៃវិមុត្តិញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ ដោយសីល តែមិនបរិបូណ៌ ដោយឧបនិស្ស័យនៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយអវិប្បដិសារៈ តែមិនបរិបូណ៌ ដោយឧបនិស្ស័យ នៃបាមុជ្ជៈ កាលបើបាមុជ្ជៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយបាមុជ្ជៈ តែមិនបរិបូណ៌ ដោយឧបនិស្ស័យ នៃបីតិ កាលបើបីតិ មាន បុគ្គលអ្នកបរិបូណ៌ ដោយបីតិ តែមិនបរិបូណ៌ដោយឧបនិស្ស័យនៃបស្សទ្ធិ កាលបើបស្សទ្ធិ មាន បុគ្គលអ្នកបរិបូណ៌ ដោយបស្សទ្ធិ តែមិនបរិបូណ៌ ដោយឧបនិស្ស័យនៃសុខៈ កាលបើសុខៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយសុខៈ តែមិនបរិបូណ៌ ដោយឧបនិស្ស័យនៃសម្មាសមាធិ កាលបើសម្មាសមាធិ មាន បុគ្គលអ្នកបរិបូណ៌ដោយសម្មាសមាធិ តែមិនបរិបូណ៌ដោយឧបនិស្ស័យ នៃយថាភូតញាណទស្សនៈ កាលបើ យថាភូតញាណទស្សនៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយយថាភូតញាណទស្សនៈ តែមិនបរិបូណ៌ដោយឧបនិស្ស័យ នៃនិព្វិទា កាលបើនិព្វិទា មាន បុគ្គលអ្នកបរិបូណ៌ដោយនិព្វិទា តែមិនបរិបូណ៌ ដោយឧបនិស្ស័យ នៃវិរាគៈ កាលបើវិរាគៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយវិរាគៈ តែមិនបរិបូណ៌ដោយឧបនិស្ស័យ នៃវិមុត្តិញាណទស្សនៈ ។

## បឋមោ និស្សយវគ្គោ

សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលាស-
សម្បន្នោ តស្ស បប្បដិកាបិ បារិបូរឹ គច្ឆតិ
តចោបិ ផេគ្គុបិ សារោបិ បារិបូរឹ គច្ឆតិ
ឯវមេវ ខោ អាវុសោ សីលវតោ សីលសម្ប-
ន្នស្ស ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ
អវិប្បដិសារេ សតិ អវិប្បដិសារសម្បន្នស្ស ឧបនិ-
សសម្បន្នំ ហោតិ ។ បេ ។ វិមុត្តិញាណទស្សនន្តិ ។

(១១២) តត្រ ខោ អាយស្មា អានន្ទោ ភិក្ខូ
អាមន្តេសិ ។ បេ ។ ទុស្សីលស្ស អាវុសោ សីលវិ-
បន្នស្ស ហតូបនិសោ ហោតិ អវិប្បដិសារោ
អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូ-
បនិសំ ហោតិ បាមុជ្ជំ បាមុជ្ជេ អសតិ បាមុជ្ជវិបន្នស្ស
ហតូបនិសា ហោតិ បីតិ បីតិយា អសតិ បីតិ-
វិបន្នស្ស ហតូបនិសា ហោតិ បស្សទ្ធិ បស្សទ្ធិយា
អសតិ បស្សទ្ធិវិបន្នស្ស ហតូបនិសំ ហោតិ សុខំ

ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលបរិបូណ៌ដោយមែក និងស្លឹក ក្រមរ របស់ឈើនោះក្តី ក៏ដល់នូវការពេញលេញ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏ដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ដោយឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយអវិប្បដិសារៈ តែងបរិបូណ៌ដោយឧបនិស្ស័យ ។បេ។ នៃវិមុត្តិញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

(១១២) ក្នុងទីនោះឯង ព្រះអានន្ទដ៏មានអាយុ ហៅភិក្ខុទាំងឡាយ ។បេ។ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកទ្រុស្តសីល វិបត្តិចាកសីល តែងសាបសូន្យ ចាកឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈ មិនមាន បុគ្គលអ្នកវិបត្តិ ចាកអវិប្បដិសារៈ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃបាមុជ្ជៈ កាលបើបាមុជ្ជៈ មិនមាន បុគ្គលអ្នកវិបត្តិ ចាកបាមុជ្ជៈ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃបីតិ កាលបើបីតិ មិនមាន បុគ្គលអ្នកវិបត្តិ ចាកបីតិ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃបស្សទ្ធិ កាលបើបស្សទ្ធិ មិនមាន បុគ្គលអ្នកវិបត្តិចាកបស្សទ្ធិ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃសុខៈ

សុខេ អសតិ សុខវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតូបនិសំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ យថាភូតញាណទស្សនវិបន្នស្ស ហតូបនិសា ហោតិ និព្វិទា និព្វិទាយ អសតិ និព្វិទាវិបន្នស្ស ហតូបនិសោ ហោតិ វិរាគោ វិរាគេ អសតិ វិរាគវិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញាណទស្សនំ ។ សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលាសវិបន្នោ តស្ស បបដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ន បារិបូរឹ គច្ឆតិ ឯវមេវ ខោ អាវុសោ ទុស្សីលស្ស សីលវិបន្នស្ស ហតូបនិសោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូបនិសំ ហោតិ ។បេ។ វិមុត្តិញាណទស្សនំ ។

កាលបើសុខៈ មិនមាន បុគ្គលអ្នកវិបត្តិចាកសុខៈ តែងសាបសូន្យ ចាកឧបនិស្ស័យនៃសម្មាសមាធិ កាលបើសម្មាសមាធិ មិនមាន បុគ្គលអ្នកវិបត្តិ ចាកសម្មាសមាធិ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃយថាភូតញាណទស្សនៈ កាលបើយថាភូតញាណទស្សនៈ មិនមាន បុគ្គលអ្នកវិបត្តិ ចាកយថាភូតញាណទស្សនៈ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃនិព្វិទា កាលបើនិព្វិទា មិនមាន បុគ្គលអ្នកវិបត្តិ ចាកនិព្វិទា តែងសាបសូន្យ ចាកឧបនិស្ស័យ នៃវិរាគៈ កាលបើវិរាគៈ មិនមាន បុគ្គលអ្នកវិបត្តិចាកវិរាគៈ តែងសាបសូន្យ ចាកឧបនិស្ស័យ នៃវិមុត្តិញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចដើមឈើ ដែលប្រាសចាកមែកនិងស្លឹក ក្រមរ របស់ឈើនោះក្តី ក៏មិនដល់នូវការពេញលេញ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកទ្រុស្តសីល វិបត្តិចាកសីល តែងសាបសូន្យចាកឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈមិនមាន បុគ្គលអ្នកវិបត្តិចាកអវិប្បដិសារៈ តែងសាបសូន្យ ចាកឧបនិស្ស័យ ។ បេ ។ នៃវិមុត្តិញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

## បឋមោ និស្សយវគ្គោ

សីលវតោ អាវុសោ សីលសម្បន្នស្ស ឧបនិស-
សម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ
សតិ អវិប្បដិសារសម្បន្នស្ស ឧបនិសសម្បន្នំ
ហោតិ បាមុជ្ជំ បាមុជ្ជេ សតិ បាមុជ្ជសម្បន្នស្ស
ឧបនិសសម្បន្នា ហោតិ បីតិ បីតិយា
សតិ បីតិសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ
បស្សទ្ធិ បស្សទ្ធិយា សតិ បស្សទ្ធិសម្បន្នស្ស
ឧបនិសសម្បន្នំ ហោតិ សុខំ សុខេ សតិ
សុខសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ សម្មា-
សមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិ-
សម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ យថាភូត-
ញាណទស្សនំ យថាភូតញាណទស្សនេ សតិ
យថាភូតញាណទស្សនសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ
និព្វិទា និព្វិទាយ សតិ និព្វិទាសម្បន្នស្ស ឧបនិ-
សសម្បន្នោ ហោតិ វិរាគោ វិរាគេ សតិ វិរាគសម្បន្ន-
ស្ស ឧបនិសសម្បន្នំ ហោតិ វិមុត្តិញាណទស្សនំ ។

ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយអវិប្បដិសារៈ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃបាមុជ្ជៈ កាលបើបាមុជ្ជៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយបាមុជ្ជៈ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃបីតិ កាលបើបីតិ មាន បុគ្គលអ្នកបរិបូណ៌ ដោយបីតិ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃបស្សទ្ធិ កាលបើបស្សទ្ធិ មាន បុគ្គលអ្នកបរិបូណ៌ដោយបស្សទ្ធិ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃសុខៈ កាលបើសុខៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយសុខៈ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃសម្មាសមាធិ កាលបើសម្មាសមាធិ មាន បុគ្គលអ្នកបរិបូណ៌ ដោយសម្មាសមាធិ តែងបរិបូណ៌ដោយឧបនិស្ស័យ នៃយថាភូតញ្ញាណទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយយថាភូតញ្ញាណទស្សនៈ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃនិព្វិទា កាលបើនិព្វិទា មាន បុគ្គលអ្នកបរិបូណ៌ ដោយនិព្វិទា តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃវិរាគៈ កាលបើវិរាគៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយវិរាគៈ តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃវិមុត្តិញ្ញាណទស្សនៈ ។

សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលា-សសម្បន្នោ តស្ស បបដិកាបិ បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ បារិបូរឹ គច្ឆតិ ឯវមេវ ខោ អាវុសោ សីលវតោ សីលសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ សតិ អវិប្បដិសារសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ ។ បេ ។ វិមុត្តិញាណទស្សនន្តិ ។

(១១៣) យោ សោ ភិក្ខវេ ភិក្ខុ អក្កោសក-បរិភាសកោ អរិយុបវាទី(១) សព្រហ្មចារីនំ អដ្ឋានមេតំ អនវកាសោ យំ សោ ឯកាទសន្នំ ព្យសនានំ អញ្ញតរំ ព្យសនំ ន និគច្ឆេយ្យ ។ កតមេសំ ឯកា-ទសន្នំ ។ អនធិគតំ នាធិគច្ឆតិ អធិគតា បរិហា-យតិ សទ្ធម្មស្ស ន វោទាយន្តិ(២) សទ្ធម្មេសុ វា អធិមានិកោ ហោតិ អនភិរតោ វា ព្រហ្មចរិយំ ចរតិ

១ ម. អរិយុបវាទោ ។ ២ ម. វោទាយតិ ។

ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលបរិបូណ៌ដោយមែក និងស្លឹកហើយ ក្រមរ របស់ឈើនោះក្តី ក៏ដល់នូវការពេញលេញ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏ដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល តែងបរិបូណ៌ ដោយឧបនិស្ស័យ នៃអវិប្បដិសារៈ កាលបើអវិប្បដិសារៈ មាន បុគ្គលអ្នកបរិបូណ៌ ដោយអវិប្បដិសារៈ តែងបរិបូណ៌ដោយឧបនិស្ស័យ ។ បេ ។ នៃវិមុត្តិញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

(១១៣) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលតិះដៀលព្រះអរិយៈ ជេរប្រទេចពួកភិក្ខុជាសព្រហ្មចារី ហើយមិនគប្បីដល់នូវសេចក្តីវិនាសទាំង ១១ យ៉ាង ណាមួយ នុះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ ។ សេចក្តីវិនាសទាំង ១១ យ៉ាង តើអ្វីខ្លះ ។ គឺមិនបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ១ សាបសូន្យចាកគុណវិសេសដែលខ្លួនបានហើយ ១ ព្រះសទ្ធម្មរបស់ភិក្ខុនោះមិនផូរផង់ ១ ប្រកបដោយសេចក្តីស្មានថា បានក្នុងព្រះសទ្ធម្ម ១ មិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈ ១

អញ្ញតរំ វា សង្កិលិដ្ឋំ អាបត្តិំ អាបជ្ជតិ សិក្ខំ វា បច្ចក្ខាយ ហីនាយាវត្តតិ គាឡ្ហំ វា រោគាតង្កំ ផុសតិ ឧម្មាទំ វា បាបុណាតិ ចិត្តក្ខេបំ(១) សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ យោ សោ ភិក្ខវេ ភិក្ខុ អក្កោសកបរិភាសកោ អរិយូបវាទី សព្រហ្មចារីនំ អដ្ឋានមេតំ អនវកាសោ យំ សោ ឥមេសំ ឯកាទសន្នំ ព្យសនានំ អញ្ញតរំ ព្យសនំ ន និគច្ឆេយ្យាតិ ។

[១១៦] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សិយា នុ ខោ ភន្តេ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ

---

១ ម. ឯត្ថន្តរេ វាសទ្ទោ អត្ថិ ។

ត្រូវអាបត្តិណាមួយដ៏សៅហ្មង ១ លះបង់សិក្ខាហើយត្រឡប់មក ដើម្បីភេទជាគហដ្ឋ ១ ប៉ះទឹនភេគជូនខ្មាំង ១ ដល់នូវការឆ្កួត រវើរវាយបិត្ត ១ ធ្វើកាលកិរិយា ទាំងវង្វេង ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ១ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលតិះដៀលព្រះអរិយៈ ជេរប្រទេចពួកភិក្ខុជាសព្រហ្មចារី ហើយមិនគប្បីដល់ នូវសេចក្ដីវិនាសទាំង ១១ យ៉ាងណាមួយ នុះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ ៗ

(១១៤) គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ៗ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុបាននូវសមាធិ មានសភាពដូច្នេះ មានដែរឬ

យថា នេវ បឋវិយំ បឋវិសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសា-នញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតន-សញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវ-សញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោក-សញ្ញី អស្ស យមិទំ(១) ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ សិយា អានន្ទ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវិ-សញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស

---

១ ឱ. ម. យម្បិទំ ។ ម. យមិទំ ។

ដូចជាភិក្ខុ មិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ ភិក្ខុមិនសំគាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ៗ ម្នាលអានន្ទ ភិក្ខុ បានសមាធិមានសភាពដូច្នោះក៏មាន

ដូចជាភិក្ខុ មិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក

## បឋមោ និស្សយវគ្គោ

ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ យថាកថំ បន ភន្តេ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស

មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ មិនសំគាល់ ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចំរើន ដូចភិក្ខុ បានសមាធិ មានសភាព ដូច្នោះក៏មាន តើដូចម្តេច ដូចជាភិក្ខុ មិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់

ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស យមិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ ឥធានន្ទ ភិក្ខុ ឯវំសញ្ញី ហោតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ ឯវំ ខោ អានន្ទ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស

មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ មិនសំគាល់ ក្នុងរបស់ដែលខ្លួនឃើញ ឮ ល្វិង ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញាជាធម្មតា តែប៉ុណ្ណោះ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីសំគាល់យ៉ាងនេះថា ការរម្ងាប់នូវសង្ខារទាំងអស់ ការលះបោលនូវកិលេសទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ទុក្ខ គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះដ៏ឧត្តម ។ ម្នាលអានន្ទ ភិក្ខុបានសមាធិមានសភាពដូច្នោះ យ៉ាងនេះឯង ដូចជាភិក្ខុ មិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក

## បឋមោ និស្សយវគ្គោ

ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ
វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ
អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយ-
តនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញា-
យតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញា-
នាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស
ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ
បរលោកសញ្ញី អស្ស យម្បិទំ ទិដ្ឋំ សុតំ មុតំ
វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ
ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។
អថខោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ
អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ
អភិវាទេត្វា បទក្ខិណំ កត្វា យេនាយស្មា សារី-
បុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា
សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ
សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ មិនសំគាល់ ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ៗ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ត្រេកអរ រីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគហើយ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចូលទៅរក ព្រះសារីបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយ ទៅរកព្រះសារីបុត្រដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក ហើយអង្គុយ ក្នុងទីសមគួរ ៗ

ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ អាយ-
ស្មន្តំ សារីបុត្តំ ឯតទវោច សិយា នុ ខោ អាវុសោ
សារីបុត្ត ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ
យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ។បេ។ យម្បិទំ
ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ
មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន
អស្សាតិ ។ សិយា អាវុសោ អានន្ទ ភិក្ខុនោ តថា-
រូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវី-
សញ្ញី អស្ស ។បេ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ
បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន
សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ យថាកថំ
បនាវុសោ សារីបុត្ត សិយា ភិក្ខុនោ តថារូបោ
សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវី-
សញ្ញី អស្ស ។បេ។ យម្បិទំ ទិដ្ឋំ សុតំ
មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា

លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បាននិយាយទៅនឹង ព្រះសារីបុត្រដ៏មានអាយុ ដូច្នេះថា ម្នាលអាវុសោ សារីបុត្រ ភិក្ខុបានសមាធិ មានសភាពដូច្នោះ មានដែរឬ ដូចជាភិក្ខុ មិនសំគាល់ថា ដី ក្នុងដី ។ បេ ។ មិនសំគាល់ ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោអានន្ទ ភិក្ខុបានសមាធិ មានសភាពដូច្នោះ ក៏មាន ដូចជាភិក្ខុ មិនសំគាល់ថា ដី ក្នុងដី ។ បេ ។ មិនសំគាល់ ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោ សារីបុត្រ ដូចភិក្ខុបានសមាធិមានសភាពដូច្នោះ ដែលមាន តើដូចម្ដេច ដូចជាភិក្ខុ មិនសំគាល់ថា ដី ក្នុងដី ។ បេ ។ មិនសំគាល់ ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត

តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ ឥធាវុសោ អានន្ទ ភិក្ខុ ឯវំសញ្ញី ហោតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ ឯវំ ខោ អាវុសោ អានន្ទ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ។ បេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យត្រ ហិ នាម សត្ថុ ច[១] សាវកស្ស ច អត្ថេន អត្ថំ[២] ព្យញ្ជនេន ព្យញ្ជនំ សំសន្ទិស្សតិ សមេស្សតិ ន វិគយ្ហិស្សតិ[៣] យទិទំ អគ្គបទស្មឹ ។

---

១ ម. ចេវ ។ ២ ម. អត្ថោ ។ ៣ ខ. វិគ្គហិស្សតិ ។

គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ៗ ម្នាលអាវុសោអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីសំគាល់ យ៉ាងនេះថា ការម្ងាប់នូវសង្ខារទាំងអស់ ការលះបោល នូវកិលេសទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ទុក្ខ គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះដ៏ឧត្តម ៗ ម្នាលអាវុសោអានន្ទ ភិក្ខុបានសមាធិ មានសភាពដូច្នោះ យ៉ាងនេះឯង ដូចជាភិក្ខុមិនសំគាល់ថាដី ក្នុងដី ៗបេៗ មិនសំគាល់ក្នុងរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភុក្ស ដឹងច្បាស់ ដល់ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ៗ ម្នាលអាវុសោអស្ចារ្យណាស់ ម្នាលអាវុសោ ចំឡែកណាស់ ព្រោះថា អត្ថនិងព្យញ្ជនៈរបស់ព្រះសាស្តានិងសាវ័កត្រូវគ្នា សមគ្នា មិនបានខុសគ្នា ដោយអត្ថ ដោយព្យញ្ជនៈ ក្នុងបទដ៏ប្រសើរនេះឡើយ ៗ

ឥធាហំ អាវុសោ ភគវន្តំ ឧបសង្កមិត្វា ឯតមត្ថំ អបុច្ឆិំ ។ ភគវាបិ មេ ឯតេហិ បទេហិ ឯតេហិ ព្យញ្ជនេហិ[1] ឯតមត្ថំ ព្យាកាសិ សេយ្យថាបិ អាយស្មា សារិបុត្តោ ។ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យត្រ ហិ នាម សត្ថុ ច សាវកស្ស ច អត្ថេន អត្ថំ ព្យញ្ជនេន ព្យញ្ជនំ សំសន្ទិស្សតិ សមេស្សតិ ន វិគ្គយ្ហិស្សតិ យទិទំ អគ្គបទស្មិន្តិ ។

(១១៨) អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សិយា នុ ខោ ភន្តេ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា ន ចក្ខុំ មនសិករេយ្យ ន រូបំ មនសិករេយ្យ ន សោតំ មនសិករេយ្យ ន សទ្ទំ មនសិករេយ្យ ន ឃានំ មនសិករេយ្យ ន គន្ធំ មនសិករេយ្យ

---

១ ម. អត្ថេហិ ។

ម្នាលអាវុសោ អម្បាញ់មិញនេះ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរសេចក្តីនេះ ៗ ព្រះមានព្រះភាគ ក៏បានព្យាករសេចក្តីនេះ ដោយបទទាំងនេះ ដោយព្យញ្ជនៈទាំងនេះដល់ខ្ញុំ ដូចជាព្រះសារីបុត្រដ៏មានអាយុដែរ ៗ ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចំឡែកណាស់ ព្រោះថា អត្ថនឹងព្យញ្ជនៈរបស់ព្រះសាស្តានឹងសាវ័កត្រូវគ្នា សមគ្នា មិនបានខុសគ្នា ដោយអត្ថ ដោយព្យញ្ជនៈ ក្នុងបទដ៏ប្រសើរនេះឡើយ ៗ

(១១៥) គ្រានោះ ព្រះអានន្ទ ដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយ ក្នុងទីសមគួរ ៗ លុះ ព្រះអានន្ទ ដ៏មានអាយុ អង្គុយ ក្នុងទីសមគួរហើយ បានក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុបានសមាធិ មានសភាពដូច្នោះ មានដែរឬ ដូចជាភិក្ខុ មិនធ្វើទុកក្នុងចិត្ត នូវចក្ខុ មិនធ្វើទុកក្នុងចិត្ត នូវរូប មិនធ្វើទុកក្នុងចិត្ត នូវសោតៈ មិនធ្វើទុកក្នុងចិត្ត នូវសទ្ទៈ មិនធ្វើទុកក្នុងចិត្ត នូវឃានៈ មិនធ្វើទុកក្នុងចិត្ត នូវគន្ធៈ

ន ជិវ្ហំ មនសិការេយ្យ ន រសំ មនសិការេយ្យ ន កាយំ មនសិការេយ្យ ន ផោដ្ឋព្វំ មនសិការេយ្យ ន បឋវឹ មនសិការេយ្យ ន អាបំ មនសិការេយ្យ ន តេជំ មនសិការេយ្យ ន វាយំ មនសិការេយ្យ ន អាកាសានញ្ចាយតនំ មនសិការេយ្យ ន វិញ្ញាណញ្ចាយតនំ មនសិការេយ្យ ន អាកិញ្ចញ្ញាយតនំ មនសិការេយ្យ ន នេវសញ្ញានាសញ្ញាយតនំ មនសិការេយ្យ ន ឥធលោកំ មនសិការេយ្យ ន បរលោកំ មនសិការេយ្យ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ ន មនសិការេយ្យ មនសិ ច បន ការេយ្យាតិ ។ សិយា អានន្ទ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា ន ចក្ខុំ មនសិការេយ្យ ន រូបំ មនសិការេយ្យ ន សោតំ មនសិការេយ្យ ន សទ្ទំ មនសិការេយ្យ ន ឃានំ មនសិការេយ្យ ន គន្ធំ មនសិការេយ្យ ន ជិវ្ហំ មនសិការេយ្យ

មិនធ្វើទុកក្នុងចិត្ត នូវជិវ្ហា មិនធ្វើទុកក្នុងចិត្ត នូវរស មិនធ្វើទុកក្នុងចិត្ត នូវកាយ មិនធ្វើទុកក្នុងចិត្ត នូវផោដ្ឋព្វៈ មិនធ្វើទុកក្នុងចិត្ត នូវបឋវី មិនធ្វើទុកក្នុងចិត្ត នូវអាបោ មិនធ្វើទុកក្នុងចិត្ត នូវតេជោ មិនធ្វើទុកក្នុងចិត្ត នូវវាយោ មិនធ្វើទុកក្នុងចិត្ត នូវអាកាសានញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវវិញ្ញាណញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវនេវសញ្ញានាសញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវលោកនេះ មិនធ្វើទុកក្នុងចិត្តនូវលោកខាងមុខ មិនធ្វើទុកក្នុងចិត្ត នូវរបស់ដែលខ្លួនឃើញ ឮ ហិតក្លិន ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែធ្វើទុកក្នុងចិត្តជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអានន្ទ ភិក្ខុបានសមាធិ មានសភាពដូច្នោះក៏មាន ដូចជាភិក្ខុ មិនធ្វើទុកក្នុងចិត្តនូវចក្ខុ មិនធ្វើទុកក្នុងចិត្ត នូវរូប មិនធ្វើទុកក្នុងចិត្ត នូវសោតៈ មិនធ្វើទុកក្នុង នូវសទ្ទៈ មិនធ្វើទុកក្នុងចិត្ត នូវឃានៈ មិនធ្វើទុកក្នុងចិត្ត នូវគន្ធៈ មិនធ្វើទុកក្នុងចិត្ត នូវជិវ្ហា

ន រសំ មនសិការេយ្យ ន កាយំ មនសិការេយ្យ ន ផោដ្ឋព្វំ មនសិការេយ្យ ន បឋវឹ មនសិការេយ្យ ន អាបំ មនសិការេយ្យ ន តេជំ មនសិការេយ្យ ន វាយំ មនសិការេយ្យ ន អាកាសានញ្ចាយតនំ មនសិការេយ្យ ន វិញ្ញាណញ្ចាយតនំ មនសិការេយ្យ ន អាកិញ្ចញ្ញាយតនំ មនសិការេយ្យ ន នេវសញ្ញានាសញ្ញាយតនំ មនសិការេយ្យ ន ឥធលោកំ មនសិការេយ្យ ន បរលោកំ មនសិការេយ្យ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ ន មនសិការេយ្យ មនសិ ច បន ការេយ្យាតិ ។ យថាកថំ បន ភន្តេ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា ន ចក្ខុំ មនសិការេយ្យ ន រូបំ មនសិការេយ្យ ។បេ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ ន មនសិការេយ្យ មនសិ ច បន ការេយ្យាតិ ។

មិនធ្វើទុកក្នុងចិត្ត នូវរស មិនធ្វើទុកក្នុងចិត្ត នូវកាយ មិនធ្វើទុកក្នុងចិត្ត នូវផោដ្ឋព្វៈ មិនធ្វើទុកក្នុងចិត្ត នូវបឋវី មិនធ្វើទុកក្នុងចិត្ត នូវអាបោ មិនធ្វើទុកក្នុងចិត្ត នូវតេជោ មិនធ្វើទុកក្នុងចិត្ត នូវវាយោ មិនធ្វើទុកក្នុងចិត្ត នូវអាកាសានញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវវិញ្ញាណញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវនេវសញ្ញានាសញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវលោកនេះ មិនធ្វើទុកក្នុងចិត្ត នូវលោកខាងមុខ មិនធ្វើទុកក្នុងចិត្ត នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត ក្រៅតែធ្វើទុកក្នុងចិត្ត ផងម្តាប៉ុណ្ណោះ ៗ

បពិត្រព្រះអង្គដ៏ចំរើន ដូចភិក្ខុ បានសមាធិ មានសភាពដូច្នោះក៏មានតើដូចម្តេច ដូចជាភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវចក្ខុ មិនធ្វើទុកក្នុងចិត្ត នូវរូប ។បេ។ មិនធ្វើទុកក្នុងចិត្ត នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត ក្រៅតែធ្វើទុកក្នុងចិត្ត ផងម្តាប៉ុណ្ណោះ ៗ

ឥធានន្ទ ភិក្ខុ ឯវំ មនសិករោតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ ឯវំ ខោ អានន្ទ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា ន ចក្ខុំ មនសិករេយ្យ ន រូបំ មនសិករេយ្យ ន សោតំ មនសិករេយ្យ ន សទ្ទំ មនសិករេយ្យ ន ឃានំ មនសិករេយ្យ ន គន្ធំ មនសិករេយ្យ ន ជិវ្ហំ មនសិករេយ្យ ន រសំ មនសិករេយ្យ ន កាយំ មនសិករេយ្យ ន ផោដ្ឋព្វំ មនសិករេយ្យ ន បឋវឹ មនសិករេយ្យ ន អាបំ មនសិករេយ្យ ន តេជំ មនសិករេយ្យ ន វាយំ មនសិករេយ្យ ន អាកាសានញ្ចាយតនំ មនសិករេយ្យ ន វិញ្ញាណញ្ចាយតនំ មនសិករេយ្យ ន អាកិញ្ចញ្ញាយតនំ មនសិករេយ្យ ន នេវសញ្ញានាសញ្ញាយតនំ មនសិករេយ្យ ន ឥធលោកំ មនសិករេយ្យ ន បរលោកំ មនសិករេយ្យ យម្បិទំ ទិដ្ឋំ

ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្ត យ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះបោលកិលេសទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ទុក្ខគឺព្រះនិព្វានណា ព្រះនិព្វាននុះ ជាទីស្ងប់ ព្រះនិព្វាននុះ ដ៏ឧត្តម ។ ម្នាលអានន្ទ ភិក្ខុបានសមាធិ មានសភាពប៉ុណ្ណោះ យ៉ាងនេះឯង ដូចជាភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវចក្ខុ មិនធ្វើទុកក្នុងចិត្ត នូវរូប មិនធ្វើទុកក្នុងចិត្ត នូវសោតៈ មិនធ្វើទុកក្នុងចិត្ត នូវសទ្ទៈ មិនធ្វើទុកក្នុងចិត្ត នូវឃានៈ មិនធ្វើទុកក្នុងចិត្ត នូវគន្ធៈ មិនធ្វើទុកក្នុងចិត្ត នូវជិវ្ហា មិនធ្វើទុកក្នុងចិត្ត នូវរស មិនធ្វើទុកក្នុងចិត្ត នូវកាយ មិនធ្វើទុកក្នុងចិត្ត នូវផោដ្ឋព្វៈ មិនធ្វើទុកក្នុងចិត្ត នូវបឋវី មិនធ្វើទុកក្នុងចិត្ត នូវអាបោ មិនធ្វើទុកក្នុងចិត្ត នូវតេជោ មិនធ្វើទុកក្នុងចិត្ត នូវវាយោ មិនធ្វើទុកក្នុងចិត្ត នូវអាកាសានញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវវិញ្ញាណញ្ចាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវនេវសញ្ញានាសញ្ញាយតនៈ មិនធ្វើទុកក្នុងចិត្ត នូវលោកនេះ មិនធ្វើទុកក្នុងចិត្ត នូវលោកខាងមុខ មិនធ្វើទុកក្នុងចិត្ត នូវរបស់ដែលខ្លួនឃើញ

សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ ន មនសិករោតិ មនសិ ច បន ករោតិ ។

[១១៦] ឯកំ សមយំ ភគវា នាតិកេ វិហរតិ គិញ្ជកាវសថេ (១) ។ អថ ខោ អាយស្មា សន្ធោ (២) យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សន្ធំ ភគវា ឯតទវោច អាជានីយឈាយិតំ ខោ សន្ធ ឈាយ (៣) មា ខឡុង្គឈាយិតំ (៤) ។ កថញ្ច សន្ធ ខឡុង្គឈាយិតំ ហោតិ ។ អស្សខឡុង្គោ ហិ សន្ធ ទោណិយា ពន្ធោ យវសស្សំ យវសស្សន្តិ (៥) ឈាយតិ ។ តំ កិស្ស ហេតុ ។

---

១ ឱ. ម. គិញ្ជកាវសថេ ។ ២ ម. សទ្ធោ ។ ៣ ឱ. ឈាយថ ។
៤ ឱ. ម. ខឡុង្គឈាយិតំ ។ ។ ៥ ឱ. ម. យវសំ យវសន្តិ ។

ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែធ្វើទុកក្នុងចិត្ត ជាធម្មតាប៉ុណ្ណោះ ។

(១១៦) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងប្រាសាទ ដែលគេធ្វើអំពីឥដ្ឋ ជិតស្រុកនាទិកៈ ។ គ្រានោះ ព្រះសន្ធៈដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំ បំពោះព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះព្រះសន្ធៈដ៏មានអាយុ អង្គុយ ក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលសន្ធៈ អ្នកត្រូវគិត ដូចគំនិតសេះអាជានីយ កុំគិតដូចគំនិតសេះ ដែលមានពុតត្បុតឡើយ ។ ម្នាលសន្ធៈ គំនិតសេះដែលមានពុតត្បុត តើដូចម្តេច ។ ម្នាលសន្ធៈ សេះមានពុតត្បុត ដែលគេចងក្បែរគ្រង់នៃស្រូវ តែងគិតថា ស្រូវដំណើប ស្រូវដំណើប ។ ដំណើរនោះ ព្រោះហេតុអ្វី ។

ន ហិ សន្ធ អស្ស ខឡុង្កស្ស ទោណិយា ពទ្ធស្ស ឯវំ ហោតិ កឹ នុ ខោ មំ អជ្ជ អស្សទម្មសារថិ ការណំ ការេស្សតិ កិមស្សាហំ បដិករោមីតិ ។ សោ ទោណិយា ពទ្ធោ យវសស្សំ យវសស្សន្តិ[១] ឈាយតិ ។ ឯវមេវ ខោ សន្ធ ឥធេកច្ចោ បុរិសខឡុង្កោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ ។ សោ កាមរាគំយេវ អន្តរំ[១] ករិត្វា[២] ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អវជ្ឈាយតិ ។ ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ... ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ ... ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ ...

---

១ ឱ.ម. អន្តរំ ។ ២ ម. កត្វា ។

ម្នាលសន្ធៈ ព្រោះថា សេះមានពុតត្បុត ដែលគេចងក្បែរក្រង់នៃស្រូវ មិនមានគំនិតយ៉ាងនេះថា ថ្ងៃនេះ នាយសារថីអ្នកបង្ហាត់ សេះ នឹងឲ្យអញធ្វើនូវហេតុ ដូចម្តេច អញធ្វើតបទៅវិញ ដូចម្តេច ៗ សេះនោះ ត្រូវគេចងក្បែរក្រង់នៃស្រូវហើយ តែងគិតថា ស្រូវដំណើប ស្រូវដំណើប ៗ ម្នាលសន្ធៈ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ ទៅនៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី មានចិត្ត ដែលកាមរាគ រួបរឹត ដែលកាមរាគ គ្របសង្កត់ហើយ រមែងមិនដឹងនូវការរលាស់ចោល នូវកាមរាគ ដែលកើតឡើង ដោយពិតក៏យ៉ាងនោះដែរ ៗ បុរសនោះ តែងគិត ជញ្ជឹង ជ្រួល ជ្រប់ សុបសៅ ព្រោះធ្វើកាមរាគ ឲ្យនៅខាងក្នុង ៗ បុគ្គលមានចិត្ត ដែលព្យាបាទ រួបរឹតហើយ . . . មានចិត្ត ដែលថីនមិទ្ធៈ រួបរឹតហើយ . . . មានចិត្ត ដែលឧទ្ធច្ចកុក្កុច្ចៈ រួបរឹតហើយ . . .

វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាតិ ។ សោ វិចិកិច្ឆំយេវ អន្តរំ ករិត្វា ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អវជ្ឈាយតិ ។ សោ បឋវិម្បិ និស្សាយ ឈាយតិ អាបម្បិ និស្សាយ ឈាយតិ តេជម្បិ និស្សាយ ឈាយតិ វាយម្បិ និស្សាយ ឈាយតិ អាកាសានញ្ចាយតនម្បិ និស្សាយ ឈាយតិ វិញ្ញាណញ្ចាយតនម្បិ និស្សាយ ឈាយតិ អាកិញ្ចញ្ញាយតនម្បិ និស្សាយ ឈាយតិ នេវសញ្ញានាសញ្ញាយតនម្បិ និស្សាយ ឈាយតិ ឥធលោកម្បិ និស្សាយ ឈាយតិ បរលោកម្បិ និស្សាយ ឈាយតិ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ និស្សាយ ឈាយតិ ។ ឯវំ ខោ សន្ធ បុរិសខឡុង្កឈាយិតំ ហោតិ ។

មានចិត្ត ដែលវិចិកិច្ឆា ប្រឿត ដែលវិចិកិច្ឆា គ្របសង្កត់ហើយ រមែងមិនដឹងការរលាស់ចោលនូវវិចិកិច្ឆា ដែលកើតឡើងដោយពិត ៗ បុគ្គលនោះ តែងគិតជញ្ជឹង ជ្រុលជ្រប់ សុបសៅ ព្រោះធ្វើវិចិកិច្ឆា ឲ្យនៅតែខាងក្នុង ៗ បុគ្គលនោះ តែងគិតព្រោះអាស្រ័យ នូវផែនដីខ្លះ គិត ព្រោះអាស្រ័យនូវទឹកខ្លះ គិត ព្រោះអាស្រ័យនូវភ្លើងខ្លះ គិត ព្រោះអាស្រ័យនូវខ្យល់ខ្លះ គិត ព្រោះអាស្រ័យនូវអាកាសានញ្ចាយតនៈខ្លះ គិត ព្រោះអាស្រ័យនូវវិញ្ញាណញ្ចាយតនៈខ្លះ គិត ព្រោះអាស្រ័យ នូវអាកិញ្ចញ្ញា-យតនៈខ្លះ គិត ព្រោះអាស្រ័យ នូវនេវសញ្ញានាសញ្ញាយតនៈ ខ្លះ គិត ព្រោះអាស្រ័យ នូវលោកនេះខ្លះ គិត ព្រោះអាស្រ័យ នូវលោកខាងមុខខ្លះ គិត ព្រោះអាស្រ័យ នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត ៗ ម្នាលសន្ធៈ គំនិតរបស់បុរស ដែលមានពុតត្បុត យ៉ាងនេះឯង ៗ

កថញ្ច សទ្ធ អាជានីយឈាយិតំ ហោតិ ។ ភទ្រោ ហិ សទ្ធ អស្សាជានីយោ ទោណិយា ពទ្ធោ ន យវសំ យវសន្តិ ឈាយតិ ។ តំ កិស្ស ហេតុ ។ ភទ្រស្ស ហិ សទ្ធ អស្សាជានីយស្ស ទោណិយា ពទ្ធស្ស ឯវំ ហោតិ កឹ នុ ខោ អជ្ជ មំ(១) អស្សទម្មសារថិ ការណំ ការេស្សតិ កិមស្សាហំ បដិករោមីតិ ។ សោ ទោណិយា ពទ្ធោ ន យវសំ យវសន្តិ ឈាយតិ ។ ភទ្រោ ហិ សទ្ធ អស្សាជានីយោ យថា ឥណំ យថា ពន្ធំ យថា ជានិ(២) យថា កលឹ(៣) ឯវំ បតោទស្ស អជ្ឈោហរណំ(៤) សមនុបស្សតិ ។ ឯវមេវ ខោ សទ្ធ ភទ្រោ បុរិសាជានីយោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ

---

១ ឱ. មំ អជ្ជ ។ ម. មមជ្ជ ។ ២ ឱ. ជានឹ ។ ៣ កលឹ ។ ៤ ម. អជ្ឈោសរណំ ។

ម្នាលសន្ធ: គំនិតរបស់សេះអាជានេយ្យ តើដូចម្តេច ។ ម្នាលសន្ធ: សេះអាជានេយ្យ ដ៏ចំរើន ដែលគេចងក្បែរក្រង់ នៃស្រូវដំណើប រមែងមិនគិតថា ស្រូវដំណើប ស្រូវដំណើបទេ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។ ម្នាលសន្ធ: ព្រោះថា សេះអាជានេយ្យ ដ៏ចំរើន ដែលគេចង ក្បែរក្រង់នៃស្រូវ តែងមានសេចក្តីត្រិះរិះ យ៉ាងនេះថា ក្នុងថ្ងៃនេះ នាយសារថីអ្នកបង្ហាត់សេះ នឹងឲ្យអញធ្វើនូវហេតុដូចម្តេច អញនឹងធ្វើតបទៅវិញ ដូចម្តេច ។ សេះដែលគេចងក្បែរក្រង់ នៃស្រូវនោះ រមែងមិនគិតថា ស្រូវដំណើប ស្រូវដំណើបទេ ។ ម្នាលសន្ធ: សេះអាជានេយ្យ ដ៏ចំរើន តែងពិចារណា នូវការចាក់ ដោយជន្លួញយ៉ាងនេះថា ដូចជាបំណុល ដូចជាចំណង ដូចជាសេចក្តី សាបសូន្យ ឬដូចជាទោស ។ ម្នាលសន្ធ: បុរសអាជានេយ្យ ដ៏ចំរើន ពោះនៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី

ន កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ ន កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ បជានាតិ ។ ន ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ... ន ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ... ន ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ... ន វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ ន វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ បជានាតិ ។ សោ នេវ បឋវឹ និស្សាយ ឈាយតិ ន អាបំ និស្សាយ ឈាយតិ ន តេជំ និស្សាយ ឈាយតិ ន វាយំ និស្សាយ ឈាយតិ ន អាកាសានញ្ចាយតនំ និស្សាយ ឈាយតិ ន វិញ្ញាណញ្ចាយតនំ និស្សាយ ឈាយតិ ន អាកិញ្ចញ្ញាយតនំ និស្សាយ ឈាយតិ ន នេវសញ្ញានាសញ្ញាយតនំ និស្សាយ ឈាយតិ ន ឥធលោកំ និស្សាយ ឈាយតិ ន បរលោកំ និស្សាយ ឈាយតិ

តែងមិនឲ្យកាមរាគ រួបរឹតចិត្តបាន មិនឲ្យកាមរាគ គ្របសង្កត់ចិត្តបាន ទាំងដឹងច្បាស់ នូវការរលាស់ចោលនូវកាមរាគ ដែលកើតឡើងហើយ ដោយពិត ៗ មិនឲ្យព្យាបាទ រួបរឹតចិត្តបាន ... មិនឲ្យថីនមិទ្ធៈ រួបរឹតចិត្តបាន ... មិនឲ្យឧទ្ធច្ចកុក្កុច្ចៈ រួបរឹតចិត្តបាន ... មិនឲ្យវិកិច្ឆា រួបរឹតចិត្តបាន មិនឲ្យវិចិកិច្ឆា គ្របសង្កត់ចិត្តបាន ទាំងដឹងច្បាស់ នូវការរលាស់ចោលនូវវិចិកិច្ឆា ដែលកើតឡើងហើយ ដោយពិត ៗ បុរសនោះ មិនគិត ព្រោះអាស្រ័យ នូវបឋវី មិនគិត ព្រោះអាស្រ័យ នូវអាបោ មិនគិត ព្រោះអាស្រ័យ នូវតេជោ មិនគិត ព្រោះអាស្រ័យ នូវវាយោ មិនគិត ព្រោះអាស្រ័យ នូវអាកាសានញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវវិញ្ញាណញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវអាកិញ្ចញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវនេវសញ្ញានាសញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវលោកនេះ មិនគិតព្រោះអាស្រ័យ នូវលោកខាងមុខ

យមិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ និស្សាយ ន ឈាយតិ ឈាយតិ ច បន ។ ឯវំ ឈាយិញ្ច បន សន្ធ ភទ្រំ បុរិសាជានីយំ សឥន្ទា ទេវា សព្រហ្មកា សបជាបតិកា អារកាវ នមស្សន្តិ

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
យស្ស តេ នាភិជានាម យម្បិ និស្សាយ ឈាយតីតិ(១) ។

ឯវំ វុត្តេ អាយស្មា សភិយោ កច្ចានោ ភគវន្តំ ឯតទវោច កថំ ឈាយី បន ភន្តេ ភទ្រោ បុរិសាជានីយោ ឈាយតិ ។ សោ នេវ បឋវឹ និស្សាយ ឈាយតិ ន អាបំ និស្សាយ ឈាយតិ ន តេជំ និស្សាយ ឈាយតិ ន វាយំ និស្សាយ ឈាយតិ ន អាកាសានញ្ចាយតនំ និស្សាយ ឈាយតិ ន វិញ្ញាណញ្ចាយតនំ និស្សាយ ឈាយតិ ន អាកិញ្ចញ្ញាយតនំ និស្សាយ ឈាយតិ ន នេវសញ្ញានាសញ្ញាយតនំ និស្សាយ ឈាយតិ

១ ឱ. ម. ឈាយសីតិ ។

មិនគិត ព្រោះអាស្រ័យ នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែគិត ជាធម្មតា ប៉ុណ្ណោះ ៗ ម្នាលសទ្ធៈ ទេវតាទាំងឡាយ ព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រះព្រហ្ម ព្រមទាំងបជាបតិទេវរាជ តែងនមស្ការបុរសជាអាជានីយដ៏ចំរើន អំពីចម្ងាយ ដែលជាអ្នកមានឈាន យ៉ាងនេះថា

យើងទាំងឡាយ មិនស្គាល់អ្នកណា ជាបុរសអាជានីយ
តែងគិត ព្រោះអាស្រ័យនូវគុណធម៌ណា បពិត្របុរស
អាជានីយ យើងសូមនមស្ការ ចំពោះអ្នក បពិត្រ
បុរសដ៏ឧត្តម យើងសូមនមស្ការ ចំពោះអ្នក ៗ

កាលព្រះអង្គទ្រង់ត្រាស់ យ៉ាងនេះហើយ ព្រះសទ្ធៈដ៏មានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន បុរសអាជានីយដ៏ចំរើន មានឈាន តែងគិតដូចម្តេច ៗ បុរសអាជានីយនោះ មិនគិត ព្រោះអាស្រ័យ នូវបឋវី មិនគិត ព្រោះអាស្រ័យ នូវអាបោ មិនគិត ព្រោះអាស្រ័យ នូវតេជោ មិនគិត ព្រោះអាស្រ័យ នូវវាយោ មិនគិត ព្រោះអាស្រ័យ នូវអាកាសានញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យនូវវិញ្ញាណញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវអាកិញ្ចញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវនេវសញ្ញានាសញ្ញាយតនៈ

ន ឥធ លោកំ និស្សាយ ឈាយតិ ន បរលោកំ និស្សាយ ឈាយតិ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ និស្សាយ ន ឈាយតិ ឈាយតិ ច បន ។ ឯវំ ឈាយិញ្ច បន ភទ្ទ ភទ្រំ បុរិសាជានីយំ សឥន្ទា ទេវា សព្រហ្មកា សបជាបតិកា អារកា វ នមស្សន្តិ

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
យស្ស តេ នាភិជានាម យម្បិ និស្សាយ ឈាយសីតិ ។

ឥធ សន្ធ ភទ្រស្ស បុរិសាជានីយស្ស បថវិយា(១) បថវីសញ្ញា វិភូតា ហោតិ អាបស្មឹ អាបោសញ្ញា វិភូតា ហោតិ តេជស្មឹ តេជោសញ្ញា វិភូតា ហោតិ វាយស្មឹ វាយោសញ្ញា វិភូតា ហោតិ អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញា វិភូតា ហោតិ វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញា វិភូតា ហោតិ

---

១ ម. បឋវិយំ ។

មិនគិត ព្រោះអាស្រ័យ នូវលោកនេះ មិនគិត ព្រោះអាស្រ័យ នូវលោកខាងមុខ មិនគិត ព្រោះអាស្រ័យ នូវរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត គ្រាន់តែគិតជាធម្មតាតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុមួយ ទេវតាទាំងឡាយ ព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រហ្ម ព្រមទាំងបជាបតិទេវរាជ នមស្ការអំពីចម្ងាយ ចំពោះបុរសអាជានីយដ៏ចំរើន ដែលមានឈានយ៉ាងនេះថា

យើងទាំងឡាយ មិនស្គាល់អ្នកណា ជាបុរសអាជានីយ
តែងគិត ព្រោះអាស្រ័យ នូវគុណធម៌ណា បពិត្រ
បុរសអាជានីយ យើងសូមនមស្ការ ចំពោះអ្នក
បពិត្របុរសដ៏ឧត្តម យើងសូមនមស្ការ ចំពោះអ្នក ។

ម្នាលសន្ធៈ បុរសអាជានីយដ៏ចំរើន ក្នុងលោកនេះ សំគាល់ថា ដី ក្នុងដី ជាប្រាកដ សំគាល់ថា ទឹក ក្នុងទឹក ជាប្រាកដ សំគាល់ថា ភ្លើង ក្នុងភ្លើង ជាប្រាកដ សំគាល់ថា ខ្យល់ ក្នុងខ្យល់ ជាប្រាកដ សំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ ជាប្រាកដ សំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ

បឋមោ និស្សយវគ្គោ

អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញា វិភូតា ហោតិ នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញា វិភូតា ហោតិ ឥធលោកេ ឥធលោកសញ្ញា វិភូតា ហោតិ បរលោកេ បរលោកសញ្ញា វិភូតា ហោតិ យមិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ សញ្ញា វិភូតា ហោតិ ។ ឯវំ ឈាយី ខោ សន្ធ ភទ្រោ បុរិសាជានីយោ នេវ បឋវឹ និស្សាយ ឈាយតិ ន អាបំ និស្សាយ ឈាយតិ ន តេជំ និស្សាយ ឈាយតិ ន វាយំ និស្សាយ ឈាយតិ ន អាកាសានញ្ចាយតនំ និស្សាយ ឈាយតិ ន វិញ្ញាណញ្ចាយតនំ និស្សាយ ឈាយតិ ន អាកិញ្ចញ្ញាយតនំ និស្សាយ ឈាយតិ ន នេវសញ្ញានាសញ្ញាយតនំ និស្សាយ ឈាយតិ ន ឥធលោកំ និស្សាយ ឈាយតិ

ជាប្រាកដ សំគាល់ថា អាកិញ្ចញ្ញាយតនៈ គឺអាកិញ្ចញ្ញាយតនៈ ជាប្រាកដ សំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ គឺនេវសញ្ញានាស-ញ្ញាយតនៈ ជាប្រាកដ សំគាល់ថា លោកនេះ គឺលោកនេះជាប្រាកដ សំគាល់ថា លោកខាងមុខ គឺលោកខាងមុខ ជាប្រាកដ សំគាល់ គឺរបស់ដែលខ្លួនឃើញ ឮ លិទ្ធ ភ្លក្ស ដឹងច្បាស់ ដល់ ស្វែងរក ត្រិះរិះដោយចិត្ត ជាប្រាកដ ៗ ម្នាលសន្ធៈ បុរសអាជានីយដ៏ចំរើន អ្នកមានឈានយ៉ាងនេះ មិនគិត ព្រោះអាស្រ័យ នូវបឋវី មិនគិត ព្រោះអាស្រ័យ នូវអាបោ មិនគិត ព្រោះអាស្រ័យ នូវតេជោ មិនគិត ព្រោះអាស្រ័យ នូវវាយោ មិនគិត ព្រោះអាស្រ័យ នូវអាកាសានញ្ចា-យតនៈ មិនគិត ព្រោះអាស្រ័យ នូវវិញ្ញាណញ្ចាយតនៈ មិនគិត ព្រោះអាស្រ័យ នូវអាកិញ្ចញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវនេវសញ្ញានាសញ្ញាយតនៈ មិនគិត ព្រោះអាស្រ័យ នូវលោកនេះ

ន បរលោកំ និស្សាយ ឈាយតិ យមិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តម្បិ និស្សាយ ន ឈាយតិ ឈាយតិ ច បន ។ ឯវំ ឈាយិញ្ច បន សន្ធ ភទ្រំ បុរិសាជានីយំ សឥន្ទា ទេវា សព្រហ្មកា សបជាបតិកា អារកា វ នមស្សន្តិ

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
យស្ស តេ នាភិជានាម យម្បិ និស្សាយ ឈាយសីតិ ។

(១១៧) ឯកំ សមយំ ភគវា រាជគហេ វិហរតិ មោរនិវាបេ បរិព្វាជការាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ឯកាទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ

មិនគិត ព្រោះអាស្រ័យ នូវលោកខាងមុខ មិនគិត ព្រោះអាស្រ័យ នូវរបស់ដែលខ្លួនឃើញ ឮ លិន្ធ ភ្លក្ស ដឹងច្បាស់ ស្វែងរក ត្រិះរិះ ដោយចិត្ត គ្រាន់តែគិត ជាធម្មតាប៉ុណ្ណោះ ។ ម្នាលសន្ធៈ ហេតុយ៉ាងនេះ ទេវតាទាំងឡាយ ព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រហ្ម ព្រមទាំង បជាបតិទេវរាជ តែងនមស្ការ អំពីចម្ងាយ ចំពោះបុរសអាជានីយ ដ៏ចំរើនអ្នកមានឈាន យ៉ាងនេះថា

យើងមិនស្គាល់ច្បាស់ អ្នកណា ជាបុរសអាជានីយ
តែងគិត ព្រោះអាស្រ័យនូវគុណធម៌ណា បពិត្របុរស
អាជានីយ យើងសូមនមស្ការចំពោះអ្នក បពិត្រ
បុរសដ៏ឧត្តម យើងសូមនមស្ការចំពោះអ្នក ។

(១១៧) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងបរិព្វាជ-ការាម ជាមោរនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការ ឈ្មោះថាជាអ្នកសម្រេចមែន

## បឋមោ និស្សយវគ្គោ

អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។ កតមេហិ តីហិ ។ អសេក្ខេន(១) សីលក្ខន្ធេន អសេក្ខេន សមាធិក្ខន្ធេន អសេក្ខេន បញ្ញាក្ខន្ធេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។ អបរេហិបិ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។ កតមេហិ តីហិ ។ ឥទ្ធិបាដិហារិយេន អាទេសនាបាដិហារិយេន អនុសាសនីបាដិហារិយេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។

---

១ ឱ.ម. អសេខេន ។

ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៣ ប្រការតើដូចម្តេច ។ គឺសីលក្ខន្ធជាអសេក្ខៈ ១ សមាធិក្ខន្ធជាអសេក្ខៈ ១ បញ្ញាក្ខន្ធ ជាអសេក្ខៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការនេះឯង ទើបឈ្មោះថាជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈ មែន ចប់មែន ប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការ ដទៃទៀត ក៏ឈ្មោះថាជាអ្នកសម្រេចមែន ឈ្មោះថាក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៣ ប្រការតើដូចម្តេច ។ គឺ ឥទ្ធិប្បាដិហារិយៈ ១ អាទេសនាបាដិហារិយៈ ១ អនុសាសនីបាដិហា-រិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការនេះឯង ឈ្មោះថាជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ។

អបរេហិបិ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។ កតមេហិ តីហិ ។ សម្មាទិដ្ឋិយា សម្មាញាណេន សម្មាវិមុត្តិយា ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។ ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។ កតមេហិ ទ្វីហិ ។ វិជ្ជាយ ចរណេន ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការដទៃទៀត ឈ្មោះថា ជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៣ ប្រការ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ សម្មាញាណៈ ១ សម្មាវិមុត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ប្រការនេះឯង ឈ្មោះថាជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកប ដោយធម៌ ២ ប្រការ ឈ្មោះថាជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ២ ប្រការ តើដូចម្តេច ។ គឺវិជ្ជា ១ ចរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ ប្រការនេះ ទើបឈ្មោះថាជាអ្នកសម្រេចមែន ក្សេមចាកយោគៈមែន ប្រព្រឹត្តព្រហ្មចរិយៈមែន ចប់មែន ប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ។

ព្រហ្មុនាបេសា ភិក្ខវេ សនង្កុមារេន គាថា ភាសិតា

ខត្តិយោ សេដ្ឋោ ជនេតស្មឹ យេ គោត្តប្បដិសារិនោ
វិជ្ជាចរណសម្បន្នោ សោ សេដ្ឋោ ទេវមានុសេតិ ។

សា ខោ បនេសា ភិក្ខវេ(១) សនង្កុមារេន គាថា សុគីតា នោ ទុគ្គីតា សុភាសិតា នោ ទុព្ភាសិតា អត្ថសញ្ហិតា នោ អនត្ថសញ្ហិតា អនុមតា មយា អហំបិ ភិក្ខវេ ឯវំ វទាមិ

ខត្តិយោ សេដ្ឋោ ជនេតស្មឹ យេ គោត្តប្បដិសារិនោ
វិជ្ជាចរណសម្បន្នោ សោ សេដ្ឋោ ទេវមានុសេតិ ។

និស្សយវគ្គោ បឋមោ ។

---

១ ម. ឯត្ថន្តរេ ព្រហ្មុនាតិ បាឋោ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ គាថានេះ ព្រហ្មឈ្មោះសនង្កុមារៈ បានពោល ហើយថា

ជនទាំងឡាយណា ជាអ្នកប្រកាន់ ចំពោះគោត្រ
(បណ្តាជនទាំងនោះ) ក្សត្រិយ៍ ប្រសើរជាង
ប្រជុំជន ជនណា បរិបូណ៌ដោយវិជ្ជានិងចរណៈ
ជននោះជាបុគ្គល ប្រសើរជាងទេវតានិងមនុស្ស ។

ម្នាលភិក្ខុទាំងឡាយ គាថានេះឯង សនង្កុមារព្រហ្មបានច្រៀងត្រូវ ហើយ មិនមែនច្រៀងខុសទេ ជាសុភាសិត មិនមែនទុព្ភាសិតទេ ប្រកប ដោយប្រយោជន៍ មិនមែនមិនប្រកបដោយប្រយោជន៍ទេ ទាំងតថា-គតក៏យល់ព្រម ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគតក៏ពោលយ៉ាងនេះថា

ជនទាំងឡាយណា ជាអ្នកប្រកាន់ ចំពោះគោត្រ
(បណ្តាជនទាំងនោះ) ក្សត្រិយ៍ប្រសើរជាងប្រជុំជន
ជនណា បរិបូណ៌ដោយវិជ្ជានិងចរណៈ ជននោះ
ជាបុគ្គល ប្រសើរជាងទេវតា និងមនុស្សដែរ ។

ចប់ និស្សយវគ្គ ទី ១ ។

# តស្សុទ្ទានំ

កិមត្ថិយា ចេតនា តយោ ឧបនិសា ព្យសនេន ច
សញ្ញាមនសិការោ សទ្ធោ មោរនិវាបេន ច[២] ។

---

២ ម. ព្យសនំ ទ្វេ សញ្ញាមនសិការា សទ្ធោ មោរនិវាបន្តិ ចាហ វិស្សុតិ ។

## ឧទ្ទាននៃនិស្សយវគ្គនោះគឺ

និយាយអំពីសីល មានប្រយោជន៍ ដូចម្ដេច ១
ចេតនា មានបីលើក ឧបនិស្ស័យ ១ សេចក្ដី
វិនាស ១ សញ្ញា ១ មិនធ្វើទុកក្នុងចិត្ត ១
សេក្ខៈ ១ បរិព្វាជការាមឈ្មោះមោរនិវាបស្ថាន ១ ។

# ទុតិយោ ទុតិយវគ្គោ

(១១៨) ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មិំ និគ្រោធារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ អស្សោសិ ខោ មហានាមោ សក្កោ សម្ពហុលា កិរ ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច សុតមេតំ ភន្តេ សម្ពហុលា កិរ ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។

# ទុតិយវគ្គ ទី ២

(១១៨) សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ ក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ភិក្ខុទាំងឡាយ ច្រើនរូប ធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញ ទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ មហានាមសក្កៈ បានឮថា ពួកភិក្ខុ ច្រើនរូប ធ្វើចីវរកម្ម ថ្វាយព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់ចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ គ្រានោះ មហានាមសក្កៈ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះមហានាមសក្កៈ អង្គុយក្នុងទីសមគួរហើយ បានក្រាបទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ បានឮពាក្យ នេះថា ពួកភិក្ខុច្រើនរូប ធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់ នឹងចៀសចេញទៅ កាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។

តេសំ នោ ភន្តេ នានាវិហារេហិ វិហរតំ កេន[1] វិហារេន វិហាតព្វន្តិ ។ សាធុ សាធុ មហានាម ឯតំ ខោ មហានាម តុម្ហាកំ បតិរូបំ កុលបុត្តានំ យំ តុម្ហេ តថាគតំ ឧបសង្កមិត្វា បុច្ឆេយ្យាថ តេសំ នោ ភន្តេ នានាវិហារេហិ វិហរតំ កេន វិហារេន វិហាតព្វន្តិ ។ សទ្ធោ ខោ មហានាម អារាធកោ ហោតិ នោ អស្សទ្ធោ អារទ្ធវីរិយោ អារាធកោ ហោតិ នោ កុសីតោ ឧបដ្ឋិតស្សតិ អារាធកោ ហោតិ នោ មុដ្ឋស្សតិ សមាហិតោ អារាធកោ ហោតិ នោ អសមាហិតោ បញ្ញវា អារាធកោ ហោតិ នោ ទុប្បញ្ញោ ។ ឥមេសុ ខោ ត្វំ មហានាម បញ្ចសុ ធម្មេសុ បតិដ្ឋាយ ឆ ធម្មេ ឧត្តរឹ ភាវេយ្យាសិ ។

---

១ ឱ.ម. កេនស្សុ ។

បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គទាំងនោះ កាលនៅដោយវិហារធម៌ផ្សេង ៗ តើគួរនៅ ដោយវិហារធម៌ ដូចម្តេច ៗ ព្រះអង្គត្រាស់ថា បពិត្រមហានាម ប្រពៃហើយ ប្រពៃហើយ បពិត្រមហានាម ការសួរនេះឯង ជាកិច្ចដ៏សមគួរ ដល់ព្រះអង្គ ជាកុលបុត្រហើយ ដ្បិតថា ព្រះអង្គចូលមកគាល់ តថាគតហើយសួរថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងនោះ កាលនៅដោយវិហារធម៌ផ្សេង ៗ តើគួរនៅដោយវិហារធម៌ដូចម្តេច ៗ បពិត្រមហានាម បុគ្គលអ្នកមានសទ្ធា ញុំាងសទ្ធាឲ្យសម្រេច មិនមែនជាអ្នកមិនមានសទ្ធា ១ អ្នកប្រារព្ធសេចក្តីព្យាយាម ញុំាងព្យាយាមឲ្យសម្រេចមិនមែនជាអ្នកខ្ជិលច្រអូស ១ អ្នកមានសតិខ្ជាប់ខ្ជួន ញុំាងសតិឲ្យសម្រេច មិនមែនជាអ្នកភ្លេចសតិ ១ អ្នកមានចិត្តតាំងមាំ ញុំាងចិត្តដែលតាំងមាំឲ្យសម្រេច មិនមែនជាអ្នកមានចិត្តមិនតាំងមាំ ១ អ្នកមានប្រាជ្ញា ញុំាងប្រាជ្ញាឲ្យសម្រេច មិនមែនជាអ្នកឥតប្រាជ្ញា ១ ៗ បពិត្រមហានាម ព្រះអង្គតាំងនៅក្នុងធម៌ទាំង ៥ នេះហើយ គប្បីចំរើនធម៌ ៦ យ៉ាងទៀត ៗ

## ទុតិយោ ទុតិយវគ្គោ

ឥធ ត្វំ មហានាម តថាគតំ អនុស្ស-
រេយ្យាសិ ឥតិបិ សោ ភគវា អរហំ សម្មា-
សម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ
អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ
ពុទ្ធោ ភគវាតិ ។ យស្មឹ មហានាម សមយេ
អរិយសាវកោ តថាគតំ អនុស្សរតិ នេវស្ស
តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ
ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិ-
យុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ
សមយេ ចិត្តំ ហោតិ តថាគតំ អារព្ភ ឧជុ-
គតចិត្តោ ខោ បន មហានាម អរិយសាវកោ
លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ
ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ
បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ
សុខំ វេទិយតិ សុខិនោ ចិត្តំ សមាធិយតិ ។

បពិត្រមហានាម ក្នុងសាសនានេះ ព្រះអង្គ គប្បីរលឹកនូវតថាគតថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថីទូន្មាននូវបុរស ព្រះអង្គជាសាស្តា នៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹង នូវអរិយសច្ចធម៌ ព្រះអង្គបំបាក់បង់ នូវកព្ទូបេះ ៗ បពិត្រមហានាម អរិយសាវករលឹក នូវតថាគតក្នុងសម័យណា អរិយសាវកនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបានក្នុងសម័យនោះចិត្តរបស់អរិយ-សាវកនោះ ជាចិត្តត្រង់ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ ប្រារព្ធនូវតថាគតហើយ រមែងបានសេចក្ដីយល់នូវអត្ថ សេចក្ដីយល់នូវធម៌ មានសេចក្ដីរីករាយប្រកបដោយធម៌ កាលបើអរិយសាវក មានចិត្តរីករាយហើយ បីតិ តែងកើតឡើង កាលបើអរិយ-សាវកមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយ-សាវក មានកាយស្ងប់រម្ងាប់ហើយ តែងបានទទួល នូវសេចក្ដីសុខ កាលបើអរិយសាវក មានសេចក្ដីសុខហើយ ចិត្តក៏បានតាំងនៅល្អ ៗ

អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ
បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ឈាយ
បជាយ អព្យាបជ្ឈោ វិហរតិ ធម្មសោតសមាបន្នោ
ពុទ្ធានុស្សតឹ ភាវេតិ ។

បុន ចបរំ ត្វំ មហានាម ធម្មំ អនុស្ស-
រេយ្យាសិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ
អកាលិកោ ឯហិបស្សិកោ ឱបនយិកោ
បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ យស្មឹ មហានាម
សមយេ អរិយសាវកោ ធម្មំ អនុស្សរតិ នេវស្ស
តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ
ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ
ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ
ចិត្តំ ហោតិ ធម្មំ អារព្ភ ឧជុគតចិត្តោ ខោ បន
មហានាម អរិយសាវកោ លភតិ អត្ថវេទំ
លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ

បពិត្រមហានាម អរិយសាវ័កនេះ តថាគត ហៅថាអ្នកដល់នូវការស្មោះស្មើ ក្នុងពួកសត្វដែលមិនស្មោះស្មើ អ្នកមិនមានព្យាបាទ ក្នុងពួកសត្វដែលមានសេចក្តីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចំរើននូវធម្មានុស្សតិ ។

បពិត្រមហានាម មួយទៀត ព្រះអង្គគប្បីរលឹកនូវព្រះធម៌ថា ព្រះបរិយត្តិធម៌ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ព្រះនព្វលោកុត្តរធម៌ ជាធម៌ដែលព្រះអរិយបុគ្គលទាំង ៨ ពួក ដឹងពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណ ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សិវិធី ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីឃើញច្បាស់ ក្នុងចិត្តនៃខ្លួន ៗ បពិត្រមហានាម អរិយសាវ័ក រលឹកនូវព្រះធម៌ ក្នុងសម័យណា អរិយ-សាវ័កនោះ ឥតមានរាគៈ រួបរឹតចិត្តបាន ឥតមានទោសៈ រួបរឹតចិត្តបាន ឥតមានមោហៈ រួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ ជាចិត្តត្រង់ ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយ-សាវ័កមានចិត្តត្រង់ ប្រារព្ធនូវព្រះធម៌ តែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បាននូវសេចក្តីរីករាយ ប្រកបដោយធម៌

បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទិយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ជាយ បជាយ អព្យាបជ្ជោ វិហរតិ ធម្មសោតសមាបន្នោ ធម្មានុស្សតឹ ភាវេតិ ។

បុន ចបរំ ត្វំ មហានាម សង្ឃំ អនុស្សរេយ្យាសិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ

## ទុតិយវគ្គ ទី ២

កាលបើអរិយសាវ័ក មានសេចក្តីរីករាយហើយ បីតិ រមែងកើតឡើង កាលបើអរិយសាវ័កមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវ័កមានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើអរិយសាវ័ក មានសេចក្តីសុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម អរិយសាវ័កនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើក្នុងពួកសត្វ ដែលមិនស្មោះស្មើ អ្នកមិនមានព្យាបាទ ក្នុងពួកសត្វដែលមានសេចក្តីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចំរើននូវធម្មានុស្សតិ ។

បពិត្រមហានាម មួយទៀត ព្រះអង្គគប្បីរលឹក នូវព្រះសង្ឃថា ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយ ដោយប្រពៃ ព្រះសង្ឃសាវ័ក នៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយ ដោយត្រង់ ព្រះសង្ឃសាវ័ក នៃព្រះមានព្រះភាគ លោកប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រះសង្ឃសាវ័ក នៃព្រះមានព្រះភាគ លោកប្រតិបត្តិគួរដល់សាមីចិកម្ម ព្រះសង្ឃណា បើរាប់ជាគូ នៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគនុ៎ះ លោកគួរទទួលរបស់ដែលគេនាំមកបូជា លោកគួរទទួលរបស់ ដែលគេបំរុងទទួលភ្ញៀវ លោកគួរទទួលទក្ខិណាទាន

អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ យស្មឹ មហានាម សមយេ អរិយសាវកោ សង្ឃំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ សង្ឃំ អារព្ភ ឧជុគតចិត្តោ ខោ បន មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទិយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ជាយ បជាយ អព្យាបជ្ជោ វិហរតិ ធម្មសោតសមាបន្នោ សង្ឃានុស្សតឹ ភាវេតិ ។

លោកគួរដល់អញ្ជលិកម្ម លោកជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ បពិត្រមហានាម អរិយសាវ័ក រលឹកនូវព្រះសង្ឃ ក្នុងសម័យណា អរិយសាវ័កនោះ ឥតមានរាគៈ រួបរឹតចិត្តបាន ឥតមានទោសៈ រួបរឹតចិត្តបាន ឥតមានមោហៈ រួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយ-សាវ័កនោះ ជាចិត្តត្រង់ ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវ័ក មានចិត្តត្រង់ប្រារព្ធ នូវព្រះសង្ឃហើយ តែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បានសេចក្តីរីករាយប្រកបដោយធម៌ កាលបើអរិយសាវ័ក មានចិត្តរីករាយហើយ បីតិ តែងកើតឡើង កាលបើអរិយសាវ័ក មានចិត្តប្រកប ដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវ័ក មានកាយស្ងប់រម្ងាប់ហើយ តែងទទួលនូវសេចក្តីសុខ កាលបើអរិយសាវ័ក មានសេចក្តីសុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម អរិយសាវ័កនេះ តថាគតហៅថាអ្នកដល់នូវការស្មោះស្មើ ក្នុងពួកសត្វ ដែលមិនមានសេចក្តីស្មោះស្មើ អ្នកមិនមានសេចក្តីព្យាបាទ ក្នុងពួកសត្វដែលមានសេចក្តីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចំរើននូវសង្ឃានុស្សតិ ។

បុន ចបរំ ត្វំ មហានាម អត្តនោ សីលានិ អនុស្សរេយ្យាសិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុប្បសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានីតិ ។ យស្មឹ មហានាម សមយេ អរិយសាវកោ សីលំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ សីលំ អារព្ភ ឧជុគតចិត្តោ ខោ បន មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសំហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទិយតិ សុខិនោ ចិត្តំ សមាធិយតិ ។

ទុតិយវគ្គ ទី ២

បពិត្រមហានាម មួយទៀត ព្រះអរិយសាវ័ក រលឹកនូវសីលទាំងឡាយ របស់ខ្លួនថា សីលមិនដាច់ មិនធ្លុះ មិនពព្រុះ មិនពពាល ជា សីលជាទា ដែលពួកវិញ្ញូជនសរសើរ ជាសីល ដែលតណ្ហា និងទិដ្ឋិ មិនបានស្ទាបអង្អែល ជាសីលប្រព្រឹត្តទៅ ដើម្បីសមាធិ ។ បពិត្រ មហានាម អរិយសាវ័ក រលឹកនូវសីល ក្នុងសម័យណា អរិយសាវ័ក នោះ ឥតមានរាគៈ រួបរឹតចិត្តបាន ឥតមានទោសៈ រួបរឹតចិត្តបាន ឥត មានមោហៈ រួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័ក នោះ ជាចិត្តត្រង់ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវ័ក មានចិត្តត្រង់ ប្រារព្ធនូវសីលហើយ តែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បានសេចក្តីរីករាយ ប្រកបដោយធម៌ កាល បើអរិយសាវ័ក មានចិត្តរីករាយហើយ បីតិក៏កើតឡើង កាលបើ អរិយសាវ័ក មានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះ អរិយសាវ័ក មានកាយស្ងប់រម្ងាប់ហើយ តែងបានទទួល នូវសេចក្តី សុខ កាលបើអរិយសាវ័ក មានសេចក្តីសុខហើយ ចិត្តក៏តាំងនៅល្អ ។

អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ជាយ បជាយ អព្យាបជ្ជោ វិហរតិ ធម្មសោតសមាបន្នោ សីលា-នុស្សតឹ ភាវេតិ ។

បុន ចបរំ ត្វំ មហានាម អត្តនោ ចាគំ អនុស្សរេយ្យាសិ លាភា វត មេ សុលទ្ធំ វត មេ យោហំ មច្ឆេរមលបរិយុដ្ឋិតាយ បជាយ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសាមិ មុត្តចាគោ បយតបាណី វោស្សគ្គរតោ យាច-យោគោ ទានសំវិភាគរតោតិ ។ យស្មឹ មហានាម សមយេ អរិយសាវកោ ចាគំ អនុស្សរតិ នេវ-ស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ ចាគំ អារព្ភ ឧជុគត-ចិត្តោ ខោ បន មហានាម អរិយសាវកោ

បពិត្រមហានាម អរិយសាវកនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើ ក្នុងពពួកសត្វ ដែលមិនមានសេចក្ដីស្មោះស្មើ អ្នកមិនមានសេចក្ដីព្យាបាទ ក្នុងពពួកសត្វ ដែលមានសេចក្ដីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចំរើននូវសីលានុស្សតិ ។

បពិត្រមហានាម មួយទៀត ព្រះអង្គគប្បីរលឹកនូវចាគៈ របស់ព្រះអង្គថា ឱហ្ន៎ អាត្មាអញ ចំជាមានលាភ ឱហ្ន៎ អាត្មាអញបានល្អហើយតើ អាត្មាអញមានចិត្ត មានមន្ទិល គឺសេចក្ដីកំណាញ់ប្រាសចេញហើយ ក្នុងពពួកសត្វ ដែលមានមន្ទិលគឺសេចក្ដីកំណាញ់រួបរឹតហើយ បានបរិច្ចាគរួចហើយ មានដៃលាងស្អាតហើយ ត្រេកអរ ក្នុងការលះបង់ គួរឲ្យគេសូមបាន ត្រេកអរ ក្នុងការចែករំលែកទាន នៅគ្រប់គ្រងផ្ទះ ។ បពិត្រមហានាម អរិយសាវក រលឹកនូវចាគៈ ក្នុងសម័យណា អរិយសាវកនោះ ឥតមានរាគៈ រួបរឹតចិត្តបាន ឥតមានទោសៈ រួបរឹតចិត្តបាន ឥតមានមោហៈ រួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ជាចិត្តត្រង់ ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ ប្រារព្ធនូវចាគៈហើយ

លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូ-
បសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ
បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ
សុខំ វេទិយតិ សុខិនោ ចិត្តំ សមាធិយតិ ។
អយំ វុច្ចតិ មហានាម អរិយសាវកោ វិស-
មគតាយ បជាយ សមប្បត្តោ វិហរតិ សព្យា-
បជ្ជាយ បជាយ អព្យាបជ្ជោ វិហរតិ ធម្ម-
សោតសមាបន្នោ ចាគានុស្សតឹ ភាវេតិ ។

បុន ចបរំ ត្វំ មហានាម ទេវតា អនុស្ស-
រេយ្យាសិ សន្តិ ទេវា ចាតុម្មហារាជិកា សន្តិ
ទេវា តាវតិំសា សន្តិ ទេវា យាមា សន្តិ
ទេវា តុសិតា សន្តិ ទេវា និម្មានរតិនោ
សន្តិ ទេវា បរនិម្មិតវសវត្តិនោ សន្តិ ទេវា
ព្រហ្មកាយិកា សន្តិ ទេវា តតុត្តរិ យថា-
រូបាយ សទ្ធាយ សមន្នាគតា តា ទេវតា

## ទុតិយវគ្គ ទី ២

តែងបានសេចក្ដីយល់នូវអត្ថ បានសេចក្ដីយល់នូវធម៌ បានសេចក្ដីរីករាយប្រកបដោយធម៌ កាលបើអរិយសាវ័កមានចិត្តរីករាយហើយ បីតិតែងកើតឡើង កាលបើអរិយសាវ័កមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវ័ក មានកាយស្ងប់រម្ងាប់ហើយ តែងបានទទួលនូវសេចក្ដីសុខ កាលបើអរិយសាវ័កមានសេចក្ដីសុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម អរិយសាវ័កនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើ ក្នុងពួកសត្វ ដែលមិនមានសេចក្ដីស្មោះស្មើ អ្នកមិនមានសេចក្ដីព្យាបាទ ក្នុងពួកសត្វ ដែលមានសេចក្ដីព្យាបាទ អ្នកដល់នូវខ្សែនៃធម៌ តែងចំរើននូវចាគានុស្សតិ ។

បពិត្រមហានាម មួយវិញទៀត ព្រះអង្គគប្បីរលឹកនូវពួកទេវតាថា ពួកទេវតាជាន់ចាតុម្មហារាជិកៈ មានពួកទេវតាជាន់តាវត្តិង្ស មានពួកទេវតាជាន់យាមៈ មានពួកទេវតាជាន់តុសិត មានពួកទេវតាជាន់និម្មានរតី មានពួកទេវតាជាន់បរនិម្មិតវសវត្តី មានពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម មានពួកទេវតា តពីនោះទៅទៀត ក៏មាន ពួកទេវតាទាំងនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា

ឥតោ ចុតា តត្ថ ឧប្បន្នា(១) មយ្ហម្បិ តថារូបា សទ្ធា សំវិជ្ជតិ យថារូបេន សីលេន សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧប្បន្នា មយ្ហម្បិ តថារូបំ សីលំ សំវិជ្ជតិ យថារូបេន សុតេន សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧប្បន្នា មយ្ហម្បិ តថារូបំ សុតំ សំវិជ្ជតិ យថារូបេន ចាគេន សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧប្បន្នា មយ្ហម្បិ តថារូបោ ចាគោ សំវិជ្ជតិ យថារូបាយ បញ្ញាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧប្បន្នា មយ្ហម្បិ តថារូបា បញ្ញា សំវិជ្ជតីតិ ។ យស្មឹ មហានាម សមយេ អរិយសាវកោ អត្តនោ ច តាសញ្ច ទេវតានំ សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរតិ នេវស្ស តស្មឹ សមយេ

១ ឱ, តត្ថ ឧបបន្នា ។ ម. តត្ថូបបន្នា ។

ច្យុតអំពីទីនេះ ទៅកើត ក្នុងទីនោះ អាត្មាអញមានសទ្ធា មានសភាពដូច្នោះដែរ ពួកទេវតាទាំងនោះ ប្រកបដោយសីល មានសភាពយ៉ាងណា ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ អាត្មាអញមានសីល មានសភាពដូច្នោះ ពួកទេវតាទាំងនោះ ប្រកបដោយសុតៈ មានសភាពយ៉ាងណា ច្យុតអំពីទីនេះ ទៅកើត ក្នុងទីនោះ អាត្មាអញមានសុតៈ មានសភាពដូច្នោះដែរ ពួកទេវតាទាំងនោះ ប្រកបដោយចាគៈ មានសភាពយ៉ាងណា ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ អាត្មាអញមានចាគៈ មានសភាពដូច្នោះដែរ ពួកទេវតា ទាំងនោះ ប្រកបដោយបញ្ញា មានសភាពយ៉ាងណា ច្យុតអំពីទីនេះ ទៅកើត ក្នុងទីនោះ អាត្មាអញមានបញ្ញា មានសភាពដូច្នោះដែរ ។ បពិត្រមហានាម អរិយសាវ័ក រលឹក នូវសទ្ធា សីល សុតៈ ចាគៈ បញ្ញា របស់ខ្លួនផង របស់ពួកទេវតាទាំងនោះផង ក្នុងសម័យណា

រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ ទេវតា អារព្ភ ឧជុគតចិត្តោ ខោ បន មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទិយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ជាយ បជាយ អព្យាបជ្ជោ វិហរតិ ធម្មសោតសមាបន្នោ ទេវតានុស្សតឹ ភាវេតិ ។

(១១៩) ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។

## ទុតិយវគ្គ ទី ២

អរិយសាវ័កនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ ជាចិត្តត្រង់ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវ័ក មានចិត្តត្រង់ ប្រារព្ធនូវពួកទេវតាហើយ តែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បានសេចក្តីរីករាយ ប្រកបដោយធម៌ កាលបើអរិយសាវ័ក មានចិត្តរីករាយហើយ បីតិក៏កើតឡើង កាលបើអរិយសាវ័ក មានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវ័ក មានកាយស្ងប់រម្ងាប់ហើយ តែងបានទទួលនូវសេចក្តីសុខ កាលបើអរិយសាវ័ក មានសេចក្តីសុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម អរិយសាវ័កនេះ តថាគតហៅថា អ្នកដល់នូវការស្មោះស្មើ ក្នុងពួកសត្វ ដែលមិនមានសេចក្តីស្មោះស្មើ អ្នកមិនមានព្យាបាទ ក្នុងពួកសត្វ ដែលមានសេចក្តីព្យាបាទ អ្នកដល់នូវខ្សែនធម៌ តែងចំរើននូវទេវតានុស្សតិ ។

( ១១៩ ) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។

តេន ខោ បន សមយេន មហានាមោ សក្កោ
គិលានា វុដ្ឋិតោ ហោតិ អចិរវុដ្ឋិតោ គេលញ្ញា ។
តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ
ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា
តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។
អស្សោសិ ខោ មហានាមោ សក្កោ សម្ពហុ-
លា កិរ ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ
និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ
បក្កមិស្សតីតិ ។ អថខោ មហានាមោ សក្កោ
យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគ-
វន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ
ឯតទវោច សុតមេតំ ភន្តេ សម្ពហុលា កិរ
ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ
ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។

សម័យនោះឯង មហានាមសក្កៈ ទើបនឹងសះស្បើយ ចាកជម្ងឺ បានសះស្បើយ ចាកជម្ងឺ មិនទាន់យូរប៉ុន្មាន ។ សម័យនោះឯង ស្រាប់តែពួកភិក្ខុច្រើនរូប កំពុងធ្វើចីវរកម្ម ថ្វាយ ចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ មហានាមសក្កៈបាន ឮថា ពួកភិក្ខុច្រើនរូប កំពុងធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយនឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ គ្រានោះមហានាមសក្កៈ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះមហានាមសក្កៈ អង្គុយ ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮ ពាក្យនេះថា ពួកភិក្ខុច្រើនរូប កំពុងធ្វើចីវរកម្ម ថ្វាយ ចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយទ្រង់នឹងចៀសចេញទៅ កាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។

ទុតិយោ ទុតិយវគ្គោ

កេសំ នោ ភន្តេ នានាវិហារេហិ វិហរតំ កេន(១) វិហារេន វិហាតព្វំ ។ សាធុ សាធុ មហានាម ឯតំ ខោ មហានាម តុម្ហាកំ បដិរូបំ កុលបុត្តានំ យំ តុម្ហេ តថាគតំ ឧបសង្កមិត្វា បុច្ឆេយ្យាថ កេសំ នោ ភន្តេ នានាវិហារេហិ វិហរតំ កេន វិហារេន វិហាតព្វន្តិ ។ សទ្ធោ ខោ មហានាម អារាធកោ ហោតិ នោ អស្សទ្ធោ អារទ្ធវីរិយោ អារាធកោ ហោតិ នោ កុសីតោ ឧបដ្ឋិតស្សតិ អារាធកោ ហោតិ នោ មុដ្ឋស្សតិ សមាហិតោ អារាធកោ ហោតិ នោ អសមាហិតោ បញ្ញវា អារាធកោ ហោតិ នោ ទុប្បញ្ញោ ។ ឥមេសុ ខោ ត្វំ មហានាម បញ្ចសុ ធម្មេសុ បតិដ្ឋាយ ឆ ធម្មេ ឧត្តរឹ ភាវេយ្យាសិ ។

---

១ ឱ.ម. កេនស្សុ ។

## ទុតិយវគ្គ ទី ២

បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គទាំងនោះ កាលនៅដោយវិហារធម៌ផ្សេង ៗ តើគួរនៅ ដោយវិហារធម៌ ដូចម្ដេច ។ ព្រះអង្គត្រាស់ថា បពិត្រមហានាម ប្រពៃហើយ ប្រពៃហើយ បពិត្រមហានាម ការសួរនេះឯង ជាកិច្ចដ៏សមគួរ ដល់ព្រះអង្គជាកុលបុត្រហើយ ដែលថា ព្រះអង្គចូលមកគាល់តថាគត ហើយសួរថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងនោះ កាលនៅ ដោយវិហារធម៌ផ្សេង ៗ តើគួរនៅ ដោយវិហារធម៌ ដូចម្ដេច ។ បពិត្រមហានាម បុគ្គលជាអ្នកមានសទ្ធា បានញុំាងសទ្ធា ឲ្យសម្រេច មិនមែនជាអ្នកមិនមានសទ្ធា ១ អ្នកប្រារព្ធសេចក្ដីព្យាយាម ញុំាងព្យាយាម ឲ្យសម្រេច មិនមែន ជាអ្នកខ្ជិលច្រអូស ១ អ្នកមានសតិខ្ជាប់ខ្ជួន ញុំាងសតិឲ្យសម្រេច មិនមែនជាអ្នកភ្លេចសតិ ១ ជាអ្នកមានចិត្តតាំងមាំ បានញុំាងចិត្តដែលតាំងមាំ ឲ្យសម្រេច មិនមែនជាអ្នកមានចិត្តមិនតាំងមាំ ១ អ្នកមានប្រាជ្ញា បានញុំាងប្រាជ្ញា ឲ្យសម្រេច មិនមែនជាអ្នកអប្បឥតប្រាជ្ញា ១ ។ បពិត្រមហានាម កាលបើព្រះអង្គ បានតាំងនៅក្នុងធម៌ទាំង ៥ នេះហើយគប្បីចំរើននូវធម៌ ៦ យ៉ាង តទៅទៀត ។

ឥធ ត្វំ មហានាម តថាគតំ អនុស្សរេយ្យាសិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ យស្មិំ មហានាម សមយេ អរិយសាវកោ តថាគតំ អនុស្សរតិ នេវស្ស តស្មិំ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មិំ សមយេ ចិត្តំ ហោតិ តថាគតំ អារព្ភ ឧជុគតចិត្តោ ខោ បន មហា-នាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុ-ទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទិយតិ សុ-ខិនោ ចិត្តំ សមាធិយតិ ។ ឥមំ ខោ ត្វំ មហា-នាម ពុទ្ធានុស្សតឹ គច្ឆន្តោបិ ភាវេយ្យាសិ ឋិ-តោបិ ភាវេយ្យាសិ និសិន្នោបិ ភាវេយ្យាសិ

បពិត្រមហានាម ព្រះអង្គគប្បីរលឹកនូវព្រះតថាគត ក្នុងលោកនេះថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្ដាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ បពិត្រមហានាម អរិយសាវ័ករលឹកនូវព្រះតថាគត ក្នុងសម័យណា អរិយសាវ័កនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈ រួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ ជាចិត្តត្រង់ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវ័កមានចិត្តត្រង់ប្រារព្ធនូវព្រះតថាគតហើយ តែងបានសេចក្ដីយល់នូវអត្ថ បានសេចក្ដីយល់នូវធម៌ បានសេចក្ដីរីករាយប្រកបដោយធម៌ កាលបើអរិយសាវ័កមានចិត្តរីករាយហើយ បីតិក៏កើតឡើង កាលបើអរិយសាវ័កមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវ័កមានកាយស្ងប់រម្ងាប់ហើយ តែងបានទទួលនូវសេចក្ដីសុខ កាលបើអរិយសាវ័កមានសេចក្ដីសុខហើយ ចិត្តក៏តាំងនៅល្អ ។ បពិត្រមហានាម ព្រះអង្គកំពុងស្ដេចយាងក្ដី គប្បីចំរើន ឋិតក្ដី គប្បីចំរើន គង់ក្ដី គប្បីចំរើន

## ទុតិយោ ទុតិយវគ្គោ

សយានោបិ ករេយ្យាសិ កម្មន្តំ អធិដ្ឋហន្តោបិ ករេយ្យាសិ បុត្តសម្ពាធសយនំ អជ្ឈាវសន្តោបិ ករេយ្យាសិ ។

បុន ចបរំ ត្វំ មហានាម ធម្មំ អនុស្សរេយ្យាសិ... សង្ឃំ អនុស្សរេយ្យាសិ... អត្តនោ សីលានិ អនុស្សរេយ្យាសិ... អត្តនោ ចាគំ អនុស្សរេយ្យាសិ... ទេវតា អនុស្សរេយ្យាសិ សន្តិ ទេវា ចាតុម្មហារាជិកា... សន្តិ ទេវា តតុត្តរិំ យថារូបាយ សទ្ធាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧប្បន្នា មយ្ហម្បិ តថារូបា សទ្ធា សំវិជ្ជតិ យថារូបេន សីលេន..., សុតេន ... ចាគេន ... បញ្ញាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧប្បន្នា មយ្ហម្បិ តថារូបា បញ្ញា សំវិជ្ជតីតិ ។ យស្មិំ មហានាម សមយេ អរិយសាវកោ អត្តនោ ច តាសញ្ច ទេវតានំ សទ្ធញ្ច សីលញ្ច សុតញ្ច

ផុំក្ដី គប្បីចំរើន ផ្គូផ្គងការស៊ាំរក្ដី គប្បីចំរើន គ្រប់គ្រងទីផ្ទុំដែលបង្អៀតដោយព្រះរាជបុត្តក្ដី គប្បីចំរើន នូវពុទ្ធានុស្សតិនេះបានដែរ ។

បពិត្រមហានាម មួយទៀត ព្រះអង្គគប្បីរលឹកនូវព្រះធម៌. . . គប្បីរលឹកនូវព្រះសង្ឃ . . . គប្បីរលឹកនូវសីលទាំងឡាយរបស់ព្រះអង្គ . . . គប្បីរលឹកនូវចាគៈរបស់ព្រះអង្គ . . . គប្បីរលឹកនូវពួកទេវតាថា ពួកទេវតាក្នុងជាន់ចាតុម្មហារាជិកៈ មាន . . . ពួកទេវតាក្រៅពីនោះទៅទៀតក៏មាន ពួកទេវតាទាំងនោះ ប្រកបដោយសទ្ធាមានសភាពយ៉ាងណា ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ អាត្មាអញមានសទ្ធា មានសភាពដូច្នោះដែរ ដោយសីល មានសភាពយ៉ាងណា . . . ដោយសុតៈ . . . ដោយចាគៈ . . . ពួកទេវតាទាំងនោះប្រកប ដោយបញ្ញា ច្យុតអំពីទីនេះ មានសភាពយ៉ាងណា ទៅកើតក្នុងទីនោះ អាត្មាអញមានបញ្ញា មានសភាពដូច្នោះដែរ ។ បពិត្រមហានាម អរិយសាវ័ករលឹកនូវសទ្ធា សីល សុតៈ

ចាគញ្ច បញ្ញញ្ច អនុស្សរតិ នេវស្ស តស្មឹ សមយេ លោភបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ ទេវតា អារព្ភ ឧជុគតចិត្តោ ខោ បន មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទិយតិ សុខិនោ ចិត្តំ សមាធិយតិ ។ ឥមំ ខោ ត្វំ មហានាម ទេវតានុស្សតឹ គច្ឆន្តោបិ ភាវេយ្យាសិ តិដ្ឋន្តោបិ ភាវេយ្យាសិ និសិន្នោបិ ភាវេយ្យាសិ សយានោបិ ភាវេយ្យាសិ កម្មន្តំ អធិដ្ឋហន្តោបិ ភាវេយ្យាសិ បុត្តសម្ពាធសយនំ អជ្ឈាវសន្តោបិ ភាវេយ្យាសិ ។

បាត: បញ្ហា របស់ខ្លួនផង របស់ពួកទេវតាទាំងនោះផង ក្នុងសម័យណា អរិយសាវ័កនោះ ឥតមានរាគៈរួបរឹតចិត្តបាន ឥតមានទោសៈរួបរឹតចិត្តបាន ឥតមានមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ ជាចិត្តត្រង់ ក្នុងសម័យនោះ បពិត្រមហានាម លុះអរិយសាវ័កមានចិត្តត្រង់ ប្រារព្ធនូវពួកទេវតាហើយ រមែងបានសេចក្តីយល់នូវអត្ថ បានសេចក្តីយល់នូវធម៌ បានសេចក្តីរីករាយប្រកបដោយធម៌ កាលបើអរិយសាវ័កមានចិត្តប្រកប ដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះអរិយសាវ័ក មានកាយស្ងប់រម្ងាប់ហើយ តែងបានទទួលនូវសេចក្តីសុខ កាលបើអរិយសាវ័ក មានសេចក្តីសុខហើយ ចិត្តតាំងនៅល្អ ។ បពិត្រមហានាម ព្រះអង្គកំពុងស្តេចយាងក្តី គប្បីចំរើន ឋិតក្តី គប្បីចំរើន គង់ក្តី គប្បីចំរើន ផ្ទំក្តី គប្បីចំរើន ផ្គូរផ្គងការងារក្តី គប្បីចំរើន គ្រប់គ្រងនូវទីផ្ទំដែលចង្អៀត ដោយព្រះរាជបុត្រក្តី គប្បីចំរើននូវទេវតានុស្សតិនេះបានដែរ ។

## ទុតិយោ ទុតិយវគ្គោ

(១២០) ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន ភគវា សាវត្ថិយំ វស្សាវាសំ ឧបគន្តុកាមោ ហោតិ ។ អស្សោសិ ខោ នន្ទិយោ សក្កោ ភគវា កិរ សាវត្ថិយំ វស្សាវាសំ ឧបគន្តុកាមោតិ ។ អថខោ នន្ទិយស្ស សក្កស្ស ឯតទហោសិ យន្នូនាហម្បិ សាវត្ថិយំ វស្សាវាសំ ឧបគច្ឆេយ្យំ តត្ថ កម្មន្តញ្ចេវ អធិដ្ឋហិស្សាមិ ភគវន្តញ្ច លច្ឆាមិ កាលេន កាលំ ទស្សនាយាតិ ។ អថខោ ភគវា សាវត្ថិយំ វស្សាវាសំ ឧបគច្ឆិ(១) ។ នន្ទិយោបិ ខោ សក្កោ សាវត្ថិយំ វស្សាវាសំ ឧបគច្ឆិ តត្ថ កម្មន្តញ្ចេវ អធិដ្ឋាតិ(២) ភគវន្តញ្ច លច្ឆតិ(៣) កាលេន កាលំ ទស្សនាយ ។

---

១ ឱ. ឧបគញ្ឆិ ។ ២ ឱ. អធិដ្ឋាសិ ។ ៣ ឱ. លភិ ។

## ទុតិយវគ្គ ទី ២

(១៦០) សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ព្រះមានព្រះភាគ មានបំណងនឹងចូលទៅគង់ចាំវស្សា ក្នុងក្រុងសាវត្ថី ។ នន្ទិយសក្កៈ បានឮដំណឹងថា ព្រះមានព្រះភាគ មានបំណងនឹងចូលទៅគង់ចាំវស្សា ក្នុងក្រុងសាវត្ថី ។ គ្រានោះ នន្ទិយសក្កៈ មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ ទាំងអាត្មាអញ ក៏គួរចូលទៅនៅចាំវស្សា ក្នុងក្រុងសាវត្ថីដែរ អាត្មាអញ នឹងធ្វើផងការងារ ក្នុងក្រុងសាវត្ថីនោះផង នឹងបានចួបព្រះមានព្រះភាគ មួយវេលាមួយកាលផង ។ លំដាប់នោះ ព្រះមានព្រះភាគ ស្តេចទៅគង់ចាំវស្សា ក្នុងក្រុងសាវត្ថី ។ ចំណែកខាងនន្ទិយសក្កៈ ក៏ចូលទៅនៅចាំវស្សា ក្នុងក្រុងសាវត្ថីដែរ ទាំងធ្វើផងការងារ ក្នុងក្រុងសាវត្ថីនោះផង បានចួបព្រះមានព្រះភាគ មួយវេលាមួយកាលផង ។

តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ អស្សោសិ ខោ នន្ទិយោ សក្កោ សម្ពហុលា កិរ ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ អថ ខោ នន្ទិយោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ នន្ទិយោ សក្កោ ភគវន្តំ ឯតទវោច សុតមេតំ ភន្តេ សម្ពហុលា កិរ ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ តេសំ នោ ភន្តេ នានាវិហារេហិ វិហរតំ កេន វិហារេន វិហាតព្វន្តិ ។

សម័យនោះឯង ពួកភិក្ខុជាច្រើនរូប ធ្វើចីវរកម្ម ថ្វាយ ចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់ចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ នន្ទិយសក្កៈ បានឮថា ពួកភិក្ខុច្រើនរូប ធ្វើចីវរកម្ម ថ្វាយចំពោះព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញទៅកាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ លំដាប់នោះ នន្ទិយសក្កៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនន្ទិយសក្កៈ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ពួកភិក្ខុច្រើនរូប ធ្វើចីវរកម្ម ថ្វាយ ចំពោះ ព្រះមានព្រះភាគ ដោយគិតថា ព្រះមានព្រះភាគ មានចីវរសម្រេចហើយ ទ្រង់នឹងចៀសចេញទៅ កាន់ចារិក ដោយកាលកន្លងទៅ ៣ ខែ ។ បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងនោះកាលនៅដោយវិហារធម៌ផ្សេងៗ តើគួរនៅដោយវិហារធម៌ដូចម្តេច ។

សាធុ សាធុ នន្ទិយ ឯវំ ខោ នន្ទិយ តុម្ហាកំ បដិរូបំ កុលបុត្តានំ យំ តុម្ហេ តថាគតំ ឧបសង្កមិត្វា បុច្ឆេយ្យាថ តេសំ នោ ភន្តេ នានាវិហារេហិ វិហរតំ កេន វិហារេន វិហាតព្វន្តិ ។ សទ្ធោ ខោ នន្ទិយ អារាធកោ ហោតិ នោ អស្សទ្ធោ សីលវា អារាធកោ ហោតិ នោ ទុស្សីលោ អារទ្ធវីរិយោ អារាធកោ ហោតិ នោ កុសីតោ ឧបដ្ឋិតស្សតិ អារាធកោ ហោតិ នោ មុដ្ឋស្សតិ សមាហិតោ អារាធកោ ហោតិ នោ អសមាហិតោ បញ្ញវា អារាធកោ ហោតិ នោ ទុប្បញ្ញោ ។ ឥមេសុ ខោ តេ នន្ទិយ ឆសុ ធម្មេសុ បតិដ្ឋាយ បញ្ចសុ ធម្មេសុ អជ្ឈត្តំ សតិ ឧបដ្ឋបេតព្វា ។ ឥធ ត្វំ នន្ទិយ តថាគតំ អនុស្សរេយ្យាសិ ឥតិបិ

ព្រះអង្គត្រាស់ថា ម្នាលនន្ទិយៈ ប្រពៃហើយ ប្រពៃហើយ ម្នាលនន្ទិយៈ ការសួរនេះឯង ជាកិច្ចដ៏សមគួរ ដល់ទ្រង់ជាកុលបុត្រហើយ ដ្បិតថា ទ្រង់ ចូលមកគាល់តថាគត ហើយសួរថា បពិត្រព្រះអង្គ ដ៏ចំរើន ពួកខ្ញុំព្រះអង្គទាំងនោះ កាលនៅ ដោយវិហារធម៌ផ្សេង ៗ តើគួរនៅ ដោយវិហារធម៌ ដូចម្តេច ៗ ម្នាលនន្ទិយៈ បុគ្គល ជាអ្នកមានសទ្ធា បានញុំាងសទ្ធា ឲ្យសម្រេច មិនមែនជាអ្នកមិនមានសទ្ធា ១ ជាអ្នកមាន សីល បានញុំាងសីល ឲ្យសម្រេច មិនមែនជាអ្នកទ្រុស្តសីល ១ ជាអ្នកប្រារព្ធសេចក្តីព្យាយាម បានញុំាងព្យាយាម ឲ្យសម្រេច មិន មែនជាអ្នកខ្ជិលច្រអូស ១ ជាអ្នកមានសតិខ្ជាប់ខ្ជួន បានញុំាងសតិ ឲ្យ សម្រេច មិនមែនជាអ្នកភ្លេចសតិ ១ ជាអ្នកមានចិត្តតាំងមាំ បានញុំាង ចិត្តដែលតាំងមាំ ឲ្យសម្រេច មិនមែនជាអ្នកមានចិត្តមិនតាំងមាំ ១ ជាអ្នកមានប្រាជ្ញា បានញុំាងប្រាជ្ញា ឲ្យសម្រេច មិនមែនជាអ្នកឥ៍ប្ប ឥតប្រាជ្ញា ១ ៗ ម្នាលនន្ទិយៈ បើទ្រង់បានតាំងនៅក្នុងធម៌ ទាំង ៦ នេះហើយ គួរដម្កល់សតិ ក្នុងធម៌ ៥ យ៉ាង ក្នុងព្រះហឫទ័យ តទៅ ទៀត ៗ ម្នាលនន្ទិយៈ ទ្រង់គប្បីរលឹកនូវព្រះតថាគត ក្នុងលោកនេះថា

សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ឥតិ ខោ តេ នន្ទិយ តថាគតំ អារព្ភ អជ្ឈត្តំ សតិ ឧបដ្ឋបេតព្វា ។

បុន ចបរំ ត្វំ នន្ទិយ ធម្មំ អនុស្ស-រេយ្យាសិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ឥតិ ខោ តេ នន្ទិយ ធម្មំ អារព្ភ អជ្ឈត្តំ សតិ ឧបដ្ឋបេតព្វា ។

ព្រះមានព្រះភាគអង្គនោះ ជាអរហន្ត សម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក ទ្រង់ប្រសើរ ដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថី ទូន្មាននូវបុរស ព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ ម្នាលនន្ទិយៈ ព្រះអង្គទ្រង់គួរដម្កល់សតិ ក្នុងព្រះហឫទ័យ ប្រារព្ធនូវព្រះតថាគត ដោយប្រការដូច្នេះ ។

ម្នាលនន្ទិយៈ មួយទៀត ព្រះអង្គទ្រង់ គប្បីរលឹក នូវព្រះធម៌ថា ព្រះបរិយត្តិធម៌ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ព្រះនព្វលោកុត្តរធម៌ ជាធម៌ដែលអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ ជាធម៌ឲ្យនូវផល មិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សិវិធី ជាធម៌ដែលអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម ឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។ ម្នាលនន្ទិយៈ ព្រះអង្គទ្រង់គួរដម្កល់សតិ ក្នុងព្រះហឫទ័យ ប្រារព្ធនូវព្រះធម៌ ដោយប្រការដូច្នេះ ។

ទុតិយោ ទុតិយវគ្គោ

បុន ចបរំ ត្វំ ឆន្ទិយ កល្យាណមិត្តេ អនុស្សរេយ្យាសិ លាភា វត មេ សុលទ្ធំ វត មេ យស្ស កល្យាណមិត្តា អនុកម្បកា អត្ថកាមា ឱវាទកា អនុសាសិកាតិ(១) ។ ឥតិ ខោ តេ ឆន្ទិយ កល្យាណមិត្តេ អារព្ភ អជ្ឈត្តំ សតិ ឧបដ្ឋបេតព្វា ។

បុន ចបរំ ត្វំ ឆន្ទិយ អត្តនោ ចាគំ អនុស្សរេយ្យាសិ លាភា វត មេ សុលទ្ធំ វត មេ យោហំ មច្ឆេរមលបរិយុដ្ឋិតាយ បជាយ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសាមិ មុត្តចាគោ បយតបាណី វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោតិ ។ ឥតិ ខោ តេ ឆន្ទិយ ចាគំ អារព្ភ អជ្ឈត្តំ សតិ ឧបដ្ឋបេតព្វា ។

១ ទិ.ប. អនុសាសកាតិ ។

## ទុតិយវគ្គ ទី ២

ម្នាលនន្ទិយៈ មួយទៀត ទ្រង់គប្បីរលឹកនូវពួកកល្យាណមិត្ត ថា ឱហ្ន៎ អាត្មាអញចំជាមានលាភ អាត្មាអញបានល្អហើយ ដែលមានពួកជន ជាកល្យាណមិត្ត ជាអ្នកអនុគ្រោះ អ្នកប្រាថ្នានូវប្រយោជន៍ អ្នកទូន្មាន អ្នកប្រៀនប្រដៅ ។ ម្នាលនន្ទិយៈ ទ្រង់គួរដម្កល់សតិ ក្នុងព្រះហឫទ័យ ប្រារព្ធ នូវពួកកល្យាណមិត្ត ដោយប្រការដូច្នេះ ។

ម្នាលនន្ទិយៈ មួយទៀត ទ្រង់គប្បីរលឹក នូវចាគៈរបស់ទ្រង់ថា ឱហ្ន៎ អាត្មាអញចំជាមានលាភ អាត្មាអញល្អហើយតើ ដែលអាត្មាអញ មានចិត្តមានមន្ទិលគឺសេចក្តីកំណាញ់ប្រាសចេញហើយ ក្នុងពួកសត្វ ដែលមានមន្ទិល គឺសេចក្តីកំណាញ់ រួបរឹតហើយ មានទានបរិច្ចាគហើយ មានដៃលាងស្អាតហើយ ត្រេកអរក្នុងការលះ គួរឲ្យគេសូមបាន ត្រេកអរក្នុងការឲ្យទាននិងការចែករំលែក ហើយនៅគ្រប់គ្រងផ្ទះ ។ ម្នាលនន្ទិយៈ ទ្រង់គួរដម្កល់ នូវសតិ ក្នុងព្រះហឫទ័យ ប្រារព្ធនូវចាគៈ ដោយប្រការដូច្នេះ ។

បុន ចបរំ ត្វំ នន្ទិយ ទេវតា អនុស្សរេយ្យាសិ យា តា ទេវតា អតិក្កម្មេវ កពឡីការភក្ខានំ(១) ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នា តា ករណីយំ អត្តនោ ន សមនុបស្សន្តិ កតស្ស វា បដិចយំ សេយ្យថាបិ នន្ទិយ ភិក្ខុ អសមយវិមុត្តោ ករណីយំ អត្តនោ ន សមនុបស្សតិ កតស្ស វា បដិចយំ ឯវមេវ ខោ នន្ទិយ យា តា ទេវតា អតិក្កម្មេវ កពឡីការភក្ខានំ ទេវានំ សហព្យតំ អញ្ញតរំ មនោមយំ កាយំ ឧបបន្នា តា ករណីយំ អត្តនោ ន សមនុបស្សន្តិ កតស្ស វា បដិចយន្តិ ។ ឥតិ ខោ តេ នន្ទិយ ទេវតា អារព្ភ អជ្ឈត្តំ សតិ ឧបដ្ឋាបេតព្វា ។

---

១ ម. កពឡីការាហារភក្ខានំ ។

ម្នាលនន្ទិយៈ មួយទៀត ទ្រង់គប្បីរលឹកពួកទេវតាថា ទេវតាណា ដែលរំលងនូវពួកទេវតា ដែលមានកពឡីការាហារ ជាចំណី (កាមាវចរទេវតា) បានទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយឈាន-ចិត្ត (ព្រហ្ម) ណាមួយ ទេវតាទាំងនោះ មិនពិចារណាឃើញនូវកិច្ចរបស់ខ្លួន ឬនូវសេចក្តីចំរើន នៃអំពើដែលខ្លួនធ្វើហើយ ម្នាលនន្ទិយៈ ដូចជាភិក្ខុអសមយវិមុត្ត រមែងមិនពិចារណាឃើញ នូវកិច្ចរបស់ខ្លួន ឬ នូវសេចក្តីចំរើននៃអំពើដែលខ្លួនធ្វើហើយ យ៉ាងណាមិញ ម្នាលនន្ទិយៈ ទេវតាណា ដែលផុះរំលង នូវពួកទេវតា ដែលមានកពឡីការាហារ ជាចំណី បានទៅកើត ក្នុងពួកទេវតា ដែលសម្រេចដោយឈាន-ចិត្តណាមួយ ទេវតាទាំងនោះ រមែងមិនពិចារណាឃើញ នូវកិច្ចរបស់ខ្លួន ឬនូវសេចក្តីចំរើន នៃអំពើដែលខ្លួនធ្វើហើយ ក៏យ៉ាងនោះដែរ ។ ម្នាលនន្ទិយៈ ទ្រង់គប្បីដម្កល់សតិ ក្នុងព្រះហឫទ័យ ប្រារព្ធនូវពួកទេវតា ដោយប្រការដូច្នេះឯង ។

ទុតិយោ ទុតិយវគ្គោ

ឥមេហិ ខោ ឆន្ទិយ ឯកាទសហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ បជហតេវ បាប-កេ អកុសលេ ធម្មេ ន ឧបាទិយតិ ។ សេយ្យថាបិ ឆន្ទិយ កុម្ភោ និក្កុជ្ជោ នោ វន្តំ បច្ចាមសតិ(១) សេយ្យថាបិ ឆន្ទិយ តិ-ណា(២) អគ្គិ មុត្តោ ឱហារេញ្ញ កឌ្ឍតិ នោ ឧទ្ធំ បច្ចុទាវត្តតិ ឯវមេវ ខោ ឆន្ទិយ ឥមេហិ ឯកាទសហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ បជហតេវ បាបកេ អកុសលេ ធម្មេ ន ឧបាទិយតីតិ ។

[ ១២១ ] អថខោ អាយស្មា សុភូតិ សទ្ធេន ភិក្ខុនា សទ្ធឹ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សុភូតឹ ភគវា

១ ឱ. ម. និក្កុជ្ជោ ភមេវ ឧទកំ នោ វន្តំ បច្ចាវមតីតិ ទិស្សតិ ។ ២ ឱ. សេយ្យថាបិ វា បន ឆន្ទិយ សុក្ខេ តិណទាយេតិ ទិស្សតិ ។ ម. សេយ្យថាបិ ឆន្ទិយ សុក្ខេ តិណទាយេតី ទិស្សតិ ។

ម្នាលនន្ទិយៈ អរិយសាវ័ក ប្រកបដោយធម៌ទាំង ១១ នេះឯង តែងលះបង់ មិនប្រកាន់ពួកអកុសលធម៌ដ៏លាមកឡើយ ។ ម្នាលនន្ទិយៈ ដូចជាក្អមផ្កាប់ រមែងមិនស្រូបយកទឹក ដែលហូរចេញបានឡើយ យ៉ាងណាមិញ ម្នាលនន្ទិយៈ ពុំនោះសោត ដូចជាភ្លើង កាលឆេះរាលដាលផុតអំពីស្មៅហើយ ក៏មិនត្រឡប់មករកស្មៅដែលឆេះរួចហើយវិញ យ៉ាងណាមិញ ម្នាលនន្ទិយៈ អរិយសាវ័ក ប្រកបដោយធម៌ទាំង ១១ នេះ តែងលះបង់ មិនប្រកាន់ពួកអកុសលធម៌លាមកឡើយ ក៏យ៉ាងនោះដែរ ។

(១៦១) គ្រានោះ ព្រះសុភូតិ ដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ជាមួយនឹងសទ្ធភិក្ខុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះព្រះសុភូតិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ

ឯតទវោច កោ នាម(១) អយំ សុភូតិ ភិក្ខូតិ ។ សទ្ធោ នាមាយំ ភន្តេ ភិក្ខុ សទ្ធស្ស ឧបាសកស្ស បុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោតិ ។ កច្ចិ បនាយំ សុភូតិ សទ្ធោ ភិក្ខុ សទ្ធស្ស ឧបាសកស្ស បុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ សន្ទិស្សតិ សទ្ធាបទានេសូតិ ។ ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ ភគវា សទ្ធស្ស សទ្ធាបទានានិ ភាសេយ្យ ឥទានាហំ ជានិស្សាមិ យទិ វា អយំ ភិក្ខុ សន្ទិស្សតិ សទ្ធាបទានេសុ យទិ វា នោតិ ។ តេនហិ សុភូតិ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សុភូតិ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច ឥធ សុភូតិ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។

---

១ ឱ. នាមាយំ ។ ម. នាមោ ។

ទ្រង់ត្រាស់សួរថា ម្នាលសុភូតិ ភិក្ខុនេះឈ្មោះអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះឈ្មោះសទ្ធៈ ជាកូនឧបាសក អ្នកមានសទ្ធា បានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ដោយសទ្ធា ។ ម្នាលសុភូតិ សទ្ធភិក្ខុនេះ ជាកូនឧបាសក អ្នកមានសទ្ធា បានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ដោយសទ្ធា នឹងប្រាកដ ក្នុងសទ្ធាបទានទាំងឡាយ ដែរឬ ។ បពិត្រព្រះមានព្រះភាគ កាលនេះ ជាកាលគួរ ដល់ព្រះអង្គហើយ បពិត្រព្រះសុគត កាលនេះ ជាកាលគួរ ដល់ព្រះអង្គហើយ ព្រះមានព្រះភាគ គួរសំដែងសទ្ធាបទានទាំងឡាយ របស់បុគ្គលអ្នកមានសទ្ធា ព្រោះភិក្ខុនេះប្រាកដ ក្នុងសទ្ធាបទានទាំងឡាយក្តី មិនប្រាកដក្តី ខ្ញុំព្រះអង្គនឹងដឹង ក្នុងកាលឥឡូវនេះ ។ ម្នាលសុភូតិ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្ត ឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ព្រះសុភូតិដ៏មានអាយុ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលសុភូតិ ភិក្ខុក្នុងសាសនានេះ អ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនឹងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច ហើយសមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។

យម្បិ សុភូតិ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ឥទម្បិ សុភូតិ សទ្ធស្ស សទ្ធាបទានំ ហោតិ ។

បុន ចបរំ សុភូតិ ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។ យម្បិ សុភូតិ ភិក្ខុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា ឥទម្បិ សុភូតិ សទ្ធស្ស សទ្ធាបទានំ ហោតិ ។

បុន ចបរំ សុភូតិ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ ។

ម្នាលសុភូតិ ព្រោះជាភិក្ខុ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ម្នាលសុភូតិ នេះជាសទ្ធាចរិត របស់បុគ្គល អ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុជាពហុស្សូត អ្នកទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលំអបទដើម លំអបទកណ្តាល លំអបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះក៏បានស្តាប់ច្រើន បានទ្រទ្រង់ ចាំស្ទាត់ ត្រាច់មាត់ ត្រិះរិះ ដោយចិត្ត ត្រាស់ដឹងល្អដោយទិដ្ឋិ ។ ម្នាលសុភូតិ ភិក្ខុជាពហុស្សូត ។ បេ ។ ត្រាស់ដឹងល្អ ដោយទិដ្ឋិ ម្នាលសុភូតិ នេះជាសទ្ធាចរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយវិញទៀត បុគ្គលជាភិក្ខុ តែងជាអ្នកមានមិត្តល្អ មានសំឡាញ់ល្អ បែរឈមទៅរកមិត្តល្អ ។

យម្បិ ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ ឥទម្បិ ភិក្ខវេ សទ្ធស្ស សទ្ធាបទានំ ហោតិ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនិំ ។ យម្បិ ភិក្ខវេ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនិំ ឥទម្បិ ភិក្ខវេ សទ្ធស្ស សទ្ធាបទានំ ហោតិ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្រ(២) ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ ។

---

២ ម. តត្ថ ។

ម្នាលសុភូតិ ព្រោះថាភិក្ខុ ជាអ្នកមានមិត្តល្អ មានសំឡាញ់ល្អ បែរទៅរកមិត្តល្អ ម្នាលសុភូតិ នេះជាសទ្ធាបរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុដែលគេប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើនូវភាពជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយក ពាក្យប្រៀនប្រដៅ ដោយបំណែកខាងស្តាំ ។ ម្នាលសុភូតិ ព្រោះភិក្ខុដែលគេប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើនូវភាពជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយក ពាក្យប្រៀនប្រដៅ ដោយបំណែកខាងស្តាំ ម្នាលសុភូតិ នេះជាសទ្ធាបរិត របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត កិច្ចទាំងឡាយ ណាមួយ ធំ ឬ តូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិល ប្រអូស ក្នុងកិច្ចទាំងនោះ ប្រកប ដោយការពិចារណា ដោយឧបាយ ក្នុងកិច្ចទាំងនោះ ជាបុគ្គលអាចធ្វើបាន អាចចាត់ចែងបាន ។

## ទុតិយោ ទុតិយវគ្គោ

យស្មិំ សុក្កតិ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ។ បេ ។ អលំ កាតុំ អលំ សំវិធាតុំ ឥទម្បិ សុក្កតិ សទ្ធស្ស សទ្ធាបធានំ ហោតិ ។

បុន ចបរំ សុក្កតិ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ ។ យស្មិំ សុក្កតិ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ ឥទម្បិ សុក្កតិ សទ្ធស្ស សទ្ធាបធានំ ហោតិ ។

បុន ចបរំ សុក្កតិ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ យស្មិំ សុក្កតិ ភិក្ខុ អារទ្ធវីរិយោ វិហរតិ ។ បេ ។

ម្នាលសុភូតិ ព្រោះកិច្ចទាំងឡាយណា របស់សព្រហ្មចារីបុគ្គលទាំងឡាយ ។ បេ ។ ភិក្ខុជាអ្នកអាចធ្វើបាន អាចចាត់ចែងបាន ម្នាលសុភូតិ នេះជាសទ្ធាបរិក របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាធម៌ មានការហៅរក ដោយពាក្យជាទីស្រឡាញ់ មានសេចក្ដីរីករាយដ៏លើសលុប ក្នុងអភិធម៌ នឹងអភិវិន័យ ។ ម្នាលសុភូតិ ព្រោះភិក្ខុជាអ្នកប្រាថ្នាធម៌ មានការហៅរក ដោយពាក្យជាទីស្រឡាញ់ មានសេចក្ដីរីករាយដ៏លើសលុប ក្នុងអភិធម៌ នឹងអភិវិន័យ ម្នាលសុភូតិ នេះជាសទ្ធាបរិក របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ដើម្បីធ្វើកុសលធម៌ទាំងឡាយ ឲ្យបរិបូណ៌ ជាអ្នកមានកំឡាំង មានសេចក្ដីប្រឹងប្រែងមាំមួន មិនដាក់ធុរៈ ក្នុងកុសលធម៌ទាំងឡាយចោល ។ ម្នាលសុភូតិ ព្រោះភិក្ខុអ្នកប្រារព្ធព្យាយាម ។ បេ ។

ឥទម្បិ សុភូតិ សទ្ធស្ស សទ្ធាបទានំ ហោតិ ។

បុន ចបរំ សុភូតិ ភិក្ខុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ យម្បិ សុភូតិ ភិក្ខុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ឥទម្បិ សុភូតិ សទ្ធស្ស សទ្ធាបទានំ ហោតិ ។

បុន ចបរំ សុភូតិ ភិក្ខុ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ

ម្នាលសុភូតិ នេះជាសទ្ធាបទានៈ របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្ន ។ ម្នាលសុភូតិ ព្រោះភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្ន ម្នាលសុភូតិ នេះជាសទ្ធាបទានៈ របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយទៀត ភិក្ខុរលឹកឃើញនូវជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុន ជាច្រើនជាតិ គឺរលឹកឃើញបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ មួយពាន់ជាតិ

## ទុតិយោ ទុតិយវគ្គោ

ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ យម្បិ សុគតិ កិញ្ចិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ អនេកាបិ ជាតិ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ឥទម្បិ សុគតិ សទ្ធស្ស សទ្ធាបទានំ ហោតិ ។

## ទុតិយវគ្គ ទី ២

មួយសែនជាតិក៏បាន រលឹកឃើញបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្ប ក៏បានថា អាត្មាអញ បានកើត ក្នុងភពឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារ យ៉ាងនេះ បានទទួលសុខទុក្ខ យ៉ាងនេះ មានកំណត់អាយុ ត្រឹមប៉ុណ្ណោះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងទីណា លុះអាត្មាអញទៅកើត ក្នុងទីនោះហើយ មានឈ្មោះ យ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារ យ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុ ត្រឹមប៉ុណ្ណោះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើត ក្នុងទីនេះ (ភិក្ខុ) រលឹកឃើញជាតិដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុន បានច្រើនជាតិ ព្រមទាំងអាការ ទាំងឧទ្ទេស ដោយប្រការដូច្នេះ ៗ

ម្នាលសុភូតិ ព្រោះភិក្ខុរលឹកឃើញជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុន គឺរលឹកឃើញបាន ១ ជាតិ ២ ជាតិ ។ បេ ។ រលឹកឃើញជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុន បានច្រើនជាតិ ព្រមទាំងអាការ ទាំងឧទ្ទេស ដោយប្រការដូច្នេះ ម្នាលសុភូតិ នេះជាសទ្ធាបរតិ របស់បុគ្គលអ្នកមានសទ្ធា ។

បុន ចបរំ សុភូតិ ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មុបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតិំ សគ្គំ លោកំ ឧបបន្នាតិ

ម្នាលសុភូតិ មួយទៀត ភិក្ខុមានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត ទាំងការចាប់បដិសន្ធិ ជាសត្វថោកទាប ទាំងខ្ពង់ខ្ពស់ មានសម្បុរល្អ ទាំងសម្បុរអាក្រក់ ទៅកាន់សុគតិ ទាំងទុគ្គតិ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមយថាកម្ម (របស់ខ្លួន) ថា អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកនិយាយតិះដៀល នូវព្រះអរិយបុគ្គលទាំងឡាយ មានសេចក្ដីយល់ខុស ប្រកាន់មាំនូវអំពើដែលយល់ខុស សត្វទាំងនោះ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ពុំខាន អើហ្ន៎ ចំណែកពួកសត្វ ទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកប ដោយវចីសុចរិត ប្រកប ដោយ មនោសុចរិត ជាអ្នកមិននិយាយតិះដៀល ព្រះអរិយបុគ្គលទាំងឡាយ មានសេចក្ដីយល់ត្រូវ ប្រកាន់មាំនូវអំពើ ដែលយល់ត្រូវ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើត ក្នុងសុគតិ សួគ៌ ទេវលោក

## ទុតិយោ ទុតិយវគ្គោ

ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ យម្បិ សុភូតិ ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន ។បេ។ យថាកម្មូបគេ សត្តេ បជានាតិ ឥទម្បិ សុភូតិ សទ្ធស្ស សទ្ធាបទានំ ហោតិ ។

បុន ចបរំ សុភូតិ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ យម្បិ សុភូតិ ភិក្ខុ អាសវានំ ខយា ។បេ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥទម្បិ សុភូតិ សទ្ធស្ស សទ្ធាបទានំ ហោតីតិ ។

ឯវំ វុត្តេ អាយស្មា សុភូតិ ភគវន្តំ ឯតទវោច

ភិក្ខុមានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងនូវចក្ខុ របស់មនុស្សធម្មតា មើលឃើញនូវពួកសត្វដែលច្យុត និងការចាប់បដិសន្ធិ ជាសត្វថោកទាបនិងឧត្តម មានសម្បុរល្អ និងសម្បុរអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមយថាកម្ម (របស់ខ្លួន) ដោយប្រការដូច្នេះ ។ ម្នាលសុភូតិ ព្រោះភិក្ខុមានទិព្វចក្ខុ ដ៏បរិសុទ្ធ ។ បេ ។ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅ តាមយថាកម្ម(របស់ខ្លួន) ម្នាលសុភូតិ នេះជាសទ្ធាបទាន របស់បុគ្គលអ្នកមានសទ្ធា ។

ម្នាលសុភូតិ មួយវិញទៀត ភិក្ខុបានធ្វើឲ្យជាក់ច្បាស់ នូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមរបស់ខ្លួន ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ។ ម្នាលសុភូតិ ព្រោះភិក្ខុបានធ្វើ ឲ្យជាក់ច្បាស់ ។ បេ ។ ព្រោះអស់ទៅ នៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ម្នាលសុភូតិ នេះ ជាសទ្ធាបទាន របស់បុគ្គលអ្នកមានសទ្ធា ។

កាលដែលព្រះមានព្រះភាគ ទ្រង់សំដែង យ៉ាងនេះហើយ ព្រះសុភូតិ ដ៏មានអាយុ ក្រាបទូលចំពោះ ព្រះមានព្រះភាគ ដូច្នេះថា

យានិមានិ ភន្តេ ភគវតា សទ្ធស្ស សទ្ធាបទានានិ ភាសិតានិ សំវិជ្ជន្តិ តានិ ឥមស្ស ភិក្ខុនោ អយញ្ហិ ភិក្ខុ ឯតេសុ សន្ទិស្សន្តិ ។ អយំ ភន្តេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ អយំ ភន្តេ ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិទ្ធា ។ អយំ ភន្តេ ភិក្ខុ កល្យាណមិត្តោ (១) កល្យាណសហាយោ កល្យាណសម្បវង្កោ ។

---

១ ខ.ម. ឯត្ថន្តរេ ហោតីតិ បាឋោ ទិស្សតិ ។

បពិត្រព្រះអង្គដ៏ចំរើន សទ្ធាចរិតទាំងឡាយណា របស់បុគ្គលអ្នកមានសទ្ធា ដែលព្រះមានព្រះភាគបាន ទ្រង់សំដែងហើយ សទ្ធាចរិតទាំងនោះ រមែងមានប្រាកដ ដល់ភិក្ខុនេះ ទាំងភិក្ខុនេះ ក៏ទឹងប្រាកដ ក្នុងសទ្ធាចរិតទាំងនុ៎ះ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះជាអ្នកមានសីល សង្រួម ក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យ ក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះជាពហុស្សូត អ្នកទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំទុក នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលំអបទដើម លំអបទកណ្តាល លំអបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយ មានសភាពដូច្នោះ ភិក្ខុនោះ ក៏បានស្តាប់ច្រើន បានទ្រទ្រង់ ចាំទុក រត់មាត់ ត្រិះរិះដោយចិត្ត ត្រាស់ដឹងល្អ ដោយទិដ្ឋិ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះជាអ្នកមានមិត្រល្អ មានសំឡាញ់ល្អ បែរឈមទៅរកមិត្រល្អ ។

## ទុតិយោ ទុតិយវគ្គោ

អយំ ភន្តេ ភិក្ខុ សុវចោ(១) សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនិំ ។ អយំ ភន្តេ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កិំករណីយានិ តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ ។ អយំ ភន្តេ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ ។ អយំ ភន្តេ ភិក្ខុ អារទ្ធវិរិយោ វិហរតិ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ អយំ ភន្តេ ភិក្ខុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។

---

១ ឱ.ម. ឯត្ថន្តរេ [illegible] [illegible] ទិស្សតិ ។

## ទុតិយវគ្គ ទី ២

បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះ ជាបុគ្គលដែលគេប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើនូវភាព ជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ ។ បពិត្រព្រះអង្គដ៏ចំរើន ករណីយកិច្ចទាំងឡាយ ណាមួយ ធំឬតូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុនេះជាអ្នកប៉ិនប្រសប់ មិនខ្ជិលប្រអូស ក្នុងកិច្ចទាំងនោះ ប្រកបដោយការពិចារណា ដោយឧបាយក្នុងកិច្ចទាំងនោះ ជាបុគ្គល អាចធ្វើបាន អាចចាត់ចែងបាន ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះ ជាអ្នកប្រាថ្នា នូវធម៌ ហៅរកដោយពាក្យជាទីស្រឡាញ់ មានសេចក្តីរីករាយ ដ៏លើសលុប ក្នុងអភិធម៌ និងអភិវិន័យ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះ ជាអ្នកប្រារព្ធព្យាយាម មានកំឡាំង មានសេចក្តីប្រឹងប្រែងដ៏មាំមួន មិនដាក់ធុរៈ ក្នុងកុសលធម៌ទាំងឡាយចោល ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្ន ។

អយំ ភន្តេ ភិក្ខុ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ អយំ ភន្តេ ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មុបគេ សត្តេ បជានាតិ ។ អយំ ភន្តេ ភិក្ខុ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ យានិមានិ ភន្តេ ភគវតា សទ្ធស្ស សទ្ធាបទានានិ ភាសិតានិ សំវិជ្ជន្តិ តានិ ឥមស្ស ភិក្ខុនោ អយញ្ច ភិក្ខុ ឯតេសុ សន្ទិស្សតីតិ ។ សាធុ សាធុ សុភូតិ តេនហិ ត្វំ សុភូតិ ឥមិនា សទ្ធេន ភិក្ខុនា សទ្ធឹ វិហរេយ្យាសិ យទា ច ត្វំ សុភូតិ អាកង្ខេយ្យាសិ តថាគតំ ទស្សនាយ ឥមិនា ច សទ្ធេន ភិក្ខុនា សទ្ធឹ ឧបសង្កមេយ្យាសិ តថាគតំ ទស្សនាយាតិ ។

បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះ រលឹកឃើញនូវជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុន ច្រើនជាតិ គឺរលឹកឃើញបាន ១ ជាតិ ២ ជាតិ ។ បេ ។ រលឹកឃើញជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុនជាច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះ មានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងនូវចក្ខុ របស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅ តាមយថាកម្ម ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះ បានធ្វើឲ្យជាក់ច្បាស់ ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។ បពិត្រព្រះអង្គដ៏ចំរើន សមាបត្តិទាំងឡាយណា របស់បុគ្គលអ្នកមានសទ្ធា ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ សមាបត្តិទាំងនោះ រមែងមានប្រាកដ ដល់ភិក្ខុនេះ ទាំងភិក្ខុនេះ ទឹងប្រាកដ ក្នុងសមាបត្តិទាំងនុ៎ះ ។ ម្នាលសុភូតិ ប្រពៃហើយ ប្រពៃហើយ ម្នាលសុភូតិ បើដូច្នោះ អ្នកគប្បីនៅជាមួយនឹងសទ្ធាភិក្ខុនេះចុះ ម្នាលសុភូតិ កាលណាបើ អ្នកប្រាថ្នាដើម្បីចួបតថាគត អ្នកគប្បីចូលមក ជាមួយនឹងសទ្ធាភិក្ខុ ដើម្បីចួបតថាគត ( ក្នុងកាលនោះចុះ ) ។

[១៦៦] មេត្តាយ ភិក្ខវេ ចេតោវិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ ឯកាទសានិសំសា បាដិកង្ខា ។ កតមេ ឯកាទស ។ សុខំ សុបតិ សុខំ បដិពុជ្ឈតិ ន បាបកំ សុបិនំ បស្សតិ មនុស្សានំ បិយោ ហោតិ អមនុស្សានំ បិយោ ហោតិ ទេវតា រក្ខន្តិ នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ តុវដំ ចិត្តំ សមាធិយតិ មុខវណ្ណោ វិប្បសីទតិ អសម្មូឡ្ហោ កាលំ ករោតិ ឧត្តរិំ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ ។ មេត្តាយ ភិក្ខវេ ចេតោវិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ ឥមេ ឯកាទសានិសំសា បាដិកង្ខាតិ ។

## ទុតិយវគ្គ ទី ២

(១៦៦) ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលបានសេពគប់ បានចំរើន បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំទុក បានប្រារព្ធល្អហើយ អានិសង្ស ១១ ប្រការ រមែងកើតប្រាកដ ។ អានិសង្ស ១១ ប្រការ តើដូចម្តេច ។ គឺ មេត្តាវិហារីបុគ្គល រមែងដេកលក់ស្រួល ១ ភ្ញាក់ឡើងស្រួល ១ មិនឃើញនូវសុបិនអាក្រក់ ១ ជាទីស្រឡាញ់របស់ពួកមនុស្ស ១ ជាទីស្រឡាញ់របស់ពួកអមនុស្ស ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី មិនចូលទៅក្នុងកាយរបស់មេត្តាវិហារីបុគ្គលនោះ ១ ចិត្តរមែងតាំងនៅមាំឆាប់ ១ សម្បុរមុខថ្លាស្រស់បស់ ១ ជាអ្នកមិនវង្វេងហើយធ្វើមរណកាល ១ កាលបើមិនទាន់ត្រាស់ដឹងនូវអរហត្តដ៏ក្រៃលែងជាងមេត្តាសមាបត្តិទេ រមែងបានទៅកើតក្នុងព្រហ្មលោក ១ ។ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិដែលបុគ្គល បានសេពគប់ បានចំរើន បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំទុក បានប្រារព្ធល្អហើយ អានិសង្សទាំង ១១ ប្រការនេះ រមែងកើតប្រាកដ ។

(១២៣) ឯកំ សមយំ អាយស្មា អានន្ទោ វេសាលិយំ វិហរតិ ពេលុវគាមកេ ។ តេន ខោ បន សមយេន ទសមោ គហបតិ អដ្ឋកនាគរកោ បាដលិបុត្តំ អនុប្បត្តោ ហោតិ កេនចិទេវ ករណីយេន ។ អថខោ ទសមោ គហបតិ អដ្ឋកនាគរកោ យេន កុក្កុដារាមោ យេន អញ្ញតរោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច កហំ នុ ខោ ភន្តេ អាយស្មា អានន្ទោ ឯតរហិ វិហរតិ ទស្សនកាមា ហិ មយំ ភន្តេ អាយស្មន្តំ អានន្ទន្តិ ។ ឯសោ គហបតិ អាយស្មា អានន្ទោ វេសាលិយំ វិហរតិ ពេលុវគាមកេតិ ។ អថខោ ទសមោ គហបតិ អដ្ឋកនាគរកោ បាដលិបុត្តេ តំ ករណីយំ តីរេត្វា យេន វេសាលិពេលុវគាមកោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[១៦៣] សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងវេឡុវគ្រាម ជិតក្រុងវេសាលី ។ សម័យនោះឯង ទសមគហបតី អ្នកនៅក្នុងក្រុងឈ្មោះអដ្ឋកៈ បានមកដល់ក្រុងបាតលិបុត្ត ដោយកិច្ចនីមួយ ។ លំដាប់នោះ ទសមគហបតី អ្នកនៅក្នុងក្រុងអដ្ឋកៈ បានចូលទៅរកភិក្ខុ ១ រូប ក្នុងកុក្កុដារាម លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងភិក្ខុនោះដូច្នេះថា បពិត្រលោកដ៏ចំរើន ឥឡូវនេះ ព្រះអានន្ទដ៏មានអាយុ គង់នៅ ក្នុងទីណា បពិត្រលោកដ៏ចំរើន ព្រោះយើង ចង់ចួបព្រះអានន្ទ ដ៏មានអាយុ ។ ភិក្ខុនោះតបថា ម្នាលគហបតី ព្រះអានន្ទដ៏មានអាយុនុ៎ះ គង់នៅក្នុងវេឡុវគ្រាម ជិតក្រុងវេសាលី ។ លំដាប់នោះ ទសមគហបតី អ្នកនៅក្នុងក្រុងអដ្ឋកៈ សម្រេចនូវកិច្ចនោះ ក្នុងក្រុងបាតលិបុត្ត ហើយចូលទៅរកព្រះអានន្ទដ៏មានអាយុ ក្នុងវេឡុវគ្រាម ជិតក្រុងវេសាលី លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។

## ទុតិយោ ទុតិយវគ្គោ

ឯកមន្តំ និសិន្នោ ខោ ទសមោ គហបតិ
អដ្ឋកនាគរោ អាយស្មន្តំ អានន្ទំ ឯតទវោច
អត្ថិ នុ ខោ ភន្តេ អានន្ទ តេន ភគវតា
ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន
ឯកធម្មោ សម្មទក្ខាតោ យត្ថ ភិក្ខុនោ
អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ
អវិមុត្តំ ច ចិត្តំ វិមុច្ចតិ អបរិក្ខីណា ច
អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ ច អ-
នុត្តរំ យោគក្ខេមំ អនុបាបុណាតីតិ ។ អត្ថិ
គហបតិ តេន ភគវតា ជានតា បស្សតា
អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ សម្មទក្ខា-
តោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ
បហិតត្តស្ស វិហរតោ អវិមុត្តំ ច ចិត្តំ វិមុច្ចតិ
អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ
ច អនុត្តរំ យោគក្ខេមំ អនុបាបុណាតីតិ ។

លុះទសមគហបតី អ្នកនៅក្នុងក្រុងអដ្ឋកៈ អង្គុយ ក្នុងទីសមគួរ ហើយបានពោលពាក្យ នឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចំរើន ចិត្តរបស់ភិក្ខុអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី ក៏រមែងដល់នូវធម៌ជាទីក្សេម ចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនោះ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដោយប្រពៃ មានដែរឬ ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុ ដែលមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី ក៏រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនោះ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដោយប្រពៃ មានដែរ ។

កតមោ បន ភន្តេ អានន្ទ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ សម្មទក្ខាតោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តំ ច ចិត្តំ វិមុច្ចតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ ច អនុត្តរំ យោគក្ខេមំ អនុបាបុណាតីតិ ។ ឥធ គហបតិ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ ឥទំ (១) ខោ បឋមំ ឈានំ អភិសង្ខតំ អភិសញ្ចេតយិតំ យំ ខោ បន កិញ្ចិ អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ ។

---

១ ឱ. ឥទម្បិ ខោ ។ ម. ឥទំបិ ខោ ។

បពិត្រព្រះអានន្ទ ដ៏ចំរើន ចិត្តរបស់ភិក្ខុ អ្នកមិនមានសេចក្ដីប្រមាទ មានព្យាយាម ជាគ្រឿងដុតកំដៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះគឺ រមែងរួចស្រឡះ អាសវៈទាំងឡាយមិនទាន់អស់គឺ រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់គឺ ក៏រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនោះ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដោយប្រពៃ តើដូចម្ដេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏បានចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ។ ភិក្ខុនោះបានពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា បឋមជ្ឈាននេះ ដែល ( អាត្មាអញ ) បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ ឈានណាមួយ ដែលអាត្មាអញ បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានការរលត់ទៅ ជាធម្មតា ។

សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ អយំ (១) ខោ គហបតិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯក-ធម្មោ សម្មទក្ខាតោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តំ វា ចិត្តំ វិមុច្ចតិ អបរិក្ខីណា វា អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ វា អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។

---

១ ឱ. អយម្បិ ខោ ។ ម. ឥទម្បិ ខោ ។

ភិក្ខុនោះ បានឋិតនៅក្នុងសមថវិបស្សនាធម៌នោះ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនដល់នូវការអស់អាសវៈទាំងឡាយទេ ក៏បានជាឱបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយជាចំណែកខាងក្រោម ៥ ដោយតម្រេកក្នុងធម៌នោះ ដោយសេចក្តីរីករាយ ក្នុងធម៌នោះ បរិនិព្វានក្នុងលោកនោះ មានការមិនត្រឡប់មកលោកនោះ ជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុដែលគ្មានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បើមិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេម ចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដោយប្រពៃ ។

បុន ចបរំ គហបតិ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ ឥទម្បិ ខោ ចតុត្ថំ ឈានំ អភិសង្ខតំ អភិសញ្ចេតយិតំ យំ ខោ បន កិញ្ចិ អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ ។ សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។

ម្នាលគហបតី មួយទៀត ភិក្ខុ ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ (ក៏បានចូល) កាន់ទុតិយជ្ឈាន ជាធម្មជាត កើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក ដែលមិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ គឺ បឋមជ្ឈាន . . . តតិយជ្ឈាន . . . ចូលកាន់ ចតុត្ថជ្ឈាន ។ ភិក្ខុនោះ បានពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា ចតុត្ថជ្ឈាននេះឯង (ដែលអាត្មាអញ) បានតាក់តែង បានពិចារណា ដោយចិត្តចង់ ធម៌ឯណានីមួយ ដែលអាត្មាអញ បានតាក់តែង បានពិចារណា ដោយចិត្តចង់ហើយ ធម៌នោះ ក៏មិនទៀង មានកិរិយារលត់ទៅជាធម្មតា ។ ភិក្ខុនោះបានឋិតនៅក្នុងសមថវិបស្សនាធម៌នោះ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់ដល់នូវការអស់អាសវៈទាំងឡាយទេ រមែងបានជាឧបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ដោយតម្រេក ក្នុងធម៌នោះ ដោយសេចក្ដីរីករាយ ក្នុងធម៌នោះ ក៏បរិនិព្វាន ក្នុងលោកនោះ មានការមិនត្រឡប់ ចាកលោកនោះ ជាធម្មតា ។

## ទុតិយោ ទុតិយវគ្គោ

អយម្បិ ខោ គហបតិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ សម្មទក្ខាតោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តំ វា ចិត្តំ វិមុច្ចតិ អបរិក្ខីណា វា អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ វា អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។

បុន ចបរំ គហបតិ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អយម្បិ ខោ មេត្តាចេតោវិមុត្តិ អភិសង្ខតា

## ទុតិយវគ្គ ទី ២

ម្នាលគហបតី ចិត្តរបស់ភិក្ខុ ដែលមិនមានសេចក្តីប្រមាទ អ្នកមានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន មិនទាន់ប្រែប្រួលក្តី រមែងប្រែប្រួល អាសវៈទាំងឡាយមិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដោយប្រពៃ ៗ

ម្នាលគហបតី មួយទៀត ភិក្ខុមានចិត្តប្រកប ដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម ទីទិសទទឹង (១) មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ មានប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយយកខ្លួន ទៅប្រៀបនឹងសត្វទាំងពួង ក្នុងទីទាំងពួង ៗ ភិក្ខុនោះ បានពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា មេត្តាចេតោវិមុត្តិនេះឯង (ដែលអាត្មាអញ) បានតាក់តែង

---

១ សំដៅយកទិសតូចទាំង ៤ គឺ ទិសអាគ្នេយ៍ ឦសាន និរតី ពាយ័ព្យ ។

អភិសញ្ចេតយិតា យំ បន កិញ្ចិ អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ ។ សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ អយម្បិ ខោ គហបតិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ សម្មទក្ខាតោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តំ ច ចិត្តំ វិមុច្ចតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ ច អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។

បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ឈានណាមួយ ដែលអាត្មាអញ បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានការរលត់ទៅ ជាធម្មតា ។ ភិក្ខុនោះ បានឋិតនៅ ក្នុងសមថវិបស្សនាធម៌នោះ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់ បានដល់ នូវការអស់អាសវៈទាំងឡាយទេ ក៏គង់បានជាឧបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ដោយតម្រេក ក្នុងធម៌នោះ ដោយសេចក្តីរីករាយ ក្នុងធម៌នោះ ហើយក៏បរិនិព្វាន ក្នុងលោកនោះ មានការមិនត្រឡប់ ចាកលោកនោះ ជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុ ដែលមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកំដៅកិលេស មានចិត្តផ្ដោះទៅ កាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី រមែងដល់ នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្ត សម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដោយប្រពៃ ។

## ទុតិយោ ទុតិយវគ្គោ

បុន ចបរំ គហបតិ ភិក្ខុ ករុណាសហគតេន ចេតសា . . . មុទិតាសហគតេន ចេតសា . . . ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អយម្បិ ខោ ឧបេក្ខាចេតោវិមុត្តិ អភិសង្ខតា អភិសញ្ចេតយិតា យំ ខោ បន កិញ្ចិ អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ ។ សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ

ម្នាលគហបតី មួយទៀត ភិក្ខុមានចិត្តប្រកប ដោយករុណា ... មានចិត្តប្រកប ដោយមុទិតា ... មានចិត្តប្រកប ដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម ទទឹងទិសទទឹង មានចិត្តប្រកប ដោយឧបេក្ខាដ៏ធំទូលាយ ដ៏ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបនឹងសត្វទាំងពួង ក្នុងទីទាំងពួង ។ ភិក្ខុនោះ បានពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា ឧបេក្ខាចេតោវិមុត្តិនេះឯង ដែល (អាត្មាអញ) បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ក៏ឈានឯណានីមួយ ដែលអាត្មាអញ បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានការរលត់ទៅ ជាធម្មតា ។ ភិក្ខុនោះ បានឋិតនៅ ក្នុងសមថ-វិបស្សនាធម៌នោះហើយ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់បានដល់ នូវការអស់អាសវៈទាំងឡាយទេ ក៏គង់បានជាឧបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ដោយតម្រេក ក្នុងធម៌នោះ ដោយសេចក្តីរីករាយ ក្នុងធម៌នោះ

តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ អយម្បិ ខោ គហបតិ តេន ភគវតា ជានតា បស្សតា អរហតា សម្មា-សម្ពុទ្ធេន ឯកធម្មោ សម្មទក្ខាតោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិ-ហរតោ អវិមុត្តំ វា ចិត្តំ វិមុច្ចតិ អបរិក្ខី-ណា វា អាសវា បរិក្ខយំ គច្ឆន្តិ អននុ-ប្បត្តំ វា អនុត្តរំ យោគក្ខេមំ អនុបាបុ-ណាតិ ។

បុន ចបរំ គហបតិ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អយម្បិ ខោ អាកាសា-នញ្ចាយតនសមាបត្តិ អភិសង្ខតា អភិសញ្ចេតយិតា

ហើយក៏បរិនិព្វាន ក្នុងលោកនេះ មានការមិនត្រឡប់ចាកលោកនេះជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុ អ្នកមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកំដៅកិលេស មានចិត្តតោះតោងទៅកាន់ព្រះនិព្វាន មិនបានរួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនបានដល់ក្តី រមែងដល់នូវធម៌ជាទីក្សេម ចាកយោគៈដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្ត សម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដោយប្រពៃ ។

ម្នាលគហបតី មួយទៀត ភិក្ខុបានដល់អាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាស មិនមានទីបំផុតដូច្នេះ ព្រោះប្រព្រឹត្តកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះវិនាសនៃបដិឃសញ្ញាទាំងឡាយ ព្រោះលែងធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ។ ភិក្ខុនោះបានពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា អាកាសានញ្ចាយតនសមាបត្តិនេះឯង ដែលអាត្មាអញ បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ

យំ ខោ ភិញ្ញុំ អភិសន្ធតំ អភិវេញ្ញត-
យិតំ តចនិច្ចំ និកេជជន្តិ បជាជាតិ ។
សោ តត្ថ ឋិតោ អាសភនំ ខយំ ធាវុ-
ណាតិ ពោ វេ អាសភនំ ខយំ ធាវុណាតិ
តេនេវ ចន្ទភាគេន តាយេ ជន្ទនក្ខិយា បញ្ញន្តិ
ឱរព្ភតិយានំ សំយោជនានំ បរិក្ខយា ឱប-
ធាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិ-
ធម្មោ តស្មា លោកា ។ អយម្បិ ខោ
គហបតិ តេន ភគវតា ជានតា បស្សតា
អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ សម្មទក្ខាតោ
យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស
វិហរតោ អវិមុត្តំ វា ចិត្តំ វិមុច្ចតិ អបរិក្ខីណា
វា អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ វា
អនុត្តរំ យោគក្ខេមំ អនុធាវុណាតិ ។

ឈានណាមួយ ដែលអាត្មាអញបានតាក់តែង បានពិចារណាដោយផ្ចិត ផ្ចង់ហើយ ឈាននោះក៏មិនទៀង មានការរលត់ជាធម្មតា ។ ភិក្ខុនោះ ឋិតនៅក្នុងសមថវិបស្សនាធម៌នោះ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់ដល់ នូវការអស់អាសវៈទាំងឡាយទេ ក៏គង់បានជាឱបបាតិកៈ ព្រោះអស់សំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ដោយ សេចក្តីត្រេកអរ ក្នុងធម៌នោះ ដោយសេចក្តីរីករាយ ក្នុងធម៌ នោះ ហើយក៏បរិនិព្វាន ក្នុងលោកនោះ មានការមិនត្រឡប់បាក លោកនោះ ជាធម្មតា ។ ម្នាលគហបតី ចិត្តរបស់ភិក្ខុ ដែលមិន មានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកំដៅកិលេស មាន ចិត្តផ្ពោះទៅ កាន់ព្រះនិព្វាន ចិត្តមិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ មិនទាន់អស់ក្តី ក៏រមែងដល់នូវការអស់ ចិត្តដែល មិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេម បាកយោគៈដ៏ប្រសើរ ក្នុង ធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគ អង្គ នោះ ជាអរហន្ត សម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដោយប្រពៃ ។

បុន ចបរំ គហបតិ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ... សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អយម្បិ ខោ អាកិញ្ចញ្ញាយតនសមាបត្តិ អភិសង្ខតា អភិសញ្ចេតយិតា យំ ខោ កិញ្ចិ អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ ។ សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។

ម្នាលគហបតី មួយទៀត ភិក្ខុកន្លងអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណ មិនមានទីបំផុត ... ក្នុងវិញ្ញាណញ្ចាយ-តនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វត្ថុតិចតួច មិនមានដូច្នេះ ។ ភិក្ខុនោះពិចារណាដូច្នេះ ក៏ដឹងច្បាស់ថា អាកិញ្ចញ្ញាយតនសមាបត្តិនេះឯង ដែលអាត្មាអញ បានតាក់តែង បានពិចារណា ដោយផ្ចិតផ្ចង់ហើយ ក៏ឈានណាមួយ ដែលអាត្មាអញ បានតាក់តែង បានពិចារ-ណា ដោយផ្ចិតផ្ចង់ហើយ ឈាននោះ ក៏មិនទៀង មានការរលត់ ជាធម្មតា ។ ភិក្ខុនោះ បានឋិតនៅ ក្នុងសមថវិបស្សនាធម៌នោះហើយ រមែងដល់នូវការអស់អាសវៈទាំងឡាយ បើមិនទាន់បានដល់នូវការអស់អាសវៈទាំងឡាយទេ ក៏គង់បានជាឧបបាតិកៈព្រោះអស់សំយោជនៈទាំងឡាយ ជាបំណែកខាងក្រោម ៥ ដោយតម្រេកក្នុងធម៌នោះ ដោយសេចក្តីរីករាយ ក្នុងធម៌នោះ ហើយបរិនិព្វានក្នុងលោកនោះ មានការមិនត្រឡប់ ចាកលោកនោះ ជាធម្មតា ។

## ទុតិយោ ទុតិយវគ្គោ

អយម្បិ ខោ គហបតិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ សម្មទក្ខាតោ យត្ថ ភិក្ខុ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តំ វា ចិត្តំ វិមុច្ចតិ អបរិក្ខីណា វា អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តំ វា អនុត្តរំ យោគក្ខេមំ អនុបាបុណាតីតិ ។

ឯវំ វុត្តេ ទសមោ គហបតិ អដ្ឋកនាគរោ អាយស្មន្តំ អានន្ទំ ឯតទវោច សេយ្យថាបិ ភន្តេ អានន្ទ បុរិសោ ឯកំ និធិមុខំ គវេសន្តោ សកិទេវ ឯកាទស និធិមុខានិ អធិគច្ឆេយ្យ ឯវមេវ ខោ អហំ ភន្តេ ឯកំ អមតទ្វារំ គវេសន្តោ សកិទេវ ឯកាទសន្នំ អមតទ្វារានំ អលត្ថំ សវនាយ(១) ។

---

១ ឱ.ម. សេវនាយ ។

ទុតិយវគ្គ ទី ២

ម្នាលគហបតី ចិត្តរបស់ភិក្ខុ ដែលមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកំដៅកិលេស មានចិត្តខ្ពស់ ទៅកាន់ព្រះនិព្វាន មិនទាន់រួចស្រឡះក្តី រមែងរួចស្រឡះ អាសវៈទាំងឡាយ ដែលមិនទាន់អស់ក្តី រមែងដល់នូវការអស់ ចិត្តដែលមិនទាន់ដល់ក្តី រមែងដល់នូវធម៌ជាទីក្សេម ជាគុណដ៏ប្រសើរ ក្នុងធម៌តែមួយណា ធម៌តែមួយនេះឯង ដែលព្រះមានព្រះភាគ អង្គនោះ ជាអរហន្ត សម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដោយប្រពៃ ៗ

កាលដែលព្រះអានន្ទ ដ៏មានអាយុ បានពោលយ៉ាងនេះហើយ ទសមគហបតី អ្នកនៅក្នុងស្រុកអដ្ឋកៈ បានពោលនឹងព្រះអានន្ទ ដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចំរើន ដូចជាបុរស អ្នកស្វែងរកកំណប់ទ្រព្យតែមួយ ស្រាប់តែ បានកំណប់ទ្រព្យ ១១ តែម្តង យ៉ាងណាមិញ បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណា ស្វែងរកទ្វារនៃព្រះនិព្វានឈ្មោះអមតៈតែមួយ ស្រាប់តែ បានស្តាប់នូវទ្វារនៃព្រះនិព្វាន ឈ្មោះអមតៈទាំងឡាយ ១១ តែម្តង យ៉ាងនោះដែរ ៗ

សេយ្យថាបិ ភន្តេ បុរិសស្ស អគារំ ឯកាទសទ្វារំ សោ តស្មឹ អគារេ អាទិត្តេ ឯកមេកេន ទ្វារេន សក្កុណេយ្យ អត្តានំ សោត្ថឹ កាតុំ ។ ឯវមេវ ខោ អហំ ភន្តេ ឥមេសំ ឯកាទសន្នំ អមតទ្វារានំ ឯកមេកេន អមតទ្វារេន សក្កុណិស្សាមិ អត្តានំ សោត្ថឹ កាតុំ ។ ឥមេ ហិ នាម ភន្តេ អញ្ញតិត្ថិយា អាចរិយស្ស អាចរិយធនំ បរិយេសិស្សន្តិ (១) កឹ បនាហំ អាយស្មតោ អានន្ទស្ស បូជំ (២) ករិស្សាមីតិ ។ អថ ខោ ទសមោ គហបតិ អដ្ឋកនាគរកោ វេសាលិកញ្ច បាដលិបុត្តកញ្ច ភិក្ខុសង្ឃំ សន្និបាតាបេត្វា បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ឯកមេកញ្ច ភិក្ខុំ បច្ចេកទុស្សយុគេន អច្ឆាទេសិ

១ ម. បរិយេសន្តិ ។ ២ ឱ.ម. ឯក្ខត្តរេ ឧសាខ្ខា អគ្គិ ។

បពិត្រលោកដ៏ចំរើន ដូចជាផ្ទះ របស់បុរសមានទ្វារ ១១ កាលបើភ្លើងឆេះផ្ទះនោះ បុរសនោះ ក៏អាចធ្វើខ្លួន ឲ្យមានសួស្តី ដោយទ្វារតែមួយ ៗ បាន យ៉ាងណាមិញ បពិត្រលោកដ៏ចំរើន បណ្តាអមតទ្វារ ១១ នេះ ខ្ញុំព្រះករុណា នឹងអាចធ្វើខ្លួន ឲ្យមានសួស្តី ដោយអមតទ្វារតែមួយ ៗ បាន ក៏យ៉ាងនោះដែរ ។ បពិត្រលោកដ៏ចំរើន អម្បាលដូចជា ពួកអន្យតិរ្ថិយ ទាំងនេះ តែងស្វែងរកទ្រព្យសម្រាប់អាចារ្យ ដើម្បីអាចារ្យ ចុះខ្ញុំព្រះករុណា នឹងធ្វើនូវការបូជាដល់ព្រះអានន្ទដ៏មានអាយុ តើដូចម្តេចទៅវិញ ។ គ្រានោះ ទសមគហបតី អ្នកនៅក្នុងក្រុងអដ្ឋកៈ ក៏បានប្រជុំភិក្ខុសង្ឃ ដែលនៅក្នុងក្រុងវេសាលីផង នៅក្នុងក្រុងបាតលិបុត្តផង ហើយអង្គាសភិក្ខុសង្ឃ ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃរបស់ខ្លួន គ្រាតែហាមឃាត់ ហើយញ៉ាំងភិក្ខុ ១ រូប ៗ ឲ្យស្លៀកដណ្តប់ ដោយគូនៃសំពត់ គ្រប់អង្គ

អាយស្មន្តញ្ច អានន្ទំ តិចីវរេន អាយស្មតោ ច អានន្ទស្ស បញ្ចសតំ វិហារំ ការាបេសីតិ ។

[ ១២៤ ] ឯកាទសហិ ភិក្ខវេ អង្គេហិ សមន្នាគតោ គោបាលកោ អភព្វោ គោគណំ បរិហរិតុំ ផាតិកាតុំ (១) ។ កតមេហិ ឯកាទសហិ ។ ឥធ ភិក្ខវេ គោបាលកោ ន រូបញ្ញូ ហោតិ ន លក្ខណកុសលោ ហោតិ ន អាសាដិកំ សាដេតា (២) ហោតិ ន វណំ បដិច្ឆាទេតា ហោតិ ន ធូមំ កត្តា ហោតិ ន តិត្ថំ ជានាតិ ន បីតំ ជានាតិ ន វីថឹ ជានាតិ ន គោចរកុសលោ ហោតិ អនវសេសទោហី ហោតិ យេ តេ ឧសភា គោបិតរោ គោបរិណាយកា តេ ន អតិរេកបូជាយ បូជេតា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឯកាទសហិ អង្គេហិ សមន្នាគតោ គោបាលកោ អភព្វោ គោគណំ បរិហរិតុំ ផាតិកាតុំ ។

---

១ ម. ផាតីកាតុំ ។ ២ ម. ហារេតា ។

ញ៉ាំងព្រះអានន្ទដ៏មានអាយុ ឲ្យស្លៀកដណ្តប់ ដោយត្រៃចីវរផង ញ៉ាំងជាងឲ្យធ្វើវិហារ(១) តម្លៃ ៥០០ កហាបណៈ ប្រគេនព្រះអានន្ទដ៏មានអាយុផង ។

(១២៤) ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គ ១១ ប្រការ មិនគួររក្សាហ្វូងគោ មិនគួរធ្វើគោ ឲ្យចំរើនបានឡើយ ។ ប្រកបដោយអង្គ ១១ ប្រការតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ក្នុងលោកនេះ មិនស្គាល់រូបគោ ១ មិនឈ្លាសវៃក្នុងលក្ខណៈ (គ្រឿងចំណាំ) ១ មិនបេះក្អឹះក្អៀលពងរុយ ១ មិនបេះបិទដំបៅ ១ មិនធ្វើក្នក់ផ្សែង ១ មិនស្គាល់កំពង់ ១ មិនស្គាល់ទឹកដែលគោផឹក ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសវៃក្នុងគោចរដ្ឋាន ១ រឹតយកទឹកដោះមិនឲ្យសេសសល់ ១ មិនបូជាពួកគោឈ្មោល ជាបិតារបស់គោ ជាមេដឹកនាំហ្វូងគោ ដោយអតិរេកបូជា ១ ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គ ១១ ប្រការនេះ មិនគួររក្សាហ្វូងគោ មិនគួរធ្វើគោ ឲ្យចំរើនបានឡើយ ។

១. ពាក្យថាវិហារក្នុងទីនេះ បានដល់សាលាដែលប្រក់ស្បូវ ។ អដ្ឋកថា ។

ឯវមេវ ខោ ភិក្ខវេ ឯកាទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជិតុំ ។ កតមេហិ ឯកាទសហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន រូបញ្ញូ ហោតិ ន លក្ខណកុសលោ ហោតិ ន អាសាដិកំ សាដេតា ហោតិ ន វណំ បដិច្ឆាទេតា ហោតិ ន ធូមំ កត្តា ហោតិ ន តិត្ថំ ជានាតិ ន បីតំ ជានាតិ ន វីថឹ ជានាតិ ន គោចរកុសលោ ហោតិ អនវសេសទោហី ហោតិ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ ន អតិរេកបូជាយ បូជេតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន រូបញ្ញូ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យំ កិញ្ចិ រូបំ ចត្តារិ ច មហាភូតានិ ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបន្តិ យថាភូតំ នប្បជានាតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ១១ ប្រការ មិនគួរដល់នូវការចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ យ៉ាងនេះឯង ។ ប្រកបដោយអង្គ ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនស្គាល់រូប ១ មិនឈ្លាសវៃក្នុងលក្ខណៈ ១ មិនបេះក្តិះក្តៀលពងរុយ ១ មិនបិទដំបៅ ១ មិនធ្វើក្នក់ផ្សែង ១ មិនស្គាល់កំពង់ ១ មិនស្គាល់ទឹក ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសវៃក្នុងគោចរដ្ឋាន ១ រូតយកទឹកដោះទាល់តែអស់រលីង ១ មិនបូជាពួកភិក្ខុដែលជាថេរៈ អ្នកដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនស្គាល់រូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះមិនដឹងច្បាស់តាមសេចក្តីពិត នូវរូបឯណានីមួយ គឺមហាភូតរូបទាំង ៤ ផង ឧបាទាយរូប ដែលអាស្រ័យនូវមហាភូតរូបទាំង ៤ ផង ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ ន រូបញ្ញូ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន លក្ខណកុសលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ កម្មលក្ខណោ ពាលោ កម្មលក្ខណោ បណ្ឌិតោតិ យថាភូតំ នប្បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន លក្ខណកុសលោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន អាសាដិកំ សាដេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ អធិវាសេតិ ន បជហតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ ... ឧប្បន្នំ វិហឹសាវិតក្កំ ... ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ អធិវាសេតិ ន បជហតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន អាសាដិកំ សាដេតា ហោតិ ។

## ទុតិយវគ្គ ទី ២

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់រូប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនឈ្លាសវៃ ក្នុងលក្ខណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិតថា បុគ្គលពាលមានកម្មជាលក្ខណៈ បុគ្គលជាបណ្ឌិត ក៏មានកម្មជាលក្ខណៈដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈ្លាសវៃ ក្នុងលក្ខណៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ មិនបេះឆ្កឹះឆ្កៀលពងរុយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទទួលត្រងរងយកកាមវិតក្កៈដែលកើតឡើងហើយ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនបានធ្វើ មិនឲ្យកើតតទៅទៀត ទទួលត្រងរងយកព្យាបាទវិតក្កៈដែលកើតឡើងហើយ . . . វិហឹសាវិតក្កៈ ដែលកើតឡើងហើយ . . . អកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ៗ មិនលះបង់ មិនបន្ទោបង់ មិនបានធ្វើឲ្យវិនាស មិនបានធ្វើ មិនឲ្យកើត តទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបេះឆ្កឹះឆ្កៀលពងរុយ យ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ ភិក្ខុ ន វណំ បដិច្ឆាទេតា
ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ
ទិស្វា និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វា-
ធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈា-
ទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្ស-
វេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ
ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ ន សំវរំ អាបជ្ជតិ ។ សោ
តេន សទ្ទំ សុត្វា ... ឃានេន គន្ធំ ឃាយិត្វា ...
ជិវ្ហាយ រសំ សាយិត្វា ... កាយេន ផោដ្ឋព្វំ
ផុសិត្វា ... មនសា ធម្មំ វិញ្ញាយ និមិត្ត-
គ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណ-
មេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោ-
មនស្សា បាបកា អកុសលា ធម្មា អន្វាស្ស-
វេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ
មនិន្ទ្រិយំ មនិន្ទ្រិយេ ន សំវរំ អាបជ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនចេះបិទដំរៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូប ដោយចក្ខុ ហើយប្រកាន់និមិត្ត ប្រកាន់អនុព្យញ្ជនៈ ពួកអកុសលធម៌ ដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីគ្របសង្កត់បុគ្គលនុ៎ះ ដែលមិនសង្រួមចក្ខុន្ទ្រិយ ព្រោះមិនសង្រួមចក្ខុន្ទ្រិយណា ក៏មិនប្រតិបត្តិ ដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សាចក្ខុន្ទ្រិយ មិនដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយឡើយ ស្តាប់សំឡេង ដោយត្រចៀក . . . ធុំក្លិន ដោយច្រមុះ . . . ភ្លក្សរស ដោយអណ្តាត . . . ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ . . . ដឹងធម្មារម្មណ៍ ដោយចិត្ត ហើយប្រកាន់និមិត្ត ប្រកាន់អនុព្យញ្ជនៈ ពួកអកុសលធម៌ ដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីគ្របសង្កត់បុគ្គលនុ៎ះ ដែលមិនសង្រួមនូវមនិន្ទ្រិយ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ក៏មិនប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ មិនរក្សាមនិន្ទ្រិយ មិនដល់នូវការសង្រួម ក្នុងមនិន្ទ្រិយឡើយ ។

ទុតិយោ ទុតិយវគ្គោ

ឯវំ ខោ ភិក្ខវេ ភិក្ខុ ន វណំ បដិច្ឆាទេតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន ធូមំ កត្តា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ន យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតា ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន ធូមំ កត្តា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន តិត្ថំ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេ កាលេន កាលំ ឧបសង្កមិត្វា ន បរិបុច្ឆតិ ន បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ ។ តស្ស តេ អាយស្មន្តោ អវិវដញ្ចេវ ន វិវរន្តិ អនុត្តានីកតញ្ច ន ឧត្តានីករោន្តិ អនេកវិហិតេសុ (១) កង្ខាដ្ឋានិយេសុ (២) ធម្មេសុ កង្ខំ ន បដិវិនោទេន្តិ ។

១ ឱ. ម. ឯត្ថន្តរេ ចសទ្ទោ អត្ថិ ។ ២ ឱ. ម. កង្ខាឋានិយេសុ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបេះបិទដំបៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនធ្វើ ភ្នក់ផ្សែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនសំដែងធម៌តាមខ្លួនស្តាប់មក តាមខ្លួនរៀនមក ដល់ជនទាំងឡាយដទៃ ដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនធ្វើភ្នក់ផ្សែងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនស្គាល់កំពង់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅរកពួកភិក្ខុដែលជាអ្នកចេះដឹងច្រើន ចេះចាំនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា គឺបាតិមោក្ខទាំងពីរ គ្រប់ ៗ កាល ប៉ុន្តែមិនបានសាកសួរ មិនបានដេញដោលថា បពិត្រលោកដ៏ចំរើន ហេតុនេះ ដូចម្តេច សេចក្តីនៃពាក្យ នេះ តើដូចម្តេច ។ លោកដ៏មានអាយុ ទាំងនោះ មិនបើកបំហនូវសេចក្តី ដែលកំបាំងផង មិនធ្វើឲ្យរាក់នូវសេចក្តី ដែលជ្រៅផង មិនបន្ទោបង់នូវសេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយ ដែលគួរសង្ស័យច្រើនប្រការ ដល់ភិក្ខុនោះផង ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ ន តិត្ថំ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន បីតំ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ ន លភតិ អត្ថវេទំ ន លភតិ ធម្មវេទំ ន លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បីតំ ន ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន វីថឹ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ យថាភូតំ នប្បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន វីថឹ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន គោចរកុសលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចត្តារោ សតិបដ្ឋានេ យថាភូតំ នប្បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន គោចរកុសលោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អនវសេសទោហី ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់កំពង់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ មិនស្គាល់ទឹកផឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើធម្មវិន័យ ដែលតថាគតបានប្រាប់ បានសំដែងហើយ ក៏មិនបាននូវការដឹងអត្ថ មិនបាននូវការដឹងធម៌ មិនបានបាមុជ្ជៈ ដែលប្រកបដោយធម៌ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ទឹកផឹក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ មិនស្គាល់ផ្លូវ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិត នូវមគ្គដែលប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ផ្លូវ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនឈ្លាសវៃ ក្នុងគោចរដ្ឋាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិត នូវសតិប្បដ្ឋាន ៤ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈ្លាសវៃ ក្នុងគោចរដ្ឋាន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ រូតយកទឹកដោះ អស់រលីង តើដូចម្តេច ។

ទុតិយោ ទុតិយវគ្គោ

ឥធ ភិក្ខវេ ភិក្ខុ សទ្ធា គហបតិកា អភិហដ្ឋុំ បវារេន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេ-សជ្ជបរិក្ខារេន តត្រ ភិក្ខវេ ភិក្ខុ មត្តំ ន ជានាតិ បដិគ្គហណាយ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អនាសេសភោគី ហោតិ ។ កតមញ្ច ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរប្បព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ ន អតិរេកប្បជាយេ បូជេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរប្បព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេសុ ន មេត្តំ កាយកម្មំ បច្ចុបដ្ឋាបេតិ អាវី ចេវ រហោ ច ន មេត្តំ វចីកម្មំ . . . ន មេត្តំ មនោកម្មំ បច្ចុបដ្ឋាបេតិ អាវី ចេវ រហោ ច ។

## ទុតិយវគ្គ ទី ២

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានពួកគហបតី អ្នកមានសទ្ធា នាំគ្នាមកបវារណា ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ប្រមាណក្នុងការទទួលបច្ច័យទាំងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរឹតយកទឹកដោះអស់លើង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនបូជាពួកភិក្ខុដែលជាថេរៈអ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ភិក្ខុក្នុងសាសនានេះ មិនដំកល់កាយកម្មប្រកបដោយមេត្តា ក្នុងពួកភិក្ខុទាំងនោះ ក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងមុខក្តី មិនដំកល់វចីកម្ម ប្រកបដោយមេត្តា ... មិនដំកល់មនោកម្ម ប្រកបដោយមេត្តា ក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងមុខក្តី ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ ន អតិរេកបូជាយ បូជេតា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឯកាទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ ។ ឯកាទសហិ ភិក្ខវេ អង្គេហិ សមន្នាគតោ គោបាលកោ ភព្វោ គោគណំ បរិហរិតុំ ផាតិកាតុំ ។ កតមេហិ ឯកាទសហិ ។ ឥធ ភិក្ខវេ គោបាលកោ រូបញ្ញូ ហោតិ លក្ខណកុសលោ ហោតិ អាសាដិកំ សាដេតា ហោតិ វណំ បដិច្ឆាទេតា ហោតិ ធូមំ កត្តា ហោតិ តិត្ថំ ជានាតិ បីតំ ជានាតិ វីថឹ ជានាតិ គោចរកុសលោ ហោតិ សាវសេសទោហី ហោតិ យេ តេ ឧសភា គោបិតរោ គោបរិណាយកា តេ អតិរេកបូជាយ បូជេតា ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបូជាពួកភិក្ខុ ដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ១១ ប្រការនេះ មិនគួរដល់នូវការចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះទេ ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គ ១១ ប្រការ ទើបគួររក្សាហ្វូងគោ ធ្វើគោឲ្យចំរើនបាន ។ ប្រកបដោយអង្គ ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោក្នុងលោកនេះ ជាអ្នកស្គាល់រូបគោ ១ ឈ្លាសវៃក្នុងលក្ខណៈ ១ ចេះក្តិះក្តៀលពងរុយ ១ ចេះបិទដំបៅ ១ ចេះធ្វើក្នក់ផ្សែង ១ ស្គាល់កំពង់ ១ ស្គាល់ទឹកផឹក ១ ស្គាល់ផ្លូវ ១ ឈ្លាសវៃក្នុងគោចរដ្ឋាន ១ ត្រូវយកទឹកដោះ ឲ្យមានសេសសល់ ១ បូជានូវពួកគោឈ្មោលដែលជាបិតារបស់គោ ជាមេដឹកនាំហ្វូងគោ ដោយអតិរេកបូជា ១ ។

## ទុតិយោ ទុតិយវគ្គោ

ឥមេហិ ខោ ភិក្ខវេ ឯកាទសហិ អង្គេហិ សមន្នាគតោ គោបាលកោ ភព្វោ គោគណំ បរិហរិតុំ ផាតិកាតុំ ។ ឯវមេវ ខោ ភិក្ខវេ ឯកាទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ ។ កតមេហិ ឯកាទសហិ ។ ឥធ ភិក្ខវេ ភិក្ខុ រូបញ្ញូ ហោតិ លក្ខណកុសលោ ហោតិ អាសាដិកំ សាដេតា ហោតិ វណំ បដិច្ឆាទេតា ហោតិ ធូមំ កត្តា ហោតិ តិត្ថំ ជានាតិ បីតំ ជានាតិ វីថឹ ជានាតិ គោចរកុសលោ ហោតិ សាវសេសទោហី ហោតិ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ អតិរេកបូជាយ បូជេតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ រូបញ្ញូ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គទាំង ១១ ប្រការនេះ ទើបគួររក្សាហ្វូងគោ ធ្វើគោ ឲ្យចំរើនបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ១១ ប្រការ ទើបគួរដល់នូវការចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះបាន ក៏យ៉ាងនោះឯង ។ ប្រកបដោយធម៌ ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្គាល់រូប ១ ឈ្លាសវៃក្នុងលក្ខណៈ ១ ចេះក្អេះក្អៀលពងរុយ ១ ចេះបិទដំបៅ ១ ចេះធ្វើភក់ផ្សែង ១ ស្គាល់កំពង់ ១ ស្គាល់ទឹកផឹក ១ ស្គាល់ផ្លូវ ១ ឈ្លាសវៃក្នុងគោចរដ្ឋាន ១ រូតយកទឹកដោះឲ្យមានសេសសល់ ១ បូជាពួកភិក្ខុដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ស្គាល់រូប តើដូចម្តេច ។

ឥធ ភិក្ខវេ ភិក្ខុ យំ កិញ្ចិ រូបំ ចត្តារិ ច មហាភូតានិ ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបន្តិ យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ រូបញ្ញូ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ លក្ខណកុសលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ កម្មលក្ខណោ ពាលោ កម្មលក្ខណោ បណ្ឌិតោតិ យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ លក្ខណកុសលោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អាសាដិកំ សាដេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ . . . ឧប្បន្នំ វិហឹសាវិតក្កំ . . . ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិត នូវរូបណាមួយ គឺមហាភូតរូបទាំង ៤ ផង ឧបាទាយរូប ដែលអាស្រ័យនូវមហាភូតរូបទាំង ៤ ផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកស្គាល់រូបយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសវៃក្នុងលក្ខណៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា បុគ្គលពាលមានកម្មជាលក្ខណៈ បុគ្គលជាបណ្ឌិត មានកម្មជាលក្ខណៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសវៃក្នុងលក្ខណៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបេះឆ្កឹះឆ្កៀលពងរុយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទទួលត្រងរងយកកាមវិតក្កៈដែលកើតឡើងហើយ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតទៅទៀតបាន នូវព្យាបាទវិតក្កៈដែលកើតឡើងហើយ ... វិហឹសាវិតក្កៈដែលកើតឡើងហើយ ... មិនទទួលត្រងរងយកអកុសលធម៌ ដ៏លាមក ដែលកើតឡើងហើយ ៗ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើត តទៅទៀត ៗ

ទុតិយោ ទុតិយវគ្គោ

ឯវំ ខោ ភិក្ខវេ ភិក្ខុ អាសាដិកំ សាដេតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ វណំ បដិច្ឆាទេតា ហោតិ ។ ឥធ ភិក្ខវេ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា . . . ឃានេន គន្ធំ ឃាយិត្វា . . . ជិវ្ហាយ រសំ សាយិត្វា . . . កាយេន ផោដ្ឋព្វំ ផុសិត្វា . . . មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។

ទុតិយវគ្គ ទី ២

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបេះគ្រឹះគ្រៀល ពន់ពេក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ជាអ្នកបេះបិទដំបៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូប ដោយចក្ខុ ហើយជាអ្នកមិនប្រកាន់និមិត្ត មិនប្រកាន់អនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយ ដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមបុគ្គលនុ៎ះ ដែលមិនសង្រួមចក្ខុន្ទ្រិយ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយ ស្តាប់សំឡេង ដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ភ្លក្សរស ដោយអណ្តាត ... ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ ... ដឹងច្បាស់ធម្មារម្មណ៍ ដោយចិត្ត ហើយជាអ្នកមិនប្រកាន់និមិត្ត មិនប្រកាន់អនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមបុគ្គលនុ៎ះ ដែលមិនសង្រួមមនិន្ទ្រិយ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ វណ្ណំ បដិច្ឆាទេតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធូមំ កត្តា ហោតិ ឥធ ភិក្ខវេ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតា ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ធូមំ កត្តា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ តិត្ថំ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេ កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ ។ តស្ស តេ អាយស្មន្តោ អវិវដញ្ចេវ វិវរន្តិ អនុត្តានីកតញ្ច ឧត្តានីករោន្តិ អនេកវិហិតេសុ កង្ខដ្ឋានីយេសុ ធម្មេសុ កង្ខំ វិនោទេន្តិ(១) បដិវិនោទេន្តិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ តិត្ថំ ជានាតិ ។

---

១ ឱ. ម. វិនោទេន្តីតិ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកចេះបិទដំបៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកចេះធ្វើភ្នក់ផ្សែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសំដែងធម៌តាមខ្លួនបានស្តាប់ តាមខ្លួនបានរៀនមក ដល់ជនទាំងឡាយដទៃ ដោយសេចក្តីពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកចេះធ្វើភ្នក់ផ្សែង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅរកពួកភិក្ខុ ដែលជាអ្នកចេះដឹងច្រើន ចេះចាំនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា គ្រប់កាល ហើយសាកសួរថា បពិត្រលោកដ៏ចំរើន ហេតុនេះ ដូចម្តេច សេចក្តីនៃភាសិតនេះ ដូចម្តេច ។ លោកដ៏មានអាយុទាំងនោះ ក៏បើក បង្ហាញ កំចាត់កំចាយសេចក្តីដែលកំបាំងផង ធ្វើឲ្យរាក់នូវរបស់ដែលជ្រៅផង បន្ទាប់ កំចាត់កំចាយសេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយ ដែលគួរសង្ស័យច្រើនប្រការដល់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់កំពង់ យ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ ភិក្ខុ បីតំ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បីតំ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ វីថឹ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ វីថឹ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ គោចរកុសលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចត្តារោ សតិបដ្ឋានេ យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ គោចរកុសលោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សាវ-សេសទោហី ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធា គហបតិកា អភិហដ្ឋុំ បវារេន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុស្គាល់ទឹកដីក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើធម្មវិន័យ ដែលតថាគតបានប្រាប់ បានសំដែងហើយ ក៏បាននូវការដឹងអត្ថ បាននូវការដឹងធម៌ បានបាមុជ្ជៈ ដែលប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់ទឹកដីក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុស្គាល់ផ្លូវ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្គាល់តាមពិត នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់ផ្លូវ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុឈ្លាសវៃ ក្នុងគោចរដ្ឋាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិត នូវសតិប្បដ្ឋាន ៤ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសវៃ ក្នុងគោចរដ្ឋាន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ រូតយកទឹកដោះ ឲ្យមានសេសសល់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានពួកគហបតី អ្នកមានសទ្ធា នាំគ្នាមក បវារណា ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ

តត្រ ភិក្ខុ មត្តំ ជានាតិ បដិគ្គហណាយ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សាវសេសទោហី ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ អតិរេកបូជាយ បូជេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេសុ មេត្តំ កាយកម្មំ បច្ចុបដ្ឋាបេតិ អាវី ចេវ រហោ ច មេត្តំ វចីកម្មំ . . . មេត្តំ មនោកម្មំ បច្ចុបដ្ឋាបេតិ អាវី ចេវ រហោ ច ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ អតិរេកបូជាយ បូជេតា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឯកាទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ ។

ភិក្ខុក៏ស្គាល់ប្រមាណ ក្នុងការទទួលបច្ច័យទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នករូតយកទឹកដោះ ឲ្យមានសេសសល់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបូជា ពួកភិក្ខុដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដំកល់កាយកម្ម ប្រកបដោយមេត្តា ចំពោះពួកភិក្ខុដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងមុខក្តី ដំកល់វចីកម្មប្រកបដោយមេត្តា ... ដំកល់មនោកម្ម ប្រកបដោយមេត្តា ក្នុងទីចំពោះមុខផង ក្នុងទីកំបាំងមុខផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបូជាពួកភិក្ខុដែលជាថេរៈ អ្នកដឹងរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាអ្នកត្រួតត្រាសង្ឃ ដោយអតិរេកបូជា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ១១ ប្រការនេះ ទើបគួរដល់នូវការចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះបាន ។

(១២៨) អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ សិយា នុ ខោ ភន្តេ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស យម្បិទំ (១) ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា

---

១ ឱ. ម. យម្បីទំ ។

## ទុតិយវគ្គ ទី ២

(១៤៩) គ្រានោះ ពួកភិក្ខុជាច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ៗ លុះភិក្ខុទាំងនោះ អង្គុយ ក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុបាននូវសមាធិ មានសភាពដូច្នោះ មានដែរឬ ដូចជាភិក្ខុមិនសំគាល់ថា ដីក្នុងដី មិនសំគាល់ថាទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ របស់ណាដែលគេបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្ត

តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ សិយា ភិក្ខវេ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ។ បេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ យថាកថំ បន ភន្តេ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ។ បេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឯវំសញ្ញី ហោតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។

ហើយក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបានសមាធិ មានសភាពដូច្នោះ មានដែរ ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី ។បេ ។ របស់ណាដែលគេបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុបានសមាធិ មានសភាពដូច្នោះ តើដូចម្តេច ដូចជាភិក្ខុដែលមិនសំគាល់ថាដី ក្នុង ដី ។ បេ ។ របស់ណាដែលគេបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីសំគាល់ យ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះកិលេសទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ដ៏ឧត្តម ។

## ទុតិយោ ទុតិយវគ្គោ

ឯវំ ខោ សិយា ភិក្ខវេ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។

(១២៦) តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។

## ទុតិយវគ្គ ទី ២

ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នេះ យ៉ាងនេះឯង ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ របស់ណា ដែលគេបានឃើញ ឮ ទទួលរស ដឹង ពាល់ ស្វែងរក ត្រិះរិះដោយចិត្ត ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។

(១៦៦) ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ ចំពោះ ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។

ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សិយា នុ ខោ ភិក្ខវេ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បថវិយំ បថវីសញ្ញី អស្ស ន អាបស្មិំ អាបោសញ្ញី អស្ស ន តេជស្មិំ តេជោសញ្ញី អស្ស ន វាយស្មិំ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។

ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានសមាធិ មានសភាពដូច្នេះ មានដែរឬ ដូចជា ភិក្ខុមិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះមិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ របស់ណាដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាដោយធម្មតាតែប៉ុណ្ណោះ ។

## ទុតិយោ ទុតិយវគ្គោ

ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សិយា ភិក្ខវេ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បថវិយំ បថវីសញ្ញី អស្ស ។ បេ ។ យមិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ យថាកថំ បន ភន្តេ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បថវិយំ បថវីសញ្ញី អស្ស ។ បេ ។ យមិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា

ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយ របស់យើងខ្ញុំព្រះអង្គ មានតែព្រះមានព្រះភាគ ជាមូល មានតែព្រះមានព្រះភាគ ជាអ្នកណែនាំ មានតែព្រះមានព្រះភាគ ជាទីពឹង បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស សូមទ្រង់បំភ្លឺសេចក្ដីនៃភាសិតនេះឲ្យទាន ភិក្ខុទាំងឡាយ បានស្ដាប់ព្រះវាចានៃព្រះមានព្រះភាគហើយ នឹងចាំទុកបាន ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកប្រុងស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបានសមាធិ មានសភាពដូច្នេះ មានដែរ ដូចជាភិក្ខុមិនសំគាល់ថា ដី ក្នុងដី ។ បេ ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលបានសមាធិ មានសភាពដូច្នោះ តើដូចម្ដេច ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី ។ បេ ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ

តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឯវំសញ្ញី ហោតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ ឯវំ ខោ ភិក្ខវេ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បថវិយំ បថវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស

ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្ដីសំគាល់យ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះឧបធិទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់តណ្ហា គឺព្រះនិព្វាន ណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នោះ យ៉ាងនេះឯង ដូចជាភិក្ខុមិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ

## ទុតិយោ ទុតិយវគ្គោ

យមិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។

(១២៧) អថខោ សម្ពហុលា ភិក្ខូ យេនាយស្មា សារីបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ សារីបុត្តំ ឯតទវោចុំ សិយា នុ ខោ អាវុសោ សារីបុត្ត ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស

របស់ណា ដែលបានឃើញ ៗ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ នូវរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាថាជាធម្មតាតែប៉ុណ្ណោះ ។

(១៦៧) លំដាប់នោះ ពួកភិក្ខុជាច្រើនរូប ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះសារីបុត្ត ដ៏មានអាយុ លុះបញ្ចប់ពាក្យ ដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏បានពោលទៅនឹងព្រះសារីបុត្ត ដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុបានសមាធិ មានសភាពដូច្នោះមានដែរឬ ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ

ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញា-
យតនសញ្ញី អស្ស ន ឥធលោកេ ឥធលោក-
សញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស
យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ
អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី
ច បន អស្សាតិ ។ សិយា អាវុសោ ភិក្ខុនោ
តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ
បឋវីសញ្ញី អស្ស ។ បេ ។ យម្បិទំ ទិដ្ឋំ សុតំ
មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា
តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។
យថាកថំ បនាវុសោ សារីបុត្ត សិយា ភិក្ខុនោ
តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ
បឋវីសញ្ញី អស្ស ។ បេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ
វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ
ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។

មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ត្រង់នេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ របស់ណាដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោ ភិក្ខុបានសមាធិ មានសភាពដូច្នោះ មានដែរ ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី ។ បេ ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោ សារីបុត្ត ចុះភិក្ខុ បានសមាធិ មានសភាពដូច្នោះ តើដូចម្តេច ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី ។ បេ ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។

ឥធ អាវុសោ ភិក្ខុ ឯវំសញ្ញី ហោតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ ឯវំ ខោ អាវុសោ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្ដីសំគាល់យ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះឧបធិទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់តណ្ហា គឺ ព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ដ៏ឧត្ដម ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នោះ យ៉ាងនេះ ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។

(១២៨) តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ
អាមន្តេសិ សិយា នុ ខោ អាវុសោ ភិក្ខុនោ
តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ
បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស
ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោ-
សញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសា-
នញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ
វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ
អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញា-
យតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន
ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ
បរលោកសញ្ញី អស្ស យម្បិទំ ទិដ្ឋំ សុតំ មុតំ
វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ
ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។

(២២៨) គ្រានោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នោះ មានដែរ ឬ ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្នុងលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្នុងលោកខាងមុខ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។

ទូរតោបិ ខោ មយំ អាវុសោ អាគច្ឆេយ្យាម អាយស្មតោ សារីបុត្តស្ស សន្តិកេ ឯតស្ស ភាសិតស្ស អត្ថមញ្ញាតុំ សាធុ វតាយស្មន្តំយេវ សារីបុត្តំ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ អាយស្មតោ សារីបុត្តស្ស សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហាវុសោ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច សិយា អាវុសោ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ។ បេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ យថាកថំ បនាវុសោ សារីបុត្ត សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ។ បេ ។

ម្នាលអាវុសោ យើងទាំងឡាយ មកអំពីចម្ងាយ ចង់ដឹងសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះសារីបុត្តដ៏មានអាយុ សូមអភ័យទោស សូមព្រះសារីបុត្តដ៏មានអាយុ បំភ្លឺសេចក្តីនៃភាសិតនេះឲ្យបាន ភិក្ខុទាំងឡាយ បានស្តាប់ភាសិតរបស់ព្រះសារីបុត្តដ៏មានអាយុនឹងចាំទុកបាន ។ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរស្តាប់ធម៌នោះ ចូរធ្វើទុក ក្នុងចិត្តដោយប្រពៃចុះ ខ្ញុំនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលថេរវាចា របស់ព្រះសារីបុត្តដ៏មានអាយុថា ករុណា អាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នោះ មានដែរ ដូចជាភិក្ខុមិនសំគាល់ថា ដី ក្នុងដី ។ បេ ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ នូវរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុ បានសមាធិមានសភាពដូច្នោះតើដូចម្តេច ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី ។ បេ ។

យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ យថាកថំ បនាវុសោ សារីបុត្ត សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ។ បេ ។ យម្បិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ន សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ ឥធ អាវុសោ ភិក្ខុ ឯវំសញ្ញី ហោតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ ឯវំ ខោ អាវុសោ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស

របស់ណា ដែលបានឃើញ ឮ ទទួលរស ធុំ ពាល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ ក្នុងរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោសារីបុត្ត ចុះភិក្ខុបានសមាធិ មានសភាពដូច្នោះ ជាអ្នកមិនសំគាល់ថា ដី ក្នុងដី តើយ៉ាងណា ។ បេ ។ របស់ណា ដែលបានឃើញ ឮ ទទួលរស ធុំ ពាល់ ស្វែងរក ត្រិះរិះ ដោយចិត្ត មិនសំគាល់ ក្នុងរបស់ទាំងនោះ គ្រាន់តែមានសញ្ញាជាធម្មតាតែប៉ុណ្ណោះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីសំគាល់យ៉ាងនេះថា ការរម្ងាប់សង្ខារទាំងអស់ ការលះបង់ឧបធិទាំងអស់ ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ដ៏ឧត្តម ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសមាធិ មានសភាពដូច្នោះ យ៉ាងនេះ ដូចជាភិក្ខុដែលមិនសំគាល់ថា ដី ក្នុងដី មិនសំគាល់ថា ទឹក ក្នុងទឹក មិនសំគាល់ថា ភ្លើង ក្នុងភ្លើង មិនសំគាល់ថា ខ្យល់ ក្នុងខ្យល់ មិនសំគាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសំគាល់ថា វិញ្ញាណញ្ចាយតន ក្នុងវិញ្ញាណញ្ចាយតនៈ

ទុតិយោ ទុតិយវគ្គោ

ច អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ច នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ច ឥធលោកេ ឥធលោកសញ្ញី អស្ស ច បរលោកេ បរលោកសញ្ញី អស្ស យមិទំ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា តត្រាបិ ច សញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។

ទុតិយវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

ទ្វេ មហានាមា(១) ច(២) នន្ទិយេន សុភូតិនា ច(២) មេត្តា
ទសមោ(៣) គោបាលកោ(៤) ចន្ទាភេ ច សមាធិនោតិ ។

---

១ ម. ទ្វេ វុត្តា មហានាមេន ។ ២ ម. ចសទ្ទោ នត្ថិ ។ ៣ ឱ. ទសមោ ចេវ ។
៤ ឱ.ម. គោបាលោ ។

ទុតិយវគ្គ ទី ២

មិនសំគាល់ថា អាកិញ្ចញ្ញាយតនៈ ក្តីអាកិញ្ចញ្ញាយតនៈ មិនសំគាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្តីនេវសញ្ញានាសញ្ញាយតនៈ មិនសំគាល់ថា លោកនេះ ក្តីលោកនេះ មិនសំគាល់ថា លោកខាងមុខ ក្តីលោកខាងមុខ របស់ណា ដែលបានឃើញ ឮ ទទួលរស ដឹង ដល់ ស្វែងរក ត្រិះរិះ ដោយចិត្តហើយ ក៏មិនសំគាល់ ក្តីរបស់ទាំងនោះឡើយ គ្រាន់តែមានសញ្ញា ជាធម្មតាតែប៉ុណ្ណោះ ។

ចប់ ទុតិយវគ្គ ទី ២ ។

## ឧទ្ទាននៃវគ្គនោះគឺ

និយាយអំពីមហានាម មាន ៤ លើក អំពីនន្ទិយៈ ១

អំពីសុភូតិ ១ អំពីមេត្តា ១ អំពីទសមគហបតី ១

អំពីគោបាល ១ អំពីសមាធិមាន ៤ លើក ។

# បណ្ណាសកាសង្គហិតា សុត្តា

(១២៩) ឯកាទសហិ ភិក្ខវេ អង្គេហិ សមន្នាគតោ គោបាលកោ អភព្វោ គោគណំ បរិហរិតុំ ផាតិំ កាតុំ ។ កតមេហិ ឯកាទសហិ ។ ឥធ ភិក្ខវេ គោបាលកោ ន រូបញ្ញូ ហោតិ ន លក្ខណកុសលោ ហោតិ ន អាសាដិកំ សាដេតា ហោតិ ន វណំ បដិច្ឆាទេតា ហោតិ ន ធូមំ កត្តា ហោតិ ន តិត្ថំ ជានាតិ ន បីតំ ជានាតិ ន វីថឹ ជានាតិ ន គោចរកុសលោ ហោតិ អនវសេសទោហី ហោតិ យេ តេ ឧសភា គោបិតរោ គោបរិណាយកា តេ ន អតិរេកបូជាយ បូជេតា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឯកាទសហិ អង្គេហិ សមន្នាគតោ គោបាលកោ អភព្វោ គោគណំ បរិហរិតុំ ផាតិំ កាតុំ ។ ឯវមេវ ខោ ភិក្ខវេ ឯកាទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ ចក្ខុស្មឹ អនិច្ចានុបស្សី វិហរិតុំ ។ បេ ។

# សូត្រដែលរួបរួមដោយបណ្ណាសកៈ

(២២៩) ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គ ១១ ប្រការ មិនគួររក្សាហ្វូងគោ មិនគួរធ្វើគោ ឲ្យចំរើនបានទេ ។ ប្រកបដោយអង្គទាំង ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ក្នុងលោកនេះ មិនស្គាល់រូបគោ ១ មិនឈ្លាសវៃក្នុងលក្ខណៈ ១ មិនបេះត្កឹះត្កៀលពងរុយ ១ មិនបេះបិទដំបៅ ១ មិនបេះធ្វើក្តក់ផ្សែង ១ មិនស្គាល់កំពង់ ១ មិនស្គាល់ទឹកផឹក ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសវៃ ក្នុងគោចរដ្ឋាន ១ រូតទឹកដោះមិនឲ្យមានសេសសល់ ១ មិនបូជាគោឈ្មោល ដែលជាបិតារបស់គោ ជាមេដឹកនាំគោ ដោយអតិរេកបូជា ១ ។ ម្នាលភិក្ខុទាំងឡាយ នាយគោបាល ប្រកបដោយអង្គ ១១ នេះឯង មិនគួររក្សាហ្វូងគោ មិនគួរធ្វើគោ ឲ្យចំរើនបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជា ភិក្ខុប្រកបដោយធម៌ទាំង១១ ប្រការ មិនគួរឃើញរឿយ ៗ ថា មិនទៀង ក្នុងចក្ខុ ។ បេ ។

អកញ្ញោ ចក្ខុស្មឹ ទុក្ខានុបស្សី វិហរតិ អកញ្ញោ ចក្ខុស្មឹ អនត្តានុបស្សី វិហរតិ អកញ្ញោ ចក្ខុស្មឹ ខយានុបស្សី វិហរតិ អកញ្ញោ ចក្ខុស្មឹ វយានុបស្សី វិហរតិ អកញ្ញោ ចក្ខុស្មឹ វិរាគានុបស្សី វិហរតិ អកញ្ញោ ចក្ខុស្មឹ និរោធានុបស្សី វិហរតិ អកញ្ញោ ចក្ខុស្មឹ បដិនិស្សគ្គានុបស្សី វិហរតិ អកញ្ញោ សោតស្មឹ ឃានស្មឹ ជិវ្ហាយ កាយស្មឹ មនស្មឹ រូបេសុ សទ្ទេសុ គន្ធេសុ រសេសុ ផោដ្ឋព្វេសុ ធម្មេសុ ចក្ខុវិញ្ញាណេ សោតវិញ្ញាណេ ឃានវិញ្ញាណេ ជិវ្ហាវិញ្ញាណេ កាយវិញ្ញាណេ មនោវិញ្ញាណេ ចក្ខុសម្ផស្សេ សោតសម្ផស្សេ ឃានសម្ផស្សេ ជិវ្ហាសម្ផស្សេ កាយសម្ផស្សេ មនោសម្ផស្សេ ចក្ខុសម្ផស្សជាយ វេទនាយ សោតសម្ផស្សជាយ វេទនាយ

## សូត្រដែលរួបរួមដោយបណ្ណាសកៈ

មិនគួរឃើញរឿយ ៗ នូវសេចក្តីទុក្ខ ក្នុងចក្ខុ មិនគួរឃើញរឿយ ៗ នូវការមិនមានខ្លឹមសារ ក្នុងចក្ខុ មិនគួរឃើញរឿយ ៗ នូវការអស់ទៅ ក្នុងចក្ខុ មិនគួរឃើញរឿយ ៗ នូវការសូន្យទៅ ក្នុងចក្ខុ មិនគួរឃើញរឿយ ៗ នូវការប្រាសចាកតម្រេក ក្នុងចក្ខុ មិនគួរឃើញរឿយ ៗ នូវការរលត់ទៅ ក្នុងចក្ខុ មិនគួរឃើញរឿយ ៗ នូវការលះបោល ក្នុងចក្ខុ មិនគួរឃើញរឿយ ៗ នូវការមិនទៀង មិនគួរឃើញរឿយ ៗ នូវសេចក្តីទុក្ខ មិនគួរឃើញរឿយ ៗ នូវការមិនមានខ្លឹមសារ មិនគួរឃើញរឿយ ៗ នូវការអស់ទៅ មិនគួរឃើញរឿយ ៗ នូវការសូន្យទៅ មិនគួរឃើញរឿយ ៗ នូវការប្រាសចាកតម្រេក មិនគួរឃើញរឿយ ៗ នូវការរលត់ទៅ មិនគួរឃើញរឿយ ៗ នូវការលះបោល ក្នុងត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត រូប សំឡេង ក្លិន រស ផ្សព្វ ធម្មារម្មណ៍ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស វេទនាដែលកើត អំពីចក្ខុសម្ផស្ស វេទនាដែលកើត អំពីសោតសម្ផស្ស

ឃានសម្ផស្សជាយ វេទនាយ ជិវ្ហាសម្ផស្សជាយ វេទនាយ កាយសម្ផស្សជាយ វេទនាយ មនោសម្ផស្សជាយ វេទនាយ រូបសញ្ញាយ សទ្ទសញ្ញាយ គន្ធសញ្ញាយ រសសញ្ញាយ ផោដ្ឋព្វសញ្ញាយ ធម្មសញ្ញាយ រូបសញ្ចេតនាយ សទ្ទសញ្ចេតនាយ គន្ធសញ្ចេតនាយ រសសញ្ចេតនាយ ផោដ្ឋព្វសញ្ចេតនាយ ធម្មសញ្ចេតនាយ រូបតណ្ហាយ សទ្ទតណ្ហាយ គន្ធតណ្ហាយ រសតណ្ហាយ ផោដ្ឋព្វតណ្ហាយ ធម្មតណ្ហាយ រូបវិតក្កេ សទ្ទវិតក្កេ គន្ធវិតក្កេ រសវិតក្កេ ផោដ្ឋព្វវិតក្កេ ធម្មវិតក្កេ រូបវិចារេ សទ្ទវិចារេ គន្ធវិចារេ រសវិចារេ ផោដ្ឋព្វវិចារេ ធម្មវិចារេ អនិច្ចានុបស្សី វិហរិតុំ ទុក្ខានុបស្សី វិហរិតុំ អនត្តានុបស្សី វិហរិតុំ ខយានុបស្សី វិហរិតុំ វយានុបស្សី វិហរិតុំ វិរាគានុបស្សី វិហរិតុំ និរោធានុបស្សី វិហរិតុំ បដិនិស្សគ្គានុបស្សី វិហរិតុម្បិ ។

វេទនាដែលកើត អំពីឃានសម្ផស្ស វេទនាដែលកើត អំពីជិវ្ហាសម្ផស្ស វេទនាដែលកើត អំពីកាយសម្ផស្ស វេទនាដែលកើត អំពីមនោសម្ផស្ស រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា រូបវិតក្កៈ សទ្ទវិតក្កៈ គន្ធវិតក្កៈ រសវិតក្កៈ ផោដ្ឋព្វវិតក្កៈ ធម្មវិតក្កៈ រូបវិចារៈ សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ ។

(២៣០) ឯកាទសហិ ភិក្ខវេ អង្គេហិ សមន្នាគតោ គោបាលកោ ភព្វោ គោគណំ បរិហរិតុំ ផាតិកាតុំ ។ កតមេហិ ឯកាទសហិ ។ ឥធ ភិក្ខវេ គោបាលកោ រូបញ្ញូ ហោតិ ។ បេ ។ ឯវមេវ ខោ ភិក្ខវេ ឯកាទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ ចក្ខុស្មឹ អនិច្ចានុបស្សី វិហរិតុំ ។ បេ ។ បដិនិស្សគ្គានុបស្សី វិហរិតុន្តិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឯកាទស ធម្មា ភាវេតព្វា ។ កតមេ ឯកាទស ។ បឋមជ្ឈានំ ទុតិយជ្ឈានំ តតិយជ្ឈានំ ចតុត្ថជ្ឈានំ មេត្តាចេតោវិមុត្តិ ករុណាចេតោវិមុត្តិ មុទិតាចេតោវិមុត្តិ ឧបេក្ខាចេតោវិមុត្តិ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ឯកាទស ធម្មា ភាវេតព្វាតិ ។

(២៣០) ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គទាំង ១១ ប្រការ ទើបគួរ ដើម្បីរក្សាហ្វូងគោ ធ្វើគោឲ្យចំរើនបាន ។ ប្រកបដោយអង្គទាំង ១១ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ក្នុងលោកនេះ ជាអ្នកស្គាល់រូបគោ ១ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកប ដោយធម៌ ១១ ប្រការ ទើបគួរឃើញរឿយ ៗ នូវការមិនទៀង ក្នុងចក្ខុ ។ បេ ។ ឃើញរឿយ ៗ នូវការលះបោលយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១១ ប្រការ បុគ្គលគួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ទាំង ១១ ប្រការ តើដូចម្តេច ។ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ មេត្តាចេតោវិមុត្តិ ១ ករុណាចេតោវិមុត្តិ ១ មុទិតាចេតោវិមុត្តិ ១ ឧបេក្ខាចេតោវិមុត្តិ ១ អាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១១ ប្រការនេះ បុគ្គលគួរចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។

(២៣១) រាគស្ស ភិក្ខវេ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ ឯកាទស ធម្មា ភាវេតព្វា ។ ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ ឯកាទស ធម្មា ភាវេតព្វាតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

នវសុត្តសហស្សានិ ភិយ្យោ បញ្ចសតានិ ច
សត្តបញ្ញាស សុត្តន្តា អង្គុត្តរសមាយុតាតិ ។

ឯកាទសកនិបាតោ និដ្ឋិតោ ។

( ១៣១ ) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១១ ប្រការនេះ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ កំណត់ដឹង អស់រលីង លះបង់ អស់ទៅ សូន្យទៅ ប្រាសចាកតម្រេក រលត់ លះបោល បោះបង់នូវរាគៈ ។ ធម៌ទាំង ១១ ប្រការនេះ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ កំណត់ដឹង អស់រលីង លះបង់ អស់ទៅ សូន្យទៅ ប្រាសចាកតម្រេក រលត់ លះបោល បោះបង់នូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះចប់ហើយ ។ ភិក្ខុទាំងនោះ មានចិត្តរីករាយ ត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

សូត្រទាំងឡាយ ប្រាំបួនពាន់ ប្រាំរយ នឹង ៥៧ សូត្រដ៏ក្រៃលែង មានមក ក្នុងគម្ពីរអង្គុត្តរនិកាយ ។

ចប់ ឯកាទសកនិបាត ។

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស ទសកនិបាតោ

## ទ្វាទសមោ ភាគោ

---

មាតិកា អង្កេ


តតិយបណ្ណាសកេ សមណសញ្ញាវគ្គោ បឋមោ . . . ១

តិសមណសញ្ញាកថា . . . . . . . . . . . ១

តិសមណសញ្ញានំ ភាវិតត្តា សត្តន្នំ ធម្មានំ បារិបូរិកថា . ១

សត្តពោជ្ឈង្គកថា . . . . . . . . . . . ២

សត្តពោជ្ឈង្គានំ ភាវិតត្តា តិស្សន្នំ វិជ្ជានំ បារិបូរិកថា . ២

មិច្ឆត្តំ អាគម្ម វិរាធនកថា . . . . . . . ៣

សម្មត្តំ អាគម្ម អារាធនកថា . . . . . . . ៤

មិច្ឆាទិដ្ឋិកស្ស វេទនាទីនំ ទុក្ខាយ សំវត្តនកថា . . . ៥

សម្មាទិដ្ឋិកស្ស វេទនាទីនំ សុខាយ សំវត្តនកថា. . . . ៦

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ទសកនិបាត

# ទ្វាទសមភាគ

---

មាតិកា ទំព័រ


តតិយបណ្ណាសក សមណសញ្ញាវគ្គ ទី១ . . . . ១

ពោលអំពីសមណសញ្ញា ៣ . . . . . ១

ពោលអំពីការបរិបូណ៌នៃធម៌ ៧ ប្រការ ព្រោះបានចំរើន
នូវសមណសញ្ញា ៣ . . . . . ១

ពោលអំពីពោជ្ឈង្គ ៧ . . . . . . ២

ពោលអំពីការបរិបូណ៌នៃវិជ្ជា ព្រោះបានចំរើននូវពោជ្ឈង្គ ៧ . ២

ពោលអំពីការឃ្លាត (ចាកបានសួគ៌ និងមគ្គ) ព្រោះមិច្ឆត្តៈ (១០) . ៣

ពោលអំពីការសម្រេច (បានសួគ៌ និងមគ្គ) ព្រោះសម្មត្តៈ (១០) . ៤

ពោលអំពីការប្រព្រឹត្តទៅដើម្បីទុក្ខ នៃធម៌មានចេតនា
ជាដើមរបស់ជនជាមិច្ឆាទិដ្ឋិ . . . . ៥

ពោលអំពីការប្រព្រឹត្តទៅដើម្បីសុខ នៃធម៌មានចេតនា
ជាដើមរបស់ជនជាសម្មាទិដ្ឋិ . . . . ៦

# មាតិកាបត្តានិ

| មាតិកា | អង្កេ |
| --- | --- |
| តតិយបណ្ណាសកេ សមណសញ្ញាវគ្គោ បឋមោ ... | ១ |
| អវិជ្ជាយ អកុសលានំ ធម្មានំ សមាបត្តិយា បុព្វង្គមតាទិកថា. | ៨ |
| ទសនិជ្ជរវត្ថុកថា. | ៩ |
| ទក្ខិណេសុ ជនបទេសុ ធោវនកថា | ១៣ |
| អរិយធោវនកថា | ១៥ |
| តិកិច្ឆកានំ វិរេចនកថា | ១៧ |
| អរិយវិរេចនកថា | ១៨ |
| តិកិច្ឆកានំ វមនកថា. | ២០ |
| អរិយវមនកថា | ២១ |
| ទសនិទ្ធមនិយធម្មកថា | ២៣ |
| ទសហិ ធម្មេហិ សមន្នាគតអសេក្ខកថា | ២៥ |
| ទសអសេក្ខិយធម្មកថា | ២៦ |
| បច្ចោរោហណិវគ្គោ ទុតិយោ | ២៨ |
| អធម្មានត្ថកថា | ២៨ |
| ធម្មត្ថកថា | ២៨ |

មាតិកា ទំព័រ

តតិយបណ្ណាសក សមណសញ្ញាវគ្គ ទី ១ ១

ពោលអំពីអវិជ្ជាជាប្រធាននៃការដល់ព្រមនូវពួកអកុសលធម៌ ៨

ពោលអំពីហេតុនាំឲ្យសាបរលាប(ទោសមានមិច្ឆាទិដ្ឋិ
ជាដើម)១០ ៩

ពោលអំពីពិធីលាង(ធ្មេញ)ក្នុងទក្ខិណជនបទ ១៣

ពោលអំពីពិធីលាងដ៏ប្រសើរ ១៤

ពោលអំពីថ្នាំបញ្ចុះរបស់ពួកពេទ្យ ១៧

ពោលអំពីថ្នាំបញ្ចុះដ៏ប្រសើរ ១៨

ពោលអំពីថ្នាំក្អួត របស់ពួកពេទ្យ ២០

ពោលអំពីថ្នាំក្អួតដ៏ប្រសើរ ២១

ពោលអំពីធម៌ដែលគប្បីកំចាត់បង់ ១០ ២៣

ពោលអំពីភិក្ខុជាអសេក្ខៈប្រកបដោយធម៌ ១០ ២៥

ពោលអំពីធម៌ជាអសេក្ខៈ ១០ ២៦

បច្ចោរោហណិវគ្គ ទី ២ ២៨

ពោលអំពីសភាវៈមិនមែនជាធម៌ទាំងមិនមែនជា
ប្រយោជន៍(១០) ២៨

ពោលអំពីសភាវៈជាធម៌ទាំងជាប្រយោជន៍ (១០) ២៨

# មាតិកាបត្តាន


មាតិកា ............ អង្គ

តតិយបណ្ណាសកោ បច្ចោរោហណិវគ្គោ ទុតិយោ ...២៨

មិច្ឆាទិដ្ឋាទិប្បច្ចយានំ អកុសលធម្មានំ សម្ភវនកថា ...២៩

សម្មាទិដ្ឋាទិប្បច្ចយានំ កុសលធម្មានំ ភាវនាបារិបូរិកថា ...២៩

ភគវតោ សង្ខិត្តេន ទេសនកថា . . . ៣៤

អានន្ទត្ថេរស្ស វិត្ថារេន អត្ថស្ស វិភជនកថា . . ៣៩

បណ្ឌិតវគ្គកថា . . . . . . ៤៥

ឱរិមតីរបារិមតីរកថា . . . . . . ៤៩

,, . . . . . . ៥២

ព្រាហ្មណានំ បច្ចោរោហណីកថា . . . . ៥៤

អរិយស្ស វិនយេ បច្ចោរោហណីកថា . . . ៥៥

អរិយបច្ចោរោហណីកថា . . . . . ៥៩

កុសលានំ ធម្មានំ បុព្វង្គមបុព្វនិមិត្តសម្មាទិដ្ឋិកថា , . . ៦០

ទសន្នំ ធម្មានំ ភាវិតានំ អាសវានំ ខយាយ សំវត្តនកថា . .៦១

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| តតិយបណ្ណាសក បច្ចោរោហណវគ្គ ទី២ . . | ២៨ |
| ពោលអំពីការកើតព្រមនៃពួកអកុសលធម៌ ដែលមានមិច្ឆាទិដ្ឋិជាដើមជាបច្ច័យ . . . . . . | ២៩ |
| ពោលអំពីការបរិបូណ៌ដោយការចំរើន នៃធម៌ទាំងឡាយដែលមានសម្មាទិដ្ឋិជាដើមជាបច្ច័យ . . . . | ២៩ |
| ពោលអំពីឧទ្ទេសដោយសង្ខេបនៃព្រះមានព្រះភាគ . . | ៣៤ |
| ពោលអំពីការចែកនូវអត្ថដោយពិស្ដារនៃព្រះអានន្ទត្ថេរ . | ៣៩ |
| ពោលអំពីបណ្ឌិតវត្ត . . . . . . | ៤៥ |
| ពោលអំពីធម៌ជាត្រើយខាងអាយនិងជាត្រើយខាងនាយ . | ៤៩ |
| ,, . . . | ៥២ |
| ពោលអំពីការជម្រះបាបរបស់ពួកព្រាហ្មណ៍ . . . | ៥៤ |
| ពោលអំពីការជម្រះបាបក្នុងវិន័យរបស់អរិយេ . . . | ៥៥ |
| ពោលអំពីការជម្រះបាបដ៏ប្រសើរ . . . . | ៥៩ |
| ពោលអំពីសម្មាទិដ្ឋិជាប្រធានទាំងជាបុព្វនិមិត្តនៃកុសលធម៌ . . | ៦០ |
| ពោលអំពីធម៌ ១០ ដែលបុគ្គលបានចំរើនហើយមានការប្រព្រឹត្តទៅដើម្បីកិរិយាអស់អាសវៈ . . . . | ៦១ |

# មាតិកាបត្តានិ


| មាតិកា | អង្ក |
|---|---|
| តតិយបណ្ណាសកោ ចារិសុទ្ធិវគ្គោ តតិយោ . . . | ៦២ |
| ទសន្នំ ធម្មានំ បរិសុទ្ធានំ អញ្ញត្រ សុគតវិនយា នត្ថិភាវកថា . . | ៦២ |
| ទសន្នំ ធម្មានំ អញ្ញត្រ សុគតវិនយា អនុប្បជ្ជនកថា . . . . | ៦២ |
| ទសន្នំ ធម្មានំ មហប្ផលានំ អញ្ញត្រ សុគតវិនយា នត្ថិភាវកថា. . | ៦២ |
| ទសន្នំ ធម្មានំ រាគាទិវិនយបរិយោសានភាវកថា . . | ៦៣ |
| ទសន្នំ ធម្មានំ ឯកន្តនិព្ពិទាយ សំវត្តនកថា . . . | ៦៣ |
| ទសន្នំ ធម្មានំ អញ្ញត្រ សុគតវិនយា អនុប្បជ្ជនកថា. . | ៦៤ |
| ទសន្នំ ធម្មានំ ភាវិតានំ មហប្ផលភាវកថា . . . | ៦៤ |
| ទសន្នំ ធម្មានំ ភាវិតានំ រាគាទិវិនយបរិយោសានភាវកថា . | ៦៥ |
| ទសន្នំ ធម្មានំ ភាវិតានំ ឯកន្តនិព្ពិទាយ សំវត្តនកថា. . | ៦៥ |
| ទសមិច្ឆត្តកថា. . . . . . . | ៦៦ |
| ទសសម្មត្តកថា . . . . . . . | ៦៦ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| តតិយបណ្ណាសក ជាណុស្សោណិវគ្គ ទី ៣ . . . | ៦២ |
| ពោលអំពីធម៌ ១០ ដ៏បរិសុទ្ធមិនមានក្រៅចាកសុគតវិន័យ . . | ៦២ |
| ពោលអំពីធម៌ ១០ មិនកើតឡើងក្រៅចាកសុគតវិន័យ . | ៦២ |
| ពោលអំពីធម៌១០ដែលមានផលមិនមានក្រៅចាកសុគតវិន័យ . . | ៦២ |
| ពោលអំពីធម៌ ១០ មានការកំចាត់កត:ជាដើមជាទីបំផុត . . | ៦៣ |
| ពោលអំពីធម៌១០ប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយតែម្យ៉ាង . . . . . . . . | ៦៣ |
| ពោលអំពីធម៌ ១០ ដែលមិនកើតឡើងក្រៅចាកសុគតវិន័យ . | ៦៤ |
| ពោលអំពីធម៌ ១០ ដែលបុគ្គលចំរើនហើយ មានផលច្រើន . . | ៦៤ |
| ពោលអំពីធម៌ ១០ ដែលបុគ្គលបានចំរើន ហើយមានការកំចាត់កត:ជាដើមជាទីបំផុត . . . . . | ៦៥ |
| ពោលអំពីធម៌ ១០ ដែលបុគ្គលបានចំរើនហើយ ប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយតែម្យ៉ាង . . . | ៦៥ |
| ពោលអំពីមិច្ឆត្តធម៌ ១០ . . . . . . | ៦៦ |
| ពោលអំពីសម្មត្តធម៌ ១០ . . . . . . | ៦៦ |

# មាតិកាបត្តានី


| មាតិកា | អង្កៃ |
|---|---|
| តតិយបណ្ណាសកោ សាធុវគ្គោ ចតុត្ថោ | ៦៧ |
| សាធ្វាសាធុកថា | ៦៧ |
| អរិយានរិយធម្មកថា | ៦៨ |
| កុសលាកុសលកថា | ៦៨ |
| អត្ថានត្ថកថា | ៦៩ |
| ធម្មាធម្មកថា | ៦៩ |
| សាសវានាសវធម្មកថា | ៧០ |
| សាវជ្ជានវជ្ជធម្មកថា | ៧១ |
| តបនីយាតបនីយធម្មកថា | ៧១ |
| អាចយគាមិអបចយគាមិធម្មកថា | ៧២ |
| ទុក្ខុទ្រយសុខុទ្រយធម្មកថា | ៧៣ |
| ទុក្ខវិបាកសុខវិបាកធម្មកថា | ៧៣ |
| អរិយមគ្គវគ្គោ បញ្ចមោ | ៧៤ |
| អរិយមគ្គានរិយមគ្គធម្មកថា | ៧៤ |
| កណ្ហមគ្គសុក្កមគ្គធម្មកថា | ៧៤ |

# សន្លឹកប្រាប់មាតិកា

| មាតិកា | ទំព័រ |
| --- | --- |
| តតិយបណ្ណាសក សាធុវគ្គ ទី ២ | ៦៧ |
| ពោលអំពីសេចក្តីចំរើននឹងសេចក្តីមិនចំរើន (១០) | ៦៧ |
| ពោលអំពីធម៌ប្រសើរនឹងធម៌មិនប្រសើរ (១០) | ៦៨ |
| ពោលអំពីកុសលនឹងអកុសល (១០) | ៦៨ |
| ពោលអំពីធម៌ជាប្រយោជន៍នឹងធម៌មិនជាប្រយោជន៍ ១០ | ៦៩ |
| ពោលអំពីធម៌នឹងអធម៌ ១០ | ៦៩ |
| ពោលអំពីសាសវធម៌នឹងអនាសវធម៌ (១០) | ៧០ |
| ពោលអំពីសាវជ្ជធម៌នឹងអនវជ្ជធម៌ (១០) | ៧១ |
| ពោលអំពីតបនីយធម៌នឹងអតបនីយធម៌ (១០) | ៧១ |
| ពោលអំពីអាចយគាមិធម៌នឹងអបចយគាមិធម៌ (១០) | ៧២ |
| ពោលអំពីទុក្ខុទ្រយធម៌នឹងសុខុទ្រយធម៌ (១០) | ៧៣ |
| ពោលអំពីទុក្ខវិបាកធម៌នឹងសុខវិបាកធម៌ (១០) | ៧៣ |
| អរិយមគ្គវគ្គ ទី ៤ | ៧៤ |
| ពោលអំពីអរិយមគ្គធម៌នឹងអនរិយមគ្គធម៌ (១០) | ៧៤ |
| ពោលអំពីកណ្ហមគ្គធម៌នឹងសុក្កមគ្គធម៌ (១០) | ៧៥ |

# មាតិកាបត្តានិ


| មាតិកា | អង្គេ |
|---|---|
| តតិយបណ្ណាសកេ អរិយមគ្គវគ្គោ បឋមោ | ៧៥ |
| សទ្ធម្មាសទ្ធម្មកថា | ៧៦ |
| សប្បុរិសាសប្បុរិសធម្មកថា | ៧៧ |
| ឧប្បាទេតព្វានុប្បាទេតព្វធម្មកថា | ៧៧ |
| អាសេវិតព្វានាសេវិតព្វធម្មកថា | ៧៨ |
| ភាវេតព្វាភាវេតព្វធម្មកថា | ៧៩ |
| ពហុលីកាតព្វាពហុលីកាតព្វធម្មកថា | ៨០ |
| អនុស្សរិតព្វានានុស្សរិតព្វធម្មកថា | ៨១ |
| សច្ឆិកាតព្វាសច្ឆិកាតព្វធម្មកថា | ៨២ |
| ចតុត្ថបណ្ណាសកេ បុគ្គលវគ្គោ បឋមោ | ៨៣ |
| អាសេវិតព្វសេវិតព្វបុគ្គលកថា | ៨៣ |
| អភជិតព្វភជិតព្វាទិបុគ្គលកថា | ៨៤ |
| ជាណុស្សោណិវគ្គោ ទុតិយោ | ៨៦ |
| ព្រាហ្មណានំ បច្ចោរោហណិកថា | ៨៦ |
| អរិយស្ស វិនយេ បច្ចោរោហណិកថា | ៨៧ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| តតិយបណ្ណាសក អរិយវគ្គ ទី ៤ . . | ៧៥ |
| ពោលអំពីសទ្ធម្មនិងអសទ្ធម្ម (១០) . . | ៧៦ |
| ពោលអំពីសប្បុរិសធម៌និងអសប្បុរិសធម៌ (១០) . . | ៧៧ |
| ពោលអំពីឧប្បាទេតព្វធម៌និងអនុប្បាទេតព្វធម៌ (១០) . . | ៧៧ |
| ពោលអំពីអាសេវិតព្វធម៌និងអនាសេវិតព្វធម៌ (១០) . . | ៧៨ |
| ពោលអំពីភាវេតព្វធម៌និងអភាវេតព្វធម៌ (១០) . . | ៧៩ |
| ពោលអំពីពហុលីកាតព្វធម៌និងអពហុលីកាតព្វធម៌ (១០) . | ៨០ |
| ពោលអំពីអនុស្សរិតព្វធម៌និងអននុស្សរិតព្វធម៌ (១០) . . | ៨១ |
| ពោលអំពីសច្ឆិកាតព្វធម៌និងអសច្ឆិកាតព្វធម៌ (១០) . . | ៨២ |
| ចតុត្ថបណ្ណាសក បុគ្គលវគ្គ ទី ១ . . . | ៨៣ |
| ពោលអំពីអសេវិតព្វបុគ្គលនិងសេវិតព្វបុគ្គល . . | ៩៣ |
| ពោលអំពីបុគ្គលមានអកដិតៈ បុគ្គលទវិកដិតព្វបុគ្គលជាដើម . | ៨៤ |
| ជាណុស្សោណិវគ្គ ទី ២ . . | ៨៦ |
| ពោលអំពីការបន្សាត់បង់នូវបាបរបស់ពួកព្រាហ្មណ៍ . . | ៨៦ |
| ពោលអំពីការបន្សាត់បង់នូវបាបក្នុងអរិយវិន័យ . . | ៨៧ |

# មាតិកាបត្តានិ

| មាតិកា | អង្កៃ |
|---|---|
| ចតុត្ថបណ្ណាសកោ ជាណុស្សោណិវគ្គោ ទុតិយោ | ៨៦ |
| អរិយបច្ចោរោហណីកថា | ៩១ |
| ឱរិមតីរបារិមតីរកថា | ៩៣ |
| ” | ៩៦ |
| អធម្មានត្ថធម្មត្ថកថា | ៩៨ |
| អធម្មធម្មានត្ថត្ថកថា | ១០០ |
| មហាកច្ចានស្ស វិត្ថារេន អត្ថស្ស វិភជនកថា | ១០៧ |
| អធម្មធម្មានត្ថត្ថកថា | ១១៤ |
| តិវិធហេតុកទសអកុសលកម្មបថកថា | ១១៨ |
| សបរិក្កមនធម្មកថា | ១១៩ |
| ព្រាហ្មណានំ សោចេយ្យប្បញ្ញាបនកថា | ១២២ |
| អរិយស្ស វិនយេ សោចេយ្យកថា | ១២៣ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| ចតុត្ថបណ្ណាសក ជាណុស្សោណិវគ្គ ទី ២ . . | ៨៦ |
| ពោលអំពីការបេខ្យក្របដ៏ប្រសើរ . . . . | ៩១ |
| ពោលអំពីត្រើយខាងអាយនិងត្រើយខាងនាយ . . | ៩៣ |
| " . . . | ៩៦ |
| ពោលអំពីសភាពមិនជាធម៌ ទាំងមិនជាប្រយោជន៍ព្រម ទាំងសភាពជាធម៌ទាំងជាប្រយោជន៍ . . . | ៩៨ |
| ពោលអំពីសភាពមិនជាធម៌នឹងជាធម៌ ទាំងសភាពមិនជាប្រយោជន៍នឹងជាប្រយោជន៍ . . . | ១០០ |
| ពោលអំពីការចែកនូវអត្ថដោយពិស្តារនៃព្រះមហាកច្ចាន . | ១០៧ |
| ពោលអំពីសភាពមិនជាធម៌នឹងជាធម៌ ទាំងសភាពមិនជាប្រយោជន៍នឹងជាប្រយោជន៍ . . . | ១១៥ |
| ពោលអំពីអកុសលកម្មបថ ១០ មានហេតុ ៣ (ក្នុងមួយៗ) . | ១១៨ |
| ពោលអំពីធម៌ប្រកបដោយការកែត្រឡប់បាន . . . | ១១៩ |
| ពោលអំពីការបញ្ញត្តិនូវការស្អាតរបស់ពួកព្រាហ្មណ៍ . . | ១២២ |
| ពោលអំពីការស្អាតក្នុងអរិយវិន័យ . . . | ១២៣ |

# មាតិកាបត្តាធិ

មាតិកា អង្កេ

ចតុត្ថបណ្ណាសកោ ជាណុស្សោណិវគ្គោ ទុតិយោ . . . ៨៦

ឋានអដ្ឋានកថា . . . . . ១៣៥

អដ្ឋានេ បរិកប្បកថា . . . . . ១៣៩

សុន្ទរវគ្គោ តតិយោ . . . ១៤៦

សាត្ថាសាត្ថុកថា . . . . . ១៤៦

អរិយធម្មានរិយធម្មកថា . . . . . ១៤៧

កុសលាកុសលកម្មកថា . . . . . ១៤៧

អត្ថានត្ថកថា . . . . . ១៤៨

ធម្មាធម្មកថា . . . . . ១៤៩

សាសវានាសវកថា . . . . . ១៤៩

សាវជ្ជានវជ្ជធម្មកថា . . . . . ១៥០

តបនិយាតបនិយធម្មកថា. . . . . . ១៥១

អាចយគាមិអបចយគាមិធម្មកថា . . . . ១៥១

ទុក្ខុទ្រយសុខុទ្រយធម្មកថា . . . . ១៥២

ទុក្ខវិបាកសុខវិបាកធម្មកថា . . . . ១៥៣

# សន្លឹកប្រាប់មាតិកា


មាតិកា ទំព័រ

ចតុត្ថបណ្ណាសក ជាណុស្សោណិវគ្គ ទី ២ . ៨៦

ពោលអំពីទីគួរសម្រេចផលនិងទីមិនគួរសម្រេចផលនៃ

ទុទ្ធិស្សព្រាន . . . . . ១៣៥

ពោលអំពីបរិកប្ប (សម្រេចផល) ក្នុងទីមិនគួរ . . . ១៣៩

សុទ្ធវគ្គ ទី ៣ . . . ១៤៦

ពោលអំពីកម្មល្អ និងកម្មអាក្រក់ . . . ១៤៦

ពោលអំពីអរិយធម៌និងអនរិយធម៌ . . . ១៤៧

ពោលអំពីកុសលកម្មនិងអកុសលកម្ម . . . ១៤៧

ពោលអំពីធម៌មានប្រយោជន៍និងធម៌ឥតប្រយោជន៍ . ១៤៨

ពោលអំពីធម៌និងអធម៌ . . . . . ១៤៩

ពោលអំពីសាសវធម៌និងអនាសវធម៌ . . . ១៤៩

ពោលអំពីសាវជ្ជធម៌និងអនវជ្ជធម៌ . . . . ១៥០

ពោលអំពីតបនិយធម៌និងអតបនិយធម៌ . . . ១៥១

ពោលអំពីអាចយគាមិធម៌និងអបចយគាមិធម៌ . . ១៥១

ពោលអំពីទុក្ខុទ្រយធម៌និងសុខុទ្រយធម៌ . . . ១៥២

ពោលអំពីទុក្ខវិបាកធម៌និងសុខវិបាកធម៌ . . . ១៥៣

# មាតិកាបដ្ឋានំ


| មាតិកា | អង្កេ |
|---|---|
| ចតុត្ថបណ្ណាសកេ សេដ្ឋវគ្គោ ចតុត្ថោ | ១៥៤ |
| អរិយមគ្គានរិយមគ្គកថា | ១៥៤ |
| កណ្ហមគ្គសុក្កមគ្គកថា | ១៥៤ |
| សទ្ធម្មាសទ្ធម្មកថា | ១៥៥ |
| សប្បុរិសធម្មាសប្បុរិសធម្មកថា | ១៥៥ |
| ឧប្បាទេតព្វានុប្បាទេតព្វធម្មកថា | ១៥៦ |
| អាសេវិតព្វានាសេវិតព្វធម្មកថា | ១៥៦ |
| ភាវេតព្វាភាវេតព្វធម្មកថា | ១៥៧ |
| ពហុលីកាតព្វាពហុលីកាតព្វធម្មកថា | ១៥៧ |
| អនុស្សរិតព្វានានុស្សរិតព្វធម្មកថា | ១៥៨ |
| សច្ឆិកាតព្វាសច្ឆិកាតព្វធម្មកថា | ១៥៩ |
| សេវិតព្វាសេវិតព្វវគ្គោ បញ្ចមោ | ១៦០ |
| អសេវិតព្វសេវិតព្វបុគ្គលកថា | ១៦០ |
| អភជិតព្វភជិតព្វបុគ្គលាទិកថា | ១៦១ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| ចតុត្ថបណ្ណាសក សេដ្ឋវគ្គ ទី ៤ . . . | ១៥៤ |
| ពោលអំពីអរិយមគ្គនិងអនរិយមគ្គ . . . . | ១៥៤ |
| ពោលអំពីកណ្ហមគ្គនិងសុក្កមគ្គ . . . . | ១៥៤ |
| ពោលអំពីសទ្ធម្មនិងអសទ្ធម្ម . . . . | ១៥៥ |
| ពោលអំពីសប្បុរិសធម្មនិងអសប្បុរិសធម្ម . . . | ១៥៥ |
| ពោលអំពីឧប្បាទេតព្វធម្មនិងអនុប្បាទេតព្វធម្ម . . | ១៥៦ |
| ពោលអំពីអាសេវិតព្វធម្មនិងអនាសេវិតព្វធម្ម . . | ១៥៦ |
| ពោលអំពីភាវេតព្វធម្មនិងអភាវេតព្វធម្ម . . . | ១៥៧ |
| ពោលអំពីពហុលីកាតព្វធម្មនិងអពហុលីកាតព្វធម្ម . . | ១៥៧ |
| ពោលអំពីអនុស្សរិតព្វធម្មនិងអននុស្សរិតព្វធម្ម . . | ១៥៨ |
| ពោលអំពីសច្ឆិកាតព្វធម្មនិងអសច្ឆិកាតព្វធម្ម . . . | ១៥៩ |
| សេវិតព្វាសេវិតព្វវគ្គ ទី ៥ . . | ១៦០ |
| ពោលអំពីអសេវិតព្វបុគ្គលនិងសេវិតព្វបុគ្គល . . | ១៦០ |
| ពោលអំពីអភជិតព្វបុគ្គលនិងភជិតព្វបុគ្គលជាដើម . . | ១៦១ |

# មាតិកាបដ្ឋានំ


| មាតិកា | អង្ក |
|---|---|
| បញ្ចមបណ្ណាសកោ បឋមវគ្គោ បឋមោ . . | ១៦៣ |
| ទសហិ ធម្មេហិ សមន្នាគតបុគ្គលកថា . . . | ១៦៣ |
| ” | ១៦៦ |
| ទសហិ ធម្មេហិ សមន្នាគតមាតុគ្គាមកថា . . | ១៦៩ |
| ” . . . | ១៧០ |
| ទសហិ ធម្មេហិ សមន្នាគតឧបាសិកាកថា . . | ១៧០ |
| ” . . . . . | ១៧០ |
| ” . . . . . | ១៧១ |
| ” . . . . . | ១៧១ |
| សំសប្បតិបរិយាយធម្មកថា . . . . . | ១៧២ |
| កម្មន្តសន្ទោសព្យាបត្តិកថា . . . . . | ១៧៩ |
| កម្មន្តសម្បត្តិកថា . . . . . | ១៨៦ |
| កម្មន្តសន្ទោសព្យាបត្តិកថា . . . . . | ១៩២ |
| កម្មន្តសម្បត្តិកថា . . . . . | ១៩៤ |

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ


បញ្ចមបណ្ណាសក បឋមវគ្គ ទី ១ . . . ១៦៣

ពោលអំពីបុគ្គលប្រកបដោយធម៌ ១០ ប្រការ . . ១៦៣

" . . . . ១៦៦

ពោលអំពីមាតុគ្រាមប្រកបដោយធម៌ ១០ ប្រការ . . ១៦៩

" . . . . ១៧០

ពោលអំពីឧបាសិកាប្រកបដោយធម៌ ១០ ប្រការ . . ១៧០

" . . . . ១៧០

" . . . . ១៧១

" . . . . ១៧១

ពោលអំពីធម៌ជាហេតុនៃសេចក្តីវទ្ទត់ . . . ១៧២

ពោលអំពីសន្ទោសព្យាបត្តិ(វិបត្តិគឺទោស)នៃកម្ម . . ១៧៩

ពោលអំពីសម្បត្តិនៃកម្ម . . . . . ១៨៦

ពោលអំពីសន្ទោសព្យាបត្តិនៃកម្ម . . . . ១៩២

ពោលអំពីសម្បត្តិនៃកម្ម . . . . . ១៩៤

# មាតីកាបត្តានិ

មាតិកា | អង្កែ


បញ្ចមបណ្ណាសកេ បឋមវគ្គោ បឋមោ . . ១៦៣

ការវេតព្វមេត្តាចេតោវិមុត្យាទិកថា . . . . ១៩៧

អធម្មចរិយវិសមចរិយាកថា. . . . . ២០១

ធម្មចរិយសមចរិយាកថា . . . . . ២០១

ទុតិយវគ្គោ ទុតិយោ . . ២០៣

ទសហិ ធម្មេហិ សមន្នាគតបុគ្គលកថា . . . ២០៥

,, . . , ២០៥

វីសតិយា ធម្មេហិ សមន្នាគតបុគ្គលកថា. . . ២០៦

,, . . ២០៧

តឹសាយ ធម្មេហិ សមន្នាគតបុគ្គលកថា . . ២០៨

,, . . ២១០

ចត្តាឡីសាយ ធម្មេហិ សមន្នាគតបុគ្គលកថា . . ២១២

,, , . ២១៤

ទសហិ ធម្មេហិ សមន្នាគតាទិកថា . . . ២១៧

# មាតិកាបត្ដានិ

មាតិកា អង្កេ

បញ្ចមបណ្ណាសកេ តតិយវគ្គោ តតិយោ ។បេ។ .. ២១៨

ទសហិ ធម្មេហិ សមន្នាគតាទិកថា ..... ២១៨

រាគស្ស អភិញ្ញាយ ភាវេតព្វទសធម្មកថា .... ២២០

" ........ ២២០

" ........ ២២១

រាគស្ស បរិញ្ញាយ ភាវេតព្វទសធម្មាទិកថា ... ២២១

ទោសស្ស អភិញ្ញាយ ភាវេតព្វទសធម្មាទិកថា .... ២២២

ឯកាទសកនិបាតេ និស្សយវគ្គោ បឋមោ .. ២២៣

កុសលសីលាទីនំ អានិសំសកថា ...... ២២៣

សីលវន្តាទីនំ ធម្មតាយ អវិប្បដិសារាទិឧប្បជ្ជនកថា .. ២២៦

ទុស្សីលាទីនំ ហតូបនិសាវិប្បដិសារាទិកថា ... ២២៩

មាតិកា ទំព័រ

បញ្ចមបណ្ណាសក តតិយវគ្គ ទី៣ ។ បេ ។ . ២១៨

ពោលអំពីបុគ្គលប្រកបដោយធម៌ ១០ ប្រការជាដើម . . ២១៨

ពោលអំពីធម៌១០ប្រការដែលត្រូវចំរើនដើម្បីដឹងច្បាស់

នូវរាគៈ . . . . . . . . . . . . . ២២០

,, . . . . . . . . . . ២២០

,, . . . . . . . . . . ២២១

ពោលអំពីធម៌១០ប្រការដែលត្រូវចំរើនដើម្បីកំណត់ដឹង

នូវរាគជាដើម . . . . . . . . . . ២២១

ពោលអំពីធម៌ ១០ ប្រការដែលគួរចំរើន ដើម្បីដឹងច្បាស់

នូវទោសៈជាដើម . . . . . . . . . . ២២២

ឯកាទសកនិបាត និស្សយវគ្គទី ១ . . . . . ២២៣

ពោលអំពីអានិសង្សនៃធម៌មានកុសលសីលជាដើម . . ២២៣

ពោលអំពីការកើតឡើងនៃអវិប្បដិសារៈតាមធម្មតាជាដើម

ដល់ជនមានសីលជាដើម . . . . . . . ២២៦

ពោលអំពីអវិប្បដិសារៈដែលសូន្យពាក់ឧបនិស្ស័យជា

ដើមនៃបុគ្គលទ្រុស្តសីលជាដើម . . . . . . . ២២៩

# មាតិកាបត្តានិ

| មាតិកា | អង្កេ |
|---|---|
| ឯកាទសកនិបាតេ និស្សយវគ្គោ បឋមោ . . | ២២៣ |
| សីលវន្តាទីនិ ឧបនិសសម្បន្នាវិប្បដិសារាទិកថា . . . | ២៣០ |
| ទុស្សីលាទីនិ ហតូបនិសាវិប្បដិសារាទិកថា . . . | ២៣២ |
| សីលវន្តាទីនិ ឧបនិសសម្បន្នាវិប្បដិសារាទិកថា . . . | ២៣៤ |
| ទុស្សីលាទីនិ ហតូបនិសាវិប្បដិសារាទិកថា . . . | ២៣៥ |
| សីលវន្តាទីនិ ឧបនិសសម្បន្នាវិប្បដិសារាទិកថា . . . | ២៣៧ |
| អរិយុបវាទិនោ ព្យសននិគមនកថា. . . . . . | ២៣៨ |
| សមាធិប្បដិលាភកថា . . . . . . | ២៣៩ |
| „ . . . . . . | ២៤៦ |

មាតិកា ទំព័រ

ឯកាទសកនិបាត និស្សយវគ្គ ទី ១ . . . . ២២៣

ពោលអំពីអវិប្បដិសារៈដែលបរិបូណ៌ដោយឧបនិស្ស័យ ជាដើមនៃបុគ្គលមានសីលជាដើម . . . . . . . ២៣០

ពោលអំពីអវិប្បដិសារៈដែលសូន្យចាកឧបនិស្ស័យ ជាដើមនៃបុគ្គលទ្រុស្តសីលជាដើម . . . . . ២៣២

ពោលអំពីអវិប្បដិសារៈដែលបរិបូណ៌ដោយឧបនិស្ស័យ ជាដើមនៃបុគ្គលមានសីលជាដើម . . . . . . . ២៣៤

ពោលអំពីអវិប្បដិសារៈដែលសូន្យចាកឧបនិស្ស័យ ជាដើមនៃបុគ្គលទ្រុស្តសីលជាដើម . . . . . . . ២៣៥

ពោលអំពីអវិប្បសារៈដែលបរិបូណ៌ដោយឧបនិស្ស័យ ជាដើមនៃបុគ្គលមានសីលជាដើម . . . . . . . ២៣៧

ពោលអំពីការដល់នូវសេចក្ដីវិនាស (១០ យ៉ាងណាមួយ) របស់អ្នកតិះដៀលព្រះអរិយៈ . . . . . . . ២៣៨

ពោលអំពីការបានសមាធិ (របស់ភិក្ខុមិនមានបរិ – សញ្ញាជាដើម) . . . . . . . . ២៣៩

„ (របស់ភិក្ខុមិនមានចក្ខុមនសិការៈជាដើម) . . ២៤៦

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| ឯកាទសកនិបាតេ និស្សយវគ្គោ បឋមោ . . . | ២៣២ |
| បុរិសខឡុង្គឈាយិតកថា . . . . . . . . | ២៤០ |
| បុរិសាជានីយឈាយិតកថា . . . . . . . | ២៥៣ |
| តីហិ ធម្មេហិ អច្ចន្តយោគក្ខេមិកថា . . . . . . | ២៥៨ |
| ទុតិយវគ្គោ ទុតិយោ . . . | ២៦៣ |
| កុលបុត្តានំ វិហារកថា . . . . . . . | ២៦៤ |
| ” . . . . . . | ២៧៥ |
| ” | ២៨១ |
| សទ្ធស្ស សទ្ធាបទានកថា . . . . . . . | ២៨៦ |
| មេត្តាយ ចេតោវិមុត្តិយា ឯកាទសានិសំសកថា. . . | ២៩៧ |
| ឯកាទសាមតទ្វារកថា . . . . . . . | ២៩៨ |
| ឯកាទសហង្គេហិ សមន្នាគតគោបាលកកថា . . . | ៣១១ |
| ឯកាទសហិ ធម្មេហិ សមន្នាគតភិក្ខុកថា . . . . | ៣១២ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| ឯកាទសកនិបាត និស្សយវគ្គ ទី ១ . . . . | ២២៣ |
| ពោលអំពីគំនិតនៃបុរសមានពុតត្បុត . . . . . . | ២៥០ |
| ពោលអំពីគំនិតនៃបុរសអាជានីយជាដើម . . . . | ២៥៣ |
| ពោលអំពីបុគ្គលអ្នកក្សេមចាកយោគៈ មែនព្រោះធម៌ ៗ ជាដើម . . . . . . . | ២៥៨ |
| ទុតិយវគ្គ ទី ២ . . . . . . . | ២៦៣ |
| ពោលអំពីវិហារធម៌នៃពុទ្ធកុលបុត្ត . . . . . . | ២៦៦ |
| " . . . . . . . | ២៧៥ |
| " . . . . . . , | ២៨១ |
| ពោលអំពីសព្ទាបទាន (សព្ទាភិត) របស់ជនអ្នកមានសទ្ធា . . . . . . | ២៨៦ |
| ពោលអំពីអានិសង្ស ១១ ប្រការនៃមេត្តាចេតោវិមុត្តិ . . | ២៩៧ |
| ពោលអំពីទ្វារនៃអមតៈ (ព្រះនិព្វាន) ១១ ប្រការ . . | ២៩៨ |
| ពោលអំពីគង្វាលគោប្រកបដោយអង្គ ១១ ប្រការ . . | ៣១១ |
| ពោលអំពីភិក្ខុប្រកបដោយធម៌ ១១ ប្រការ . . . | ៣១២ |

# មាតិកាបត្តានិ


| មាតិកា | អង្កៃ |
|---|---|
| ឯកាទសកនិបាតេ ទុតិយវគ្គោ ទុតិយោ . . . | ២៦៣ |
| សមាធិប្បដិលាភកថា . . . . . . . . | ៣២៥ |
| ,, . . . . . . . . | ៣២៨ |
| ,, . . . . . . . . | ៣៣១ |
| ,, . . . . . . . . | ៣៣៦ |
| បណ្ណាសកាសង្គហិតា សុត្តន្តា . . . | ៣៣៨ |
| ឯកាទសហង្គេហិ សមន្នាគតគោបាលកកថា . . . . | ,, |
| ឯកាទសហិ ធម្មេហិ សមន្នាគតភិក្ខុកថា . . . . | ,, |
| រាគស្ស អភិញ្ញាយ ភាវេតព្វឯកាទសធម្មកថា . . . | ៣៦១ |
| រាគាទិកស្ស អភិញ្ញាយ ភាវេតព្វឯកាទសធម្មកថា: . . | ៣៦២ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| ឯកាទសកនិបាត ទុតិយវគ្គ ទី ២ . . . | ៦៦៣ |
| ពោលអំពីការបាននូវសមាធិ . . . . . | ៣២៥ |
| ,, . . . . . | ៣២៨ |
| ,, . . . . . | ៣៣១ |
| ,, . . . . . | ៣៣៤ |
| សូត្រដែលមិនរួបរួមដោយបញ្ញាសក . . . | ៣៣៨ |
| ពោលអំពីគង្វាលគោប្រកបដោយអង្គ ១១ ប្រការ . | ,, |
| ពោលអំពីភិក្ខុប្រកបដោយអង្គ ១១ ប្រការ . . | ,, |
| ពោលអំពីធម៌ ១១ ប្រការដែលគួរនាំទៅដើម្បីដឹងច្បាស់ នូវរាគៈ . . . . | ៣៤១ |
| ពោលអំពីធម៌ ១១ ប្រការដែលគួរនាំទៅដើម្បីដឹងច្បាស់ នូវរាគៈជាដើម . . . . | ៣៤២ |

# វិរុទ្ធាវិរុទ្ធបត្តិ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| សេយ្យម្បិ | លេយ្យម្បិ | ១៣ | ៤ |
| វិគជិតាយ ស្មា | វិគជតាយ ស្មា | ៣៩ | ,, |
| ទសនិបាតោ | ទសកនិបាតោ | ៥៦ | ១ |
| មិច្ឆាទិដ្ឋិ | មិច្ឆាទិដ្ឋី | ,, | ១០ |
| មិច្ឆាទិដ្ឋិ | ៗ មិច្ឆាទិដ្ឋិ | ៧៩ | ៩ |
| អកិច្ច | អកិច្ចំ | ៩៣ | ៣ |
| អវិគជិត្វា | អវិគត្តស្ស | ១១១ | ១៣ |
| វិត្តាវេន | វិត្តាវេន អត្តំ | | |
| | អវិគត្តស្ស វិត្តាវេន | ១១៣ | ១០ |
| បាណាត បាតម្យហំ | បាណាតិបាតម្យហំ | ១១៨ | ១៦ |
| អមុសំ | អមូសំ | ១២៥ | ១៤ |
| តិដ្ឋត | តិដ្ឋតិ | ១៣៨ | ៦ |
| បាណាតិបាតា | បាណាតិបាតា | ១៥៤ | ,, |
| តំ អនុកវិស្សតិ | ន តំ អនុកវិស្សតិ | ១៩៨ | ១០ |
| វេរមណិយា | វេរមណិយា ប | ២១១ | ៦ |
| នពេជាយ | ឌពេជាយ | ២២១ | ៩ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| ខទ្វុង្គឈាយតំ | ខលុង្គឈាយតិ | ២៤០ | ១៤ |
| ឧហវេញ្ញ | ឧហពោញ្ញ | ២៨៤ | ៧ |
| សំ | សំ– | ៣០២ | ១៣ |
| ទុតយោ | ទុតិយោ | ៣១៣ | ១ |
| សោ | សោ– | ៣១៦ | ៨ |
| រូបញ្ច | រូបញ្ញ | ៣២០ | ៥ |
| ២៣០ | ១៣០ | ៣៦១ | ២ |
| ២៣១ | ១៣១ | ៣៦២ | ២ |
| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
| ២២៨ | ១២៨ | ៣៣៦ | ២ |
| ២២៩ | ១២៩ | ៣៣៨ | ២ |
| ២៣០ | ១៣០ | ៣៦១ | ២ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ករយា | កិរិយា | ៣ | ៩ |
| ទិដ្ឋិចេតនាណា | ទិដ្ឋិ ចេតនាណា | ៤ | ៨ |
| ឧមេយ្យ | ឧបមេយ្យ | ៣៧ | ១០ |
| អនុត្តរិយ | អនុត្តរិយ | ៤៥ | ៤ |
| ពួកជន | ពួកជនណា | ៥១ | ១២ |
| នូវព្រះនិញា | នូវព្រះនិញាន | ៥៣ | ៧ |
| បារសុទ្ធិវគ្គ | បារិសុទ្ធិវគ្គ | ៦៦ | ១៧ |
| អរិយមគ្គ | អរិយមគ្គវគ្គ | ៣៩ | ១ |
| ប្រព្រឹត្តខុស | ប្រព្រឹត្តខុស | ៩៤ | ៥ |
| ការបន៍ | ការបន់ | " | ១៤ |
| សង្ខេប | សង្ខេប មិនបាន ចែករំលែកនូវអត្ថដោយពិស្ដារ | ១១៣ | ១២ |
| អកុលសវេទនា | អកុសលវេទនា | ១២៩ | ១៥ |
| សម្បត្ត | សម្បត្តិ | ១៨៧ | ៦ |

# សន្លឹកប្រាប់ពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| នព្វិតា | និព្វិតា | ២៣១ | ១២ |
| លុិទ្ធ | លិទ្ធ | ២៤២ | ៥ |
| ក្នុងទូវសម្តុះ | ក្នុងចិត្តទូវសម្តុះ | ២៤៧ | ១២ |
| វិកិច្ចា | វិចិកិច្ចា | ២៥៤ | ៥ |
| រប្រើន | ច្រើន | ២៨០ | ១១ |
| ស្លាក់ ៗ | ស្លាក់ ៗ | ៣០០ | ១២ |
| ភិក្ខនោះ | ភិក្ខុនោះ | ៣០៧ | ៣ |
| បក្ខុន្ទ្រីយ | បក្ខុន្ទ្រិយ | ៣២១ | ៧ |
| គ្រង់ | ក្នុង | ៣៣២ | ២ |
| ច្នោះ | ដូច្នោះ | ៣៣៤ | ១៤ |
| ដែលប្រព្រម | ដែលមិនប្រព្រម | ៣៣៨ | ១ |
| ” | ” | ៣៣៩ | ” |
| រូបវត - | រូបវិត- | ៣៤០ | ៧ |
| ដែលប្រព្រម | ដែលមិនប្រព្រម | ៣៣៨ | ១ |
| ” | ” | ៣៣៩ | ” |
| ” | ” | ៣៤១ | ” |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ ៖


Printing costs were met through the gift of

**Community Salon SEI・RAN**

| | |
|---|---|
| Mr. Hisao Kasahara | 3-4-2 Azamino-minami, Aoba-ku, Yokohama-shi, Kanagawa-ken 225 Japan Tel 045-913-1921 |
| Mr. Chiaki Tanuma | 1-38-12-112 Takada, Toshima-ku, Tokyo 171 Japan |
| Ms. Hiroko Murakami | 2-44-9 Ogikubo, suginami-ku, Tokyo 167 Japan |
| Mr. Hiroshi Moriya | 1832 Kouenbou, Hatsuseimachi, Miura-shi, Kanagawa-ken 238-02 Japan |

この本は次の方によって復刻されました。

コミュニティ・サロン 青藍

| | | |
|---|---|---|
| 笠原尚夫 | 〒225 | 神奈川県横浜市青葉区あざみ野南3-4-2<br>☎045-913-1921 |
| 田沼千秋 | 〒171 | 東京都豊島区高田1-38-12-112 |
| 村上辭子 | 〒167 | 東京都杉並区荻窪2-44-9 |
| 守屋　浩 | 〒238-02 | 神奈川県三浦市初声町高円坊1832 |

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 51 (of 110 volumes total)
"SUTTANTA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ（南伝大蔵経）全110巻・第51巻スッタンタピタカ（経部）

発　　行：プノンペン仏教研究所
復刻救援：カンボジア版トリピタカ(南伝大蔵経)復刻救援委員会
発　　行：1994年12月8日

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE